សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ • ខែ មេសា ឆ្នាំ 2015

# លីអាហូណា



## ពលិកម្មដ៏ឥតកំណត់ និង ដ៏ពិសិដ្ឋរបស់ព្រះអង្គសង្គ្រោះ ទំព័រ 34

ភាពទន់ខ្សោយមិនមែនជាអំពើបាបនោះទេ ទំព័រ 20

របៀបដើម្បីទទួលបានជោគជ័យនៅរាត្រីជួបជុំក្រុមគ្រួសារ ទំព័រ 10, 80



« ក្នុងចំណោមពួកអ្នករាល់គ្នា បើអ្នកណាមានចៀមមួយរយ តែបាត់មួយ តើមិនទុកចៀមកៅសិបប្រាំបួនឲ្យនៅទីរហោស្ថាន ដើម្បីទៅតាមរកចៀមមួយដែលបាត់ ទាល់តែឃើញទេឬអី ?
« កាលណារកឃើញហើយ នោះក៏លើកព្រនរមកដោយអំណរ ។ »

លូកា 15:4–5

រូបថតនេះ ត្រូវបានថតនៅអ៊ីស្រាអែលក្នុងឆ្នាំ 2010 វាបង្ហាញពីគ្រោះថ្នាក់ដែលអ្នកគង្វាលនឹងមានក្នុងការជួយសង្គ្រោះសត្វចៀមរបស់គាត់ ។

# លីអាហូណា ខែ មេសា ឆ្នាំ 2015




## សារលិខិត


4 **សារលិខិតគណៈប្រធានទីមួយ: ប្រធាន ម៉នសុន អំពាវនាវឲ្យមានភាពក្លាហាន**
ដោយ ប្រធាន ថូម៉ាស អេស ម៉នសុន

7 **សារលិខិតបង្រៀនសួរសុខទុក្ខ: លក្ខណៈសម្បត្តិរបស់ ព្រះយេស៊ូវគ្រីស្ទ — ដោយគ្មានការលាក់ពុត ឬ ឧបាយកលឡើយ**


## អត្ថបទពិសេស។


14 **ឥទ្ធិពលខាងវិញ្ញាណរបស់ស្ត្រី**
ដោយ ស្តាឡា អាវើរៃយេម បាត់ធ្វើរ
*ឥទ្ធិពលរបស់អ្នកជាស្ត្រីមានប្រសិទ្ធិភាពហួសពីអ្វីដែលអាចមើលឃើញ ។*

20 **ភាពទន់ខ្សោយមិនមែនជាអំពើបាបនោះទេ**
ដោយ វេនឌី អ៊ុលរីធ
*រៀនពីរបៀបដើម្បីពន្យល់ពីភាពខុសគ្នារវាងអំពើបាប និងភាពទន់ខ្សោយ ហើយពីរបៀបដើម្បីបង្វែរភាពទន់ខ្សោយទៅជាកម្លាំងវិញ ។*

26 **សាសនាពិត**
ដោយអែលឌើរ ដ័យុលយូ គ្រីស្តូហ្វឺរ វ៉ដិល
*សូមអានជំហានទាំងបីនេះ ដើម្បីការបម្រើដែលមិនគិតពីខ្លួនឯង ។*

30 **« ខ្ញុំត្រូវការទ្រង់ជានិច្ច »**
ដោយ យ៉ូណាថាន អេច ហ្វេសតូវើរ
*ការច្រៀងទំនុកតម្កើងមួយ បានបង្កើតជាអានុភាពដ៏ល្អឯកសម្រាប់គ្រួសារកូរ៉េដែលជាអ្នករៀនថ្មីនេះ ។*

34 **ពលិកកម្មដ៏ឥតកំណាញ់ និងដ៏ពិសិដ្ឋរបស់ព្រះអង្គសង្គ្រោះ**
ដោយប្រធាន បិយដ៍ េយ ផាកកឺ
*តាមរយៈដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ យើងអាចបង់ថ្លៃអំពើបាប និងកំហុសខាងវិញ្ញាណរបស់យើង ។*

80 **ខួប 100 ឆ្នាំនៃរាត្រីជួបជុំក្រុមគ្រួសារ**
*ក្នុងឆ្នាំ 1915 ប្រធាន យ៉ូសែប អេហ្វ ស្ម៊ីធ និងទីប្រឹក្សារបស់លោកបានអញ្ជើញសមាជិកទាំងអស់ឲ្យចាប់ផ្តើមរៀបចំរាត្រីជួបជុំក្រុមគ្រួសារ ដោយពន្យល់ពី ទ្រង់ទ្រាយ គោលបំណង និងពរជ័យរបស់វា ។*


## ស្ថាប័ននានា


8 **យើងនិយាយអំពីព្រះគ្រីស្ទ: អំណាចនៃសេចក្តីជំនឿ**
ដោយ អែមេមើរ បាឡូ ដាល

10 **គេហដ្ឋាន និង ក្រុមគ្រួសាររបស់យើង: រាត្រីជួបជុំក្រុមគ្រួសារ — អ្នកអាចធ្វើបាន !**

12 **ដំណឹងល្អពីបុរាណ: ទ្រង់មានព្រះជន្មរស់ឡើងវិញ**
ដោយប្រធាន ដាវីឌ អូ មិកេយ

40 **សំឡេងពួកបរិសុទ្ធថ្ងៃចុងក្រោយ**


**នៅលើគម្រប**
ក្របមុខ ៖ *ផ្លូវទៅអេម៉ោស* ដោយ លីស្ស លីម៉ុន ស្វីនដល ហាមថតចម្លង ។ ខាងក្នុងក្របមុខ ៖ រូបថតដោយ ជីម ជែហ្វ្រី ។ ខាងក្នុងក្របក្រោយ៖ រូបថតបង្ហាញដោយ ខូឌី ប៊ែល ។

## មជ្ឈិមវ័យយុវវ័យ





44 **ឆ្ពោះទៅមុខដោយជំនឿ**
ដោយ អែលឌើរ អាន់ចូនី ឌី ភើគីន
*រៀនសូត្រពីនីហ្វៃ នូវអ្វីដែលត្រូវធ្វើពេលអ្នកប្រឈមមុខនឹងការសម្រេចចិត្តដ៏សំខាន់ ។*




*ចាំមើលថា តើអ្នកអាចរកឃើញរូបលីអាហូណាដែលលាក់នៅក្នុងលេខនេះដែរឬទេ ។ តម្រុយ ៖ តើកន្លែងណាដែលអ្នកអាចអុចទៀនបាន ?*

## យុវវ័យ


49 **ប័ណ្ណប្រកាស: ចូរសូមស្វែងរកទ្រង់**

50 **ដោយសារតែ យ៉ូសែប**
ដោយ ធិឌ បានិស
*មានយ៉ាងហោចណាស់ប្រាំមួយវិធីដែលជីវិតរបស់អ្នកបានផ្លាស់ប្តូរ ដោយសារតែព្យាការី យ៉ូសែប ស្ម៊ីធ ។*

53 **ព្យាការីដែលនៅរស់**
ប្រធាន អែសរ៉ា ថាហ្វ បែនសឹន
*អ័ដាម ? នីហ្វៃ ? ម៉ូសេ ? អ្នកប្រហែលជាមានការភ្ញាក់ផ្អើល ក្នុងការរៀនថា ព្យាការីដែលសំខាន់បំផុតគឺជានរណានោះ ។*

54 **គំរូរបស់ព្រះអង្គសង្គ្រោះនៃការគោរពប្រតិបត្តិ**
*វិធីប្រាំបួនយ៉ាងដែលព្រះយេស៊ូវគ្រីស្ទបានកំណត់មាគ៌ាសម្រាប់ឲ្យយើងដើរតាម ។*

58 **ទីកន្លែងរបស់យើង**

60 **របៀបដើម្បីមានប្រាជ្ញា**
ដោយ អែលឌើរ នែលអិល អាន់ឌើរសិន
*តើអ្វីខុសប្លែកគ្នារវាងប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ ?*

61 **ទៅកាន់គោលដៅ**

62 **ហ្វូងតែមួយ និងអ្នកគង្វាលតែមួយ**
*ការយល់ដឹងពីសាច់រឿងលម្អិតនៃតួនាទីរបស់អ្នកគង្វាលចៀម អាចនាំយើងឲ្យកាន់តែខិតទៅជិតព្រះអង្គសង្គ្រោះ ។*

64 **សំណួរ និង ចម្លើយទាំងឡាយ**
*តើខ្ញុំអាចមានអារម្មណ៍ល្អគ្រប់គ្រាន់ល្មមដើម្បីនិយាយទៅបីស្សពរបស់ខ្ញុំអំពី បញ្ហានានា ឬកង្វល់ដោយរបៀបណា ?*





## កុមារ





66 **តើនរណាជាវិរបុរសរបស់អ្នក ?**
ដោយ ឆាឡុត មេ ហ្សិបប៉ឺដ
*អែលលីមានការភ័យខ្លាច ដើម្បីប្រាប់ដល់ថ្នាក់របស់នាងថាវិរៈបុរសរបស់នាងជានរណា ។*

68 **ការអធិស្ឋាន និង ព្រះវិហារ**
ដោយ ម៉ាក់ឃែល ចច
*ពេល ដានី ទៅលេងនៅព្រះវិហារមួយនៅប្រទេសអង់គ្លេស នាងបានរៀនពីមេរៀនដ៏សំខាន់មួយអំពីការអធិស្ឋាន ។*

70 **សាក្សីពិសេស: ហេតុអ្វីបានជាការគោរពប្រតិបត្តិតាមសំខាន់ម្ល៉េះ ?**
ដោយអែលឌើរ រ័សុល អិម ណិលសុន

71 **គំនិតឆ្លាតវៃ**

72 **ពេលវេលាសម្រាប់ខគម្ពីរ: ព្រះយេស៊ូវ បានប្រោសមនុស្សម្នាក់ឲ្យជា**
ដោយ អេរិន សាន់ដឺសុន

74 **តួអង្គនៅក្នុងខគម្ពីរ: ព្រះយេស៊ូវ បានប្រោសមនុស្សឈឺឲ្យជា**

75 **មាគ៌ាដែលត្រឹមត្រូវ**
ដោយ អែលឌើរ ក្លូឌីអូ ឌី ស្ស៊ីវីក
*ការដើរតាមមាគ៌ាដែលត្រឹមត្រូវ គឺជាជម្រើសយ៉ាងល្អ ។*

76 **សម្រាប់កុមារតូចៗ: ខ្ញុំដឹងថាព្រះសង្គ្រោះខ្ញុំស្រឡាញ់ខ្ញុំ**
ដោយ ជេន ម៉ាកប្រាយដ៍ ឆូត

# គំនិតទាំងឡាយសម្រាប់រាត្រីជួបជុំក្រុមគ្រួសារ

*ច្បាប់នេះមាននូវអត្ថបទ និង សកម្មភាពនានាដែលអាចយកទៅប្រើប្រាស់សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ នៅខាងក្រោមជាគំនិតចំនួនពីរ ។*



**« ខ្ញុំត្រូវការទ្រង់ជានិច្ច »** ទំព័រ 47 ៖ ដូចជាពាក្យនៅក្នុងទំនុកតម្កើងបានច្រៀងថា « ខ្ញុំត្រូវការទ្រង់ជានិច្ច » បានជួយឲ្យ ជាក មី ជុង សម្រេចចិត្តទទួលបុណ្យជ្រមុជទឹក ទំនុកតម្កើងអាចមានឥទ្ធិពលដ៏អស្ចារ្យក្នុងជីវិតរបស់យើងរាល់គ្នា ។ សូមគិតពីពេលវេលាមួយដែលពាក្យទាំងឡាយនៅក្នុងទំនុកតម្កើងបានប្រទានពរដល់ជីវិតអ្នក ហើយសូមគិតដល់ការចែកចាយបទពិសោធន៍នោះជាមួយនឹងក្រុមគ្រួសារអ្នក ។ សូមអញ្ជើញសមាជិកគ្រួសារម្នាក់ៗ ដើម្បីជ្រើសរើសទំនុកតម្កើងដែលពេញចិត្ត ហើយសូមប្រាប់ពីរបៀបដែលវាបានប្រទានពរដល់ជីវិតរបស់គេ ។ បន្ទាប់មក សូមច្រៀងចម្រៀងនីមួយៗជាមួយក្រុមគ្រួសារអ្នក ។ ( អ្នកអាចពន្លាតរបៀបនេះចេញជាពីរសប្ដាហ៍ ) ។

**« ការអធិស្ឋាន និង ព្រះវិហារ »** ទំព័រ 68 ៖ បន្ទាប់ពីអ្នកបានអានរឿងនេះ សូមបង្ហាញរូបភាពនៃព្រះវិហារ ឬរំឭកប្រាប់ពីព្រះវិហារផ្សេងៗគ្នាក្នុងទីក្រុងរបស់អ្នក ហើយសូមនិយាយពីសំណួរទាំងនេះជាមួយគ្រួសារអ្នក ៖ តើអ្វីខ្លះទៅជាភាពស្រដៀងគ្នាមួយចំនួន ដែលយើងមានជាមួយសាសនាដទៃទៀត ? តើព្រះវរបិតាមានអារម្មណ៍យ៉ាងណាចំពោះកូនចៅទាំងអស់របស់ទ្រង់ ? តើយើងគួរប្រព្រឹត្តចំពោះមនុស្ស ដែលមានជំនឿខុសគ្នាពីយើងដោយរបៀបណា ? សូមគិតពីការប្រើអត្ថបទនេះ « លំនឹងសេចក្ដីពិត និង ការអត់ឱន » ដោយ អែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ( *លីអាហូណា*, ខែ កុម្ភៈ ឆ្នាំ 2013, ទំព័រ 28–35 ) ដើម្បីជួយឆ្លើយនឹងសំណួរទាំងនេះ ។

## ជាភាសារបស់អ្នក

*លីអាហូណា* និងធនធានផ្សេងទៀតរបស់សាសនាចក្រ មានជាច្រើនភាសានៅលើគេហទំព័រ **languages.lds.org ។**

**ប្រធានបទទាំងឡាយក្នុងច្បាប់នេះ**
*លេខទាំងឡាយ គឺតំណាងឲ្យទំព័រទីមួយនៃអត្ថបទ ។*


***ការគោរពប្រតិបត្តិ,*** *44, 54, 58*
***ការតមអាហារ,*** *30*
***ការបម្រើ,*** *26, 42*
***ការប្រែចិត្ត,*** *34, 64*
***ការប្រែចិត្តជឿ,*** *30*
***ការប្រោសឲ្យជា,*** *8, 72, 74*
***ការរស់ឡើងវិញ,*** *12, 49*
***ការសម្រេចចិត្ត,*** *44, 60, 75*
***ការស្ដារឡើងវិញ,*** *50*
***ការអធិស្ឋាន,*** *68*
***ការអភ័យទោស,*** *20, 34*
***កិច្ចការផ្សព្វផ្សាយសាសនា,*** *30, 40*
***កិច្ចការព្រះវិហារបរិសុទ្ធ,*** *30, 43*
***កំហុស,*** *20, 34*
***ក្រុមគ្រួសារ,*** *10, 50*
***គំរូ,*** *14, 66*
***ដង្វាយធួន,*** *20, 34, 49*
***តន្ត្រី,*** *30, 40*
***ទុក្ខព្រួយ,*** *30, 41*
***និស្ស័យនៃព្រះ,*** *58*
***បទបញ្ញត្តិទាំងឡាយ,*** *70, 75*
***បព្វជិតភាព,*** *50*
***ព្យាការីទាំងឡាយ,*** *53*
***ព្រះគម្ពីរសញ្ញាថ្មី,*** *54, 62, 72, 74*
***ព្រះយេស៊ូវគ្រីស្ទ,*** *7, 8, 12, 20, 26, 34, 49, 54, 62, 66, 72, 74, 76*
***ព្រះវិញ្ញាណបរិសុទ្ធ,*** *30, 41, 42, 43, 44, 50, 58*
***ភាពក្លាហាន,*** *4*
***មរណៈភាព,*** *30, 41*
***យ៉ូសែប ស្ម៊ីធ,*** *12, 50*
***រាត្រីជួបជុំក្រុមគ្រួសារ,*** *10, 80*
***រូបអាសគ្រាម,*** *34*
***សាតាំង,*** *34, 61*
***សិទ្ធិជ្រើសរើស,*** *4, 20, 44*
***សេចក្ដីជំនឿ,*** *8, 20, 44*
***សេចក្ដីស្រឡាញ់,*** *76*
***ស្ត្រី,*** *14*
***អំពើបាប,*** *20, 34*
***អ្នកដឹកនាំទាំងឡាយរបស់សាសនាចក្រ,*** *53, 64*



**ខែ មេសា ឆ្នាំ 2015 វ៉ុល 14 លេខ 2**
**លីអាហូណា 12564 258**
ទស្សនាវដ្ដីអន្តរជាតិរបស់សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ



**គណៈប្រធានទីមួយ** ៖ ថូម៉ាស អេស. ម៉នសុន, ហិនរី ប៊ី. អាវរិង, ឌៀថើរ អេហ្វ. អុជដូហ្វ

**កូរ៉ុមនៃពួកសាវកដប់ពីរនាក់** ៖ ឞិយដ៏ ខេ. ផាកកឺ, អិល. ថម ភែរី, រ័សុល អិម. ណិលសុន, ដាល្លិន អេក. អូក, អិម. រ័សុល បាឡឺដ, រីឆាដ ជី. ស្កត, រ៉ូប៊ឺត ឌី. ហែល, ជែហ្វ្រី អ័រ. ហូឡិន, ដេវីឌ អេ. បែដណា, ឃ្វីនថិន អិល. ឃុក, ឌី ថត. គ្រីស្តូហ្វឺសិន, នែល អិល. អាន់ឌើរសិន

**អ្នកកែសម្រួល** ៖ ក្រេក អេ. ខារដុន
**អ្នកប្រឹក្សា** ៖ សម៉ើរីន ប៊ី អាណុល, ឡារី អ័រ ឡរ៉ែរិន, ជេមស៍ ប៊ី ម៉ាទីណូ, យ៉ូសែប ដបុលយូ ស៊ីតាទី គ្រីស្តូហ្វែល ហ្គូលឌិន

**នាយកគ្រប់គ្រង** ៖ ដេវីឌ ធី. វ៉នើរ
**នាយកគាំទ្រគ្រួសារ និង សមាជិក** ៖ វីនសេនត៍ អេ. វ៉ាញ
**នាយកទស្សនាវដ្ដីសាសនាចក្រ** ៖ អាលែន អ័រ. ឡយប៊ិច
**អ្នកគ្រប់គ្រងពាណិជ្ជកម្ម** ៖ ហ្គាស្វ ខាណុន

**អ្នកគ្រប់គ្រងផ្នែកកែសម្រួល** ៖ អ័រ. វ៉ាល ចនសុន
**ជំនួយការអ្នកគ្រប់គ្រងផ្នែកកែសម្រួល** ៖ រ៉ៃអិន ខារ
**ជំនួយការផ្នែកបោះពុម្ព** ៖ លីស្សា ស៊ី ឡូប៉េស្ស
**និពន្ធ និងកែសម្រួល** ៖ ប្រ៊ីតថានី ប៊ីតធី, ដេវីដ ឌិកសុន, ដេវីដ អេ. អែដវ៉ដ, ម៉ាថាយ ឌី. ហ្វលិតតុន, ឡារី ហ្វូលទ្យើរ ហ្គែរី អេច. ហ្កាហ្វ, ឡារិននេ ផតធើរ ហ្គូន, មីនឌី អាន់ ឡេរិត ម៉ៃឃើល អ័រ. ម៉ូរីស, សាលី ចនសុន អូឌេឃឹក, យ៉ូស្វេ ជេ ភឺគី, ជេន ភីនប៊ូរ៉ាហ្វ, រីឆាដ អិម. រ៉មនី, ប៉ុល វ៉ែនដិនបើជ, ម៉ារីស្សា វីឌីសុន

**នាយកគ្រប់គ្រងផ្នែកសិល្បៈ** ៖ ជេ. ស្កត នូដសិន
**នាយកផ្នែកសិល្បៈ** ៖ ចាត អ័រ. ភីធើរសុន
**រចនាម៉ូត** ៖ ជីនិត អាន់ទ្រូ, ហ្វេ ភី. អាន់ត្រួស, មែនឌី អឹម. ប៊ែនលី, ស៊ី. ឃីមប៊ីល បុត, ចូម៉ាស ឆាល, ណាត ហ្គីនេស, ខូលីន ហ៊ីងគ្លី, អេរិក ភី. ចនសិន, ស៊ូសាន ឡហ្វ្ទីន, ស្កត អិម. ម៉ូយ, ម៉ាក ដបុលយូ. រ៉ូប៊ីសុន, ប្រាត ធៀរ, ឃេ. នីកូល វ៉កឃិនហ្វូស
**អ្នកសម្របសម្រួលកម្មសិទ្ធបញ្ញា** ៖ ខូលេត នេបេឃើ អាន
**អ្នកគ្រប់គ្រងផ្នែកផលិតកម្ម** ៖ ជេន អាន ភិធើរស៍
**ផលិតកម្ម** ៖ ខននី ប៊ូស្រូប ប្រ៊ីដ, ជូលី បើរដែត, កាធី ដន់ខេន, ប្រាយអែន ដបុលយូ. ជីគី, ដេនីស គើបែ, ជីន្នី ហ្គីននី ជេ. នីលសុន, ហ្គេលី ថេត រ៉ាហ្វើធី
**អ្នកពិនិត្យមុនការបោះពុម្ព** ៖ ជេហ្វ អិល. ម៉ាទីន

**នាយកផ្នែកបោះពុម្ព** ៖ ក្រេហ្គ ខេ. សែតវីត
**នាយកផ្នែកចែកចាយ** ៖ ស្តេហ្វិន អ័រ គ្រីស្ទិនសិន



ចំពោះការជាវ និង តម្លៃនៅខាងក្រៅសហរដ្ឋ និង កាណាដា សូមចូលទៅកាន់គេហទំព័រ store.lds.org ឬ សូមទាក់ទងមជ្ឈមណ្ឌលចែកចាយរបស់សាសនាចក្រក្នុងមូលដ្ឋានរបស់អ្នក ឬ ទាក់ទងអ្នកដឹកនាំវួដ ឬ សាខារបស់អ្នក ។

**សូមផ្ញើអត្ថបទ និងសំណួរទាំងឡាយ** តាមអ៊ិនធើរណិតនៅគេហទំព័រ liahona.lds.org តាមអ៊ីម៉េលទៅកាន់ liahona@ldschurch.org ឬ តាមសំបុត្រទៅកាន់ Liahona, Rm. 2420, 50 E. North Temple St., Salt Lake City, UT 84150-0024, USA ។

*លីអាហូណា* ( ពាក្យក្នុងព្រះគម្ពីរមរមនមានន័យថា « ត្រីវិស័យ » ឬ « វត្ថុនាំផ្លូវ » ) ត្រូវបានបោះពុម្ពជាភាសា អាល់បានី, អាមេនី, ប៊ីស្លាមា, ប៊ុលហ្គារី, ខ្មែរ, សេប៊ូអាណូ, ចិន, ចិន ( ងាយស្រួល ), ក្រូអាត, ឆែក, ដាណាម៉ាក, ហូឡង់, អង់គ្លេស, អេស្តូអានី, ហ្វីជី, ហ្វាំងឡង់, បារាំង, អាល្លឺម៉ង់, ក្រិច, ហុងហ្គារី, អាយឡេនឌិក, ឥណ្ឌូនេស៊ី, អ៊ីតាលី, ជប៉ុន, គីរីបាទី, កូរ៉េ, ឡាវៀន, លីទុយអានី, ម៉ាឡាហ្គាស៊ី, ម៉ាស្សែល, ម៉ុងហ្គោលី,នរវេ, ប៉ូឡូញ, ព័រទុយហ្គាល់, រ៉ូម៉ានី, រុស្ស៊ី, សាម័រ, ស្លូវ៉ានី, អេស្ប៉ាញ, ស្វាហ៊ីលី, ស៊ុយអែត, តាហ្កាឡុក, តាហ៊ីទី, ថៃ, តុងហ្គា, អ៊ុយក្រែន, អ៊ឺឌូ និង វៀតណាម ។ ( ការចេញផ្សាយញឹកញាប់ប៉ុនណា គឺប្រែប្រួលទៅតាមភាសា ) ។



© 2015 ដោយ Intellectual Reserve, Inc ។ រក្សាសិទ្ធិគ្រប់យ៉ាង ។ បោះពុម្ពនៅសហរដ្ឋអាមេរិក ។

អត្ថបទ និង សម្ភារដែលមើលឃើញ ដែលមាននៅក្នុង *លីអាហូណា* អាចថតចម្លងយកទៅប្រើប្រាស់ជាបន្ទាប់បន្សំ ដែលមិនមែនជាការធ្វើពាណិជ្ជកម្មតាមសាសនាចក្រ ឬ តាមគេហដ្ឋានឡើយ ។ សម្ភារដែលមើលឃើញ មិនអាចថតចម្លងបានឡើយ ប្រសិនបើមានដាក់បម្រាម ដែលបានចង្អុលបង្ហាញត្រង់បន្ទាត់សម្គាល់ ដែលនៅជាមួយនឹងរូបសិល្បៈ ។ សំណួរទាក់ទងនឹងការរក្សាសិទ្ធិ គួរតែសាកសួរទៅកាន់ Intellectual Property Office, 50 E. North Temple St., Salt Lake City, UT 84150, USA អ៊ីម៉េល ៖ cor-intellectualproperty@ldschurch.org ។



**For Readers in the United States and Canada:**
April 2015 Vol. 14 No. 2. LIAHONA (USPS 311-480) Cambodian (ISSN 1538-4535) is published six times a year (January, April, June, July, October, and December) by The Church of Jesus Christ of Latter-day Saints, 50 E. North Temple St., Salt Lake City, UT 84150. USA subscription price is $5.00 per year; Canada, $6.00 plus applicable taxes. Periodicals Postage Paid at Salt Lake City, Utah. Sixty days' notice required for change of address. Include address label from a recent issue; old and new address must be included. Send USA and Canadian subscriptions to Salt Lake Distribution Center at address below. Subscription help line: 1-800-537-5971. Credit card orders (American Express, Discover, MasterCard, Visa) may be taken by phone or at store.lds.org. (Canada Post Information: Publication Agreement #40017431)

POSTMASTER: Send all UAA to CFS (see DMM 707.4.12.5). NONPOSTAL AND MILITARY FACILITIES: Send address changes to Distribution Services, Church Magazines, P.O. Box 26368, Salt Lake City, UT 84126-0368, USA.



ដោយ ប្រធាន
ថូម៉ាស អេស. ម៉នសុន

# ប្រធាន ម៉នសុន អំពាវនាវឲ្យមាន ភាពក្លាហាន



មួយម៉ោងបានកន្លងទៅយ៉ាងសន្សឹមៗ ប្រធាន ថូម៉ាស អេស ម៉នសុន បានសង្កេតថា តើអ្វីទៅដែលយើងបានហៅឲ្យធ្វើការជ្រើសរើសពីប្រភេទមួយ ឬមួយផ្សេងទៀត ។

ដើម្បីធ្វើការជ្រើសដ៏ឆ្លាតវៃ លោកបានទូន្មានថា យើងត្រូវការភាពក្លាហាន — « ភាពក្លាហានដើម្បីនិយាយថាទេ ភាពក្លាហានដើម្បីនិយាយថាបាន ។ ការសម្រេចចិត្តកំណត់ ដល់ជោគវាសនា »[1]

នៅក្នុងការដកស្រង់ខាងក្រោមនេះ ប្រធានម៉នសុន បានរំឭកដល់ពួកបរិសុទ្ធថា ពួកគេត្រូវការភាពក្លាហានដើម្បីឈរគាំទ្រចំពោះសេចក្ដីពិត និងសេចក្ដីសុចរិត ដើម្បីការពារអ្វីដែលយើងជឿ និងដើម្បីប្រឈមនឹងលោកីយ ដែលបដិសេធតម្លៃ និងគោលការណ៍ដ៏អស់កល្បជានិច្ច ។

លោកបានមានប្រសាសន៍ថា « យើងទាំងអស់គ្នាចាំបាច់ត្រូវមានភាព ក្លាហានជានិច្ច » ។ « វាតម្រូវឲ្យមានភាពក្លាហានក្នុងអតីតកាល ហើយនិងអនាគតកាលជារៀងរហូត »[2] ។

**ភាពក្លាហាននាំមកនូវការគាំទ្រពីព្រះអម្ចាស់**

« យើងទាំងអស់គ្នានឹងប្រឈមការភ័យខ្លាច ជួបការចំអក និងការប្រឆាំង ។ ចូរយើង — ទាំងអស់គ្នា — មានភាពក្លាហានឡើងដើម្បីតតាំងនឹងមតិទូទៅ និងគោលការណ៍ដើម្បីឈរឡើងចំពោះគោលការណ៍របស់យើង ។ ចូរក្លាហានកុំចុះញ៉ម ដើម្បីនាំភាពញញឹមដល់ការគាំទ្ររបស់ព្រះ ។ ភាពក្លាហានក្លាយជាគុណធម៌រស់រវើក ហើយទាក់ទាញវាមិនគ្រាន់តែជាការស្ម័គ្រចិត្តស្លាប់ដោយ ថ្លៃថ្នូប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជាការប្តេជ្ញាចិត្តរស់នៅ ដោយត្រឹមត្រូវផងដែរ ។ នៅពេលយើងបោះជំហានទៅមុខ ព្យាយាមរស់នៅដូចដែលយើងគួរតែរស់នៅ នោះយើងនឹងទទួលបានជំនួយពីព្រះពិតប្រាកដ ហើយអាចរកបានការលួងលោមចិត្តក្នុងព្រះបន្ទូលរបស់ទ្រង់ »[3]

**ស៊ូទ្រាំដោយភាពក្លាហាន**

« តើការស៊ូទ្រាំមានន័យដូចម្តេច ? ខ្ញុំស្រឡាញ់និយមន័យ ៖ *ដើម្បីស៊ូទ្រាំដោយភាពក្លាហាន* ។ ភាពក្លាហាន អាចជាការចាំបាច់សម្រាប់អ្នកដើម្បីជឿ វានឹងមានពេលខ្លះដែលចាំបាច់ឲ្យអ្នកគោរពប្រតិបត្តិផងដែរ ។ វាច្បាស់ណាស់ថាវានឹងតម្រូវឲ្យអ្នកស៊ូទ្រាំរហូតដល់ថ្ងៃនោះ ជាថ្ងៃដែលអ្នកនឹងចាកចេញពីជីវិតរមែងស្លាប់នេះ »[4]

**មានភាពក្លាហានដើម្បីឈរគាំទ្រដល់សេចក្តីពិត**

« [ សូម ] អ្នកមានភាពក្លាហានឡើង ដើម្បីឈរឲ្យរឹងមាំចំពោះសេចក្តីពិត និងសេចក្តីសុចរិត ។ ដោយសារ និន្នាការក្នុងសង្គមសព្វថ្ងៃងាកចេញពីគោលតម្លៃ និង គោលការណ៍ដែលព្រះអម្ចាស់បានប្រទានឲ្យយើង នោះអ្នកនឹងច្បាស់ជាត្រូវហៅឲ្យការពានូវអ្វី ដែលអ្នកជឿនោះ ។ លុះត្រាតែឫសនៃទីបន្ទាល់របស់អ្នកបានចាក់យ៉ាងរឹងមាំ វានឹងមានការពិបាកសម្រាប់អ្នកដើម្បីទប់ទល់នឹងអស់អ្នកណាដែលផ្ចាញ់ផ្ចាលសេចក្តីជំនឿរបស់អ្នក ។ ពេលអ្នកបានចាក់ឫសយ៉ាងរឹងមាំហើយ ទីបន្ទាល់របស់អ្នកនៃដំណឹងល្អ នៃព្រះសង្គ្រោះ និងនៃព្រះវរបិតាសួគ៌របស់យើង នឹងមានឥទ្ធិពលលើគ្រប់អ្វីដែលអ្នកធ្វើពេញមួយជីវិតរបស់អ្នក »[5]

**យើងត្រូវការភាពក្លាហានទាំងផ្នែកសីលធម៌ និងខាងវិញ្ញាណ**

« សារលិខិតនេះបានបង្ហាញលើទូរទស្សន៍ ក្នុងភាពយន្ត និងក្នុងប្រព័ន្ធផ្សព្វផ្សាយដទៃទៀត [ សព្វថ្ងៃនេះ ] គឺជាញឹកញាប់នៅក្នុងការប្រឆាំងដោយផ្ទាល់ទៅនឹងអ្វី ដែលយើងចង់ឲ្យកូនចៅរបស់យើងទទួលយក និងអោបក្រសោប ។ វាគឺជាទំនួលខុសត្រូវរបស់យើង មិនត្រឹមបង្រៀនពួកគេឲ្យរឹងមាំនៅក្នុងវិញ្ញាណ និងគោលលទ្ធិប៉ុណ្ណោះទេ ប៉ុន្តែក៏ជួយពួកគេឲ្យដាក់លំនឹងយ៉ាងមាំមួនផងដែរ ដោយមិនគិតពីកម្លាំងខាងក្រៅដែលពួកគេអាចនឹងប្រឈមមុខឡើយ ។ « វានឹងទាមទារនូវពេលវេលា និងការខិតខំប្រឹងប្រែងជាច្រើននៅលើផ្នែករបស់យើង — ហើយដើម្បីជួយដល់អ្នកដទៃ នោះយើងខ្លួនឯងត្រូវការភាពក្លាហានខាងវិញ្ញាណ និងខាងសាច់ឈាម ដើម្បីតស៊ូនឹងសេចក្តីអាក្រក់ដែលយើងឃើញគ្រប់ពេលវេលានោះ » ។[6]

**សូមយើងមានភាពក្លាហានជានិច្ច**

« ពេលដែលយើងព្យាយាមរស់នៅពីមួយថ្ងៃទៅមួយមួយថ្ងៃ វាស្ទើរតែជៀសមិនរួចថាសេចក្តីជំនឿ នឹងត្រូវបានផ្ចាញ់ផ្ចាល់ ។ ពេលខ្លះយើងអាចរកឃើញថាខ្លួនឯងត្រូវបានរុំព័ទ្ធដោយអ្នកដទៃជាច្រើន ហើយប៉ុន្តែនៅតែឈរនៅក្នុងចំណោមមនុស្សមួយចំនួនតូច ឬឈរម្នាក់ឯងដោយបារម្ភពីអ្វីដែលអាចទទួលយកបាន និងអ្វីដែលមិនអាចទទួលបាន ។ . . .

« សូមយើងមានភាពក្លាហានជានិច្ច ហើយរៀបចំខ្លួនដើម្បីឈរគាំទ្រចំពោះអ្វីដែលយើងជឿ ហើយបើយើងត្រូវឈរម្នាក់ឯងនៅក្នុងដំណើរការនោះ ចូរយើងធ្វើដូច្នោះដោយភាពក្លាហាន បានពង្រឹងដោយចំណេះដឹងដែលតាមពិតនោះ យើងមិនដែលនៅម្នាក់ឯងទេ ពេលយើងឈរជាមួយនឹងព្រះវរបិតាសួគ៌នោះ »[7] ■

**ការបង្រៀនចេញពីសារលិខិតនេះ**

អ្នកអាចសួរដល់អស់អ្នកដែលអ្នកបង្រៀន ឲ្យគិតពីស្ថានភាពមួយក្នុងសប្តាហ៍ខាងមុខនេះ — នៅផ្ទះ នៅកន្លែងធ្វើការ នៅសាលារៀន ឬនៅព្រះវិហារ — ដែលតម្រូវឲ្យគេបញ្ចេញសកម្មភាពដោយភាពក្លាហាន ។ ពួកគេអាចប្រឈមមុខនឹងការភ័យខ្លាច ស៊ូទ្រាំនឹងអ្វីដែលលំបាក ឈរសម្រាប់សេចក្តីជំនឿរបស់គេ ឬសម្រេចចិត្តធ្វើតាមគោលការណ៍នៃដំណឹងល្អបន្ថែមទៀតពេញលេញ ។ សូមអញ្ជើញឲ្យពួកគេចែកចាយនូវគំនិតរបស់ពួកគេ ឬសរសេរគំនិតនោះ ។

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « Three Goals to Guide You, » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ 2010, ទំព័រ 67, 68 ។
2. ថូម៉ាស អេស ម៉នសុន « The Race of Life » *លីអាហូណា*, ខែ ឧសភា ឆ្នាំ 2004 ទំព័រ 55 ។
3. ថូម៉ាស អេស ម៉នសុន « Be Strong and of a Good Courage » *លីអាហូណា*, ខែ ឧសភា ឆ្នាំ 2014 ទំព័រ 66, 67, 69 ។
4. ថូម៉ាស អេស ម៉នសុន, « Be Thou an Example » *លីអាហូណា*, ខែ ឧសភា ឆ្នាំ 2012, ទំព័រ 129 ។
5. ថូម៉ាស អេស ម៉នសុន « May You Have Courage » *លីអាហូណា*, ខែ ឧសភា ឆ្នាំ 2009, ទំព័រ 126 ។
6. ថូម៉ាស អេស ម៉នសុន « Three Goals to Guide You » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ 2007, ទំព័រ 118–19 ។
7. ប្រធាន ថូម៉ាស អេស ម៉នសុន « Dare to Stand Alone » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ 2011, ទំព័រ 60, 67 ។

រូបភាពដោយ ISTOCK/THINKSTOCK

## សារ៉ា របស់នរណាម្នាក់ផ្សេងទៀត

ដោយ ម៉ាក់ឃែនហ្ស៊ី មៀលលើរ

ខ្ញុំធ្លាប់រកឃើញថា វាលំបាកក្នុងការប្រើជំនឿរបស់ខ្ញុំជាការឆ្លើយតបទៅនឹងសំណួរសាមញ្ញដូចជា « ហេតុអ្វីបានជាអ្នកមិនផឹកកាហ្វេ ? » ក្នុងពេលកន្លងមក ខ្ញុំបាននឹកឃើញពីពាក្យដោះសារដូចជា « វាមានរស់ជាតិល្វីងពេក » ឬ « ខ្ញុំមិនចូលចិត្តរស់ជាតិវាទេ » ។

តើហេតុអ្វី បានជាខ្ញុំមានការខ្មាស់អៀន ? តើហេតុអ្វីបានជាខ្ញុំមានការភ័យខ្លាច ដើម្បីឈរគាំទ្រចំពោះអ្វីដែលខ្ញុំជឿដូច្នេះ ? ដោយសន្លឹងមើលទៅក្រោយវិញក្នុងពេលឥឡូវនេះ ខ្ញុំមិនយល់ច្បាស់ពីអ្វីដែលខ្ញុំភ័យខ្លាចនោះទេ ។ ប៉ុន្តែ ខ្ញុំចាំច្បាស់ពីពេលដែលខ្ញុំបានឈប់លាក់ខ្លួននៅពីក្រោយការដោះសារទាំងនោះ ។

ថ្ងៃមួយ ក្នុងថ្នាក់ភាសាអង់គ្លេសរបស់ខ្ញុំនៅវិទ្យាល័យ លោកគ្រូបានប្រកាសថា យើងនឹងមើលរឿងភាគកម្មវិធីតាមទូរទស្សន៍មួយ ខ្ញុំបានដឹងថាយើងមិនគួរមើលវាទេ ។ ខណៈដែលសិស្សដទៃទៀតបានស្រែកហោនៅក្នុងការរំភើប មិត្តរួមថ្នាក់របស់ខ្ញុំម្នាក់ គឺសារ៉ា បានលើកដៃឡើង ហើយសួរថាតើនាងអាចចាកចេញបានទេ ។

ពេលដែលលោកគ្រូសួរពីមូលហេតុ សារ៉ាបានឆ្លើយតបតាមត្រង់ថា « ដោយសារខ្ញុំគឺជានារីមរមន ហើយខ្ញុំមិនមើលកម្មវិធីដែលមានពាក្យប្រមាថនោះទេ » ។

ភាពក្លាហានរបស់នាងដើម្បីឈរឡើងនៅចំពោះមុខថ្នាក់ គឺអស្ចារ្យមែនទេ ។ អរគុណដល់សារ៉ា ខ្ញុំក៏ក្រោកឈរឡើង ហើយរង់ចាំនៅខាងក្រៅថ្នាក់ជាមួយនឹងមនសិការច្បាស់លាស់ សម្រាប់ឲ្យកម្មវិធីនោះចប់ ។

ខ្ញុំត្រូវបានផ្លាស់ប្ដូរជារៀងរហូត ។ ខ្ញុំបានចាប់ផ្ដើមពន្យល់ពីជំនឿរបស់ខ្ញុំ ជាជាងការជៀសវាងពីប្រធានបទ ។ ហើយជាលទ្ធផល ខ្ញុំបានរកឃើញទំនុកចិត្តលើខ្លួនឯង ហើយបានចូលរួមកាន់តែសកម្មនៅក្នុងសាសនាចក្រ និងសកម្មភាពនានានៅសាលា ។

ខ្ញុំមិនធ្លាប់បានប្រាប់ សារ៉ា ថាគំរូរបស់នាងមានន័យយ៉ាងណាចំពោះខ្ញុំទេ ប៉ុន្តែខ្ញុំព្យាយាមធ្វើតាមគំរូនៃទំនុកចិត្តរបស់នាង ។ ឥឡូវនេះខ្ញុំដឹងថា ការធ្វើជាសមាជិករបស់ព្រះ គឺអស្ចារ្យណាស់ សាសនាចក្រដ៏ពិសិដ្ឋគឺគ្មានអ្វីដែលត្រូវខ្មាស់អៀននោះទេ ។ ខ្ញុំសង្ឃឹមថា តាមរយៈគំរូរបស់ខ្ញុំ ខ្ញុំអាចក្លាយជាសារ៉ារបស់នរណាម្នាក់ផ្សេងទៀត ។

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*



## ភាពក្លាហាននៅក្នុងព្រះគម្ពីរ

ប្រធាន ម៉នសុន បង្រៀនយើងឲ្យមានភាពក្លាហាន ហើយឈរគាំទ្រចំពោះអ្វីដែលយើងជឿ ។ មានគំរូជាច្រើននៃតួអង្គនៅក្នុងព្រះគម្ពីរដែលបានបង្ហាញពីភាពក្លាហាន។ សូមអានខម្ពីរនៅក្បែរនឹងឈ្មោះនីមួយៗ ។ តើមនុស្សទាំងនេះបង្ហាញភាពក្លាហាន និងឈរគាំទ្រចំពោះអ្វីដែលពួកគេបានដឹងថាត្រឹមត្រូវដោយរបៀបណា ? សូមប្រើចន្លោះទាំងនេះ ដើម្បីសរសេរ ឬគូររូបភាពមួយនៃចម្លើយរបស់អ្នក ។



យ៉ូសែប ស្ម៊ីធ ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ 1:11–17 )

ដានីយ៉ែល ( ដានីយ៉ែល 6:7, 10–23 )

សាំយូអែលសាសន៍លេមិន ( ហេលេមិន 13:2–4; 16:1–7 )

នាងអេសធើរ ( នាងអេសធើរ 4:5–14; 5:1–8; 7:1–6 )

រូបថតដោយ ISTOCK/THINKSTOCK

*សូមសិក្សាឯកសារនេះដោយការអធិស្ឋាន ហើយព្យាយាមយល់ដឹងនូវអ្វីដែលត្រូវចែកចាយ ។ តើការយល់ដឹងពីខ្សែជីវិត និង បេសកកម្មរបស់ព្រះអង្គសង្គ្រោះ នឹងពង្រឹងសេចក្ដីជំនឿរបស់អ្នកទៅលើទ្រង់ ហើយប្រទានពរដល់អ្នកទាំងឡាយណាដែលអ្នកមើលថែ តាមរយៈការបង្រៀនសួរសុខទុក្ខបានដោយរបៀបណា ? សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅគេហទំព័រ reliefsociety.lds.org ។*

# លក្ខណៈសម្បត្តិរបស់ព្រះយេស៊ូវគ្រីស្ទ ៖ ដោយគ្មានការលាក់ពុត ឬ ឧបាយកលឡើយ

*នេះជាផ្នែកនៃគំរូមួយអំពីសារលិខិតបង្រៀនសួរសុខទុក្ខ ដែលឆ្លុះបញ្ចាំងពីលក្ខណៈសម្បត្តិរបស់ព្រះអង្គសង្គ្រោះ ។*

ការយល់ដឹងថា ព្រះយេស៊ូវគ្រីស្ទ គ្មានការលាក់ពុត និង ឧបាយកល នឹងជួយយើងឲ្យព្យាយាមដោយស្មោះត្រង់ ដើម្បីធ្វើតាមគំរូរបស់ទ្រង់ ។ អែលឌើរ យ៉ូសែប ប៊ី. វ៉ឺតលីន ( ឆ្នាំ 1917–2008 ) នៃកូរ៉ុមនៃ ពួកសាវក ដប់ពីរនាក់ បានមានប្រសាសន៍ថា ៖ « ការល្បួងលោម គឺជាការបោកបញ្ឆោត ឬនាំឲ្យវង្វេង ។ . . . មនុស្សម្នាក់ដែលគ្មានឧបាយកល គឺជាមនុស្សម្នាក់ដែលទៀងត្រង់ ចេតនាស្មោះត្រង់ និងបំណងបរិសុទ្ធ ជាជីវិតដែលឆ្លុះបញ្ចាំងពីការអនុវត្តដ៏សាមញ្ញ នៃការបញ្ជាក់ពីសកម្មភាពប្រចាំថ្ងៃរបស់[គាត់]ទៅនឹងគោលការណ៍នៃសេចក្ដីសុចរិត ។ . . . ខ្ញុំជឿថា ភាពចាំបាច់សម្រាប់សមាជិកនៃសាសនាចក្រដើម្បីឲ្យគ្មានឧបាយកល ប្រហែលជាបន្ទាន់ជាងគ្រាណាៗទាំងអស់ ដោយសារមនុស្សជាច្រើននៅក្នុងពិភពលោកនេះ ជាក់ស្ដែងមិនយល់ពីសារៈសំខាន់នៃគុណធម៌ទេ » ។[1]

អែលឌើរ ឌៀថើរ អេហ្វ អុជដូហ្វ ទីប្រឹក្សាទីពីរ នៅក្នុងគណៈប្រធានទីមួយ បានមានប្រសាសន៍ថា ដោយគំនិតលាក់ពុត ៖ « គ្មាននរណាម្នាក់ក្នុងចំណោមយើងដូចព្រះគ្រីស្ទទេ ទោះជាយើងដឹងថា យើងគួរតែធ្វើឲ្យដូចក្ដី ។ តែយើងមានបំណងអស់ពីចិត្ត ដើម្បីយកឈ្នះកំហុស និងនិន្នាការធ្វើអំពើបាប ។ ជាមួយនឹងដួងចិត្ត និងព្រលឹងយើង យើងចង់ប្រែក្លាយកាន់តែប្រសើរ ដោយមានជំនួយពីដង្វាយធួនរបស់ព្រះគ្រីស្ទ » ។[2]

យើងដឹងថា « យើងនឹងត្រូវជំនុំជំរះស្របតាមទង្វើរបស់យើង បំណងប្រាថ្នានៃដួងចិត្តរបស់យើង និងប្រភេទមនុស្សដែលយើងបានក្លាយទៅជា »[3] ប៉ុន្តែពេលដែលយើងខិតខំ យើងនឹងក្លាយជាបរិសុទ្ធបន្ថែមទៀត — និង « មានពរហើយ អស់អ្នកដែលមានចិត្តបរិសុទ្ធ ដ្បិតអ្នកទាំងនោះនឹងបានឃើញព្រះ » ( ម៉ាថាយ 5:8 ) ។



### ខគម្ពីរបន្ថែម

ទំនុកដំកើង 32:2; យ៉ាកុប 3:17; ពេត្រុសទី 1 2:1–2, 22

### សូមពិចារណាចំណុចនេះ

តើយើងអាចរៀនអ្វីខ្លះ អំពីការគ្មានឧបាយកលពីកូនក្មេងតូចទាំងនេះ ? ( សូមមើល សេចក្ដីណែនាំដល់បទគម្ពីរ, « ឧបាយកល » ។ )

**កំណត់ចំណាំ**

1. យ៉ូសែប ប៊ី វ៉ឺតលីន, "Without Guile," *Ensign*, ខែ ឧសភា ឆ្នាំ 1988, ទំព័រ 80, 81 ។
2. ឌៀថើរ អេស្វ អុជដូហ្វ, « មក ចូលរួមនឹងពួកយើង, » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ 2013, ទំព័រ 23 ។
3. *ក្បួនខ្នាតភាគ 2 ៖ ការគ្រប់គ្រងសាសនាចក្រ* ( ឆ្នាំ 2010 ), ទំព័រ 1.2.1 ។

**សេចក្ដីជំនឿ ក្រុមគ្រួសារ ការសង្គ្រោះ**

### ដកស្រង់ចេញពីព្រះគម្ពីរ

កុមារតូចៗគ្មានឧបាយកលឡើយ ។ ព្រះយេស៊ូវគ្រីស្ទទ្រង់ មានព្រះបន្ទូលថា ៖ « ទុកឲ្យកូនក្មេងមកឯខ្ញុំចុះ កុំឃាត់វាឡើយ ដ្បិតនគរព្រះមានសុទ្ធតែមនុស្ស ដូចវារាល់គ្នាដែរ ។ . . . ទ្រង់ក៏ឱប [ ក្មេងរាល់គ្នា ] ហើយដាក់ព្រះហស្ដលើ ទាំងប្រទានពរឲ្យផង » ( ម៉ាកុស 10:14, 16 ) ។

ព្រះគ្រីស្ទ ក៏បានបង្រៀនកូនក្មេងនៅក្នុងទ្វីបអាមេរិក បន្ទាប់ពីការឆ្កាងរបស់ទ្រង់ ។ ទ្រង់បានបញ្ជាប្រជាជនឲ្យនាំកូនក្មេងតូចៗរបស់គេមកឯទ្រង់ហើយ « នាំកូនក្មេងតូចៗមកអង្គុយនៅលើទីដីជុំវិញព្រះអង្គ ហើយព្រះយេស៊ូវទ្រង់ឈរនៅកណ្ដាល . . .

« . . . [ ហើយ ] ទ្រង់ព្រះកន្សែង ហើយបណ្ដាជនបានធ្វើបន្ទាល់ពីការណ៍នេះ ហើយទ្រង់បានយកកូនក្មេងរបស់ពួកគេ ម្ដងម្នាក់ៗ ហើយបានប្រទានពរដល់ពួកវា ហើយបានអធិស្ឋានដល់ព្រះវរបិតាសម្រាប់ពួកវា ។ . . .

« ហើយនៅពេលពួកគេក្រលេកមើលទៅនោះពួកគេបានសម្លឹងទៅលើផ្ទៃមេឃ ហើយពួកគេឃើញពួកទេវតាហោះចុះមកពីស្ថានសួគ៌ហាក់បីដូចជានៅកណ្ដាលភ្លើង ហើយពួកទេវតាក៏ចុះមកហែរហមជុំវិញពួកកូនក្មេង ទាំងនោះ . . . ហើយពួកទេវតាបានធ្វើការបម្រើដល់ពួកកូនក្មេង » ( នីហ្វៃទី 3 17:12, 21, 24 ) ។

# អំណាចនៃសេចក្ដីជំនឿ

**ដោយ អែមមើរ បាឡូ ដាល**

*ប្រសិនបើព្រះវរបិតាសួគ៌បានដោះលែងយើងពីបញ្ហាប្រឈមទាំងអស់របស់យើង គ្រាន់តែដោយសារយើងបានសុំដល់ទ្រង់ នោះទ្រង់នឹងបដិសេធមិនទទួលស្គាល់បទពិសោធន៍ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។*

ក្នុងឆ្នាំមួយនៅក្នុងមហាវិទ្យាល័យ ពេលខ្ញុំកំពុងធ្វើការប្រឡងមួយ ករបស់ខ្ញុំបានចាប់ផ្ដើមឈឺ ។ ការឈឺចាប់នោះមិនបាត់សោះ សូម្បីតែភាពតានតឹងនៃការប្រឡងបានកន្លងហួសទៅក៏ដោយ ។ ខ្ញុំបានប្រឹក្សាជាមួយនឹងវេជ្ជបណ្ឌិត និងអ្នកព្យាបាលរោគ ហើយបានព្យាយាមសាកល្បងនឹងការព្យាបាលខុសៗគ្នាជាច្រើន ប៉ុន្តែការឈឺចាប់នោះនៅតែបន្ត ។ នៅឆ្នាំក្រោយនោះ ពេលដែលខ្ញុំបានពុះពារស៊ូទ្រាំនឹងការឈឺចាប់នេះ ខ្ញុំក៏បានពុះពារ ដើម្បីបង្កើនសេចក្ដីជំនឿរបស់ខ្ញុំដែរ ។ ខ្ញុំបានចំណាយពេលជាច្រើនធ្វើការអធិស្ឋាន ខ្ញុំបានសិក្សាព្រះគម្ពីរ និងខ្ញុំបានសុំការប្រសិទ្ធពរនៃបព្វជិតភាព ។ ខ្ញុំមានអារម្មណ៍ថា ប្រសិនបើខ្ញុំមានសេចក្ដីជំនឿគ្រប់គ្រាន់ នោះខ្ញុំនឹងត្រូវបានប្រោសឲ្យជាសះស្បើយ ។

ព្រះយេស៊ូវគ្រីស្ទបានប្រោសអ្នកឈឺឲ្យជាមនុស្សខ្វាក់ឲ្យមើលឃើញ មនុស្សខ្វិនឲ្យដើររួច មនុស្សឃ្លង់ពីរោគា — « ស្របតាមសេចក្ដីជំនឿរបស់ [ ពួកគេ ] » ( ម៉ាថាយ 9:29 ) ។ ខ្ញុំដឹងថាទ្រង់មានព្រះចេស្ដាដើម្បីប្រោសខ្ញុំ ដូចដែលទ្រង់បានប្រោសមនុស្សជាច្រើនផ្សេងទៀតក្នុងអំឡុងជីវិតរមែងស្លាប់របស់ទ្រង់ ។ ដូច្នេះហើយខ្ញុំបានសរុបថា មកពីខ្ញុំខ្វះសេចក្ដីជំនឿ វាបានបញ្ឈប់ខ្ញុំពីការប្រោសឲ្យជា ដូច្នេះខ្ញុំបានខិតខំទ្វេដងលើការប្រឹងប្រែងរបស់ខ្ញុំ ។ ខណៈពេលដែលខ្ញុំបន្តជាមួយនឹងការព្យាបាលដោយការពង្រឹងកាយវិប្បកម្មខ្ញុំបានអធិស្ឋាន និងតមអាហារ និងសិក្សា ហើយមានជំនឿ ។ ប៉ុន្តែការឈឺចាប់របស់ខ្ញុំនៅតែបន្តមាន ។

ព្រះគម្ពីរបង្រៀនយើងថា ដោយសេចក្ដីជំនឿយើងអាចធ្វើឲ្យមានអព្ភូតហេតុដ៏អស្ចារ្យកើតឡើង ( សូមមើល ម៉ាថាយ 17:20 ) ប៉ុន្តែខ្ញុំមិនអាចបានធូរស្រាលពីការរងទុក្ខវេទនាយ៉ាងតិចតួចនេះសោះ ។ តើអំណាចនៃសេចក្ដីជំនឿរបស់ខ្ញុំនៅឯណា ? ទីបំផុត ខ្ញុំបានទទួលយកស្ថានភាពរបស់ខ្ញុំដោយស្ងាត់ស្ងៀម បានរកឃើញវិធីដើម្បីស៊ូទ្រាំនឹងភាពមិនសុខស្រួលរបស់ខ្ញុំ ហើយបានក្លាយទៅជាមានចិត្តរីករាយដើម្បីរក្សាទុកការយល់ដឹងដ៏ពេញលេញនៃសេចក្ដីជំនឿ និងការព្យាបាលនាពេលអនាគត ។

ជាច្រើនឆ្នាំក្រោយមក ខ្ញុំបាននិយាយជាមួយមិត្តភក្ដិម្នាក់ដែលបានពុះពារជាមួយនឹងការចង់ក្អួតចង្អោរដ៏អាក្រក់ ដែលបានបញ្ជូនគាត់ទៅមន្ទីរពេទ្យជាច្រើនដង ក្នុងអំឡុងពេលមានផ្ទៃពោះជាលើកដំបូងរបស់គាត់ ។ អេរិន ចង់មានកូនម្នាក់ទៀត ប៉ុន្តែគាត់មានការភ័យខ្លាចថាគាត់នឹងត្រូវទ្រាំទ្រនឹងភាពមិនសុខស្រួលដូចដែលគាត់បានប្រឈមជាមួយនៅការមានផ្ទៃពោះជាលើកដំបូងរបស់គាត់ ។ គាត់បានប្រាប់ខ្ញុំថា គាត់បានធ្វើការតមអាហារ និងអធិស្ឋាន ហើយថាគាត់ពិតជាជឿថាព្រះវរបិតាសួគ៌នឹងមិនឲ្យគាត់ជួបនឹងបញ្ហាដដែលនៅលើកទីពីរទេ ។

ពេលដែលយើងបាននិយាយគ្នា ខ្ញុំបាននឹកឃើញពីខគម្ពីរមួយ « ចូរបង្អង់សិន ឲ្យបានដឹងថាអញជាព្រះ » ( ទំនុកដំកើង 46:10 ) ។ ខ្ញុំបានគិតពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំ ក្នុងការរៀនសូត្រមានចិត្តស្ងប់នៅកណ្ដាលទុក្ខវេទនា ហើយបានជម្រុញឲ្យ អេរិន បន្តមានជំនឿ ប៉ុន្តែកុំឲ្យអាស្រ័យលើជំនឿនោះថា គាត់នឹងមានបទពិសោធន៍នៃការចង់ក្អួតចង្អោរជាមួយនឹងការមានផ្ទៃពោះលើកក្រោយរបស់គាត់ ឬអត់ ។

ពេលដែលខ្ញុំបន្តសិក្សាគោលការណ៍នៃសេចក្ដីជំនឿ ខ្ញុំបានត្រឡប់ទៅសម្ដីរបស់អាល់ម៉ាលើសេចក្ដីជំនឿ ដែលគាត់បានបង្រៀនថា « បើសិនជាអ្នករាល់គ្នាមានសេចក្ដីជំនឿ នោះអ្នករាល់គ្នាសង្ឃឹមទៅលើអ្វីៗ ដែលមើលមិនឃើញ ហើយដែលពិត » ( អាលម៉ា 32:21 ) ។

ការពិចារណាពីខគម្ពីរនេះ ខ្ញុំបានរកឃើញថាសេចក្ដីជំនឿ មិនមែនជាអ្វីដូចដែលខ្ញុំបានគិតនោះទេ ។ អាល់ម៉ាបង្រៀនយើងថា សេចក្ដីជំនឿគឺជាសេចក្ដីសង្ឃឹមនៅក្នុងគោលការណ៍ពិត ។ ការមានសេចក្ដីជំនឿ មិនមានន័យថាយើងជឿថា



**ឈរឲ្យខ្ពស់ជាងការសាកល្បង**

« តើវាមិនមែនជាប្រាជ្ញានៅក្នុង [ ព្រះវរបិតាសួគ៌ ] ដែលប្រទានដល់យើងនូវការសាកល្បងដែលយើងអាចយកឈ្នះលើវា ដើម្បីយើងអាចសម្រេចបាននូវការទទួលខុសត្រូវ ធ្វើការដើម្បីពង្រឹងសាច់ដុំរបស់យើង ហើយទុក្ខព្រួយដើម្បីសាកល្បងព្រលឹងយើងទេឬអី ? តើយើងពុំត្រូវបានបណ្ដាលឲ្យជកពិសោធន៍ពីការល្បួង ដើម្បីល្បងពីកម្លាំងរបស់យើង ជម្ងឺ ដើម្បីឲ្យយើងអាចរៀនពីការអត់ធ្មត់ សេចក្ដីស្លាប់ ដើម្បីយើងអាចទទួលបានអមតភាព និង សិរីល្អទេឬអី ? »

« ប្រសិនបើអ្នកឈឺគ្រប់រូបដែលយើងបានអធិស្ឋានឲ្យបានជាសះស្បើយ ប្រសិនបើមនុស្សសុចរិតទាំងអស់ត្រូវបានការពារ ហើយមនុស្សទុច្ចរិតទាំងអស់ត្រូវបំផ្លាញ នោះកម្មវិធីទាំងមូលរបស់ព្រះវរបិតា នឹងត្រូវទុកជាមោឃៈ ហើយគោលការណ៍មូលដ្ឋាននៃដំណឹងល្អ គឺសិទ្ធិជ្រើសរើស នឹងត្រូវបញ្ចប់ ។ គ្មានមនុស្សណាម្នាក់ចាំបាច់ត្រូវរស់ដោយសេចក្ដីជំនឿ » ។

**ប្រធាន ស្ពែនស៊ើរ ដបុលយូ឵ ឃីមបឹល ( ឆ្នាំ 1895–1985 ), *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ ស្ពែនស៊ើរ ដបុលយូ ឃីមបឹល* ( ឆ្នាំ 2006 ), ទំព័រ 15 ។**



ព្រះវរបិតាសួគ៌នឹងតែងតែប្រទានដល់យើងនូវអ្វីដែលយើងសុំ នៅពេលដែលយើងសុំវាពីទ្រង់នោះទេ ។ កាមានសេចក្ដីជំនឿថា ព្រះគ្រីស្ទនឹងធ្វើឲ្យករបស់ខ្ញុំបានជា ឬថាទ្រង់នឹងប្រទានដល់ អេរិន កុំឲ្យមានអាការចង់ក្អួតចង្អោរនៅពេលមានផ្ទៃពោះ គឺមិនមែនមានសេចក្ដីជំនឿនៅក្នុងគោលការណ៍ពិតនោះទេ ។ ទោះជាយ៉ាងណា យើងអាចមានសេចក្ដីជំនឿថាព្រះគ្រីស្ទ មានព្រះចេស្ដាដើម្បីប្រោស ថាទ្រង់មានព្រះទ័យទុកដាក់ចំពោះយើងទាំងអស់គ្នា ថាទ្រង់នឹងពង្រឹងយើង ហើយថាបើយើងស៊ូទ្រាំកាន់តែខ្លាំង យើងនឹងមានភាពសក្ដិសមសម្រាប់ជីវិតដ៏អស់កល្បជានិច្ច ។

ព្រះអម្ចាស់បានសន្យាថា « អ្វីក៏ដោយ ដែលអ្នកសូមដោយសេចក្ដីជំនឿ ដោយជឿថា អ្នកនឹង បានទទួល ដោយនូវព្រះនាមនៃព្រះគ្រីស្ទ អ្នកនឹងបានទទួលជាមិនខានឡើយ » ( អេណុស 1:15 ) ។ ខ្ញុំជឿថាអំណាចក្នុងការសន្យានេះ ស្ថិតនៅក្នុងការទូន្មានឲ្យជឿលើ « ព្រះនាមនៃព្រះអម្ចាស់ » ។ វចនានុក្រមនៃព្រះគម្ពីរបរិសុទ្ធអំពីការអធិស្ឋានបង្រៀនយើងថា « យើងអធិស្ឋាននៅក្នុងព្រះនាមព្រះគ្រីស្ទ ពេលគំនិតយើងជាគំនិតរបស់ព្រះគ្រីស្ទ ហើយសេចក្ដីប្រាថ្នាយើងជាសេចក្ដីប្រាថ្នារបស់ព្រះគ្រីស្ទ — ពេលព្រះបន្ទូលទ្រង់នៅជាប់ក្នុងយើងរាល់គ្នា ( យ៉ូហាន 15:7 ) ។ រួចហើយយើងទូលសុំនូវអ្វីៗដែលអាចធ្វើបានដើម្បីឲ្យព្រះអាចប្រទាន ។ ការអធិស្ឋាន ជាច្រើននៅតែមិនទាន់ឆ្លើយតបនៅឡើយ ពីព្រោះអ្វីៗទាំងនេះមិននៅក្នុងព្រះនាមរបស់ព្រះគ្រីស្ទ ទាល់តែសោះ វាពុំមែនជាតំណាងនៃគំនិតរបស់ទ្រង់ ប៉ុន្តែដុះចេញមកពីចិត្តកំណាញ់នៃដួងចិត្តរបស់មនុស្ស » ។

ពេលដែលយើងសុំនៅក្នុងសេចក្ដីជំនឿសម្រាប់អ្វីដែលស្របតាមព្រះឆន្ទៈរបស់ព្រះអម្ចាស់ ទ្រង់នឹងប្រទានដល់យើងស្របតាមបំណងប្រាថ្នារបស់យើងដែរ ។ ព្រះវរបិតាសួគ៌ទ្រង់ស្គាល់យើងម្នាក់ៗ ទ្រង់ស្រឡាញ់យើង ហើយចង់ឲ្យយើងមានអ្វីគ្រប់យ៉ាងដែលចាំបាច់សម្រាប់យើងត្រឡប់ទៅកាន់វត្តមានទ្រង់ ។ ហើយពេលខ្លះវារួមបញ្ចូលទាំងការសាកល្បង រឿងអំពល់ និងបញ្ហាផ្សេងៗផង ( សូមមើល ពេត្រុសទី 1 1:7 ) ។ ប្រសិនបើព្រះវរបិតាសួគ៌បានដោះលែងយើងពីបញ្ហាប្រឈមទាំងអស់របស់យើង គ្រាន់តែដោយសារយើងបានសុំដល់ទ្រង់ នោះទ្រង់នឹងបដិសេធមិនទទួលស្គាល់បទពិសោធន៍ដែលចាំបាច់សម្រាប់សេចក្ដីសង្គ្រោះរបស់យើង ។ យើងត្រូវតែរៀនដើម្បីទុកចិត្តលើផែនការរបស់ព្រះអម្ចាស់ដែលមានសម្រាប់យើងរាល់គ្នា ហើយដាក់ឆន្ទៈរបស់យើងទៅក្នុងព្រះឆន្ទៈរបស់ទ្រង់ ។ នៅពេលយើងតម្រឹមបំណងប្រាថ្នាជាមួយនឹងបំណងប្រាថ្នារបស់ទ្រង់ ហើយទទួលស្គាល់ការពឹងផ្អែកទាំងស្រុងរបស់យើងទៅលើទ្រង់ នោះយើងអាចសក្ដិសមដើម្បីទទួលបាន « ចុងបំផុតនៃសេចក្ដីជំនឿរបស់ [ យើងរាល់គ្នា ] គឺជាសេចក្ដីសង្គ្រោះដល់ព្រលឹង [ យើង ] » ( ពេត្រុសទី 1 1:9 ) ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ អូរីហ្គិន ស.រ.អា ។*



# រាត្រីជួបជុំក្រុមគ្រួសារ — អ្នកអាចធ្វើបាន !

*មិនថាក្រុមគ្រួសាររបស់អ្នកយ៉ាងណាទេ រាត្រីជួបជុំក្រុមគ្រួសារអាចប្រទានពរ និងពង្រឹងអ្នក ។*

ឪពុកម្នាក់ត្រឡប់មកផ្ទះវិញដោយការនឿយហត់បន្ទាប់ពីធ្វើការពេញមួយថ្ងៃមក ហើយឃើញថាសមាជិកគ្រួសារដទៃទៀតកំពុងពុះពារនឹងអារម្មណ៍មួម៉ៅស្រដៀងគ្នាដែរ ។ វាជារាត្រីថ្ងៃច័ន្ទ ហើយការធ្វើរាត្រីក្រុមគ្រួសារ ហាក់ដូចជាមិនអាចទៅរួចសោះ ។ បន្ទាប់ពីអធិស្ឋានសុំជំនួយ ឪពុក និងម្ដាយសម្រេចចិត្តធ្វើរាត្រីជួបជុំក្រុមគ្រួសារនោះយ៉ាងសាមញ្ញ ។ ពួកគេបានហៅក្រុមគ្រួសារមកជួបជុំគ្នា ច្រៀងទំនុកតម្កើង ហើយអធិស្ឋានរួមគ្នា ។ ពួកគេបានឲ្យទៀនតូចមួយដល់សមាជិកគ្រួសារម្នាក់ៗ ដើម្បីបំភ្លឺពេលដែលពួកគេប្រាប់ពីអ្វី ដែលបំផុសគំនិតពួកគេក្នុងពេលថ្មីៗ ។ នៅក្នុងបន្ទប់ដ៏ងងឹត ពន្លឺរបស់ភ្លើងទៀនតំណាងឲ្យការបំផុសគំនិត និងឲ្យកូនៗផ្ដោតយកចិត្តទុកដាក់ ។ ពេលដែលទីបន្ទាល់ត្រូវបានចែកចាយ អារម្មណ៍នៃសេចក្ដីសុខសាន្តដ៏ផ្អែមល្ហែមមួយ បានជ្រៀតចូលនៅក្នុងផ្ទះ ។ ក្រុមគ្រួសារ បានបញ្ចប់រាត្រីនោះដោយសេចក្ដីអំណរដែលពួកគេបានធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។

តើអ្នកបានដឹងទេថា រាត្រីជួបជុំក្រុមគ្រួសារបានកើតមានជាកម្មវិធីសាសនាចក្រអស់រយៈពេល 100 ឆ្នាំហើយទេ ? នៅខែ មេសា ឆ្នាំ 1915 គណៈប្រធានទីមួយ បានដឹកនាំសមាជិកឲ្យទុកមួយយប់រាល់សប្ដាហ៍ សម្រាប់ការអធិស្ឋានជាក្រុមគ្រួសារ តន្ត្រី ការរៀនសូត្រដំណឹងល្អ រឿងនិទាន និងសកម្មភាពនានា ។ ( សូមមើលទំព័រ 80 សម្រាប់ការដកស្រង់ពីសារលិខិតរបស់គណៈប្រធានទីមួយ ) ព្យាការីទាំងឡាយ បានបន្តរំឭកយើងពីសារៈសំខាន់នៃរាត្រីជួបជុំក្រុមគ្រួសារ ។ ប្រធាន ថូម៉ាស អេស ម៉នសុន បានមានប្រសាសន៍ថា « យើងមិនអាចធ្វេសប្រហែសនឹងកម្មវិធីដែលបានបំផុសគំនិតពីស្ថានសួគ៌នេះបានទេ » ។ « វាអាចនាំមកនូវការរីកចម្រើនខាងវិញ្ញាណដល់សមាជិកគ្រួសារម្នាក់ៗ ជួយគាត់ឲ្យស៊ូទ្រាំនឹងការល្បួងដែលមាននៅគ្រប់ទីកន្លែង »[1]

ខាងក្រោមនេះ គឺជាឥរិយាបទមួយចំនួនដើម្បីរក្សាទុកក្នុងចិត្តថា ពេលដែលអ្នកធ្វើឲ្យរាត្រីជួបជុំក្រុមគ្រួសារជាផ្នែកមួយនៃសប្ដាហ៍របស់អ្នក ៖

*វាបានអនុវត្តចំពោះខ្ញុំ ។* អែលឌើរ អិល ថម ភែរី នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់បានមានប្រសាសន៍ថា « រាត្រីជួបជុំក្រុមគ្រួសារ គឺសម្រាប់មនុស្សគ្រប់គ្នា » ។[2] យើងទាំងអស់គ្នា — អ្នកដែលរៀបការហើយ ឬនៅលីវ — អាចលះបង់ពេលវេលាដើម្បីពង្រឹងគ្រួសារ និងរៀនសូត្រដំណឹងល្អ ។

*ខ្ញុំអាចរកពេលវេលាបាន ។* សាសនាចក្របានស្ដាបនាគំរូ ដោយរក្សាយប់ថ្ងៃច័ន្ទទំនេរពីសកម្មភាពសាសនាចក្រនានា ។ អ្នកអាចបង្ហាញព្រះអម្ចាស់ និងក្រុមគ្រួសាររបស់អ្នកថា អ្នកមានឆន្ទៈនឹងញែកពេលវេលាទុកសម្រាប់អ្វីដែលសំខាន់បំផុត ។

*ខ្ញុំអាចរកឃើញអ្វីដែលដំណើរការល្អសម្រាប់គ្រួសាររបស់ខ្ញុំ ។* ប្រសិនបើក្រុមគ្រួសាររបស់អ្នក រស់នៅឆ្ងាយពីគ្នា ក្នុងភូមិសាស្ត្រខុសគ្នា សូមព្យាយាមធ្វើ « រាត្រីជួបជុំក្រុមគ្រួសារតាមអ៊ិនធើរណែត » ដើម្បីនិយាយជាមួយនឹងសមាជិកគ្រួសារតាមអ៊ិនធើរណែត ឬតាមទូរសព្ទ ។ តើមាននរណាម្នាក់ត្រូវធ្វើការយឺតទេ ? សូមធ្វើ « រាត្រីជួបជុំក្រុមគ្រួសារនៅសួនច្បារ » នៅជិតកន្លែងធ្វើការក្នុងអំឡុងពេលឈប់សំរាក ។ ឪពុកដែលបានលែងលះម្នាក់ធ្វើ « រាត្រីជួបជុំក្រុមគ្រួសារតាមសំបុត្រ » ជារៀងរាល់ថ្ងៃច័ន្ទ សរសេរទៅកូនៗរបស់គាត់ដែលរស់នៅឆ្ងាយពីគាត់ ។[3] សូមឲ្យឧបសគ្គក្លាយជាកាតាលីករសម្រាប់ការច្នៃប្រឌិតដ៏អស្ចារ្យ ។

*ខ្ញុំអាចចាប់ផ្ដើមធ្វើវានៅសប្ដាហ៍នេះ ។* រាត្រីជួបជុំក្រុមគ្រួសារ អាចត្រូវរៀបចំឡើងស្របទៅតាមតម្រូវការ និងកាលៈទេសៈនៃគេហដ្ឋានរបស់អ្នក ។ ខាងក្រោមនេះ គឺជាការផ្ដល់យោបល់ទូទៅមួយចំនួន ៖

- ចាប់ផ្ដើម និង បញ្ចប់ជាមួយនឹងការអធិស្ឋាន ។
- ប្រើតន្ត្រី រួមបញ្ចូលទាំងទំនុកតម្កើង និងចម្រៀងកុមារ ។
- រៀនពីព្រះគម្ពីរ និងព្យាការីសម័យទំនើប ។
- រួមបញ្ចូលសកម្មភាពរាងកាយខុសៗគ្នាមួយចំនួន គម្រោងនៃការបម្រើ និងសកម្មភាពផ្ដោតលើដំណឹងល្អ ពីសប្ដាហ៍មួយទៅសប្ដាហ៍មួយ ។
- សប្បាយរីករាយចុះ ! លេងហ្គេម ឬធ្វើអាហារសម្រន់ ។
- សូមធ្វើឲ្យមានស្ថិរភាព ប្រសិនអ្នកមិនអាចធ្វើវានៅថ្ងៃចន្ទ សូមរកថ្ងៃមួយផ្សេងទៀតដែលដំណើរការល្អ ។

*ខ្ញុំចង់បានពរជ័យ ។* ព្យាការីទាំងឡាយបានសន្យាថា បើយើងចូលរួមក្នុងរាត្រីជួបជុំក្រុមគ្រួសារនឹងមានពរជ័យ ដែលជាលទ្ធផលដ៏អស្ចារ្យ ៖ សេចក្ដីស្រឡាញ់ និងការគោរពប្រតិបត្តិ នៅគេហដ្ឋាននឹងកើនឡើង ។ សេចក្ដីជំនឿនឹងអភិវឌ្ឍនៅក្នុងដួងចិត្តរបស់យុវវ័យ ។ ក្រុមគ្រួសារ « នឹង



ទទួលបានអំណាច ដើម្បីទប់ទល់នឹងឥទ្ធិពលអាក្រក់ និងការល្បួងទាំងឡាយ » ដែលរុំព័ទ្ធជុំវិញពួកគេ ។[4]

ខណៈពេលដែលរាត្រីជួបជុំក្រុមគ្រួសាររបស់អ្នកមិនអាចមានបទពិសោធន៍ដ៏ល្អឥតខ្ចោះរាល់ពេល នោះក្រុមគ្រួសាររបស់អ្នកនឹងត្រូវបានពង្រឹងឡើង និងប្រទានពរឲ្យ ដោយសារតែការខិតខំប្រឹងប្រែងរបស់អ្នក ។ អែលឌើរ ដាវីឌ អេ បែដណា នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « រាត្រីជួបជុំក្រុមគ្រួសារនីមួយៗ គឺជាការផាត់ពណ៌ដោយច្រាស់សើៗនៅលើផ្ទាំងគំនូរនៃព្រលឹងរបស់យើង » ។ « គ្មានព្រឹត្តិការណ៍ណាមួយ ដែលទំនងជាគួរឲ្យចាប់អារម្មណ៍ ឬគួរឲ្យចងចាំហួសហេតុនោះទេ ។ ប៉ុន្តែ ក៏ដូចជាការផាត់ទឹកថ្នាំបំពេញគ្នាទៅវិញទៅមក ហើយនោះវាបានបង្កើតផ្ទាំងគំនូរដ៏គួរឲ្យចាប់អារម្មណ៍មួយ ដូច្នេះភាពស្ថិរភាពរបស់យើងក្នុងការធ្វើអ្វីដែលហាក់ដូចជាតូចមួយ អាចនាំមកនូវលទ្ធផលខាងវិញ្ញាណដ៏សំខាន់ »[5] ■

**កំណត់ចំណាំ**

1. ថូម៉ាស អេស ម៉នសុន « Constant Truths for Changing Times » *លីអាហូណា*, ខែ ឧសភា ឆ្នាំ 2005, ទំព័រ 19 ។
2. អិល ថម ភែរី, « Therefore I Was Taught » *Ensign,* ខែ ឧសភា ឆ្នាំ 1994, ទំព័រ 38 ។
3. « រាត្រីជួបជុំក្រុមគ្រួសារ ៖ ទំហំណាមួយ, ស្ថានភាពណាមួយ » *Ensign,* ខែ ធ្នូ ឆ្នាំ 2001, ទំព័រ 42 ។
4. គណៈប្រធានទីមួយ, ក្នុង ជេម អ័រ ក្លាក, comp., *សារលិខិតគណៈប្រធានទីមួយ នៃសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ*, វ៉ុល 6. ( ឆ្នាំ 1965–75 ), 4:339 ។
5. ដេវីឌ អេ បែដណា « More Diligent and Concerned at Home » *Liahona,* ខែ វិច្ឆិកា ឆ្នាំ 2009, ទំព័រ 19–20 ។

**សូមផ្តល់អាទិភាពជាចម្បងដល់វា**

« យើងសូមស្នើដល់ឪពុកម្ដាយ និងកូនៗ ឲ្យផ្តល់អាទិភាពជាចម្បងដល់រាត្រីជួបជុំក្រុមគ្រួសារ សិក្សាដំណឹងល្អ និងការបង្ហាញ ព្រមទាំងសកម្មភាពគ្រួសារល្អទាំងអស់ ។ ថ្វីបើតម្រូវការ ឬសកម្មភាពដទៃទៀតដែលមើលទៅ ហាក់ដូចជាសក្ដិសម និងត្រឹមត្រូវក៏ដោយ ក៏មិនត្រូវអនុញ្ញាតឲ្យវាមកជំនួសកាតព្វកិច្ច ដែលបានចាត់មកពីព្រះនោះឡើយ មានតែឪពុកម្ដាយប៉ុណ្ណោះ ទើបអាចធ្វើបានដោយសក្ដិសម » ។

**សារលិខិតគណៈប្រធានទីមួយចុះថ្ងៃទី 11 ខែ កុម្ភៈ ឆ្នាំ 1999 ។**

រូបថតប្រវត្តិសាស្ត្រទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការដោយ សាកលវិទ្យាល័យប៊ើរមីងហាំ រូបថតនៃគំនូរដោយ ISTOCK/THINKSTOCK

# ទ្រង់មានព្រះជន្មរស់ឡើងវិញ

*ជំនឿដែលឥតងាករេនៅក្នុងព្រះគ្រីស្ទ គឺជាតម្រូវការដ៏សំខាន់បំផុតនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ។*



**ដោយប្រធាន ដាវីឌ អូ មិកឃេ**
**( ឆ្នាំ 1873–1970 )**
ប្រធានទីប្រាំបួននៃសាសនាចក្រ

*ដេវីឌ អូ មិកឃេ បានកើតនៅ ថ្ងៃទី 8 ខែ កញ្ញា ឆ្នាំ 1873 ។ លោកត្រូវបានតែងតាំងធ្វើជាសាវកនៅថ្ងៃទី 9 ខែ មេសា ឆ្នាំ 1906 នៅអាយុ 32 ឆ្នាំ ហើយនៅថ្ងៃទី 9 ខែ មេសា ឆ្នាំ 1951 លោកត្រូវបានគាំទ្រឲ្យធ្វើជាប្រធានទីប្រាំបួននៃសាសនាចក្រ ។ ខាងក្រោមនេះ គឺជាការដកស្រង់ចេញពីសុន្ទរកថាដែលលោកបានផ្ដល់នៅសន្និសីទទូទៅ ខែ មេសា ឆ្នាំ 1966 ។ សម្រាប់សុន្ទរកថាទាំងមូល សូមមើលកំណត់ត្រាសន្និសីទ ខែ មេសា ឆ្នាំ 1966 ទំព័រ 55–59 ។*

ប្រសិនបើអព្ភូតហេតុដ៏អស្ចារ្យមួយ គឺជាព្រឹត្តិការណ៍ជំនឿអរូបីយដែលមានលើសពីប្រាជ្ញាដែលមានកម្រិតរបស់មនុស្ស នោះដំណើររស់ឡើងវិញរបស់ព្រះយេស៊ូវគ្រីស្ទ គឺជាការអស្ចារ្យដ៏សម្បើមបំផុតជាងពេលណាៗទាំងអស់ ។ នៅក្នុងជំហរវាបង្ហាញពីអំណាចដ៏អស្ចារ្យនៃព្រះ និងអមតភាពរបស់មនុស្ស ។

ទោះបីជាដំណើររស់ឡើងវិញ គឺជាអព្ភូតហេតុមួយក៏ដោយ នៅតែមានន័យថា វាហួសពីការយល់ដឹងរបស់មនុស្សទៅទៀត ។ ដល់អស់អ្នកដែលទទួលស្គាល់ថាវាជាការពិត ប៉ុន្តែវាជាការបង្ហាញនៃច្បាប់ឯកសណ្ឋាននៃជីវិតប៉ុណ្ណោះ ។ . . .

ការស្លាបនាវាជាការពិតថា ព្រះគ្រីស្ទបានយកព្រះកាយទ្រង់ ហើយបានលេចចេញមកក្នុងសិរីរុងរឿង ជាអង្គដែលបានរស់ឡើងវិញ នោះអ្នកឆ្លើយសំណួរជាយូរអង្វែងមកថា ៖ « បើមនុស្សស្លាប់ទៅ តើនឹងមានជីវិតរស់ឡើងទៀតឬ ? » ( យ៉ូប 14:14 ) ។

### សាក្សីនៃ ដំណើររស់ឡើងវិញ

ការរស់ឡើងវិញជាក់ស្ដែងរបស់ព្រះគ្រីស្ទពីផ្នូរនោះ គឺជាការពិតយ៉ាងជាក់ច្បាស់ចំពោះពួកសាវកដែលបានស្គាល់ទ្រង់យ៉ាងជិតស្និទ្ធ ។ នៅក្នុងគំនិតរបស់ពួកគេ ពិតជាពុំមានការសង្ស័យទេ ។ ពួកគេគឺជាសាក្សីនៃការពិតនោះ ពួកគេបានដឹងដោយសារតែពួកគេបានឃើញផ្ទាល់ភ្នែក បានឮផ្ទាល់ត្រចៀកពួកគេ ហើយដៃពួកគេបានស្ទាបវត្ថុមានព្រះកាយនៃព្រះដ៏ប្រោសលោះដែលមានព្រះជន្មរស់ឡើងវិញ ។

ក្នុងឱកាសដែលពួកសាវកទាំងដប់មួយនាក់បានជួបជុំគ្នា ដើម្បីជ្រើសរើសម្នាក់ឲ្យជំនួសកន្លែងរបស់ យូដាសអ៊ីស្ការីយ៉ុត ពេត្រុសដែលជាប្រធានសាវកបានមានប្រសាសន៍ថា « ដូច្នេះ ក្នុងពួកអ្នក . . . ត្រូវឲ្យមានម្នាក់ទៀតធ្វើជាទីបន្ទាល់ ជាមួយនឹងយើង ពីដំណើរដែលទ្រង់មានព្រះជន្មរស់ឡើងវិញ » ( កិច្ចការ 1:21–22 ) ។ . . .

ក្នុងឱកាសមួយផ្សេងទៀត ពេត្រុសបានប្រកាសនៅមុខខ្មាំងសត្រូវរបស់គេ ជាក្រុមមនុស្សតែមួយដែលបានធ្វើគត់ព្រះយេស៊ូវនៅលើឈើឆ្កាងថា ៖

> « ឱពួកសាសន៍អ៊ីស្រាអែលអើយ សូមស្ដាប់ពាក្យនេះចុះ . . . ឯព្រះយេស៊ូវនេះ ព្រះបានប្រោសឲ្យទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយពួកយើងនេះជាទីបន្ទាល់ពីទ្រង់ទាំងអស់គ្នា » ( កិច្ចការ 2:22, 32 ) ។ . . .

### សាក្សីបន្ថែម

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ឈរជាមួយនឹងពេត្រុស ប៉ុល យ៉ាកុប និងជាមួយនឹងពួកសាវកជំនាន់ដើមដទៃទៀត ដែលមិនត្រឹមតែបានទទួលយកដំណើររស់ឡើងវិញថាជាការពិតដ៏ជាក់ស្ដែងនោះទេ ប៉ុន្តែថែមទាំងជាការបំពេញបេសកកម្មដ៏ទេវភាពរបស់ព្រះគ្រីស្ទនៅលើផែនដីនេះផង ។

ដប់ប្រាំបីរយឆ្នាំ បន្ទាប់ពី ការសុគតនៅលើឈើឆ្កាងរបស់ព្រះយេស៊ូវ ព្យាការីយ៉ូសែប ស្ម៊ីធ បានប្រកាសថា ព្រះដែលមានព្រះជន្មរស់ឡើងវិញបានបង្ហាញអង្គទ្រង់ចំពោះលោក ដោយមានប្រសាសន៍ថា ៖ « ខ្ញុំបានឃើញតួអង្គពីរ ដែលមានរស្មី និងសិរីរុងរឿងដែលពុំអាចពណ៌នាបានឡើយ ឈរនៅលើអាកាស ពីលើរូបខ្ញុំ ។ តួអង្គមួយមានព្រះបន្ទូលមកខ្ញុំ ដោយហៅខ្ញុំតាមឈ្មោះ ហើយចង្អុលទៅតួអង្គមួយទៀត ដោយមានព្រះបន្ទូលថា — *នេះជា ព្រះរាជបុត្រា ដ៏ស្ងួនភ្ងារបស់យើង ។ ចូរស្ដាប់ទ្រង់ចុះ !* » ( យ៉ូសែប ស្ម៊ីធ — ប្រវត្តិ 1:17 ) ។ . . .

ប្រសិនបើទីបន្ទាល់របស់យ៉ូសែប ស្ម៊ីធ ឈរតែឯកឯង វានឹងដូចជាព្រះគ្រីស្ទបានមានបន្ទូលពីទីបន្ទាល់របស់ទ្រង់ នៅពេលដែលទ្រង់បានមានបន្ទូលពីអង្គទ្រង់ផ្ទាល់ ប៉ុន្តែព្រះយេស៊ូវមានទីបន្ទាល់របស់ព្រះ ហើយពួកសាវកមានទីបន្ទាល់ទ្រង់ ។ ហើយយ៉ូសែប ស្ម៊ីធ មានសាក្សីឯទៀត [ អ្នកដែល ] បានបញ្ជាក់អះអាងពីទីបន្ទាល់របស់[លោក] សេចក្ដីពិតដែលបានធ្វើឲ្យដឹងដោយការបង្ហាញព្រះកាយរបស់ទេវតាម៉ូរ៉ូណៃដល់ពួកគេ ។ . . .

. . . សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ[ក៏]ប្រកាសពីការនិមិត្តដ៏រុងរឿងរបស់ព្យាការី យ៉ូសែប ស្ម៊ីធដែរថា ៖

> « ហើយឥឡូវនេះ បន្ទាប់ពីទីបន្ទាល់ជាច្រើនដែលបានថ្លែងអំពីទ្រង់នេះ គឺជាទីបន្ទាល់ចុងក្រោយបង្អស់ ដែលយើងខ្ញុំសូមថ្លែងអំពីទ្រង់ ៖ គឺថាទ្រង់មានព្រះជន្មរស់ ! » ( គ និង ស 76:22 ) ។ . . .




**ព្រះគ្រីស្ទដ៏មានព្រះជន្មរស់**

សូមអានទីបន្ទាល់របស់ព្រះយេស៊ូវគ្រីស្ទដែលបានផ្ដល់ដោយពួកសាវកសម័យទំនើប និងពួកព្យាការីនៅក្នុង *លីអាហូណា* ខែ មេសា ឆ្នាំ 2000 ទំព័រ 2–3 ។



នៅក្នុងពន្លឺនៃទីបន្ទាល់ដែលមិនបដិសេធបានដែលបានផ្ដល់ដោយពួកព្យាការីពីបុរាណ — ជាទីបន្ទាល់ចាប់តាំងពីប៉ុន្មានឆ្នាំជាបន្តបន្ទាប់ទៅនឹងព្រឹត្តិការណ៍នោះផ្ទាល់ — នៅក្នុងពន្លឺនៃវិរណៈដែលអស្ចារ្យបំផុតនៅក្នុងជំនាន់ដែលព្រះគ្រីស្ទនៅមានព្រះជន្មនោះ វាហាក់ដូចជាមានការលំបាកពិតក្នុងការយល់ពីរបៀបដែលមនុស្សអាចនៅតែបដិសេធទ្រង់ ហើយអាចសង្ស័យពីអមតភាពរបស់មនុស្ស ។

**អ្វីដែលយើងត្រូវការនៅសព្វថ្ងៃនេះគឺ**

ជំនឿដែលឥតងាករេនៅក្នុងព្រះគ្រីស្ទ គឺជាតម្រូវការដ៏សំខាន់បំផុតនៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ ។ វាមានន័យជ្រាលជ្រៅជាងការមានអារម្មណ៍ទៅទៀត ។ វាគឺជាអំណាចដែលអាចបោះជំហានទៅជាសកម្មភាព ហើយវាជាកម្លាំងលើកទឹកចិត្តជាមូលដ្ឋានបំផុត ដែលគួរតែនៅក្នុងជីវិតមនុស្សម្នាក់ៗ ។ . . .

ប្រសិនបើមនុស្សនឹង « ធ្វើតាមព្រះហឫទ័យទ្រង់ » ជំនួសឲ្យការមើលទៅផ្នូរដ៏ងងឹត និងអាប់អួរដោយអស់សង្ឃឹមនោះ ពួកគេនឹងបង្វែរភ្នែករបស់ពួកគេទៅកាន់ស្ថានសួគ៌ ហើយដឹងថាព្រះគ្រីស្ទមានព្រះជន្មរស់ឡើងវិញហើយ ! . . .

សាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទ នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ប្រកាសទៅដល់ពិភពលោកទាំងមូលថា ព្រះគ្រីស្ទ គឺជាព្រះរាជបុត្រារបស់ព្រះ ជាព្រះដ៏ប្រោសលោះនៃពិភពលោក ! គ្មានសិស្សពិតប្រាកដណាម្នាក់ដែលពេញចិត្តនឹងទទួលយក ទ្រង់ជាព្រះដែលបានបង្កើតដ៏អស្ចារ្យ គ្រូបង្រៀនដ៏ល្អ ឬសូម្បីតែជាមនុស្សម្នាក់ដ៏ឥតខ្ចោះនោះទេ ។ បុរសនៃកាលីឡេនេះ — មិនមែនជាន័យធៀបទេ, ប៉ុន្តែ *ជាក់ស្ដែងជា* — ព្រះរាជបុត្រារបស់ព្រះអម្ចាស់ដ៏មានព្រះជន្មរស់ ។ . . .

**ពិតជាកើតជាថ្មី**

គ្មាននរណាម្នាក់អាចដោះស្រាយដោយចិត្តស្មោះ ដើម្បីអនុវត្តការបង្រៀនរបស់ព្រះយេស៊ូវពីណាសារ៉ែត នៅក្នុងជីវិតប្រចាំថ្ងៃរបស់ខ្លួន ដោយគ្មានការចង់ផ្លាស់ប្ដូរខ្លួនទាំងមូលរបស់គេនោះទេ ។ ឃ្លាដែលថ្លែងថា « កើតជាថ្មី » មានអត្ថសញ្ញាណជាប្រជ្រៅជាងអ្វីដែលមនុស្សជាច្រើនបានគិតទៅទៀត ។ . . . មនុស្សដែលមានសុភមង្គលគឺជាមនុស្សដែលបានដឹងពិតពីការលើកទឹកចិត្តនេះ អំណាចកែប្រែដែលមកពីការនៅជិតព្រះអង្គសង្គ្រោះនេះ ទៅជាបងប្អូនរបស់ព្រះគ្រីស្ទដែលមានព្រះជន្មនៅរស់វិញ ។ ខ្ញុំមានអំណរគុណ ដែលខ្ញុំដឹងថាព្រះយេស៊ូវ គឺជាព្រះដ៏ប្រោសលោះ ។ . . .

សារខិលិតស្ដីពីដំណើររស់ឡើងវិញ . . . គឺជាការលួងលោមចិត្តដ៏ប្រសើរបំផុត ជាសេចក្ដីរុងរឿងបំផុតដែលមិនធ្លាប់បានផ្ដល់ឲ្យមនុស្សពីមុនមក ដោយសារតែពេលដែលសេចក្ដីស្លាប់ឆក់យកមនុស្សជាទីស្រឡាញ់ពីយើង ដួងចិត្តដែលពោរពេញទៅដោយទុក្ខព្រួយរបស់យើងត្រូវបានសម្រាល ដោយសេចក្ដីសង្ឃឹម និងការធានាដ៏ទេវភាពបានបញ្ជាក់នៅក្នុងពាក្យ ៖ « *ទ្រង់មិនគង់នៅទីនេះទេ ដ្បិតទ្រង់មានព្រះជន្មរស់ឡើងវិញហើយ !* » [ សូមមើល ម៉ាថាយ 28:6; ម៉ាកុស 16:6 ] ។

ខ្ញុំដឹងដោយពេញក្នុងព្រលឹងខ្ញុំថា សេចក្ដីស្លាប់ត្រូវបានយកជ័យជំនះដោយព្រះយេស៊ូវគ្រីស្ទ ហើយដោយសារព្រះដ៏ប្រោសលោះរបស់យើងទ្រង់រស់ នោះយើងក៏ដូច្នេះដែរ ។ ■

*ចំណងជើងរងបានកែប្រែ ដោយការដាក់អក្សរធំ និង ការដាក់វណ្ណយុត្តឲ្យតាមបទដ្ឋាន ។*

# ឥទ្ធិពលខាងវិញ្ញាណរបស់

*« យើងហៅស្ត្រីនៃសាសនាចក្រឲ្យឈររួមគ្នាសម្រាប់សេចក្ដីសុចរិត ។ . . . ខ្ញុំមើលឃើញថា ការណ៍នេះគឺជាសេចក្ដីសង្ឃឹមមួយដ៏ភ្លឺត្រចះត្រចង់ [ នៅ ] ក្នុងពិភពលោក »* ។ — ប្រធាន ហ្គរដុន ប៊ី ហ៊ិងគ្លី ( ឆ្នាំ 1910–2008 )



# ស្ត្រី

*តើយើងស្គាល់អំណាចនៃកម្លាំងខាងវិញ្ញាណរបស់យើងដែរឬទេ ?*

**ដោយ ស្តាទ្បា អេវ៉រ៉ៃម ចាត់ធ្វើរ**

ស្ត្រីដ៏អស្ចារ្យ និងមានចិត្តរាបទាបជាច្រើននៅក្នុងសាសនាចក្រ បានខិតខំផ្តល់ការបម្រើដោយពុំដឹងពីឥទ្ធិពលដ៏ទូលំទូលាយ ដែលជីវិតរបស់ពួកគេមាន — ជាគំរូនៃការបម្រើខាងសាច់ឈាម ប៉ុន្តែក៏ជាកេរ្តិ៍ដំណែលនៃកម្លាំងខាងវិញ្ញាណផងដែរ ។ ស្ត្រីម្នាក់បែបនោះ ជាជីដូនរបស់ខ្ញុំ គឺឆែរី ភីធើរសិន ។ គាត់បានបម្រើយ៉ាងស្មោះត្រង់ នៅក្នុងការហៅបម្រើដ៏ស្ងាត់ស្ងៀមអស់មួយជីវិតរបស់គាត់ ។ ប្រសិនបើអ្នកសួរគាត់ គាត់នឹងអះអាងថាគាត់ពុំមានទេពកោសល្យជាច្រើន ដើម្បីផ្តល់ជូនពិភពលោកទេ ។ ទោះជាយ៉ាងណាក្តី នៅពេលដែលខ្ញុំបានចាប់ផ្តើមរៀនអំពីជីវិតរបស់គាត់ ខ្ញុំបានដឹងថាកម្លាំងខាងវិញ្ញាណរបស់គាត់មានឥទ្ធិពលមកលើជីវិតខ្ញុំដល់កម្រិតណា ។

ឪពុកម្តាយរបស់ឆែរី បានឈប់ទៅចូលរួមនឹងសាសនាចក្រ ហើយបានលែងលះគ្នាពេលដែលគាត់នៅក្មេងនៅឡើយ ដូច្នេះគាត់បានធំឡើងជាមួយនឹងម្តាយគាត់ គឺហ្វ៉ររិន ដែលតែងតែធ្វើការជានិច្ច ។ ហ្វ៉ររិន កាន់តែមិនត្រូវបានគេអើពើពេលដែលគាត់នៅក្មេង គាត់ត្រូវបានចិញ្ចឹមឲ្យធំឡើងនៅក្នុងសាលា ខណៈពេលដែលម្តាយគាត់ គឺចចចា បានរស់នៅក្នុងជីវិតខាងលោកិយ ។ ថ្វីបើមានបញ្ហាក្នុងការអប់រំបីបាច់របស់នាង ឆែរីនៅតែសកម្មនៅក្នុងដំណឹងល្អ ចូលរួមក្នុងសាសនាចក្រដោយស្មោះត្រង់ជាមួយនឹងក្រុមគ្រួសាររបស់ជីដូនទួត គឺអេលីសាបិត ឬជាមួយមិត្តភក្តិរបស់គាត់ ។ គាត់បានឃើញនៅក្នុងគ្រួសាររបស់គេ នូវអ្វីដែលគាត់ចង់បានសម្រាប់ខ្លួនគាត់ផ្ទាល់ដែរ ។ គាត់មិនបានដឹងច្បាស់ពីអ្វីដែលក្រុមគ្រួសារមួយគួរតែមានគុណសម្បត្តិបែបណាឡើយ ប៉ុន្តែគាត់បានដឹងពីគុណសម្បត្តិអវិជ្ជមាន ហើយគាត់បានប្តេជ្ញាថានឹងមានក្រុមគ្រួសារនៅថ្ងៃអនាគតឲ្យខុសពីនេះ ។

ជីតា ឌែល ជាស្វាមីរបស់ជីដូន ឆែរី របស់ខ្ញុំ — បានប្រាប់ខ្ញុំម្តងនោះថា « ដើម្បីមានទីបន្ទាល់មួយ ចៅត្រូវតែចង់បានវា » ។ ឆែរី តែងតែចង់បានទីបន្ទាល់មួយនោះ ។ ទោះជាច្រើនឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍របស់ពួកគាត់ត្រូវបានពោរពេញ ដោយការតស៊ូក្តី ពួកគាត់បានប្តេជ្ញាថានឹងនៅតែរឹងមាំជាក្រុមគ្រួសារ ។ ពួកគាត់ពុំសូវសកម្ម នៅឆ្នាំដំបូងនៃអាពាហ៍ពិពាហ៍របស់ពួកគាត់ ដោយសារតែកាលវិភាគការងាររបស់ ជីតា ឌែល ប៉ុន្តែការហៅបម្រើនៅក្នុងថ្នាក់កុមារ បានជម្រុញឲ្យឆែរីចាប់ផ្តើមចូលរួមនៅក្នុងសាសនាចក្រ ហើយរយៈពេលខ្លីបន្ទាប់មក ជីតា ឌែលបានចូលរួមជាមួយគាត់នៅក្នុងសាសនាចក្រ ជាទីប្រឹក្សាកូរ៉ុមឌីកុនម្នាក់ ។ ពួកគាត់ទាំងពីរគឺសកម្ម និងរឹងមាំនៅក្នុងសាសនាចក្រ ចាប់តាំងពីពេលនោះមក ។ ការតាំងចិត្តដើម្បីបម្រើ និងការប្តេជ្ញាដើម្បីបង្កើតក្រុមគ្រួសារ



*មិត្តនៃទេវតា* ដោយខាតលីន ភីធើរសុន ហាមថតចម្លង

ដ៏រឹងមាំមួយរបស់ ឆេរី បានជួយម្ដាយខ្ញុំឲ្យក្លាយជាស្ត្រីរឹងមាំ ហើយគំរូរបស់ម្ដាយខ្ញុំ បានជួយកំណត់ជីវិតរបស់ខ្ញុំ ជាពិសេសនៅពេលដែលខ្ញុំ ចាប់ផ្ដើមក្រុមគ្រួសារផ្ទាល់ខ្លួនរបស់ខ្ញុំ ។

ក្នុងនាមជាស្ត្រី យើងអាចមានឥទ្ធិពលខាងវិញ្ញាណដ៏ជ្រាលជ្រៅ ទៅលើជីវិតរបស់អ្នកទាំងឡាយដែលនៅជុំវិញយើង ។ ពិតណាស់ យ៉ូសែប ស្ម៊ីធ បានបង្រៀនថា តួនាទីរបស់យើងគឺ « មិនត្រឹមតែដើម្បីជួយសង្គ្រោះជនក្រីក្រប៉ុណ្ណោះទេ តែដើម្បីសង្គ្រោះដល់ព្រលឹងផងដែរ » ។[1] ព្រះយេស៊ូវគ្រីស្ទបានហៅស្ត្រីទាំងឡាយនៃសាសនាចក្ររបស់ទ្រង់ ដើម្បីក្លាយជាសិស្សរបស់ទ្រង់ និងដើម្បីឈរយ៉ាងរឹងមាំខាងវិញ្ញាណ ។ កម្លាំងខាងវិញ្ញាណ និងឥទ្ធិពលរបស់យើង មានសារៈសំខាន់ណាស់ នៅក្នុងដំណើររីកលូតលាស់នៃសេចក្ដីសង្គ្រោះ ហើយយើងត្រូវតែស្វែងរកឱកាសដើម្បីពង្រឹងដល់វិញ្ញាណអ្នកដែលនៅជុំវិញយើង ។ ពេលយើងធ្វើដូច្នោះ ឥទ្ធិពលនៃសេចក្ដីជំនឿ និងសេចក្ដីសុចរិតរបស់យើងនឹងនៅជាអង្វែងលើសពីអ្វីដែលយើងអាចមើលឃើញទៀត ។



បួនជំនាន់ ៖ អេលីសាបិត ( ឆ្វេង ) កំពុង-ព គាត់នចៅស្រីរបស់គាត់ ។ អានី ( កណ្ដាល ) បានមករដ្ឋយូថាហ៍ជាមួយនឹងឪពុកម្ដាយរបស់គាត់ ហើយគាត់ជាម្ដាយរបស់អេលីសាបិត ។ ចចចា ( ស្ដាំ ) គឺជាកូនស្រីរបស់អេលីសាបិត ប៉ុន្តែចចចា និងកូនស្រីរបស់គាត់ គាត់ន បានចាកចេញពីសាសនាចក្រ ។ រាគីជា អេលីសាបិត ដែលពោរពេញទៅដោយសេចក្ដីជំនឿ ដែលបានជួយចៅស្រីទួតរបស់គាត់គឺឆេរី និងពូជពង្សរបស់ឆេរីឲ្យត្រឡប់មករកដំណឹងល្អវិញ ។

## បានហៅឲ្យធ្វើជាសិស្ស

អែលឌើរ ជេម អ៊ិ ថាល់មេហ្គ ( 1862–1933 ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានសរសេរថា « ម្ចាស់ជើងឯកដ៏ធំបំផុតក្នុងពិភពលោករបស់ស្ត្រី និងភាពជាស្ត្រី គឺជាព្រះយេស៊ូវគ្រីស្ទ »[2] ជាឧទាហរណ៍ សូមគិតពីអ្វីដែលទ្រង់បានបង្រៀនកូនសិស្សស្ត្រីពីនាក់របស់ទ្រង់ គឺនាងម៉ារា និងនាងម៉ាថា នៅក្នុងព្រះគម្ពីរសញ្ញាថ្មី ។ សៀវភៅ *បុត្រី នៅក្នុងនគររបស់យើង* ពន្យល់ថា ៖ « លូកា 10 មានរឿងពីម៉ាថាបើកទ្វារផ្ទះរបស់នាងទទួលស្វាគមន៍ព្រះយេស៊ូវ ។ នាងបានបម្រើព្រះអម្ចាស់ដោយយកចិត្តទុកដាក់ចំពោះតម្រូវការខាងសាច់ឈាមរបស់ទ្រង់ ហើយម៉ារាបានអង្គុយនៅឯចុងព្រះបាទារបស់លោកគ្រូ និងបានស្រូបយកការបង្រៀនរបស់ទ្រង់ ។

« នៅយុគសម័យដែលស្ត្រីជាទូទៅ ត្រូវបានគេរំពឹងឲ្យតែផ្ដល់ការបម្រើខាងសាច់ឈាមប៉ុណ្ណោះ ព្រះអង្គសង្គ្រោះបានបង្រៀន ម៉ាថា និងម៉ារាថា ស្ត្រីក៏អាចចូលរួមខាងវិញ្ញាណនៅក្នុងកិច្ចការរបស់ទ្រង់ដែរ ។ ទ្រង់បានអញ្ជើញពួកគេឲ្យក្លាយជាសិស្សទ្រង់ ហើយទទួលទាននូវសេចក្ដីសង្គ្រោះ ដែលជា ‹ ចំណែកយ៉ាងល្អ › ដែលនឹងមិនត្រូវដកចេញពួកគេឡើយ » ។[3]

ដូចជាម៉ាថា ពេលខ្លះយើងធ្វើកំហុសដោយការគិតថា តួនាទីចម្បងរបស់ស្ត្រី គឺ ដើម្បីផ្ដល់ការបម្រើខាងសាច់ឈាម ដូចជាការផ្ដល់ចំណីអាហារ ដេរប៉ាក់ និងសម្អាតសម្រាប់អ្នកដទៃទៀត ។ ការបម្រើនេះ គឺការលះបង់ដ៏មានតម្លៃ និងគួរឲ្យស្រឡាញ់ ទោះជាយ៉ាងណាព្រះអម្ចាស់ត្រូវការស្ត្រីនៃអំណាចខាងវិញ្ញាណ ដែលសេចក្ដីជំនឿ សេចក្ដីសុចរិត និងសេចក្ដីសប្បុរសភ្លឺចែងចាំងពេញមួយជីវិតរបស់ពួកគេ ជាងទ្រង់ត្រូវការបងប្អូនស្ត្រីដែលអាចដេរប៉ាក់ និងបម្រុងបាន ។ ទ្រង់ជ្រាបថាយើងម្នាក់ៗមានអ្វីច្រើនណាស់ ដើម្បីថ្វាយ ។ ព្រះយេស៊ូវគ្រីស្ទហៅ *យើង* ទាំងអស់គ្នាឲ្យអភិវឌ្ឍកម្លាំងខាងវិញ្ញាណ និងសមត្ថភាពរបស់យើង ដើម្បីទទួល និងប្រព្រឹត្តតាមវិវរណៈ ដើម្បីជួយឲ្យកិច្ចការរបស់ទ្រង់រីកចម្រើនទៅមុខ ។ លីនដា ខេ បើតុន ប្រធានសមាគមសង្គ្រោះទូទៅ បានមានប្រសាសន៍ទៅកាន់បងប្អូនស្ត្រីថា « អ្នកត្រូវបានបញ្ជូនមកកាន់ផែនដី ក្នុងគ្រាកាន់កាប់ត្រួតត្រានេះ ដោយសារតែគុណសម្បត្តិ និងអត្តសញ្ញាណរបស់អ្នក ហើយអ្នកត្រូវបានរៀបចំឲ្យធ្វើអ្វីហើយនោះ ! មិនថាសាតាំងនឹងល្បួងយើងឲ្យគិតខុសអំពីគោលតម្លៃរបស់យើងបែបណានោះទេ អត្តសញ្ញាណពិតរបស់យើង គឺថាយើងជាសិស្សនៃព្រះយេស៊ូវគ្រីស្ទ ! »[4]

ព្រះអម្ចាស់ស្គាល់យើងទាំងអស់គ្នា និងស្ថានភាពរបស់យើង ហើយទ្រង់មានកិច្ចការសម្រាប់ឲ្យយើងធ្វើ នៅលើផែនដីនេះ ។ គ្មានបងប្អូនស្ត្រីណាដែលយល់ដឹងតិចពេក ឬមានទេពកោសល្យតិចពេក ដើម្បីជាកម្លាំងខាងវិញ្ញាណ សម្រាប់សេចក្ដីល្អ និងនាំអ្នកដទៃមកកាន់ព្រះគ្រីស្ទនោះទេ ។ ជាមួយនឹងសក្ដានុពលដ៏ទេវភាពនេះ យើងមានទំនួលខុសត្រូវ ដើម្បីក្លាយជាអ្នកដឹកនាំខាងវិញ្ញាណនៅក្នុងគេហដ្ឋាន និងក្នុងសហគមន៍របស់យើង ។ អែលឌើរអិម រ័សុល បាឡឺដ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានប្រកាសថា « បងប្អូនស្ត្រីទាំងអស់ នៅក្នុងសាសនាចក្រនេះ ដែលបានធ្វើសេចក្ដីសញ្ញាជាមួយនឹងព្រះអម្ចាស់ មាននូវសិទ្ធិអំណាចដ៏ទេវភាព ក្នុងការជួយសង្គ្រោះព្រលឹងទាំងឡាយក្នុងការដឹកនាំស្ត្រី នៃពិភពលោក ដើម្បីពង្រឹងគេហដ្ឋាន នៃស៊ីយ៉ូន និងស្ថាបនានគររបស់ព្រះ » ។[5]

យើងពុំចាំបាច់នៅក្នុងតំណែងខ្ពស់ ដើម្បីធ្វើកិច្ចការដែលមិនធម្មតាដើម្បីជួយអស់អ្នកដែលនៅជុំវិញយើងឲ្យធ្វើការសម្រេចចិត្ត ដែលនឹងដឹកនាំពួកគេខិតទៅកាន់តែជិតព្រះយេស៊ូវគ្រីស្ទ — ដែលជាតួនាទីដ៏សំខាន់របស់យើងនោះទេ ។ ទាំងអ្វីៗដែលធំជាងគេ និងតូចជាងគេបំផុត ដែលយើងធ្វើនៅក្នុងជីវិតរបស់មនុស្សម្នាក់ ឬពីរ សូម្បីតែនៅក្នុងគ្រួសាររបស់យើងផ្ទាល់ អាចមានឥទ្ធិពលយ៉ាងជ្រាលជ្រៅ ។

## ស្ត្រីនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ

ទំនុកតម្កើងដ៏ជាទីស្រឡាញ់មួយបានច្រៀងថា « បេសកកម្មនៃទេវតា ត្រូវបានប្រទានដល់យើង ហើយយើងប្រកាសថានេះគឺជាអំណោយទាន »[6] យើង



*ព្រះយេស៊ូវ និងម៉ារា ហើយម៉ាថា* ដោយខាតលីន ភីធើរសុន រក្សាសិទ្ធិដោយ ដែស៉ាប៉ែត ប៊ុក រូបភាពទទួលបានការអនុញ្ញាតពីអ្នកនិពន្ធ

មានអ្វីជាច្រើន ដើម្បីផ្ដល់ជូនដល់ជីវិតអស់អ្នកដែលយើងស្រឡាញ់ ។ អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានចែកចាយដំណើររឿងនៃរបៀបដែលកម្លាំងខាងវិញ្ញាណរបស់ស្ត្រីពីរនាក់បានមានឥទ្ធិពលមកលើជីវិតរបស់លោក ។

« ពេលខ្ញុំនៅក្មេង ឪពុកខ្ញុំពុំមែនជាសមាជិកនៃសាសនាចក្រទេ ហើយម្ដាយខ្ញុំបែរជាពុំសូវសកម្មទៀត ។ . . . ប៉ុន្មានខែបន្ទាប់ពីខួបកំណើតប្រាំបីឆ្នាំរបស់ខ្ញុំ លោកយាយ វីតថល បានធ្វើដំណើរឆ្លងប្រទេស មកលេងយើង ។ លោកយាយមានកង្វល់អំពីមូលហេតុ ដែលខ្ញុំនឹងបងប្រុសខ្ញុំពុំបានទទួលបុណ្យជ្រមុជទឹកនៅឡើយ ។ ខ្ញុំមិនដឹងថាគាត់និយាយអ្វីខ្លះអំពីរឿងនេះទៅឪពុកម្ដាយខ្ញុំទេ ប៉ុន្តែខ្ញុំបានដឹងថា នាព្រឹកមួយ គាត់បាននាំបងប្រុសខ្ញុំ និងខ្ញុំទៅលេងសួនច្បារ ហើយបានចែកចាយអារម្មណ៍របស់គាត់អំពីសារៈសំខាន់នៃការទទួលបុណ្យជ្រមុជទឹក និងការទៅចូលរួមក្នុងព្រះវិហារទៀងទាត់ ។ ខ្ញុំមិនចាំនូវពាក្យសម្ដីជាក់លាក់ដែលគាត់និយាយទេ ប៉ុន្តែពាក្យពេចន៍គាត់ បានចាក់ចូលដល់ដួងចិត្តខ្ញុំ ហើយមិនយូរប៉ុន្មានបងប្រុសខ្ញុំ និងខ្ញុំបានទទួលបុណ្យជ្រមុជទឹក ។ . . .

*« ព្រះអង្គសង្គ្រោះបានបង្រៀនម៉ាថា និងម៉ារា ថាស្ត្រីអាចចូលរួមក្នុងកិច្ចការខាងវិញ្ញាណរបស់ទ្រង់បាន ។ ទ្រង់បានអញ្ជើញពួកគេ ឲ្យក្លាយជាសិស្សរបស់ទ្រង់ ហើយទទួលទានសេចក្តីសង្គ្រោះ » ។*

« លោកយាយបានប្រើការលើកទឹកចិត្ត និងការគោរពត្រឹមត្រូវ ដើម្បីជួយឪពុករបស់យើងឲ្យទទួលស្គាល់សារៈសំខាន់នៃការនាំយើងទៅព្រះវិហារសម្រាប់ការប្រជុំទាំងឡាយរបស់យើង ។ គាត់បានជួយយើង ឲ្យដឹងពីតម្រូវការដើម្បីមានដំណឹងល្អ ក្នុងជីវិតយើងតាមគ្រប់វិធីត្រឹមត្រូវ » ។[7]

ប្រភពទីពីរនៃ កម្លាំងខាងវិញ្ញាណ គឺជែនីន ជាភរិយារបស់អែលឌើរ ស្កត ។ ពេលដែលពួកគេកំពុងតែដើរលេងជាមួយគ្នា ពួកគេបានចាប់ផ្ដើមនិយាយពីអនាគត ។ ជែនីន ជាអ្នកដែលបានធំឡើងនៅក្នុងផ្ទះអ្នកផ្សព្វផ្សាយសាសនាដ៏រឹងមាំមួយ បានបញ្ជាក់ពីបំណងចង់រៀបការជាមួយអ្នកត្រឡប់ពីផ្សាយសាសនា នៅក្នុងព្រះវិហារបរិសុទ្ធ ។ អែលឌើរ ស្កត ដែលពុំសូវបានគិតច្រើនអំពីការចេញបម្រើបេសកកម្មពី



មុនមក ត្រូវបានប៉ះទង្គិចជាខ្លាំងពីពាក្យសម្ដីរបស់ ជែនីន ។ « ខ្ញុំបានទៅផ្ទះវិញ ហើយខ្ញុំមិនអាចគិតអំពីអ្វីផ្សេងទៀតសោះឡើយ ។ ខ្ញុំពុំអាចគេងលក់ពេញមួយយប់ ។ . . . បន្ទាប់ពីការអធិស្ឋានជាច្រើនលើក ខ្ញុំបានធ្វើការសម្រេចចិត្ត ដើម្បីជួបជាមួយនឹងប៊ីស្សពរបស់ខ្ញុំ ហើយចាប់ផ្ដើមបំពេញពាក្យសុំចេញបេសកកម្មរបស់ខ្ញុំ » ។[8] ទោះជាជែននីន បានផ្ដល់ការណែនាំដល់គាត់ និងការជម្រុញដែលគាត់ត្រូវការក្ដី ជែននីន មិនដែលសូមឲ្យគាត់បម្រើបេសកកម្ម *សម្រាប់នាងទេ* ។ គាត់ស្រឡាញ់ខ្ញុំគ្រប់ល្មមដើម្បីចែកចាយ ពីជំនឿស៊ប់របស់គាត់ ហើយបានផ្ដល់ឱកាសដល់ខ្ញុំ ដើម្បីកំណត់យកទិសដៅនៃជីវិតផ្ទាល់របស់ខ្ញុំ ។ យើងទាំងពីរនាក់បានបម្រើបេសកកម្ម ហើយក្រោយមកបានផ្សារភ្ជាប់នៅក្នុងព្រះវិហារបរិសុទ្ធ ។ ភាពក្លាហាន និងការប្ដេជ្ញាចិត្តរបស់ជែននីនចំពោះសេចក្ដីជំនឿរបស់គាត់ បានធ្វើឲ្យមានការផ្លាស់ប្ដូរយ៉ាងធំនៅក្នុងជីវិតរបស់យើងរួមគ្នា ។ ខ្ញុំជឿជាក់ថា យើងនឹងពុំរកឃើញសុភមង្គលដែលយើងឱបក្រសោប ដោយគ្មានសេចក្ដីជំនឿដ៏រឹងមាំរបស់គាត់ទៅលើគោលការណ៍ នៃការបម្រើ

*ទំនុកតម្កើងដ៏ជាទីស្រឡាញ់មួយបានច្រៀងថា « បេសកកម្មនៃទេវតាត្រូវបានប្រទានដល់យើង ហើយយើងប្រកាសថានេះគឺជាអំណោយទាន » ។ យើងមានអ្វីជាច្រើន ដើម្បីផ្ដល់ជូនដល់ជីវិតអស់អ្នកដែលយើងស្រឡាញ់ ។*

ព្រះអម្ចាស់ជាមុនសិននោះទេ ។ គាត់គឺជាគំរូដ៏ល្អ និងសុចរិតមួយ ![9]

វាគឺជាឥទ្ធិពលខាងវិញ្ញាណរបស់បងប្អូនស្ត្រីដូចទេវតាទាំងនេះ នៅក្នុងជីវិតរបស់គាត់ដែលបានជួយបុរសវ័យក្មេងម្នាក់ — គឺអែលឌើរ ស្កត — ឲ្យធ្វើការសម្រេចចិត្តមួយចំនួនដ៏សំខាន់បំផុតនៅក្នុងជីវិតរបស់គាត់ ៖ ដើម្បីទទួលបុណ្យជ្រមុជទឹក ចេញទៅបម្រើបេសកកម្ម និងរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ ។

យើងអាចជួយអ្នកដទៃដែលចង់ធ្វើការជ្រើសរើសដ៏ល្អបាន ដោយគំរូ ទង្វើ ពាក្យសម្ដី និងសេចក្ដីសុចរិតផ្ទាល់ខ្លួនរបស់យើង ។ បងស្រី ខារ៉ូល អិម ស្ដេហ្វិន ទីប្រឹក្សាទីមួយក្នុងគណៈប្រធានសមាគមន៍សង្គ្រោះទូទៅ បានប្រកាសថា « យើងគឺជាបុត្រីនៃសេចក្ដីសញ្ញានៅក្នុងនគររបស់ព្រះ ហើយយើងមានទំនួលខុសត្រូវដើម្បីធ្វើជា ឧបករណ៍នៅក្នុងព្រះហស្តរបស់ទ្រង់ ។ . . . យើងចូលរួមក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ ជារៀងរាល់ថ្ងៃក្នុងរបៀបតូច និងសាមញ្ញដោយ — មើលការខុសត្រូវ ពង្រឹង និងបង្រៀនគ្នាទៅវិញទៅមក » ។[10]

នៅពេលដែលយើងពឹងផ្អែកទៅលើព្រះវិញ្ញាណ និងឆ្ពោះទៅមុខដោយចិត្តស្មោះ និងការខិតខំមានចិត្តរាបទាបដើម្បីជួយ អស់អ្នកដែលនៅជុំវិញយើងឲ្យខិតកាន់ជិតព្រះគ្រីស្ទ នោះយើងនឹងត្រូវបានដឹកនាំក្នុងអ្វីដែលយើងអាចធ្វើបាន និងបានផ្ដល់កម្លាំងដើម្បីធ្វើវា ហើយយើងនឹងមានអារម្មណ៍ថាមានសេចក្ដីអំណរដែលបាននាំបាននាំកូនចៅរបស់ព្រះអម្ចាស់មកកាន់ទ្រង់ ។

### ការក្លាយជាឥទ្ធិពលខាងវិញ្ញាណ

ការស្គាល់ពីទំនួលខុសត្រូវរបស់យើង យើងប្រហែលជាអាចសួរដូចជាពួកសាវកពីបុរាណថា « តើយើងខ្ញុំត្រូវធ្វើដូចម្ដេច » ( កិច្ចការ 2:37 ) ដើម្បីក្លាយជាឥទ្ធិពលខាងវិញ្ញាណ ? ក្នុងសន្និសីទទូទៅចុងក្រោយនេះ បងស្រី បើរតុនបានអញ្ជើញបងប្អូនស្ត្រីទាំងអស់ឲ្យស្រម៉ៃអំពី « សញ្ញា ‹ ប្រកាសរកជំនួយ › ខាងវិញ្ញាណមួយចំនួន ដែលទាក់ទងនឹងកិច្ចការនៃសេចក្ដីសង្គ្រោះ ៖

- ប្រកាសរកជំនួយ ៖ ឪពុកម្ដាយឲ្យចិញ្ចឹមកូនចៅរបស់ពួកគេមកក្នុងពន្លឺ និងសេចក្ដីពិត
- ប្រកាសរកជំនួយ ៖ កូនស្រី . . . , បងប្អូនស្រី . . . , មីង . . . , បងប្អូនជីដូនមួយ និងមិត្តភក្តិពិតដើម្បីបម្រើជាអ្នកចង្អុលបង្ហាញ និងផ្ដល់ជំនួយនៅតាមផ្លូវនៃសេចក្ដីសញ្ញា
- ប្រកាសរកជំនួយ៖ អ្នកទាំងឡាយដែលស្ដាប់ចំពោះការបំផុសគំនិតនៃព្រះវិញ្ញាណបរិសុទ្ធ ហើយធ្វើតាមការបំផុសដែលទទួលបាន
- ប្រកាសរកជំនួយ ៖ អ្នកទាំងឡាយណាដែលរស់នៅតាមដំណឹងល្អប្រចាំថ្ងៃ តាមរបៀបតូចៗ និងសាមញ្ញ
- ប្រកាសរកជំនួយ ៖ អ្នកធ្វើការស្រាវជ្រាវពង្សប្រវត្តិ និងកិច្ចការព្រះវិហារបរិសុទ្ធ ដើម្បីភ្ជាប់ក្រុមគ្រួសារដ៏អស់កល្បជានិច្ច
- ប្រកាសរកជំនួយ ៖ អ្នកផ្សាយសាសនា និងសមាជិក ដើម្បីផ្សាយ ‹ ដំណឹងល្អ › — ជាដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ
- ប្រកាសរកជំនួយ ៖ អ្នកជួយសង្គ្រោះ ដើម្បីស្វែងរកអ្នកទាំងឡាយណាដែលបានវង្វេងផ្លូវ
- ប្រកាសរកជំនួយ ៖ អ្នករក្សាសេចក្ដីសញ្ញា ដើម្បីឈរឲ្យរឹងមាំចំពោះសេចក្ដីពិត និងភាពត្រឹមត្រូវ
- ប្រកាសរកជំនួយ ៖ សិស្សពិតរបស់ព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទ »[11]

កិច្ចការទាំងនេះពុំមែនជាអ្វីដែលថ្មីថ្មោងនោះទេ ប៉ុន្តែពេលយើងស្វែងរកឱកាសដើម្បី ចូលរួមនៅក្នុងកិច្ចការនៃសេចក្ដីសង្គ្រោះ យើងនឹងបង្កើនសមត្ថភាពរបស់យើង ដើម្បីជួយអស់អ្នកដែលនៅជុំវិញយើង ។ អែលឌើរ បាឡឺដ បានមានប្រសាសន៍ថា « គ្មានអ្វីនៅក្នុងលោកនេះដែលមានភាពផ្ទាល់ខ្លួនដូចជា ការបីបាច់ ឬការផ្លាស់ប្ដូរជីវិត ដូចជាឥទ្ធិពលនៃសេចក្ដីសុចរិតរបស់ស្ត្រីនោះទេ »[12] ពេលដែលយើងអភិវឌ្ឍអំណាចខាងវិញ្ញាណរបស់យើង តាមរយៈការអធិស្ឋាន និងការសិក្សាព្រះគម្ពីរផ្ទាល់ខ្លួន គោរពប្រតិបត្តិតាមយ៉ាងរឹងមាំ និងរក្សាសេចក្ដីសញ្ញារបស់យើងដោយស្មោះត្រង់ នោះយើងនឹងក្លាយជាឥទ្ធិពលនោះ ។

### លើសពីអ្វីដែលយើងអាចមើលឃើញ

ប្រធាន ព្រិកហាំ យ៉ង់ ( 1801–1877 ) បានមានប្រសាសន៍ថា « តើអ្នកអាចប្រាប់ពីចំនួននៃសេចក្ដីល្អដែលម្ដាយ និងកូនស្រីទាំងឡាយរបស់អ៊ីស្រាអែលអាចធ្វើបានឬទេ ? ទេ វាមិនអាចទៅរួចទេ ។ និងសេចក្ដីល្អដែលពួកគេធ្វើ នឹងនៅជាមួយពួកគេអស់កល្បជានិច្ច »[13]

ការសម្រេចចិត្តដ៏សុចរិតរបស់ជីដូនខ្ញុំបានជះឥទ្ធិពលដល់ក្រុមគ្រួសាររបស់គាត់ជាច្រើនជំនាន់ ហួសពីអ្វីដែលគាត់អាចមើលឃើញនៅពេលគាត់ជាយុវនារីទៀត ។ ទោះជាយ៉ាងណា ឥទ្ធិពលខាងវិញ្ញាណរបស់ស្ត្រីនៅក្នុងក្រុមគ្រួសារ លាតសន្ធឹងចូលទៅក្នុងអតីតកាល ជាច្រើនជំនាន់ទៀត ។ ឆៃរីបានទទួលបានកម្លាំងខាងវិញ្ញាណផ្ទាល់ខ្លួនជាច្រើន ពីការសង្កេតជីដូនទួតរបស់គាត់ ( ជីដូនទួតទីបីរបស់ខ្ញុំ ) គឺ អេលីសាបិត ។ គំរូរបស់អេលីសាបិត នៃសេចក្ដីជំនឿ និងទីបន្ទាល់បានបញ្ចេញឥទ្ធិពលហួសពីពីរជំនាន់នៃភាពអសកម្មក្នុងការជួយចៅស្រីទួតរបស់គាត់ គឺ ឈើរី ឲ្យត្រឡប់រកនិន្នាការនៃក្រុមគ្រួសារដែលបែកបាក់ និងការវិលមកសាសនាចក្រវិញ ។

ពេលដែលយើងក្លាយជាកម្លាំងខាងវិញ្ញាណចំពោះអស់អ្នកដែលនៅជុំវិញយើង នោះឥទ្ធិពលរបស់យើងនឹងលាតត្រដាងយ៉ាងធំហួសពីអ្វីដែលយើងអាចមើលឃើញទៀត ។ ប្រធាន ហ្គរដុន ប៊ី. ហ៊ិងគ្លី ( ឆ្នាំ 1910–2008 ) បានមានប្រសាសន៍ថា « យើងហៅស្ត្រីនៃសាសនាចក្រឲ្យឈររួមគ្នាសម្រាប់សេចក្ដីសុចរិត ។ ពួកគេត្រូវតែចាប់ផ្ដើមនៅក្នុងផ្ទះរបស់គេផ្ទាល់ ។ ពួកគេអាចបង្រៀនវានៅក្នុងថ្នាក់រៀនរបស់គេ ។ ពួកគេអាចបញ្ចេញសំឡេងនៅក្នុងសហគមន៍របស់គេ ។ . . .

« ខ្ញុំមើលឃើញថា ការណ៍នេះគឺជាសេចក្ដីសង្ឃឹមមួយដ៏ភ្លឺត្រចះត្រចង់ នៅក្នុងពិភពលោកមួយ ដែលកំពុងធ្វើដំណើរឆ្ពោះទៅរកការបំផ្លាញខ្លួនឯង » ។[14]

នៅពេលដែលយើងបំពេញតាមបញ្ញត្តិនេះ កិច្ចការរបស់ព្រះអម្ចាស់នឹងត្រូវបានជម្រុញទៅមុខ ទាំងនៅពិភពលោកជុំវិញយើង និងសំខាន់បំផុត នៅក្នុងក្រុមគ្រួសាររបស់យើង និងជីវិតរបស់អ្នកទាំងឡាយដែលយើងស្រឡាញ់ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*

**កំណត់ចំណាំ**

1. *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ( ឆ្នាំ 2007 ) ទំព័រ 453 ។
2. ជេម អ៊ី ថាល់មេហ្គ *ព្រះយេស៊ូវគ្រីស្ទ*, ការបោះពុម្ពលើកទី 3 ( ឆ្នាំ 1916 ) ទំព័រ 475 ។
3. *បុត្រីនៅក្នុងនគររបស់យើង ៖ ប្រវត្តិ និង កិច្ចការរបស់សមាគមន៍សង្គ្រោះ* ( ឆ្នាំ 2011 ) ទំព័រ 3–4 ។
4. លីនដា ខេ បើតុន « ប្រកាសរក ៖ ដៃ និង ដួងចិត្តដើម្បីជួយពន្លឿនកិច្ចការ » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2014 ទំព័រ 122–123 ។
5. អិម រ័សល បាឡឺដ « ស្ត្រីនៃសេចក្ដីសុចរិត » ***Ensign,*** ខែ ធ្នូ ឆ្នាំ 2002 ទំព័រ 70 ។
6. « ជាបងប្អូនស្រីស៊ីយ៉ូន » *ទំនុកតម្កើង* ទំព័រ 309 ។
7. រីឆាដ ជី ស្កុត « ខ្ញុំបានផ្ដល់គំរូដល់អ្នក » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2014, ទំព័រ 32 ។
8. រីឆាដ ជី ស្កុត « ខ្ញុំបានផ្ដល់គំរូដល់អ្នក » ទំព័រ 33 ។
9. រីឆាដ ជី ស្កុត « ខ្ញុំបានផ្ដល់គំរូដល់អ្នក » ទំព័រ 33 ។
10. ខារ៉ូល អិម ស្ទេហ្វិន « យើងមានហេតុផលដ៏អស្ចារ្យដើម្បីអរសប្បាយ » ***Liahona,*** ខែ វិច្ឆិកា ឆ្នាំ 2013, ទំព័រ 117 ។
11. លីនដា ខេ បើតុន « ប្រកាសរក ៖ ដៃ និង ដួងចិត្តដើម្បីជួយពន្លឿនកិច្ចការ » ទំព័រ 124 ។
12. អិម រ៉ាសុល បាឡឺត « ម្ដាយ និង កូនស្រីទាំងឡាយ » ***Liahona,*** ខែ ឧសភា ឆ្នាំ 2010 ទំព័រ 18 ។
13. *ជ្រើសរើសសុន្ទរកថារបស់ ព្រិកហាំ យ៉ង់* ចន អេ វីឌសូ ( ឆ្នាំ 1954 ) ទំព័រ 216 ។
14. ហ្គរដុន ប៊ី ហ៊ិងគ្លី « ឈរដោយរឹងមាំ និងមុតមាំ » *កិច្ចប្រជុំបណ្ដុះបណ្ដាល ភាពជាអ្នកដឹកនាំនៅជុំវិញពិភពលោក* ថ្ងៃទី 10 ខែ មករា ឆ្នាំ 2004 ទំព័រ 20 ។

# ភាពទន់ខ្សោយ មិនមែន ជាអំពើបាបនោះទេ

**ដោយ វេនឌី អ៊ុលរីឆ**

« តើខ្ញុំពិតជាមានភាពសក្ដិសម ដើម្បីចូលក្នុងនគរនៃព្រះឬទេ ? តើខ្ញុំអាចមានភាពសក្ដិសមដោយរបៀបណា បើខ្ញុំមិនល្អឥតខ្ចោះផងនោះ ?

« តើព្រះអម្ចាស់ពិតជាអាចធ្វើឲ្យភាពទន់ខ្សោយរបស់ខ្ញុំ ទៅជាភាពរឹងមាំបានមែនឬ ? ខ្ញុំបានតមអាហារ និងអធិស្ឋានជាច្រើនថ្ងៃ ដើម្បីឲ្យបញ្ហានេះត្រូវបានដកចេញពីខ្ញុំ ប៉ុន្តែគ្មានអ្វីដែលហាក់ដូចជាផ្លាស់ប្ដូរសោះ » ។

« នៅក្នុងបេសកកម្ម ខ្ញុំបានរស់នៅតាមដំណឹងល្អ យ៉ាងខ្ជាប់ខ្ជួនជាងពេលណាៗទាំងអស់ក្នុងជីវិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនធ្លាប់បានដឹងពីភាពទន់ខ្សោយរបស់ខ្ញុំច្រើងជាងនេះដែរ ។ តើហេតុអ្វី បានជាពេលខ្លះខ្ញុំមានអារម្មណ៍មិនល្អ នៅពេលដែលខ្ញុំបានធ្វើទង្វើល្អ ? »

នៅពេលដែលយើងពិចារណាពីសំណួរដូចនេះ វាសំខាន់ណាស់ដើម្បីយល់ថា ខណៈពេលដែល *អំពើបាប* ដែលជៀសមិនរួច នាំយើងចេញឆ្ងាយពីព្រះអម្ចាស់ *ផ្ទុយទៅវិញ* ភាពទន់ខ្សោយអាចនាំយើងទៅរកទ្រង់ ។

**បែងចែករវាងអំពើបាប និង ភាពទន់ខ្សោយ**

ជាទូទៅយើងគិតពីអំពើបាប និងភាពទន់ខ្សោយគ្រាន់តែខុសគ្នាត្រង់ ទំហំឆ្នូតខ្មៅនៅលើផ្ទាំងក្រណាត់នៃព្រលឹងរបស់យើងប៉ុណ្ណោះ វាមានទម្ងន់ខុសគ្នាខ្លាំងពីការរំលង ។ ប៉ុន្តែព្រះគម្ពីរបញ្ជាក់ថា អំពើបាប និងភាពទន់ខ្សោយ គឺមានជាតិកំណើតខុសគ្នា វាតម្រូវឲ្យមានឱសថព្យាបាលខុសគ្នា និងមានសក្ដានុពលក្នុងការផលិតលទ្ធផលខុសគ្នាដែរ ។

ពួកយើងភាគច្រើន ស្គាល់អំពើបាបច្បាស់ជាងការយើងចង់ទទួលសារភាពទៀត ប៉ុន្តែសូមពិនិត្យឡើងវិញ ៖ អំពើបាបគឺជាជម្រើសក្នុងការមិនគោរពព្រះបញ្ញត្តិរបស់ព្រះអម្ចាស់ ឬបះបោរប្រឆាំងនឹងពន្លឺនៃព្រះគ្រីស្ទនៅក្នុងខ្លួនរបស់យើងម្នាក់ៗ ។ អំពើបាបគឺជាជម្រើស ដើម្បីទុកចិត្តលើសាតាំងជាជាងព្រះ វាធ្វើឲ្យយើងក្លាយទៅជាមច្ចាមិត្តជាមួយព្រះវរបិតា



*កម្រិតសមត្ថភាព និងការខ្វះសមត្ថភាព គឺមិនមែនជាអំពើបាបទេ ហើយវាមិនឃាត់យើងពីភាពស្អាតស្អំ និងភាពសក្ដិសមនៃព្រះវិញ្ញាណនោះទេ ។*

ខាងលើ ៖ រូបថត ដោយ ISTOCK/THINKSTOCK; ខាងក្រោម ៖ រូបថត ដោយ PHOTODISC/THINKSTOCK



ខណៈពេលដែលអំពើបាប ដែលជៀសមិនរួច នាំយើងចេញឆ្ងាយពីព្រះអម្ចាស់ ផ្ទុយទៅវិញ ភាពទន់ខ្សោយអាចនាំយើងទៅរកទ្រង់ ។



ស្លូតរបស់យើង ។ មិនដូចពួកយើង ព្រះយេស៊ូវគ្រីស្ទទ្រង់គ្មានអំពើបាបទាល់តែសោះ ហើយទ្រង់អាចពលិកម្មជំនួសអំពើបាបរបស់យើង ។ ពេលយើងប្រែចិត្តជឿដោយស្មោះ — រួមទាំងការផ្លាស់ប្ដូរគំនិត ដួងចិត្ត និងអាកប្បកិរិយារបស់យើង ថ្វាយការសុំអភ័យទោស ឬការសារភាពដ៏សមរម្យ រៀបចំកន្លែងដែលអាច និងមិនធ្វើអំពើបាបនោះឡើងវិញនាពេលអនាគត — នោះយើងអាចទទួលបានដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ត្រូវបានអភ័យទោសឲ្យ និងបានស្អាតស្អំម្ដងទៀត ។

ការប្រែជាស្អាតស្អំ គឺសំខាន់ណាស់ ដោយសារគ្មានអ្វីដែលមិនស្អាតស្អំអាចនៅក្នុងវត្តមាននៅព្រះអម្ចាស់បានទេ ។ ប៉ុន្តែប្រសិនបើគោលដៅតែមួយគត់របស់យើង គឺដើម្បីគ្មានទោសកំហុសដូចជានៅពេលដែលយើងបានចាកចេញពីវត្តមាននៃព្រះ យើងនឹងគេងនៅក្នុងកូនអង្រឹងយើងយ៉ាងសុខស្រួលពេញមួយជីវិតរបស់យើង ។ ផ្ទុយទៅវិញ យើងមកលើផែនដីដើម្បីរៀនសូត្រដោយបទពិសោធន៍ ដើម្បីបែងចែកការល្អចេញពីការអាក្រក់ រីកធំធាត់នៅក្នុងប្រជ្ញា និងភាពប៉ុនប្រសប់ រស់នៅតាមតម្លៃដែលយើងយកចិត្តទុកដាក់ និងទទួលបានលក្ខណៈនៃព្រះ — ជាការរីកចម្រើនដែលយើងមិនអាចធ្វើវា ពីការនៅក្នុងបរិវេណនៃគ្រែកូនង៉ែតដ៏មានសុវត្ថិភាពរបស់យើង ។



**ការសន្យានៃដង្វាយធួន**

« ការស្ដារឡើងនូវអ្វីដែលអ្នកមិនអាចស្ដារបាន ព្យាបាលរបួសដែលអ្នកមិនអាចព្យាបាលបាន ជួលជុលអ្វីអ្នកបានធ្វើឲ្យបែកបាក់ ហើយមិនអាចជួលជុលបាន គឺជាគោលបំណងតែមួយគត់នៃដង្វាយធួនរបស់ព្រះគ្រីស្ទ ។ . . .

« ខ្ញុំសូមបញ្ជាក់ម្ដងទៀតថា លើកលែងតែជនចំនួនតិចតួចដែលជាពួកអ្នកក្បត់ ចូលរួមជាមួយនឹងសាតាំងប៉ុណ្ណោះ វាគ្មានទម្លាប់ គ្មានការញៀន គ្មានការបះបោរ គ្មានការរំលង គ្មានការក្បត់សាសនា គ្មានឧក្រិដ្ឋកម្មណា ដែលមិនបានទទួលការសន្យានៃការអត់ទោសដ៏ពេញលេញនោះឡើយ ។ នោះគឺសន្យា នៃដង្វាយធួនរបស់ព្រះគ្រីស្ទ » ។

**ប្រធាន បូយដ៍ កេ ផាកកឺ ជាប្រធាននៃកូរ៉ុម នៃពួកសាវកដប់ពីរនាក់ "The Brilliant Morning of Forgiveness," *Ensign*, ខែ វិច្ឆិកា ឆ្នាំ 1995, ទំព័រ 19–20 ។**

ភាពទន់ខ្សោយរបស់មនុស្ស ដើរតួយ៉ាងសំខាន់នៅក្នុងគោលបំណងដ៏ចាំបាច់នៃជីវិតរមែងស្លាប់ ។ ពេលម៉ូរ៉ូណៃព្រួយបារម្ភថា ភាពទន់ខ្សោយនៅក្នុងការសរសេររបស់លោក នឹងបណ្ដាលឲ្យពួកសាសន៍ដទៃចំអកដល់អ្វីដែលពិសិដ្ឋនោះ ព្រះអម្ចាស់បានធានាដល់លោកជាមួយនឹងពាក្យសន្យាថា ៖

« ហើយបើសិនជាមនុស្សលោកមករកយើង នោះយើងនឹងបង្ហាញដល់ពួកគេនូវភាពទន់ខ្សោយរបស់ពួកគេ ។ យើងឲ្យភាពទន់ខ្សោយទៅមនុស្ស ដើម្បីឲ្យពួកគេអាចបានរាបសា ហើយគុណរបស់យើង មានគ្រប់គ្រាន់សម្រាប់មនុស្សទាំងអស់ដែលបន្ទាបខ្លួន នៅចំពោះយើង ដ្បិតបើសិនជាពួកគេបន្ទាបខ្លួននៅចំពោះយើង ហើយមានសេចក្ដីជំនឿជឿដល់យើង លំដាប់នោះយើងនឹងធ្វើឲ្យ អ្វីដែលទន់ខ្សោយ ក្លាយទៅជាខ្លាំងពូកែ ចំពោះពួកគេវិញ » ( អេធើរ 12:27; សូមមើលផងដែរ កូរិនថូសទី 1 15:42–44; កូរិនថូសទី 2 12:7–10; នីហ្វៃទី 2 3:21; និង យ៉ាកុប 4:7 ) ។

ការបញ្ជាក់ពីខគម្ពីរនេះ គឺចាក់ដោតយ៉ាងជ្រាលជ្រៅ ហើយអញ្ជើញយើងទាំងអស់គ្នាឲ្យញែកអំពើបាប ( ដែលលើកទឹកចិត្តដោយសាតាំង ) ចេញពីភាពទន់ខ្សោយ ( ពណ៌នានៅទីនេះជាលក្ខខណ្ឌ « ដែលបានផ្ដល់ » ដោយព្រះអម្ចាស់ ) ។

យើងអាចឲ្យនិយមន័យដល់ភាពទន់ខ្សោយថា ជាដែលកំណត់លើប្រាជ្ញា អំណាច និងភាពបរិសុទ្ធដែលមានមកជាមួយនឹងមនុស្ស ។ ក្នុងនាមជាមនុស្ស យើងបានកើតមកដោយគ្មានពំនឹង និងពឹងពាក់លើគេ ជាមួយនឹងគុណវិបត្តិខាងរាងកាយ និងទំនោរចិត្ត ។ យើងត្រូវបានចិញ្ចឹមថែទាំ និងហ៊ុមព័ទ្ធទៅដោយភាពទន់ខ្សោយខាងសាច់ឈាមផ្សេងទៀត ហើយការបង្រៀន គំរូ និងការប្រព្រឹត្តិរបស់ពួកវាគឺមានភាពទន់ខ្សោយ និងការបំផ្លិចបំផ្លាញនៅពេលខ្លះ ។ នៅក្នុងស្ថានភាពទន់ខ្សោយក្នុងជីវិតរមែងស្លាប់របស់យើង យើងទទួលរងជំងឺខាងរាងកាយ និងផ្លូវចិត្ត ភាពស្រេកឃ្លាន និងការនឿយហត់ ។ យើងមានបទពិសោធន៍ពីអារម្មណ៍របស់មនុស្សដូចជា កំហឹង ទុក្ខព្រួយ និងការភ័យខ្លាច ។ យើងខ្វះប្រាជ្ញា ជំនាញ ភាពអំណត់ និងកម្លាំង ។ ហើយយើងងាយទទួលរងការល្បួងជាច្រើនប្រភេទ ។

ទោះបីជាទ្រង់គ្មានអំពើបាបក្ដី ព្រះយេស៊ូវគ្រីស្ទចូលរួមនឹងយើងរាល់គ្នាយ៉ាងពេញលេញនៅក្នុង



## បែងចែករវាងអំពើបាប និង ភាពទន់ខ្សោយ

| | អំពើបាប | ភាពទន់ខ្សោយ |
|---|---|---|
| និយមន័យ ? | ការមិនគោរពប្រតិបត្តិដល់ព្រះដោយចេតនា | មនុស្ស កម្រិត ពិការភាព |
| ប្រភព ? | លើកទឹកចិត្តដោយសាតាំង | ជាផ្នែកធម្មជាតិនៃជីវិតរមែងស្លាប់របស់យើង |
| គំរូ ? | ការមិនគោរពតាមព្រះបញ្ញត្តិរបស់ព្រះដោយចេតនា ជាការជឿលើសាតាំងជាងជឿលើព្រះ | ងាយទៅរងនឹងការល្បួង ការរំខានចិត្ត ភាពល្ងិតល្ងៃ ជម្ងឺខាងរាងកាយ ឬផ្លូវចិត្ត ភាពល្ងង់ខ្លៅ ភាពលំអៀង ភាពវង្វេង ការស្លាប់ |
| តើព្រះយេស៊ូវមានកំសោយទាំងនេះទេ ? | ទេ | បាទ/ចាស |
| ចម្លើយរបស់យើងគួរតែជា ? | ការប្រែចិត្ត | ការបន្ទាបខ្លួន សេចក្ដីជំនឿលើព្រះគ្រីស្ទ និងការខិតខំដើម្បីយកឈ្នះ |
| ចម្លើយរបស់ព្រះវិញនោះគឺ ? | ការអភ័យទោស | ព្រះគុណ — គឺជាព្រះចេស្ដាដែលអាចកើតមាន |
| ដែលជាលទ្ធផលក្នុង ? | ការសម្អាតពីបាប ។ | ទទួលបានភាពបរិសុទ្ធជាកម្លាំង |

ស្ថានភាពនៃភាពទន់ខ្សោយនៅក្នុងជីវិតរមែងស្លាប់នេះ ( សូមមើល កូរិនថូស ទី2 13:4 ) ។ ទ្រង់បានប្រសូតមកជាព្រះឱរសដែលគ្មានពំនឹង នៅក្នុងរាងកាយរមែងស្លាប់ និងត្រូវបានចិញ្ចឹមដោយអាណាព្យាបាលដែលពុំល្អឥតខ្ចោះ ។ ទ្រង់ត្រូវរៀនពីរបៀបដើរ និយាយ ធ្វើការ និងចុះសម្រុងជាមួយអ្នកដទៃ ។ ទ្រង់ឃ្លាន និងនឿយហត់ មានអារម្មណ៍ដូចមនុស្ស ហើយអាចមានជំងឺ រងទុក្ខ ចេញឈាម និងសុគត ។ ទ្រង់បាន « ត្រូវសេចក្ដីល្បួងគ្រប់យ៉ាង ដូចជាយើងរាល់គ្នាដែរ តែឥតធ្វើបាបឡើយ » ទ្រង់បានដាក់អង្គទ្រង់ក្នុងជីវិតរមែងស្លាប់ ដូច្នេះទ្រង់អាច « អាណិតអាសូរ ដល់សេចក្ដីកំសោយរបស់យើងរាល់គ្នា » ហើយជួយយើងនៅក្នុង *ជម្ងឺ* ឬ ភាពកំសោយរបស់យើង ( ហេព្រើរ 4:15 សូមមើលផងដែរ អាលម៉ា 7:11–12 ) ។

យើងមិនអាចគ្រាន់តែប្រែចិត្តពីការចុះខ្សោយ — ឬក៏ភាពទន់ខ្សោយនោះផ្ទាល់ធ្វើឲ្យយើងមិនស្អាតស្អំនោះទេ ។ យើងមិនអាចរីកចម្រើនខាងវិញ្ញាណបានទេ លុះត្រាតែយើង *បដិសេធ* អំពើបាប ប៉ុន្តែយើងក៏មិនរីកចម្រើនខាងវិញ្ញាណដែរ លុះត្រាតែយើង *ទទួលយក* ស្ថានភាពទន់ខ្សោយជាមនុស្សរបស់យើង ឆ្លើយតបនឹងវាដោយរាបសា និងសេចក្ដីជំនឿ ហើយរៀនតាមរយៈភាពទន់ខ្សោយរបស់យើង ដើម្បីទុកចិត្តលើព្រះ ។ ពេលម៉ូរ៉ូណៃបារម្ភពីភាពទន់ខ្សោយក្នុងការសរសេររបស់លោក ព្រះអម្ចាស់បានប្រាប់លោកឲ្យប្រែចិត្ត ។ ព្រះអម្ចាស់បានបង្រៀនលោកឲ្យមានចិត្តរាបសា និងឲ្យមានសេចក្ដីជំនឿលើព្រះគ្រីស្ទជំនួសវិញ ។ នៅពេលដែលយើងមានចិត្តស្លូតបូត និងស្មោះត្រង់ ព្រះអម្ចាស់ប្រទានព្រះគុណ — មិនមែនជាការអភ័យទោស — ជាឱសថសម្រាប់ភាពទន់ខ្សោយទេ ។ វចនានុក្រមព្រះគម្ពីរបរិសុទ្ធកំណត់និយមន័យព្រះគុណជា អំណាចកើតមកពីព្រះដើម្បីធ្វើអ្វី ដែលយើងមិនអាចធ្វើដោយខ្លួនឯង ( សូមមើលវចនានុក្រមព្រះគម្ពីរបរិសុទ្ធលើពាក្យ « ព្រះគុណ » ) — ឱសថព្រះសមរម្យដែលទ្រង់អាច « ធ្វើឲ្យ អ្វីដែលទន់ខ្សោយក្លាយទៅជាខ្លាំងពូកែ » ។

### ការអនុវត្តភាពរាបសា និង សេចក្ដីជំនឿ

តាំងពីដើមមក នៅក្នុងបទពិសោធន៍សាសនាចក្ររបស់យើង យើងត្រូវបានបង្រៀនពីធាតុសំខាន់នៃការប្រែចិត្ត ប៉ុន្តែតើយើងពង្រឹងភាពរាបសា និងសេចក្ដីជំនឿដោយរបៀបណា ? សូមធ្វើការពិចារណាដូចខាងក្រោម ៖

- **ពិចារណា និង អធិស្ឋាន ។** ដោយសារតែយើងទន់ខ្សោយ យើងអាចនឹងមិនដឹងថាយើងកំពុងដោះស្រាយជាមួយនឹង *អំពើបាប* ( អំពាវនាវឲ្យមានការផ្លាស់ប្ដូរចិត្តជាបន្ទាន់ និងការផ្លាស់ប្ដូរ គំនិត ដួងចិត្ត និងអាកប្បកិរិយាទូទៅ ) ឬជាមួយនឹង *ភាពទន់ខ្សោយ* ( អំពាវនាវឲ្យមានភាពរាបសា ការខិតខំប្រកបដោយនិរន្តភាព ការរៀនសូត្រ និងការរីកចម្រើន ) ។ របៀបដែលយើងមើលរឿងទាំងនេះ អាចពឹងផ្អែកទៅលើការចិញ្ចឹមបីបាច់ និងភាពចាស់ទុំរបស់យើង ។ វាក៏អាចមានធាតុផ្សំ ទាំងអំពើបាប និងភាពទន់ខ្សោយនៅក្នុងអាកប្បកិរិយាតែមួយ ។ ការនិយាយថាអំពើបាប គឺពិតជាភាពទន់ខ្សោយ នាំឲ្យមានការដោះសារ ជំនួសឲ្យការប្រែចិត្តវិញ ។ ការនិយាយថាភាពទន់ខ្សោយ គឺជាអំពើបាប អាចបណ្ដាលឲ្យមានភាពអាម៉ាស់ ការស្ដីបន្ទោស ភាពអស់សង្ឃឹម និងបោះបង់ចោលការសន្យារបស់ព្រះ ។ ការពិចារណា និងការអធិស្ឋានជួយយើងឲ្យធ្វើការបែងចែកទាំងនេះ ។
- **អាទិភាព ។** ដោយសារតែយើងទន់ខ្សោយ យើងមិនអាចធ្វើការផ្លាស់ប្ដូរលើអ្វីដែលត្រូវការក្នុងពេលតែមួយបានទេ ។ នៅពេលដែលយើងតតាំងនឹងភាពទន់ខ្សោយរបស់យើងលើរឿងមួយចំនួន ដោយរាបសា និងដោយសេចក្ដីជំនឿ យើងអាចកាត់បន្ថយភាពព្រងើយកន្តើយបន្តិចម្ដងៗ ធ្វើឲ្យមានលំនាំទំលាប់ល្អ បង្កើនសុខភាព និងភាពអំណត់ខាងរាងកាយ និងខាងអារម្មណ៍ ហើយពង្រឹងទំនុកចិត្តលើព្រះអម្ចាស់ ។ ព្រះអាចជួយយើងឲ្យដឹងពីកន្លែងដែលត្រូវចាប់ផ្ដើម ។

រូបថតដោយ ISTOCK/THINKSTOCK

- **ផែនការ ។** ដោយសារតែយើងទន់ខ្សោយ ការទទួលកម្លាំងកាន់តែខ្លាំងឡើង នឹងទាមទារច្រើនជាងបំណងប្រាថ្នាសុចរិត និងការលត់ដំខ្លួនជាច្រើន ។ យើងក៏ត្រូវការផែនការផងដែរ រៀនពីកំហុស អភិវឌ្ឍយុទ្ធសាស្រ្តមានប្រសិទ្ធភាពច្រើនថែមទៀត កែសម្រួលផែនការរបស់យើងឡើងវិញ ហើយព្យាយាមម្តងទៀត ។ យើងត្រូវការជំនួយពីព្រះគម្ពីរ សៀវភៅនានាដែលទាក់ទង និងមនុស្សដទៃទៀត ។ យើងចាប់ផ្តើមពីតូច មានអំណរក្នុងការរីកចម្រើន និងទទួលយកហានិភ័យ ( ទោះបីជាវាធ្វើឲ្យយើងមានអារម្មណ៍ថាងាយរងគ្រោះ និងទន់ខ្សោយក្តី ) ។ យើងត្រូវការគាំទ្រ ដើម្បីជួយយើងឲ្យធ្វើការសម្រេចចិត្តដ៏ល្អ ទោះបីជាពេលដែលយើងនឿយហត់ ឬបាក់ទឹកចិត្ត ហើយមានគម្រោងត្រឡប់មកផ្លូវវិញពេលដែលយើងរអិលដួល ។
- **អនុវត្តការអត់ធ្មត់ ។** ដោយសារតែយើងទន់ខ្សោយ ការផ្លាស់ប្តូរប្រហែលជាត្រូវការពេលខ្លះ ។ យើងមិនបោះបង់ចោលភាពទន់ខ្សោយ ដូចជាយើងបោះបង់ចោលអំពើបាបនោះទេ ។ ពួកសិស្សដ៏រាបទាបស្ម័គ្រចិត្តធ្វើអ្វីដែលបានទាមទារដល់ពួកគេ រៀនអត់ធន់ ខិតខំព្យាយាម និងមិនបោះបង់ចោលឡើយ ។ ការបន្ទាបខ្លួនជួយយើងឲ្យមានការអត់ធ្មត់ នឹងខ្លួនយើង និងជាមួយនឹងអ្នកដទៃដែលទន់ខ្សោយដែរ ។ ការអត់ធ្មត់ គឺជាការសម្តែងចេញនូវសេចក្តីជំនឿរបស់យើងទៅលើព្រះ ដឹងគុណសម្រាប់ទំនុកចិត្តរបស់ទ្រង់មកលើយើងរាល់គ្នា និងទុកចិត្តលើការសន្យាទាំងឡាយរបស់ទ្រង់ ។

សូម្បីតែនៅពេលដែលយើងប្រែចិត្តពីអំពើបាបរបស់យើងដោយស្មោះ ទទួលបានការអភ័យទោស និងក្លាយជាស្អាតស្អំម្តងទៀតក្តី ក៏យើងនៅតែទន់ខ្សោយដែរ ។ យើងនៅតែជាប្រធានបទសម្រាប់ជម្ងឺ ការរម្ខួលចិត្ត ភាពល្ងង់ខ្លៅ ភាពទំនោរចិត្ត ភាពល្ហិតល្ហៃ និងការល្បួង ។ *ប៉ុន្តែ កម្រិតសមត្ថភាព និងការខ្វះសមត្ថភាពគឺមិនមែនជាអំពើបាបទេ ហើយវាមិនឃាត់យើងពីភាពស្អាតស្អំ និងភាពសក្តិសមនៃព្រះវិញ្ញាណនោះទេ ។*

**ភាពទន់ខ្សោយទៅជាកម្លាំង**

ខណៈពេលដែលសាតាំង ខ្នះខ្នែងប្រើភាពទន់ខ្សោយរបស់យើង ដើម្បីល្បួងយើងឲ្យប្រព្រឹត្តអំពើបាប ព្រះអាចប្រើភាពទន់ខ្សោយរបស់មនុស្ស ដើម្បី



**ញែកកំហុសក្នុងន័យស្លាបនា ( ទុក្ខព្រួយរបស់ព្រះ ) និងភាពរាបសាចេញពីភាពអាម៉ាស់ក្លែងក្លាយដែលឥតប្រយោជន៍**

| កំហុសក្នុងន័យស្លាបនា — ជាទុក្ខព្រួយរបស់ព្រះសម្រាប់អំពើបាប | សេចក្ដីជំនឿ & សេចក្ដីរាបសា — ជាចិត្តស្លូតបូតក្នុងភាពទន់ខ្សោយដូចជាព្រះគ្រីស្ទ | ភាពអាម៉ាស់បំផ្លិចបំផ្លាញ — ជាភាពក្លែងក្លាយឥតប្រយោជន៍ |
|---|---|---|
| យើងមានទំនោរទៅ ៖<br>• មានអារម្មណ៍សោកស្ដាយចំពោះការបំពានលើក្រមខាងសីលធម៌របស់យើង ។<br>• កែប្រែចិត្ត ផ្លាស់ប្ដូរគំនិត ដួងចិត្ត ឥរិយាបថរបស់យើង ។<br>• បើកសារភាពកំហុសទាំងឡាយរបស់យើង ធ្វើការជួសជុល ។<br>• រីកលូតលាស់ និងរៀន ។<br>• មើលឃើញខ្លួនយើង ដូចជាតម្លៃល្អពីធម្មជាតិ ។<br>• ប្រាថ្នាចង់តម្រឹមឥរិយាបថរបស់យើងជាមួយនឹងភាពវិជ្ជមានរបស់យើង ។<br>• ជឿទុកចិត្តយ៉ាងពេញលេញលើអំណាចប្រោសលោះនៃដង្វាយធួនរបស់គ្រីស្ទ ។ | យើងមានទំនោរទៅ ៖<br>• មានអារម្មណ៍ពីការធានាដ៏ស្ងប់ស្ងាត់ និងការទទួលយកខ្លួនឯងការណ៍ទាំងអស់ ។<br>• ទទួលយកហានិភ័យក្នុងការរីកលូតលាស់ និងចូលរួមចំណែក ។<br>• ទទួលយកទំនួលខុសត្រូវលើកំហុស ហើយមានបំណងចង់ឲ្យប្រសើរឡើង ។<br>• រៀនពីកំហុស និងព្យាយាមម្ដងទៀត ។<br>• អភិវឌ្ឍភាពកំប្លុកកំប្លែង និងរីករាយជាមួយជីវិត និងអ្នកដទៃទៀត ។<br>• មើលឃើញភាពទន់ខ្សោយរបស់យើង ដូចជាការផ្ដល់ឲ្យយើងនូវជំហរតែមួយជាមួយអ្នកដទៃ ។<br>• មានចិត្តអត់ធ្មត់នឹងភាពទន់ខ្សោយ និងគុណវិបត្តិរបស់អ្នកដទៃ ។<br>• បង្កើនទំនុកចិត្តទៅលើសេចក្ដីស្រឡាញ់ និងជំនួយរបស់ព្រះ ។ | យើងមានទំនោរទៅ ៖<br>• មានអារម្មណ៍ថាគ្មានតម្លៃ អស់សង្ឃឹម ។<br>• ព្យាយាមលាក់ភាពទន់ខ្សោយរបស់យើងពីអ្នកដទៃ ។<br>• ភ័យខ្លាចត្រូវលាតត្រដាង ។<br>• ស្ដីបន្ទោសអ្នកដទៃលើបញ្ហាទាំងឡាយ ។<br>• ជៀសវាងការទទួលយកហានិភ័យ មើលឃើញការបរាជ័យជាការអាម៉ាស ។<br>• ប្រកួតប្រជែង និងប្រៀបធៀបខ្លួនយើងជាមួយនឹងអ្នកដទៃ ។<br>• តតាំងដោះសារ និងរឹងចចេស ឬក៏មិនសូវក្លៀវក្លា ។<br>• ចំអកបញ្ឈឺចិត្ត ឬម៉ត់ចត់ហួសហេតុពេក ។<br>• ជាប់រវល់ហួសជាមួយនឹងកំហុស ឬឧត្ដមភាពរបស់យើង ។<br>• ភ័យខ្លាចការបដិសេធ និងការស្អប់ខ្ពើមរបស់ព្រះ ។ |

បង្រៀន ពង្រឹង និងប្រទានពរដល់យើង ។ ទោះបីជាវាផ្ទុយទៅនឹងអ្វីដែលយើងអាចរំពឹង ឬសង្ឃឹម ព្រះទ្រង់មិនតែងតែ « ធ្វើឲ្យ អ្វីដែលទន់ខ្សោយ ក្លាយទៅជាខ្លាំងពូកែ » ចំពោះយើងដោយបំបាត់ចោលភាពទន់ខ្សោយរបស់យើងនោះទេ ។ ពេលសាវកប៉ុល អធិស្ឋានអង្វរម្ដងហើយម្ដងទៀតដើម្បីឲ្យព្រះអម្ចាស់បានដកយក « បន្លាចេញពីសាច់ឈាម » ដែលសាតាំងបានប្រើដើម្បីធ្វើទារុណកម្មលោក ព្រះអម្ចាស់បានមានបន្ទូលប្រាប់សាវកប៉ុលថា « គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំឡាំងអញបានពេញខ្នាត ដោយសេចក្ដីកំសោយ » ( កូរិនថូសទី 2 12:7, 9 ) ។

មានវិធីជាច្រើនដែលព្រះអម្ចាស់បានធ្វើឲ្យ « អ្វីដែលទន់ខ្សោយ ក្លាយទៅជាខ្លាំងពូកែ » ។ ខណៈពេលដែលទ្រង់បំបាត់ចោលភាពទន់ខ្សោយតាមរយៈការព្យាបាលដ៏មានប្រសិទ្ធិភាពដែលយើងសង្ឃឹមលើ នៅក្នុងបទពិសោធន៍ផ្ទាល់ខ្លួនរបស់ខ្ញុំថា ថាកម្រនឹងកើតឡើងណាស់ ។ ឧទាហរណ៍ ខ្ញុំមិនឃើញមានភស្តុតាងណាដែលទ្រង់បានបំបាត់ចោលភាពទន់ខ្សោយរបស់ម៉ូរ៉ូណៃ នៅក្នុងការសរសេរ បន្ទាប់ពីខដ៏ល្បីនៅក្នុង អេធើរ 12 ។ ព្រះអម្ចាស់ក៏អាចធ្វើឲ្យអ្វីដែលទន់ខ្សោយទៅជាខ្លាំងពូកែបាន ដោយជួយយើងកែលម្អភាពទន់ខ្សោយរបស់យើង ទទួលបានអារម្មណ៍លេងសើចសមរម្យ ឬទស្សនវិស័យអំពីវា ហើយធ្វើឲ្យវាប្រសើរឡើងជាលំដាប់តាមពេលវេលា ។ ហើយជារឿយៗ កម្លាំង និងភាពទន់ខ្សោយពាក់ព័ន្ធគ្នា ( ដូចជាកម្លាំងនៃការតស៊ូ និងភាពទន់ខ្សោយនៃភាពចចេស ) ហើយយើងអាចរៀនដើម្បីឲ្យតម្លៃដល់កម្លាំង និងបន្ថយភាពទន់ខ្សោយដែលនៅជាមួយវា ។

មានវិធីមួយទៀតដែលកាន់តែមានអនុភាព ដែលព្រះអម្ចាស់ធ្វើឲ្យអ្វីដែលទន់ខ្សោយ ក្លាយទៅជាខ្លាំងពូកែមកដល់យើង ។ ព្រះអម្ចាស់ មានបន្ទូលទៅម៉ូរ៉ូណៃនៅក្នុង អេធើរ 12:37 ថា « ពីព្រោះអ្នកបានឃើញភាពទន់ខ្សោយរបស់ខ្លួន នោះអ្នកនឹងត្រូវបានធ្វើឲ្យខ្លាំងពូកែ រហូតដល់បានអង្គុយឯទីកន្លែង ដែលយើងបានរៀបចំទុក នៅក្នុងវិមានទាំងឡាយនៃព្រះវរបិតារបស់យើង » ។

ត្រង់នេះ ព្រះទ្រង់មិនបានផ្ដល់ជូននូវការផ្លាស់ប្ដូរភាពទន់ខ្សោយរបស់ម៉ូរ៉ូណៃទេ តែដើម្បីផ្លាស់ប្ដូរម៉ូរ៉ូណៃវិញ ។ ដោយដោះស្រាយបញ្ហានៃភាពទន់ខ្សោយរបស់មនុស្ស ម៉ូរ៉ូណៃ — និងយើងរាល់គ្នា — អាចរៀនពីសប្បុរសធម៌ មេត្តាធម៌ ភាពស្លូតបូត ភាពអត់ធ្មត់ ភាពក្លាហាន ការអត់ធ្មត់ ប្រាជ្ញា កម្លាំង ការអភ័យទោស ការអត់ធន់ ការដឹងគុណ ការច្នៃប្រឌិត និងគុណធម៌ឥតគណនាដទៃទៀត ដែលធ្វើឲ្យយើងកាន់តែដូចព្រះវរបិតាសួគ៌ ។ ទាំងនេះគឺជាគុណសម្បត្តិ ដែលយើងមកកាន់ផែនដីដើម្បីបណ្ដុះបណ្ដាល គុណលក្ខណៈទាំងឡាយដែលដូចជាព្រះគ្រីស្ទដែលរៀបចំយើងសម្រាប់វិមានទាំងឡាយនៅខាងលើ ។

គ្មានកន្លែងណាដែលសេចក្ដីស្រឡាញ់ ប្រាជ្ញា និងអំណាចប្រោសលោះរបស់ព្រះ ដែលពិតជាក់ស្ដែងច្រើនជាងព្រះសមត្ថភាពរបស់ទ្រង់ដើម្បីប្រែការតស៊ូរបស់យើងជាមួយនឹងភាពទន់ខ្សោយរបស់មនុស្ស ឲ្យទៅជាគុណធម៌ និងកម្លាំងដ៏មានតម្លៃរបស់ព្រះ ដែលធ្វើឲ្យយើងកាន់តែដូចទ្រង់នោះទេ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*






**ដោយអែលឌើរ ដ័ប៊ុលយូ គ្រីស្តូហ្វើរ វ៉ែឌិល**
នៃពួកចិតសិបនាក់


# សាសនាពិត

*ការបម្រើដោយមិនគិតពីខ្លួនឯង — ការបំភ្លេចខ្លួនឯង ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដទៃ ហើយលះបង់ជីវិតរបស់យើងទៅក្នុងការបម្រើ — តែងតែជាលក្ខណៈពិសេសនៃសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។*

នៅក្នុងគម្ពីរ ម៉ាថាយ ជំពូក 11 ព្រះអង្គសង្គ្រោះ បង្រៀនយើងពីមេរៀនដ៏សំខាន់មួយ ដោយអ្វីដែលទ្រង់ *មិន* មានបន្ទូលតបឆ្លើយទៅនឹងសំណួរសួរដោយពួកសាវករបស់ទ្រង់ពីយ៉ូហានបាទីស្ទ ៖

« រីឯយ៉ូហានដែលជាប់នៅក្នុងគុក គាត់បានឮពីការទាំងប៉ុន្មាន ដែលព្រះគ្រីស្ទទ្រង់ធ្វើ ហើយក៏ចាត់សិស្សគាត់២នាក់ ឲ្យទៅទូលសួរទ្រង់ថា

« តើទ្រង់ជាព្រះអង្គដែលត្រូវយាងមកនោះ ឬត្រូវឲ្យយើងខ្ញុំចាំ១អង្គទៅទៀត

« ព្រះយេស៊ូវទ្រង់មានព្រះបន្ទូលតបថា ចូរទៅប្រាប់យ៉ូហានពីសេចក្តីទាំងប៉ុន្មានដែលអ្នកកំពុងតែឮ ហើយឃើញ ៖

« គឺថាមនុស្សខ្វាក់បានភ្លឺ មនុស្សខ្វិនបានដើររួច មនុស្សឃ្លង់បានជាស្អាត មនុស្សថ្លង់បានឮ មនុស្សស្លាប់បានរស់ឡើងវិញ ហើយមនុស្សទាល់ក្របានឮដំណឹងល្អផង » ( ម៉ាថាយ 11:2–5 ) ។

ជាជាងការផ្តល់នូវការពន្យល់ពីគោលលទ្ធិ ដែលពណ៌នាថាទ្រង់ពិតជា « ព្រះអង្គដែលត្រូវយាងមកនោះ » ព្រះអង្គសង្គ្រោះ បានតបដោយរបៀបដែលទ្រង់បានធ្វើវិញ — ជាគំរូនៃការបម្រើរបស់ទ្រង់ ។

នៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ 2014 អែលឌើរ រ៉ូណាត ជី ស្កុត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានរំឭកយើងថា ៖ « យើងបម្រើព្រះវរបិតាសួគ៌យើងយ៉ាងល្អបំផុត តាមរយៈឥទ្ធិពលសុចរិតលើអ្នកដទៃ និងការបម្រើដល់ពួកគេ ។ ព្រះអង្គសង្គ្រោះយើង ព្រះយេស៊ូវគ្រីស្ទ គឺជាគំរូដ៏ល្អបំផុតដែលបានរស់នៅលើផែនដី »[1]

ការបម្រើដោយមិនគិតពីខ្លួនឯង — ការបំភ្លេចខ្លួនឯង ឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកដទៃ ហើយលះបង់ជីវិតរបស់យើងទៅក្នុងការបម្រើ — តែងតែជាលក្ខណៈពិសេសនៃសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ ដូចស្ដេច បេនយ៉ាមីន បានបង្រៀនជាង 100 ឆ្នាំ មុនការប្រសូតរបស់ព្រះអង្គសង្គ្រោះថា « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ 2:17 ) ។

លោកយ៉ាកុបរំឭកយើងថា ចំណុចដ៏សំខាន់នៃ « សាសនាពិត » គឺត្រូវបានរកឃើញនៅក្នុងការបម្រើរបស់យើងចំពោះអ្នកដទៃ ពេលដែលយើង « ទៅសួរពួកកំព្រា និងពួកមេម៉ាយ ក្នុងកាលដែលគេមានសេចក្តី វេទនា » ( យ៉ាកុប 1:27 ) ។ « សាសនាពិត » គឺច្រើនជាងការប្រកាសនៃជំនឿ វាគឺជាការបង្ហាញពីជំនឿ ។

**ចូរស្រឡាញ់អ្នករួមដំណើរជាមួយអ្នក**

នៅពាក់កណ្តាលខែ កក្កដា ឆ្នាំ 1984 ប៉ុន្មានសប្តាហ៍បន្ទាប់ពីខ្ញុំ និងភរិយារបស់ខ្ញុំគឺខារ៉ូល បានរៀបអាពាហ៍ពិពាហ៍នៅក្នុងព្រះវិហារបរិសុទ្ធ នាទីក្រុងឡូស អាន់ជេឡែស រដ្ឋ កាលីហ្វូញ៉ា យើងកំពុងនៅតាមផ្លូវទៅរដ្ឋយូថាហ៍ ជាកន្លែងដែលខ្ញុំនឹងចាប់ផ្តើមអាជីពរបស់ខ្ញុំ ហើយខារ៉ូលនឹងបញ្ចប់ការសិក្សានៅមហាវិទ្យាល័យរបស់គាត់ ។ យើងបានបើកឡានខុសគ្នា ។ រវាងរថយន្តទាំងពីរនេះ យើងកំពុងដឹកជញ្ជូនរបស់របរគ្រប់យ៉ាងដែលជាកម្មសិទ្ធិរបស់យើង ។

នៅប្រមាណជាងពាក់កណ្តាលផ្លូវ ខារ៉ូលបានឈប់ជាប់ឡានរបស់ខ្ញុំ ហើយចាប់ផ្តើមធ្វើកាយវិការមកកាន់ខ្ញុំ ។ វាមុនពេលដែលមានទូរសព្ទដៃ ទូរសព្ទទំនើប កម្មវិធី Twitter និងផ្ញើសារទៅទៀត ។ ដោយមើលឃើញទឹកមុខរបស់គាត់តាមបង្អួចឡាន ខ្ញុំអាចប្រាប់បានថា គាត់មិនស្រួលខ្លួននោះទេ ។


រូបថតដោយ អេរី ម៉ៃនវ៉ៃ

គាត់បានឆ្លើយឆ្លងថា គាត់អាចបន្តបើកបរទៅមុខទៀត ប៉ុន្តែខ្ញុំបារម្ភពីភរិយាថ្មីថ្មោងរបស់ខ្ញុំ ។

នៅពេលដែលយើងទៅដល់ទីប្រជុំជនតូចមួយនៃទីក្រុងប៊ីរើរ រដ្ឋយូថាហ៍ គាត់បានឈប់នៅជិតខ្ញុំ ហើយខ្ញុំអាចប្រាប់ថា គាត់ត្រូវការឈប់សម្រាក ។ គាត់ឈឺ ហើយមិនអាចបន្តដំណើរទៅមុខទៀតទេ ។ យើងមានទូឡានពីរដែលពេញទៅដោយសម្លៀកបំពាក់ និងអំណោយអាពាហ៍ពិពាហ៍ ប៉ុន្តែជាអកុសល យើងមានប្រាក់កាសតែបន្តិចបន្តួចប៉ុណ្ណោះ ។ យើងគ្មានលុយគ្រប់ដើម្បីជួលបន្ទប់សណ្ឋាគារទេ ។ ខ្ញុំមិនដឹងថាត្រូវធ្វើអ្វីនោះទេ ។

យើងទាំងពីរនាក់មិនធ្លាប់មកទីក្រុងប៊ីរើរពីមុនមកសោះ ហើយក៏មិនដឹងថាខ្ញុំកំពុងតែរកមើលអ្វីដែរ យើងបានបើកជុំវិញអស់រយៈពេលពីរបីនាទី រហូតដល់យើងឃើញសួនច្បារមួយ ។ យើងបត់ចូលកន្លែងចតឡានក្នុងសួនច្បារនោះ ហើយបានឃើញដើមឈើមួយដើមដែលមានម្លប់ខ្លះ ជាកន្លែងដែលខ្ញុំបានក្រាលភួយឲ្យខារ៉ូលបានសម្រាក ។

ពីរបីនាទីក្រោយមក មានឡានមួយទៀតបានបើកចូលមកក្នុងកន្លែងចតឡានដែលស្ទើតែគ្មានឡានសោះ ហើយបានចតនៅជិតឡានរបស់យើង ។ ស្ត្រីម្នាក់ដែលមានអាយុប្រហាក់ប្រហែលនឹងម្ដាយរបស់យើង បានចេញពីឡានរបស់គាត់ ហើយសួរថា តើមានបញ្ហាអ្វី ហើយគាត់អាចជួយបានឬទេ ។ គាត់បាននិយាយថា គាត់បានសង្កេតឃើញយើងពេលដែលគាត់បើកកាត់ គាត់មានអារម្មណ៍ថា គាត់គួរតែឈប់មើលសិន ។ ពេលដែលយើងបានពន្យល់ពីស្ថានភាពរបស់យើង គាត់បានអញ្ជើញយើងទៅផ្ទះរបស់គាត់ភ្លាម ជាកន្លែងដែលយើងអាចសំរាកនៅយូរតាមដែលយើងត្រូវការ ។

យើងរកឃើញថា យើងនៅលើគ្រែយ៉ាងកក់ក្ដៅ នៅក្នុងបន្ទប់សម្រាន្តក្រោមដីផ្ទះរបស់គាត់ ។ នៅពេលដែលយើងបានសម្រាកបន្តិច បងស្រីដ៏អស្ចារ្យម្នាក់នេះ បានប្រាប់ថា គាត់មានកិច្ចការមួយចំនួនដែលត្រូវធ្វើ ហើយដូច្នេះយើងនៅផ្ទះតែឯងពីរបីម៉ោង ។ គាត់បានប្រាប់យើងថា ប្រសិនបើយើងឃ្លានយើងអាចបរិភោគអ្វីដែលយើងអាចរកបាននៅក្នុងផ្ទះបាយ ហើយបើយើងត្រូវទៅមុនពេលដែលគាត់ត្រឡប់មកផ្ទះវិញនោះ សូមបិទទ្វារមុខ ។

បន្ទាប់ពីបានសម្រាន្តគ្រប់គ្រាន់ល្មម ខារ៉ូលមានអារម្មណ៍ធូរស្បើយឡើង ហើយយើងអាចបន្តដំណើរទៅមុខដោយពុំចាំបាច់ទៅរកអ្វីបរិភោគនៅផ្ទះបាយឡើយ ។ ពេលដែលយើងចាកចេញ ស្ត្រីចិត្តល្អម្នាក់នោះមិនទាន់ត្រឡប់មកផ្ទះវិញទេ ។ គួរឲ្យសោកស្ដាយណាស់ យើងមិនបានកត់អាសយដ្ឋាននោះទុក ហើយពុំដែលបានអរគុណស្ត្រីសាសន៍សាម៉ារីដ៏មានចិត្តសប្បុរសរបស់យើងដែលបានឈប់តាមផ្លូវ ហើយបានបើកផ្ទះរបស់គាត់ដល់មនុស្សចម្លែកដែលត្រូវ ការជំនួយឲ្យត្រឹមត្រូវសោះ ។

នៅពេលដែលខ្ញុំជញ្ជឹងគិតពីបទពិសោធន៍នេះ ពាក្យសម្ដីរបស់ប្រធានថូម៉ាស អេស ម៉នសុន ដែលតំណាងឲ្យបន្ទូលដាស់តឿនរបស់ព្រះអង្គសង្គ្រោះឲ្យ « ទៅចុះ ចូរអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ » ( សូមមើល លូកា 10:37 ) នៅពេលគិតដល់ជីវិតរមែងស្លាប់ ៖ « យើងពិតជាមិនអាចស្រឡាញ់ព្រះដោយពិតប្រាកដបានឡើយ បើយើងមិនស្រឡាញ់អ្នករួមដំណើររបស់យើងនៅលើដំណើរនៃជីវិតរមែងស្លាប់នេះផងនោះ »[2]

គ្រប់ទីកន្លែងដែលយើងជួបប្រទះនឹង « អ្នករួមដំណើរ » — នៅតាមផ្លូវ ឬនៅក្នុងផ្ទះរបស់យើង នៅសួនកុមារ ឬនៅក្នុងសាលារៀនរបស់យើង នៅកន្លែងធ្វើការ ឬនៅឯព្រះវិហារ — នៅពេលដែលយើងស្វែងរក មើលឃើញ ហើយធ្វើសកម្មភាព នោះ យើងនឹងក្លាយកាន់តែដូចព្រះអង្គសង្គ្រោះ ពរជ័យ និងការបម្រើនឹងមកតាមផ្លូវ ។

**ស្វែងរក**

អែលឌើរ នែល អេ ម៉ាក់ស្វែល ឆ្នាំ ( 1926–2004 ) នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ៖

« មិនដូចជាព្រះអង្គសង្គ្រោះដ៏មានតម្លៃរបស់យើង យើងប្រាកដជាមិនអាចធ្វើដង្វាយធួនសម្រាប់អំពើបាបរបស់មនុស្សបានទេ ! លើសពីនេះទៅទៀត យើងពិតជាមិនអាចទ្រាំទ្រនឹងជម្ងឺ ភាពពិការ និងទុក្ខព្រួយទាំងឡាយក្នុងជីវិតរមែងស្លាប់បានទេ ( សូមមើល អាលម៉ា 7:11–12 ) ។

« ទោះបីជាយ៉ាងណា ដូចជាព្រះយេស៊ូវបានអញ្ជើញ នៅលើមាត្រដ្ឋានតូចរបស់យើង យើងអាចព្យាយាមឲ្យបានដូច ‹ ជាទ្រង់ › ( នីហ្វៃទី 3 27:27 ) ។ »[3]

នៅពេលដែលយើងស្វែងរកដើម្បីឲ្យបានដូចជាទ្រង់ ដោយបំណងប្រាថ្នាដ៏ស្មោះត្រង់ ដើម្បីប្រទានពរដល់ « អ្នករួមដំណើររបស់យើង » យើងនឹងត្រូវបានផ្ដល់នូវឱកាស ដើម្បីបំភ្លេចខ្លួនឯងហើយលើកស្ទួយអ្នកដទៃ ។ ជាញឹកញាប់ឱកាសទាំងនេះអាចមានការរអាក់រអួល ការសាកល្បងបំណងប្រាថ្នាពិតរបស់យើងក្នុងការក្លាយកាន់តែដូចព្រះអម្ចាស់ ដែលមានការបម្រើដ៏អស្ចារ្យជាងគេទាំងអស់ ដង្វាយធួនដ៏គ្មានទីបញ្ចប់របស់ទ្រង់ គឺមិនងាយស្រួលនោះទេ ។ « ទោះជាយ៉ាងណាក៏ដោយ » ទ្រង់បានមានបន្ទូលថា « សូមព្រះវរបិតាបានសិរីល្អ ហើយយើងបានទទួលទាន និងសម្រេចការរៀបចំរបស់យើងចំពោះកូនចៅមនុស្ស » ( គ និង ស 19:19 ) ។

ការស្វែងរកដោយស្មោះត្រង់ ដើម្បីក្លាយកាន់តែដូចព្រះអង្គសង្គ្រោះ នឹងអនុញ្ញាតឲ្យយើងឃើញនូវអ្វីដែលយើងមិនអាចមើលឃើញបើយើងមិនស្វែងរកដោយស្មោះត្រង់នោះទេ ។ សាសន៍សាម៉ារីដ៏មានចិត្តសប្បុរសរបស់យើងរស់នៅជិតស្និទ្ធនឹងព្រះវិញ្ញាណល្មម ដើម្បីឆ្លើយតបទៅនឹងការបំផុសគំនិត និងបានទៅជួបនឹងមនុស្សចម្លែកដែលត្រូវការជំនួយ ។

**សូមមើល**

ការមើលឃើញដោយចក្ខុខាងវិញ្ញាណ គឺការមើលឃើញធាតុពិតរបស់អ្វីគ្រប់យ៉ាង ហើយដើម្បីទទួលដឹងពីតម្រូវការដែលយើងមិនអាចសង្កេតដោយភ្នែកទទេបាន ។ នៅក្នុងរឿងប្រៀបធៀប នៃសត្វចៀម និងសត្វពពែ មិនមានអ្នកណាមួយដែលត្រូវបាន « ប្រទានពរ » ក៏មិនមានអ្នកណាមួយដែលត្រូវ « បណ្ដាសា » បានទទួលស្គាល់ព្រះអង្គសង្គ្រោះនៅក្នុងចំណោមអ្នកដែលបានឃ្លាន បានស្រេក បានអាក្រាត ឬក៏ជាប់គុកឡើយ ។ ពួកគេបានឆ្លើយតបទៅនឹងម្ចាន់ពួកគេដោយទូលសួរទ្រង់ថា « តើយើងខ្ញុំបានឃើញទ្រង់ពីកាលណា ? » ( សូមមើល ម៉ាថាយ 25:34–44 ) ។

មានតែអ្នកដែលបានមើលដោយចក្ខុខាងវិញ្ញាណតែប៉ុណ្ណោះ ដែលយល់ដឹងអំពីតម្រូវការ បានធ្វើសកម្មភាព និងប្រទានពរដល់អ្នកដែលរងទុក្ខ ។ សាសន៍

សាម៉ារីដ៏មានចិត្តសប្បុរសរបស់យើង ទទួលស្គាល់តម្រូវការពេលដែលគាត់មើលដោយចក្ខុខាងវិញ្ញាណ ។

### អនុវត្ត

យើងអាចមើលឃើញតម្រូវការ នៅជុំវិញខ្លួនយើង ប៉ុន្តែមានអារម្មណ៍ថាគ្មានលទ្ធិភាពដើម្បីឆ្លើយតបទៅនឹងតម្រូវការនោះ ដោយសន្មតថា អ្វីដែលយើងមានដើម្បីឲ្យគឺមិនគ្រប់គ្រាន់ទេ ។ នៅពេលដែលយើងស្វែងរកដើម្បីឲ្យបានដូចជាទ្រង់ ហើយយើងមើលឃើញតម្រូវការនៅក្នុងអ្នករួមដំណើររបស់យើងតាមរយៈចក្ខុខាងវិញ្ញាណ នោះយើងត្រូវតែទុកចិត្តថាព្រះអម្ចាស់អាចធ្វើកិច្ចការតាមរយៈយើងរាល់គ្នា ហើយនៅពេលនោះយើងត្រូវតែបញ្ចេញសកម្មភាព ។

កាលកំពុងដើរចូលទៅក្នុងព្រះវិហារ ពេត្រុស និងយ៉ូហានបានប្រទះនឹងបុរសម្នាក់ដែល « ខ្វិនពីកំណើត » ដែលបានសូមទានពីពួកលោក ( សូមមើល កិច្ចការ 3:1–3 ) ។ ចម្លើយរបស់ពេត្រុស គឺជាគំរូមួយ ហើយជាការអញ្ជើញដល់យើងរាល់គ្នាថា ៖

« ឯប្រាក់ ហើយនិងមាស ខ្ញុំគ្មានទេ តែរបស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក គឺដោយសារព្រះនាមព្រះយេស៊ូវគ្រីស្ទ ពីស្រុកណាសារ៉ែត ចូរអ្នកក្រោកឡើងដើរទៅចុះ »

« រួចក៏ចាប់ដៃស្តាំលើកគាត់ឡើង » ( កិច្ចការ 3:6–7 ) ។

យើងអាចធ្វើសកម្មភាពដោយ ផ្តល់ពេលវេលា និងទេពកោសល្យ ពាក្យល្អៗ ឬជាជំហរមួយដ៏រឹងមាំ ។ នៅពេលដែលយើងស្វែងរក ហើយឃើញ យើងនឹងត្រូវបានដាក់នៅក្នុងកាលៈទេសៈ និងស្ថានភាពផ្សេងៗដែលយើងអាចធ្វើសកម្មភាព និងប្រទានពរ ។ ទង្វើរបស់សាសន៍សាម៉ារីដ៏មានចិត្តសប្បុរសរបស់យើង ។ គាត់បានយកយើងទៅផ្ទះរបស់គាត់ ហើយបានផ្តល់ឲ្យយើងនូវអ្វីដែលគាត់មាន ។ នៅក្នុងខ្លឹមសារនោះ គាត់បាននិយាយថា « របស់ដែលខ្ញុំមាន នោះខ្ញុំនឹងឲ្យដល់អ្នក » ។ វាជាអ្វីដែលយើងពិតជាត្រូវការ ។

ប្រធាន ម៉នសុន បានបង្រៀនពីគោលការណ៍ដូចគ្នានេះថា ៖

« នៅក្នុងដំណើរជីវិតរមែងស្លាប់ យើងម្នាក់ៗនឹងធ្វើដំណើរនៅលើផ្លូវយេរីខូររៀងៗខ្លួន ។ តើអ្វីទៅនឹងជាបទពិសោធន៍របស់អ្នករាល់គ្នា ? តើអ្វីទៅជាបទពិសោធន៍របស់ខ្ញុំ ? តើខ្ញុំនឹងបរាជ័យក្នុងការសម្គាល់ឃើញអ្នកដែលបានធ្លាក់នៅក្នុងចំណោមពួកចោរ ហើយត្រូវការជំនួយរបស់ខ្ញុំឬទេ ? ចុះអ្នកវិញ ?

« តើខ្ញុំនឹងជាមនុស្សម្នាក់ដែលមើលឃើញអ្នករងរបួស ហើយឮការអង្វររបស់គាត់ ហើយដើររៀងទៅម្ខាងទៀតទេ ? ចុះអ្នកវិញ ?

« ឬតើខ្ញុំនឹងក្លាយជាមនុស្សម្នាក់ដែលមើលឃើញ ស្តាប់ឮ ឈប់បង្អង់ ហើយជួយឬទេ ? ចុះអ្នកវិញ ?

« ព្រះយេស៊ូវបានប្រទានឲ្យយើងនូវការណែនាំចំពោះការប្រព្រឹត្តថា ‹ ទៅចុះ ចូរអ្នកប្រព្រឹត្តបែបយ៉ាងដូច្នោះដែរ › ។ ពេលដែលយើងគោរពតាមសេចក្តីប្រកាសនោះ នឹងមានការបើកនូវទិដ្ឋភាពដ៏អស់កល្បជានិច្ចរបស់យើង ជាទស្សនីយភាពនៃក្តីអំណរមួយដែលកម្រនឹងប្រៀបផ្ទឹមបានឡើយ »[4] ។

ហើយក្លាយកាន់តែដូចព្រះអង្គសង្គ្រោះដោយការស្វែងរក និងការធ្វើសកម្មភាព អ្នកនឹងដឹងពីសេចក្តីពិតពេញលេញ នៃព្រះបន្ទូលរបស់ស្តេច បេនយ៉ាមីនថា ៖ « កាលណាអ្នករាល់គ្នានៅក្នុងការបម្រើដល់មនុស្សទូទៅ នោះអ្នករាល់គ្នាគ្រាន់តែនៅក្នុងការបម្រើដល់ព្រះរបស់អ្នកតែប៉ុណ្ណោះ » ( ម៉ូសាយ 2:17 ) ។ ■

#### កំណត់ចំណាំ

1. រីឆាដ ជី ស្កុត « ខ្ញុំបានផ្តល់គំរូដល់អ្នក » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2014, ទំព័រ 35 ។
2. ថូម៉ាស អេស. ម៉នសុន « សេចក្តីស្រឡាញ់ — ជាខ្លឹមសារនៃដំណឹងល្អ » *Liahona,* ខែ ឧសភា ឆ្នាំ 2014, ទំព័រ 91 ។
3. នែល អេ ម៉ាក់ស្វែល « Apply the Atoning Blood of Christ, » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1997, ទំព័រ 22 ។
4. ថូម៉ាស អេស ម៉នសុន « Your Jericho Road » *Ensign,* ខែ ឧសភា ឆ្នាំ 1977, ទំព័រ 71 ។

ចូរស្វែងរកដោយស្មោះត្រង់ | មើលឃើញដោយចក្ខុខាងវិញ្ញាណ | ធ្វើសកម្មភាព ហើយប្រទានពរ





# « ខ្ញុំត្រូវការទេវ់ជានិច្ច »

*ពេលដែលយើងមិនដឹងថា យើងអាចបង្រៀនអ្វីថែមទៀត ដៃគូរបស់ខ្ញុំបានស្នើថាយើងគួរច្រៀងទំនុកតម្កើងមួយនេះ ។*

**ដោយ យ៉ូណាថាន អេច ហ្វេសតូវើរ**

រសៀលថ្ងៃអាទិត្យដ៏រីករាយមួយ នៅក្នុងបេសកកម្មរបស់ខ្ញុំនៅបាល់សានប្រទេសកូរ៉េ ខ្ញុំ នឹងដៃគូរបស់ខ្ញុំបាននិយាយលាទៅសមាជិកបន្ទាប់ពីការប្រជុំនៅព្រះវិហារ ហើយរៀបនឹងចេញទៅផ្សព្វផ្សាយសាសនា ស្រាប់តែអ្នកដឹកនាំបេសកកម្មវួដបានណែនាំយើងឲ្យស្គាល់ក្មេងប្រុសមានអាយុ 12 ឆ្នាំម្នាក់ឈ្មោះ គង់ សុងគុន ។ គាត់បានចូលរួមសាសនាចក្រនៅថ្ងៃនោះ ហើយចង់រៀនពីដំណឹងល្អបន្ថែមទៀត ។

ពិតណាស់ យើងរំភើបចិត្តអំពីលទ្ធភាពនៃការបង្រៀនគាត់ ប៉ុន្តែខ្ញុំក៏ភ័យខ្លាចផងដែរពីការបង្រៀនអ្នកណាម្នាក់ដែលមានវ័យក្មេងដូច្នេះ ។ យើងបានសម្រេចចិត្ត ធ្វើឲ្យប្រាកដថា គាត់បានទទួលការអនុញ្ញាតពីឪពុកម្ដាយរបស់គាត់ ដូច្នេះខ្ញុំបានហៅទូរស័ព្ទទៅផ្ទះរបស់គង់ សុងគុន ហើយបាននិយាយយ៉ាងខ្លីជាមួយនឹងម្ដាយរបស់គាត់ គឺ ប៉ាក់មីជុង ។ ខ្ញុំមានការភ្ញាក់ផ្អើល នៅពេលដែលគាត់និយាយថា គាត់មានក្ដីរីករាយដែលកូនប្រុសរបស់គាត់រំពឹងចង់ចូលរួមក្នុងសាសនាចក្រ ហើយថាគាត់សប្បាយចិត្តឲ្យយើងមកបង្រៀនកូនគាត់ ។

## អ្នករៀនថ្មីដែលមិនបានរំពឹងទុកជាមុន

នៅល្ងាចបន្ទាប់ យើងបានមកដល់ផ្ទះរបស់ក្មេងប្រុសនោះ ត្រៀមខ្លួនជាស្រេចដើម្បីបង្រៀន ។ យើងមានការភ្ញាក់ផ្អើលដោយដឹងថាប៉ាក់មីជុង ក៏ចង់ឲ្យយើងបង្រៀនកូនស្រីគាត់ គឺគង់ ស៊ូជីន ដែរ ។ ហើយដោយសារយើងជាអ្នកចម្លែកនៅក្នុងផ្ទះរបស់គាត់ ប៉ាក់មីជុង ចង់ចូលរួមក្នុងមេរៀនទាំងឡាយ ។ ពិតណាស់ យើងរីករាយក្នុងការបង្រៀនអ្នកទាំងឡាយណាដែលចង់ស្ដាប់ ។

បន្ទាប់ពីពួកគេបានបម្រើអាហារសម្រន់ដល់យើងហើយ យើងបានអង្គុយចុះជាមួយគ្នា ហើយចាប់ផ្ដើមពិភាក្សា ។ ជាជាងឲ្យយើងចាប់ផ្ដើមមេរៀនយើងភ្លាម ប៉ាក់ មីជុង ចង់ស្គាល់យើងបន្ថែមទៀត ហើយប្រាប់យើងអំពីស្ថានភាពក្រុមគ្រួសាររបស់គាត់ ។ គាត់បានប្រាប់យើងអំពី ការសាកល្បង និងការលំបាកថ្មីៗដែលពួកបានឆ្លងកាត់ រួមទាំងការពុះពារថ្មីៗរបស់កូនប្រុសគាត់ជាមួយនឹងជម្ងឺមហារីក ។ កូនប្រុសគាត់បានឆ្លងកាត់ការព្យាបាលដោយកាំរស្មីវិទ្យុសកម្មដោយជោគជ័យ ហើយសព្វថ្ងៃនេះ ជម្ងឺមហារីកនេះ គឺនៅក្នុងការផ្អាច់ តែវេជ្ជបណ្ឌិតបានព្រមានពួកគេថា ថាអាចកើតឡើងម្ដងទៀតនៅពេលណាមួយ ។ វាមានការលំបាកជាខ្លាំងមកលើគ្រួសារនេះ ។ ពួកគេជាគ្រួសារអ្នកធ្វើការងារ ហើយឪពុកខិតខំធ្វើការយ៉ាងខ្លាំង ដើម្បីរក្សាជំរក និងមានម្ហូបអាហារនៅលើតុ ។

ខ្ញុំតក់ស្លុតជាខ្លាំង ហើយសោកស្ដាយដោយការសាកល្បងនៅក្នុងជីវិតរបស់ពួកគេ ។ ជីវិតមិនងាយស្រួលទេសម្រាប់ពួកគេទេ ប៉ុន្តែភាពជិតស្និទនៅក្នុងក្រុមគ្រួសារ បង្ហាញជាភស្តុតាងយ៉ាងធំលើសលប់ ដែលខ្ញុំធ្លាប់បានឃើញនៅក្នុងក្រុមគ្រួសារដទៃទៀត ដែលខ្ញុំបានជួបនៅប្រទេសកូរ៉េ ដែលមានអត្ថន័យយ៉ាងធំសម្បើម នៅក្នុងសង្គមដែលផ្ដោតទៅលើក្រុមគ្រួសារ ដូចជាប្រទេសកូរ៉េនេះ ។ យើងបានចាកចេញពីផ្ទះពួកគេនៅល្ងាចនោះ ដោយបានស្គាល់ក្រុមគ្រួសារដ៏ពិសេសនេះជាងមុន ហើយបានមានឱកាសដើម្បីចែកចាយសារលិខិតដំណឹងល្អជាមួយពួកគេ ។

ខ្ញុំ និងដៃគូខ្ញុំបានត្រឡប់ទៅបង្រៀនពួកគេពីរបីដងទៀតនៅសប្ដាហ៍នោះ រាល់ពេល យើងមានបទពិសោធន៍ពីភាពកក់ក្ដៅ និងភាពសប្បុរសដូចជាបទ

រូបភាពដោយ [illegible] ISTOCK/THINKSTOCK

ពិសោធន៍ដំបូងដែលយើងមកផ្ទះគេដែរ ។ ពេលដែលប្រធានបទនៃការបុណ្យជ្រមុជទឹកបានលើកឡើង កូនទាំងពីរចង់ចូលរួមនឹងសាសនាចក្រខ្លាំងណាស់ ។ ប៉ុន្តែ ម្ដាយរបស់គេមិនមានអារម្មណ៍រំភើបដូចពួកគេទេ ។ ទោះបីជាការបង្រៀនរបស់យើងសមហេតុផលចំពោះគាត់ ហើយគាត់បានសង្ឃឹមថាសារលិខិតនោះពិតក្ដី គាត់មិនមានអារម្មណ៍ថា គាត់អាចធ្វើតាម និងរក្សាបទបញ្ញត្តិទាំងនេះ ដែលតម្រូវឲ្យធ្វើតាម នៅពេលចូលរួមក្នុងសាសនាចក្រឡើយ ។ គាត់ក៏មិនមានអារម្មណ៍ថា វាសក្ដិសមសម្រាប់គាត់ទទួលបុណ្យជ្រមុជទឹកដោយគ្មានស្វាមីគាត់ ដែលយើងមិនធ្លាប់បានជួបដែរ ។ ប៉ុន្តែ គាត់មានឆន្ទៈដើម្បីជួបជាមួយយើង ហើយក៏ចង់ចូលរួមជាមួយកូនៗរបស់គាត់ ក្នុងការមកចូលរួមក្នុងសាសនាចក្រដែរ ។

នៅជិតទីបញ្ចប់នៃសប្ដាហ៍ទីពីរនោះ ពេលដែលយើងបន្តបង្រៀននៅក្នុងផ្ទះរបស់គាត់ យើងបានជួបស្វាមីរបស់គាត់ គឺគង់ គុកវ៉ុន — គាត់ជាបុរសរាបសារួសរាយ និងចិត្តល្អម្នាក់ ។ គាត់បានចូលរួមជាមួយយើងក្នុងការពិភាក្សាចុងក្រោយ ហើយជឿភ្លាមលើអ្វីៗ គ្រប់យ៉ាងដែលយើងបានបង្រៀន រួមទាំងគោលលទ្ធិនានា ដែលអ្នកដទៃទៀតដែលជារឿយៗពិបាកយល់ដូចជា ដង្វាយមួយភាគក្នុងដប់ និងច្បាប់សុខភាព ។ ទោះបីជាស្ថានភាពហិរញ្ញវត្ថុរបស់ពួកគេខ្សត់ខ្សោយ ពួកគេចាប់ផ្ដើមបង់ដង្វាយមួយភាគដប់ ។ ឧបសគ្គតែមួយរបស់ឪពុកគឺត្រូវធ្វើការនៅថ្ងៃអាទិត្យ ។ គាត់ធ្វើការនៅអាកាសយានអន្តរជាតិក្រុងសេអ៊ូលរៀងរាល់ថ្ងៃអាទិត្យ ដូច្នេះគាត់មិនអាចមកចូលរួមក្នុងសាសនាចក្រជាមួយនឹងគ្រួសាររបស់គាត់បានទេ ។ ថ្វីបើកាលវិភាគការងាររបស់គាត់រវល់ ភរិយាគាត់និងគាត់បានរៀបចំដើម្បីមកចូលរួមពិធីបុណ្យជ្រមុជទឹករបស់កូនៗគាត់នៅថ្ងៃអាទិត្យបន្ទាប់ដែរ ។

បន្ទាប់ពីការជ្រមុជទឹករបស់ក្មេងទាំងពីរមក យើងបានបន្តជួបជាមួយគេជាញឹកញាប់នៅក្នុងផ្ទះរបស់ក្រុមគ្រួសារនោះ ។ យើងបានធ្វើរាត្រីជួបជុំក្រុមគ្រួសារ ចែកចាយខគម្ពីរ និងបទពិសោធន៍លើកទឹកចិត្តនានា ហើយបានណែនាំពួកគេឲ្យជួបនឹងសមាជិកវួដផ្សេងៗទៀត ។ ទោះជាយ៉ាងណាក្រៅពីបទពិសោធន៍ដំណឹងល្អ ឪពុកម្ដាយនេះ មិនទាន់ឈានមកដល់ការជ្រមុជទឹកនៅឡើយទេ ។

នៅក្នុងពេលនោះ ដៃគូរបស់ខ្ញុំបានផ្លាស់ប្ដូរតំបន់ ហើយដៃគូថ្មីរបស់ខ្ញុំ ជាអែលឌើរដែលទើបតែចេញមកពីមជ្ឈមណ្ឌលហ្វឹកហ្វឺនអ្នកផ្សព្វផ្សាយសាសនា ។ គាត់ពោរពេញទៅដោយសេចក្ដីជំនឿ ថាមពល និងការរំភើប ហើយខ្ញុំពិតជាមានការពិបាកដើម្បីតាមឲ្យទាន់គាត់ណាស់ ។ បន្ទាប់ពីជួបជាមួយ គង់ គុកវ៉ុន និង ប៉ាក់ ម៉ីជុង ពីរបីលើកមក ដៃគូរបស់ខ្ញុំបានមកងខ្ញុំ ហើយសួរថាតើខ្ញុំ និងដៃគូមុនរបស់ខ្ញុំបានធ្វើការតមអាហារសម្រាប់ពួកគេ ។ យើងមិនបានធ្វើដូច្នោះទេ ។ តាមពិតទៅ គំនិតនោះមិនធ្លាប់លេចឡើងចំពោះខ្ញុំសោះ ។ ដូច្នេះ យើងបានជួបជាមួយក្រុមគ្រួសារនោះ ហើយបានស្នើសុំការតមអាហារ ។ ខ្ញុំភ្ញាក់ផ្អើលដោយ




*មានព្រះវិញ្ញាណខ្លាំងណាស់នៅក្នុងបន្ទប់ពេលដែលយើងបញ្ចប់វគ្គចុងក្រោយ ។ ប៉ាក់ ម៉ីជុងបានមើលចំភ្នែករបស់ខ្ញុំ ហើយនិយាយថា « ខ្ញុំត្រូវការធ្វើបុណ្យជ្រមុជទឹក » ។*

ដឹងថា ពួកគេបានធ្វើការតមអាហារយ៉ាងទៀងទាត់ដោយខ្លួនឯង ទាំងសម្រាប់សុខភាពរបស់កូនប្រុសគេ និងសម្រាប់ការផ្លាស់ប្ដូរកាលវិភាគការងារ ដែលនឹងអនុញ្ញាតឲ្យគង់ គុកវ៉ុនចូលរួមនឹងសាសនាចក្រ ។ បន្ទាប់ពីខ្ញុំ និងដៃគូរបស់ខ្ញុំបានចូលរួមនឹងគេនៅក្នុងការតមអាហារ ការអធិស្ឋានរបស់យើងត្រូវបានឆ្លើយតប ហើយកាលវិភាគការងាររបស់គង់ គុកវ៉ុនបានផ្លាស់ប្ដូរ ។ ប៉ុន្តែ ប៉ាក់ ម៉ីជុងនៅតែចចេសមិនទទួលបុណ្យជ្រមុជទឹក ។

**ការបំផុសគំនិតមួយ**

បន្ទាប់មកដៃគូរបស់ខ្ញុំ មានគំនិតដ៏អស្ចារ្យមួយទៀត ។ គាត់បានទាញយកសៀវភៅទំនុកតម្កើងតូចមួយចេញពីហោប៉ៅមក ហើយសួរថាតើយើង

អាចច្រៀងជាមួយពួកគេបានទេ ។ ទោះបីយើងបានច្រៀងរួមគ្នានៅពេលមុនៗក្ដី ខ្ញុំមិនដែលឃើញប៉ាក់ ម៉ីជុង ច្រៀង ហើយគ្រាន់តែសន្មតថា គាត់មិនចូលចិត្តច្រៀង ឬវាមិនស្រួលដោយសារតែតន្ត្រីនោះគឺជាទស្សនៈថ្មីសម្រាប់គាត់ ។ ដៃគូរបស់ខ្ញុំបានសួរគាត់ថា តើគាត់មានទំនុកតម្កើងដែលគាត់ចូលចិត្តដែរឬទេ ហើយខ្ញុំបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយគាត់បានអួលដើមក ហើយបានឆ្លើយតបថា តាំងពីគាត់នៅតូច ទំនុកតម្កើងសំណព្វចិត្តរបស់គាត់តែងតែជាបទ « ខ្ញុំត្រូវការទ្រង់ជានិច្ច » ( *ទំនុកតម្កើង* ទំព័រ 47 ) ។ យើងបានចាប់ផ្ដើមច្រៀងរួមគ្នាជាបួនផ្នែក ដោយមានឪពុកច្រៀងម៉េទ្បូឌី ម្ដាយច្រៀងអ័លតូ ដៃគូខ្ញុំច្រៀងសម្លេងខ្ពស់ ហើយខ្ញុំច្រៀងសម្លេងទាប ។

ព្រះវិញ្ញាណបានគង់នៅក្នុងបន្ទប់យ៉ាងពេញទំហឹង ។ ពេលដែលយើងច្រៀងនៅវគ្គទីបី មនោសញ្ចេតនារបស់គាត់បានសំដែងចេញមក ហើយសម្លេងរបស់គាត់បានឈប់នៅពេលដែលយើងបន្តច្រៀង ៖

*ខ្ញុំត្រូវការទ្រង់ជានិច្ច*
*ទោះខ្ញុំអរ ឬខ្ញុំព្រួយ ។*
*ឱសូមទ្រង់មកប្រោសប្រាណ*
*ហើយគង់នៅជាប់ជាមួយ*
*ខ្ញុំ ត្រូវការឱព្រះយេស៊ូវ*
*ត្រូវការនឹងទ្រង់ជានិច្ច*
*សូមផ្ដល់ព្រះពរមកខ្ញុំផង*
*ខ្ញុំមកពឹងព្រះអង្គ !*

នៅពេលដែលយើងបានបញ្ចប់វគ្គទីបួនជាវគ្គចុងក្រោយ គាត់កំពុងតែយំខ្សឹបខ្សួល ។ ស្វាមីគាត់បានព្យាយាមលួងចិត្តគាត់ ហើយនៅទីបញ្ចប់គាត់អាចទប់អារម្មណ៍បាន ។ គាត់បានមើលចំភ្នែករបស់ខ្ញុំ ហើយនិយាយថា « ខ្ញុំត្រូវការធ្វើបុណ្យជ្រមុជទឹក » ។

ពិធីបុណ្យជ្រមុជទឹកសម្រាប់ គង់ គុកវ៉ុន និង ប៉ាក់ ម៉ីជុង នៅរសៀលថ្ងៃអាទិត្យនោះ ជាបទពិសោធន៍ខាងវិញ្ញាណដ៏ធំបំផុតនៅក្នុងបេសកកម្មរបស់ខ្ញុំ ។ កូនៗរបស់ពួកគេបានចូលរួមនៅក្នុងកម្មវិធីនោះ ហើយមានសមាជិកមូលដ្ឋានជាច្រើនបានចូលរួម ដើម្បីសម្ដែងការគាំទ្រសម្រាប់ គ្រួសារផ្លាស់ប្រែចិត្តជឿថ្មីបំផុតនៅក្នុងរួងរបស់ពួកគេ ។ ខ្ញុំ និងដៃគូរបស់ខ្ញុំបានផ្ដល់ចម្រៀងពិសេសបទ ៖ « ខ្ញុំត្រូវការទ្រង់ជានិច្ច » ។

នៅទីបំផុត ខ្ញុំបានបញ្ចប់បេសកកម្មរបស់ខ្ញុំ ហើយបានត្រឡប់មកផ្ទះវិញ ។ បន្ទាប់ពីចូលរៀននៅមហាវិទ្យាល័យបានមួយឆ្នាំ ខ្ញុំបានត្រឡប់ទៅប្រទេសកូរ៉េសម្រាប់កម្មសិក្សារដូវក្ដៅ ហើយនៅរៀងរាល់ចុងសប្ដាហ៍ ខ្ញុំបានផ្ដោតលើការទៅលេងមិត្តភក្ដិ និងក្រុមគ្រួសារពិសេសជាច្រើនដែលខ្ញុំបានជួបនៅក្នុងបេសកកម្មរបស់ខ្ញុំ ។ ពីរបីសប្ដាហ៍បន្ទាប់មក ខ្ញុំបានត្រឡប់ទៅបាល់សាន ហើយបានជួបជាមួយនឹងក្រុមគ្រួសារដ៏ពិសេសនេះ ។ នៅពេលដែលមកដល់ផ្ទះរបស់ពួកគេ ខ្ញុំសម្គាល់ឃើញថាមានបាត់មនុស្សម្នាក់ — កូនប្រុសរបស់ពួកគេ ។ ដោយមានកែវភ្នែករលីងរលោង ប៉ាក់ ម៉ីជុងបានប្រាប់ដំណឹងមកខ្ញុំថា ៖ ជម្ងឺមហារីករបស់កូនប្រុសគាត់បានត្រឡប់មកវិញ ហើយគាត់បានទទួលមរណភាពនៅអាយុ 14 ឆ្នាំ ។

នៅពេលដែលខ្ញុំព្យាយាមសម្ដែងការរំលែកទុក្ខ ហើយដោះស្រាយជាមួយនឹងការឈឺចាប់ដែលខ្ញុំមាន គង់ គុកវ៉ុនបានអះអាងនឹងខ្ញុំថា អ្វីគ្រប់យ៉ាងនឹងប្រសើរឡើង ។ ពួកគាត់ស្រឡាញ់ដំណឹងល្អ បានទៅព្រះវិហារដោយស្មោះត្រង់ ហើយកំពុងទន្ទឹងរង់ចាំដល់ថ្ងៃដែលក្រុមគ្រួសាររបស់គាត់អាចផ្សារភ្ជាប់ជាមួយគ្នា សម្រាប់ពេលដ៏នៅអស់កល្បជានិច្ច នៅក្នុងព្រះវិហារបរិសុទ្ធនៃទីក្រុងសេអ៊ូល ប្រទេសកូរ៉េ ។ ថ្វីបើពួកគេមានការឈឺចាប់ក្នុងដួងចិត្តក្ដី ក្រុមគ្រួសារនេះបានដឹងថា ពួកគេនឹងជួប គង់ សុងគុន និងបានរួបរួមជាថ្មីម្ដងទៀត ។ ប៉ាក់ ម៉ីជុងក៏ប្រាប់ខ្ញុំផងដែរថា ការច្រៀងទំនុកតម្កើងជាប្រចាំ ជួយគាត់ឲ្យរកឃើញកម្លាំងដើម្បីស៊ូទ្រាំ និងមាននូវអារម្មណ៍សុខសាន្តដែលព្រះវិញ្ញាណនាំមក ។

នៅពេលដែលខ្ញុំចាកចេញពីផ្ទះពួកគេនាល្ងាចនោះ ខ្ញុំបានគិតជាថ្មីម្ដងទៀតលើពាក្យទំនុកតម្កើងសំណព្វចិត្តរបស់ ប៉ាក់ ម៉ីជុង ។ ខ្ញុំមានអំណរគុណ ដែលព្រះវរបិតាសួគ៌បានប្រទានពរដល់គ្រួសារនេះ ជាមួយនឹងភាពសុខសាន្តបន្ទាប់ពីការស្លាប់របស់គង់ សុងគុន ហើយជាពិសេស ខ្ញុំមានអំណរគុណសម្រាប់តួនាទីរបស់ព្រះវិញ្ញាណនៅក្នុងប៉ាក់ ម៉ីជុងដែលអនុញ្ញាតឲ្យគ្រួសារនេះ មានភាពសក្ដិសមសម្រាប់ពរជ័យដ៏អស់កល្បនៃព្រះវិហារបរិសុទ្ធ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*

**ទំនុកតម្កើង លួងលោមចិត្ត ដល់អ្នកដែលមានទុក្ខព្រួយ**

« ទេសនកថាដ៏អស្ចារ្យបំផុតមួយចំនួន គឺត្រូវបានផ្សាយ តាមរយៈការច្រៀងទំនុកតម្កើង ។ ទំនុកតម្កើងធ្វើឲ្យយើងមានការប្រែចិត្ត និងធ្វើកិច្ចការល្អ ស្ថាបនាទីបន្ទាល់ និងសេចក្ដីជំនឿ លួងលោមចិត្តដល់អ្នកនឿយហត់ លួងចិត្តអ្នកមានទុក្ខព្រួយ និងបំផុសគំនិតយើងឲ្យស៊ូទ្រាំដល់ទីបំផុត » ។

« អារម្ភកថាគណៈប្រធានទីមួយ » *ទំនុកតម្កើង* ix ។



**ដោយប្រធាន**
**ប៊យដ៍ ឃេ ផាកកឺ**
ប្រធានកូរ៉ុម
នៃពួកសាវកដប់ពីរនាក់

# ពលិកកម្មដ៏ ឥតកំណាញ់ និងដ៏ពិសិដ្ឋរបស់ ព្រះអង្គសង្គ្រោះ

*ព្រះអម្ចាស់តែងតែគង់នៅទីនោះ ។ ទ្រង់បានរងទុក្ខ និងសងទោសកំហុស បើអ្នកព្រមទទួលយកទ្រង់ ជាព្រះប្រោសលោះរបស់អ្នក ។*



យើងទាំងអស់គ្នារស់នៅក្នុងបំណុលខាងវិញ្ញាណ ។ ដោយហេតុដូច្នេះហើយ បញ្ជីបំណុលចេះតែកើនឡើងៗ ។ បើអ្នកសងបំណុលនោះជាបន្តបន្ទាប់ នោះអ្នកមានការបារម្ភតែបន្តិចបន្តួចប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន អ្នកចាប់ផ្ដើមរៀនពីវិន័យ ហើយដឹងថាមានថ្ងៃទូទាត់មួយនៅខាងមុខ ។ ចូររៀនដើម្បីរក្សាការសងបំណុលខាងវិញ្ញាណរបស់អ្នក ឲ្យបានទៀងទាត់ ជាជាងទុកឲ្យវាប្រមូលការប្រាក់ និងប្រាក់ពិន័យ ។

ដោយសារអ្នកត្រូវបានសាកល្បង នោះគឺត្រូវបានរំពឹងទុកជាមុនថា អ្នកនឹងធ្វើខុសខ្លះៗ ។ ខ្ញុំសន្មតថា អ្នកបានធ្វើនូវរឿង ដែលអ្នកសោកស្ដាយក្នុងជីវិត រឿងដែលអ្នកមិនអាចទាំងសុំនូវការអភ័យទោសផង ហេតុនោះហើយអ្នកស្ពាយបន្ទុកមួយ ។ ឥឡូវនេះដល់ពេលត្រូវប្រើពាក្យ *កំហុស* ដែលអាចធ្វើឲ្យប្រឡាក់ដូចជាទឹកខ្មៅដែលជិតជាប់ហើយមិនងាយនឹងលុបចេញបាន ។ លទ្ធផលរបស់កំហុស គឺការខកចិត្តសោកស្ដាយចំពោះការបាត់បង់ពរជ័យ និងឱកាស ។

បើអ្នកកំពុងតែពុះពារជាមួយនឹងកំហុស នោះអ្នកមិនខុសអ្វីពីប្រជាជននៃព្រះគម្ពីរមរមននោះទេ ជាអស់អ្នកដែលព្យាការីបាននិយាយថា « ដោយអំពើទុច្ចរិតរបស់គេ នោះសាសនាចក្របានចាប់ផ្ដើម ចុះអន់ថយហើយ ពួកគេបានចាប់ផ្ដើមមិនជឿវិញ្ញាណ នៃការព្យាករណ៍ និងវិញ្ញាណនៃវិវរណៈ ហើយសេចក្ដីជំនុំជំរះទាំងឡាយនៃព្រះបានសម្លឹងមើលគេចំពីមុខ » ( ហេលេមិន 4:23 ) ។

ជាញឹកញាប់ យើងព្យាយាមដោះស្រាយបញ្ហាដោយការប្រាប់គ្នាទៅវិញទៅមក និងប្រាប់ខ្លួនយើងថាវាមិនអី

ខាងឆ្វេង ៖ ការបង្ហាញពីរូបភាព photos.com/Thinkstock; ខាងស្ដាំ ៖ *ព្រះគ្រីស្ទ នៅសួនច្បារគែតសេម៉ានី* ដោយ អារី ស្កេហ្វឺ រូបភាពសារៈមន្ទីរ Dordrechts នៅ ក្រុង Dordrecht ប្រទេស ប្រទេសហូឡង់ ហាមថតចម្លង; ផ្ទៃខាងក្រោយពី iStock/Thinkstock





ទេ ។ តែនៅជ្រៅខាងក្នុង យើងមិនជឿដល់វាទេ ។ ក៏មិនជឿខ្លួនយើងថា យើងនិយាយបែបនេះដែរ ។ យើងដឹងច្បាស់ជាងនោះ ។ វាពិតជាមានបញ្ហា !

ព្យាការីទាំងឡាយតែងបង្រៀនពីការប្រែចិត្ត ។ អាលម៉ាបានមានប្រសាសន៍ថា « មើលចុះទ្រង់នឹងយាងមក ប្រោសលោះអស់អ្នកណាដែលនឹងទទួលបុណ្យជ្រមុជទឹក ចំពោះការប្រែចិត្តស្របតាម សេចក្ដីជំនឿជឿដល់ព្រះនាមទ្រង់ » ( អាលម៉ា 9:27 ) ។

អាលម៉ាបានប្រាប់កូនប្រុសដ៏ចចេសរបស់គាត់ដោយចំៗថា « ឥឡូវនេះការប្រែចិត្តពុំអាចមានដល់មនុស្សទេ លើកលែងតែមានទោស ដែលនៅអស់កល្បជានិច្ច ដូចជាជីវិតនៃព្រលឹងដែរ ដែលបានភ្ជាប់ទុកផ្ទុយទៅនឹងផែនការនៃសុភមង្គល » ( អាលម៉ា 42:16 ) ។

មានគោលបំណងសំខាន់ពីរសម្រាប់ជីវិតរមែងស្លាប់ ។ ទីមួយគឺ ដើម្បីទទួលរូបកាយដែលអាច ត្រូវបានសំអាត និងលើកតម្កើងហើយរស់នៅរហូត ។ គោលបំណងទីពីរគឺដើម្បីត្រូវបានសាកល្បង ។ ក្នុងការសាកល្បង យើងពិតជានឹងធ្វើកំហុស ។ តែបើយើងនឹងមានកំហុស យើងអាចរៀនពីកំហុសរបស់យើង ។ « បើយើងថាយើងមិនដែលធ្វើបាបសោះ នោះឈ្មោះថាយើងធ្វើឲ្យទ្រង់ទៅជាអ្នកកុហកវិញ ហើយព្រះបន្ទូលទ្រង់មិននៅក្នុងយើងទេ » ( យ៉ូហានទី 1 1:10 ) ។

ប្រហែលជាអ្នកអាចមានអារម្មណ៍ទន់ខ្សោយនៅក្នុងគំនិត និងរូបកាយ ហើយមានបញ្ហា ឬមានបន្ទុកដោយទម្ងន់នៃបំណុលខាងវិញ្ញាណដែលត្រូវ « ហួសកំណត់ » ។ ពេលអ្នកជួបប្រទះនឹងគ្រានៃការត្រិះរិះដោយស្ងប់ស្ងាត់ទាំងនោះ ( ដែលយើងភាគច្រើនព្យាយាមគេចវេះ ) តើមានរឿងដែលមិនទាន់បានដោះស្រាយ មួយចំនួនដែលរំខានអ្នកឬទេ ? តើអ្នកមានវិប្បដិសារីណាមួយក្នុងមនសិការរបស់អ្នកទេ ? តើអ្នកនៅតែមានកំហុសចំពោះរឿងតូចតាច ឬធំក្នុងកម្រិតណាមួយទេ ?

ជាញឹកញាប់ណាស់ យើងទទួលសំបុត្រពីពួកអ្នកដែលបានធ្វើកំហុសដ៏ធំ ឬមានបន្ទុកធ្ងន់ក្រៃលែង ។ ពួកគេទទូចថា ៖ « តើខ្ញុំអាចទទួលបានការអភ័យទោសទេ ? តើខ្ញុំអាចផ្លាស់ប្ដូរបានទេ ? » ចម្លើយគឺបាន !

សាវកប៉ុលបានបង្រៀន ពួកកូរិនថូសថា « ដ្បិតគ្មានសេចក្ដីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្ដីល្បួង ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្ដីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចនឹងទ្រាំបាន » ( កូរិនថូសទី 1 10:13 ) ។

ដំណឹងល្អបង្រៀនយើងថា ការបានធូរស្រាលពីទារុណកម្ម និងកំហុសអាចទទួលបានតាមរយៈការប្រែចិត្ត ។ លើកលែងតែពួកអ្នកមួយចំនួនតូច — ដែលបានក្បត់ទៅចូលរួមជាមួយអារក្សសាតាំង ក្រោយពីការដឹងនូវភាពពេញលេញថា គ្មានទម្លាប់ គ្មានការញៀន គ្មានការបះបោរ គ្មានការរំលង គ្មានការបំពានតូច ឬធំណា ដែលរួចផុតពីការសន្យានៃការអភ័យទោសដ៏ពេញលេញនោះឡើយ ។ មិនថាមានអ្វីកើតឡើងក្នុងជីវិតអ្នកនោះទេ ព្រះអម្ចាស់បានរៀបចំផ្លូវសម្រាប់ឲ្យអ្នកត្រឡប់មកវិញ បើអ្នកនឹងស្ដាប់តាមការបំផុសគំនិតពីព្រះវិញ្ញាណបរិសុទ្ធ ។

អ្នកខ្លះពេញទៅដោយការជម្រុញដ៏បង្ខំមួយ ជាការល្បួងមួយដែលវិលចុះឡើងក្នុងគំនិត ប្រហែលរហូតដល់ក្លាយជាទម្លាប់ បន្ទាប់មកជាការញៀន ។ យើងងប់ងល់នឹងការរំលង និងអំពើបាបខ្លះ និងភាពសមហេតុសមផលខ្លះផងដែរ ដែលយើងមិនមានកំហុសទេ ដោយព្រោះយើងកើតមកក្នុងភាពនោះ ។ យើងក្លាយជាជាប់អន្ទាក់ ហើយដោយហេតុនេះ វានាំមកនូវការឈឺចាប់ និងទារុណកម្មដែលមានតែព្រះអង្គសង្គ្រោះប៉ុណ្ណោះអាចព្យាបាលបាន ។ អ្នកមានអំណាចដើម្បីបញ្ឈប់ និងត្រូវបានប្រោសលោះ ។

**សាតាំងវាយប្រហារមកលើក្រុមគ្រួសារ**

មានម្ដងនោះ ប្រធាន ម៉ារ៉ុន ជី រ៉មនី ( ឆ្នាំ 1897–1988 ) បានប្រាប់ខ្ញុំថា « ចូរកុំគ្រាន់តែប្រាប់ពួកគេ ដើម្បីពួកគេអាចយល់ តែសូមប្រាប់ពួកគេ ដើម្បីពួកគេមិនអាចយល់ខុសវិញ » ។

នីហ្វៃបាននិយាយថា « ត្បិតព្រលឹងខ្ញុំត្រេកអរចំពោះការច្បាស់លាស់ ត្បិតដោយរបៀបនេះហើយ ដែលព្រះអម្ចាស់

ដ៏ជាព្រះទ្រង់ បានធ្វើកិច្ចការនៅក្នុងចំណោមកូនចៅមនុស្ស ។ ត្បិតព្រះអម្ចាស់ដ៏ជាព្រះ ទ្រង់បានប្រទានពន្លឺដល់យោបល់ » ( នីហ្វៃទី 2 31:3 ) ។

ដូច្នេះចូរស្ដាប់ ! ខ្ញុំនឹងនិយាយដោយច្បាស់លាស់ដូចជាមនុស្សម្នាក់ដែលត្រូវបានហៅ និងមានកាតព្វកិច្ចដើម្បីធ្វើដូច្នេះ ។

អ្នកដឹងថាមានបច្ចាមិត្ត ។ ព្រះគម្ពីរកំណត់ន័យពីវាក្នុងពាក្យទាំងនេះថា ៖ « សត្វពស់ពីដើមនោះដែលជាអារក្ស . . . ដែលជាបិតានៃសេចក្ដីកុហក » ( នីហ្វៃទី 2 2:18 ) ។ វាត្រូវបានបណ្ដេញចេញតាំងពីដើមមក ( សូមមើល គ និង ស 29:36–38 ) ហើយមិនបានទទួលរូបកាយរមែងស្លាប់ទេ ។ វាបានស្បថថានឹងបង្អាក់ « ផែនការនៃសុភមង្គលដ៏មហិមា » ( អាលម៉ា 42:8 ) ហើយក្លាយជាខ្មាំងសត្រូវដល់គ្រប់ទាំងសេចក្ដីសុចរិត ។ វាផ្ដោតការវាយលុករបស់វាលើក្រុមគ្រួសារ ។

អ្នករស់នៅក្នុងជំនាន់មួយដែលបញ្ហានៃរូបអាសគ្រាម កំពុងតែរាលដាលទូទាំងពិភពលោក ។ វាពិបាកនឹងគេចពីវា ។ រូបអាសគ្រាម ផ្ដោតទៅលើផ្នែកនៃធម្មជាតិរបស់អ្នក ដែលតាមរយៈផ្នែកនេះ អ្នកមានអំណាចដើម្បីបង្កើតជីវិត ។

ការផ្ដេកផ្ដួលទៅលើរូបអាសគ្រាម នាំទៅកាន់ការលំបាក ការលែងលះ រោគា និងបញ្ហាជាច្រើនប្រភេទ ។ គ្មានផ្នែកណាមួយរបស់វា ដែលគ្មានទោសនោះទេ ។ ការប្រមូលវាទុក មើលវា ឬយកវាក្នុងទម្រង់ណាក៏ដោយ គឺដូចជាទុកពស់ពិសនៅក្នុងកាបូបស្ពាយរបស់អ្នកអញ្ចឹង ។ វាស្មើនឹងការដាក់ខ្លួនអ្នកឲ្យពស់ពិសដ៏សាហាវ ចឹកស្លាប់ខាងវិញ្ញាណដែលមិនអាចជៀសរួចដែរ ។ ដោយពិភពលោកបែបនេះ នោះមនុស្សម្នាក់អាចងាយយល់ថា អ្នកជិតនឹងអាចប្រឈមជាមួយវាបាន ដែលស្ទើរតែឥតទោស ក្នុងការអានវា មើលវាដោយមិនបានដឹងពីលទ្ធផលដ៏អាក្រក់ទាំងឡាយ ។ បើការនេះពិពណ៌នាពីអ្នក ខ្ញុំសូមព្រមានអ្នកថាបញ្ឈប់វាទៅ ។ បញ្ឈប់វាឥឡូវនេះភ្លាមទៅ !

ព្រះគម្ពីរមរមនបង្រៀនថាគ្រប់ « មនុស្សលោកបានប្រៀនប្រដៅគ្រប់គ្រាន់ឲ្យដឹងខុស និង ត្រូវ » ( នីហ្វៃទី 2 2:5 ) ។ វារួមទាំងអ្នកដែរ ។ អ្នកដឹងនូវអ្វីដែលត្រូវ និងអ្វីដែលខុស ។ ចូរប្រុងប្រយ័ត្នកុំប្រព្រឹត្តិរំលងនឹងព្រះបញ្ញត្តិនោះឲ្យសោះ ។

ទោះជាកំហុសភាគច្រើន អាចត្រូវបានសារភាព ដោយសម្ងាត់ទៅកាន់ព្រះក្ដី ក៏មាននូវការរំលងមួយចំនួនដែលតម្រូវ



*មានតែមួយអង្គនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រមនុស្សទាំងអស់ ដែលគ្មានទោសសោះដែលមានអំណាចនឹងធ្វើឲ្យធួនដល់អំពើបាប និងការរំលងរបស់មនុស្សទាំងអស់ ។*

ច្រើនជាងនោះ ដើម្បីទទួលបានការអភ័យទោស ។ បើកំហុសរបស់អ្នកធ្ងន់ធ្ងរ សូមជួបប៊ីស្សពអ្នក ។ បើមិនដូច្នេះទេ ការសារភាពធម្មតាដោយស្ងៀមស្ងាត់ និងដោយផ្ទាល់ខ្លួននឹងធ្វើបាន ប៉ុន្តែសូមចាំថាព្រឹកព្រលឹមនៃការអភ័យទោសដ៏អស្ចារ្យនោះ អាចមិនមកទាំងអស់ក្នុងពេលតែមួយនោះទេ ។ បើអ្នកជំពប់ជើងដួលចុះលើកទីមួយ សូមក្រោកឈរឡើងវិញ ការយកឈ្នះការបាក់ទឹកចិត្ត ជាផ្នែកមួយនៃការសាកល្បង ។ សូមកុំបោះបង់ ។ ហើយដូចខ្ញុំបានផ្ដល់ដំបូន្មានពីមុនថា ពេលអ្នកសារភាព និងបោះបង់អំពើបាបទាំងឡាយរបស់អ្នក ហើយសូមកុំក្រឡេកមើលទៅក្រោយ ។

## ព្រះអង្គសង្គ្រោះបានរងទុក្ខ ជំនួសអំពើបាបរបស់យើង

ព្រះអម្ចាស់តែងតែគង់នៅទីនោះ ។ ទ្រង់បានរងទុក្ខ និងសងទោសកំហុស បើអ្នកព្រមទទួលយកទ្រង់ជាព្រះប្រោសលោះរបស់អ្នក ។

ព្រោះយើងជាមនុស្សរមែងស្លាប់ យើងអាចមិនយល់ទាំងស្រុងពី *របៀប* ដែលព្រះអង្គសង្គ្រោះទ្រង់ បានបំពេញពលិកម្មដ៏ធួនរបស់ទ្រង់នោះទេ ។ ប៉ុន្តែ សម្រាប់ពេលឥឡូវនេះ *របៀប* ដែល ទ្រង់រងទុក្ខគឺមិនសំខាន់ដូចជា *មូលហេតុ* ដែលទ្រង់រងទុក្ខនោះទេ ។ តើហេតុអ្វីទ្រង់ធ្វើការណ៍នោះ សម្រាប់អ្នក សម្រាប់ខ្ញុំ សម្រាប់មនុស្សគ្រប់រូប ? ទ្រង់បានធ្វើបែបនេះ ដោយព្រោះក្ដីស្រឡាញ់ចំពោះព្រះជាព្រះវរបិតា និងចំពោះមនុស្សគ្រប់គ្នា ។ « គ្មានអ្នកណាមានសេចក្ដីស្រឡាញ់ធំជាងនេះ គឺដែលអ្នកណានឹងប្ដូរជីវិត ជំនួសពួកសម្លាញ់របស់ខ្លួននោះទេ » ( យ៉ូហាន 15:13 ) ។

ក្នុងសួនច្បារ គែតសេម៉ានី ព្រះគ្រីស្ទបានចេញពីពួកសាវករបស់ទ្រង់ទៅអធិស្ឋាន ។ អ្វីដែលបានកើតឡើងគឺហួសពីអំណាចរបស់យើងដើម្បីយល់ដឹង ! តែយើងពិតជាដឹងថាទ្រង់បានសម្រេចដង្វាយធួន ។ ទ្រង់ព្រមលើកដាក់លើអង្គទ្រង់នូវកំហុស និងអំពើបាប មន្ទិលសង្ស័យ និងការភ័យខ្លាចនៃពិភពលោកទាំងមូល ។ ទ្រង់បានរងទុក្ខជំនួសយើង ដើម្បីយើងមិនបាច់ត្រូវរងទុក្ខ ។ មនុស្សរមែងស្លាប់ជាច្រើនបានរងទារុណកម្ម ហើយស្លាប់ជាការស្លាប់ដ៏ឈឺចាប់ និងគួរឲ្យខ្លាចក្រៃលែង ។ តែការឈឺចាប់របស់ទ្រង់លើសពីការឈឺចាប់ទាំងអស់នោះទៀត ។

ក្នុងវ័យរបស់ខ្ញុំ ខ្ញុំបានដឹងថា អ្វីជាការឈឺចាប់ខាងរូបកាយ ហើយវាពុំមែនជាអ្វីដែលសប្បាយទេ ! គ្មាននរណាម្នាក់ចាកចេញពីជីវិតនេះទៅ ដោយមិនបានរៀនអ្វីសោះពីការរងទុក្ខនោះទេ ។ តែទារុណកម្មផ្ទាល់ខ្លួនដែលខ្ញុំមិនអាចទ្រាំទ្របាន នោះគឺពេលខ្ញុំបានដឹងថា ខ្ញុំបានធ្វើឲ្យមនុស្សដទៃទៀតរងទុក្ខ ។ ពេលនោះហើយ ដែលខ្ញុំបានយល់បន្តិចពីការឈឺចាប់ដែលព្រះអង្គសង្គ្រោះ បានជួបក្នុងសួនច្បារគែតសេម៉ានី ។

ការរងទុក្ខរបស់ទ្រង់ គឺខុសពីការរងទុក្ខផ្សេងទៀតទាំងអស់ ឬដោយព្រោះទ្រង់បានយកដាក់លើអង្គទ្រង់ នូវទោសទាំងអស់ដែលធ្លាប់មានលើគ្រួសារមនុស្សជាតិ ។ សូមស្រមៃពីការណ៍នោះ ! ទ្រង់គ្មានជំពាក់បំណុលដើម្បីនឹងសងសោះឡើយ ។ ទ្រង់ពុំបានធ្វើខុសសោះឡើយ ។ ទោះយ៉ាងណា ការបូកបញ្ចូលគ្នាទាំងអស់នៃកំហុស ទុក្ខព្រួយ ការឈឺចាប់ និងសេចក្ដីទាបថោក ទារុណកម្មទាំងខាង ផ្លូវចិត្ត អារម្មណ៍ និង ផ្លូវកាយទាំងអស់ ដែលមនុស្សលោកស្គាល់ — គឺទ្រង់បានភ្លក់នូវបទពិសោធន៍ទាំងអស់ ។ មានតែមួយអង្គនៅក្នុងកំណត់ត្រាប្រវត្តិសាស្ត្រមនុស្សទាំងអស់ ដែលគ្មានទោសសោះដែលមានអំណាចនឹងធ្វើឲ្យធួនដល់បាប និងការរំលងរបស់មនុស្សទាំងអស់ ហើយអាចស៊ូនឹងការឈឺចាប់ ដែលមានពេលធ្វើដង្វាយធួននោះ ។

ទ្រង់ព្រមលះបង់ជីវិតទ្រង់ ហើយមានបន្ទូលដ៏មានខ្លឹមសារថា « គឺយើងនេះហើយ ដែលទទួលយកអំពើបាបទាំងឡាយ នៃមនុស្សលោកមកលើខ្លួន » ( ម៉ូសាយ 26:23 ) ។ ទ្រង់ត្រូវបានគេឆ្កាង ទ្រង់បានសុគត ។ ពួកគេមិនអាចយកជីវិតពីទ្រង់ទេ ។ គឺទ្រង់ទេតើដែលព្រមសុគតនោះ ។

**ការអភ័យទោសដ៏ពេញលេញ គឺអាចធ្វើឡើងបាន**

បើអ្នកបានដួលចុះ ឬសូម្បីវង្វេងមួយរយៈ បើអ្នកមានអារម្មណ៍ថាឥឡូវនេះបច្ចាមិត្តសង្កត់អ្នកជាប់នោះ អ្នកអាចឈានទៅមុខដោយជំនឿ និងដោយមិនវង្វេងទៅមកក្នុងលោកិយនេះទៀតឡើយ ។ មានពួកអ្នកដែលត្រៀមរួចជាស្រេច ដើម្បីដឹកនាំអ្នកឲ្យត្រឡប់ទៅភាពសុខសាន្ត និងសុវត្ថិភាពវិញ ។ ដូចដែលបានសន្យាក្នុងព្រះគម្ពីរថា សូម្បីព្រះគុណនៃព្រះបានមក « បន្ទាប់ពីអ្វីៗទាំងអស់ដែលយើងអាចធ្វើបាន » ( នីហ្វៃទី 2 25:23 ) ។ ចំពោះខ្ញុំ លទ្ធភាពក្នុងការសម្រេចបាននូវការណ៍នេះ គឺជាសេចក្ដីពិតដែលមានតម្លៃបំផុតដើម្បីដឹង ។

ខ្ញុំសូមសន្យាថា ព្រឹកព្រលឹមដ៏ស្រស់បំព្រងនៃការអភ័យទោស អាចមកដល់ ។ ពេលនោះ « សេចក្ដីសុខសាន្តរបស់ព្រះដែលហួសលើសពីអស់ទាំងគំនិត » ( ភីលីព 4:7 ) ចូលមកក្នុងជីវិតអ្នកម្ដងទៀត ជាអ្វីមួយដែលដូចជាព្រះអាទិត្យរះ ហើយអ្នកដូចជាទ្រង់ដែរ « នឹងលែងនឹកចាំពីអំពើបាបរបស់អ្នកទៀតជាដរាបទៅ » ( យេរេមា 31:34 ) ។ តើអ្នកនឹងដឹងដោយរបៀបណា ? អ្នកនឹងដឹង ! ( សូមមើល ម៉ូសាយ 4:1–3 ។ )

នោះជាអ្វីដែលយើងបង្រៀនដល់អ្នកដែលមានបញ្ហា ។ ទ្រង់នឹងលូកព្រះហស្ត ហើយដោះស្រាយបញ្ហា តែអ្នកត្រូវសងថ្លៃនោះវិញ ។ វាពុំបានមកដោយមិនធ្វើដូច្នោះឡើយ ។ ទ្រង់ជាអ្នកគ្រប់គ្រង មានន័យថាទ្រង់បានសងថ្លៃដែលចាំបាច់ តែទ្រង់ចង់ឲ្យអ្នកធ្វើនូវអ្វីដែលអ្នកគួរធ្វើ សូម្បីតែវាឈឺចាប់ក្ដី ។

ខ្ញុំស្រឡាញ់ព្រះអម្ចាស់ ហើយខ្ញុំស្រឡាញ់ព្រះវរបិតាដែលបានបញ្ជូនទ្រង់មក ។ បន្ទុកនៃការខកចិត្ត អំពើបាប និងកំហុសរបស់យើង អាចដាក់នៅចំពោះព្រះភ័ក្រទ្រង់ និងក្នុងលក្ខខណ្ឌដ៏សប្បុរសរបស់ទ្រង់ គ្រប់ចំណុចនីមួយៗនៅក្នុងបញ្ជី អាចត្រូវបានបានគូសថា « បានបង់យ៉ាងពេញថ្លៃ » ។

« ព្រះយេហូវ៉ាទ្រង់មានបន្ទូលថា មកចុះយើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ » ។ នេះគឺជាអ្វីដែលអេសាយ បានបន្តថា « បើសិនជាឯងរាល់គ្នាស្ម័គ្រចិត្តតាមហើយស្ដាប់បង្គាប់ » ( អេសាយ 1:18–19 ) ។

**ចូរមកឯទ្រង់**

បទគម្ពីរដែលថា « ឲ្យចេះមានប្រាជ្ញានៅក្នុងយុវ័យរបស់កូនចុះ មែនហើយចូររៀននៅក្នុងយុវ័យរបស់កូន

ឲ្យចេះកាន់តាមព្រះបញ្ញត្តិទាំងឡាយនៃព្រះ » ( អាលម៉ា 37:35 ) ជាការអញ្ជើញដែលអមមកជាមួយនូវការសន្យានៃក្ដីសុខសាន្ត និងការការពារពីបច្ចាមិត្ត ។ « កុំឲ្យអ្នកណាមើលងាយអ្នក ដោយព្រោះនៅក្មេងនោះឡើយ ចូរធ្វើជាគំរូដល់ពួកអ្នកជឿ ដោយពាក្យសម្ដីកិរិយាប្រព្រឹត្ត សេចក្ដីស្រឡាញ់ សេចក្ដីជំនឿ និងសេចក្ដីបរិសុទ្ធ » ( ធីម៉ូថេទី 1 4:12 ) ។

កុំរំពឹងថាអ្វីទាំងអស់ នឹងដំណើរទៅដោយរលូនអស់មួយជីវិតអ្នកឡើយ ។ សូម្បីពួកអ្នកដែលរស់នៅដូចដែលគេគួររស់នៅ ក៏មានពេលខ្លះវានឹងពិបាកដែរ ។ ចូរប្រឈមនឹងឧបសគ្គនៃជីវិត ដោយសុទុដ្ឋិនិយម និងភាពប្រាកដប្រជា ហើយអ្នកនឹងមានភាពសុខសាន្ត និងជំនឿដើម្បីគាំទ្រអ្នកក្នុងពេលនេះ និងពេលអនាគត ។

ចំពោះអ្នកទាំងឡាយ ដែលមិនទាន់មានពរជ័យទាំងអស់ដែលអ្នកមានអារម្មណ៍ថាគឺជាតម្រូវការចាំបាច់ដែលអ្នកចង់បាន និងត្រូវការ ខ្ញុំជឿយ៉ាងមុតមាំថា គ្មានបទពិសោធន៍ ឬឱកាសណាដែលចាំបាច់ដល់ការប្រោសលោះ និងការសង្គ្រោះដែលនឹងបដិសេធអ្នកដែលរស់នៅដោយស្មោះត្រង់ឡើយ ។ ចូរបន្តរស់នៅដោយសក្ដិសម ត្រូវមានសង្ឃឹម អត់ធ្មត់ និងពេញដោយការអធិស្ឋាន ។ ការណ៍ទាំងឡាយមានផ្លូវមួយដើម្បីបានសម្រេច ។ អំណោយទានព្រះវិញ្ញាណបរិសុទ្ធ នឹងដឹកនាំសកម្មភាពរបស់អ្នក ។

បើអ្នកជាបុគ្គលម្នាក់ដែលកំពុងពុះពារជាមួយនឹងកំហុស ការខកចិត្ត ឬការក្រៀមក្រំ ដែលជាលទ្ធផលនៃកំហុសដែលអ្នកបានធ្វើ ឬពរជ័យដែលមិនទាន់មកដល់នោះ សូមអានការបង្រៀន ដែលជាការលើកទឹកចិត្ត ដែលមានក្នុងទំនុកតម្កើង « មកឯព្រះយេស៊ូវ » ។

*មកឯព្រះយេស៊ូវ អស់អ្នកដែលផ្ទុកធ្ងន់អើយ*
*នឿយព្រួយ ហើយបាក់ទឹកចិត្តព្រោះបាបកម្ម ។*
*ទ្រង់នឹងដឹកនាំអ្នក ទៅទីដ៏សុខសាន្ត*
*អ្នកទុកចិត្តទ្រង់អាចសម្រាក សម្រាក ។*

*មកឯព្រះយេស៊ូវ ទ្រង់ស្ដាប់អ្នកជានិច្ច*
*ទោះជាអ្នកវង្វេងក្នុងផ្លូវងងឹត*
*ទ្រង់នឹងដឹកនាំអ្នកដោយសេចក្ដីស្រឡាញ់*
*នាំពីងងឹត ទៅពន្លឺ ពន្លឺ ។*

*មកឯព្រះយេស៊ូវ ទ្រង់ឮអ្នកយ៉ាងពិត*
*បើអ្នកសុំក្ដីស្នេហ៍ ទ្រង់ដោយរាបសារ ។*
*ឱ ! អ្នកមិនដឹងថា ទេវតាគង់នៅជិត*
*នៅឯនគរភ្លឺខាងលើ ខាងលើ ?*[1]



ខាងឆ្វេង ៖ ការបង្ហាញពី PHOTOS.COM/THINKSTOCK; ខាងស្ដាំ ៖ សេចក្ដីលម្អិតពី *ទោះបើអំពើរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ* ដោយ ហាវើដ លីយ៉ុង មិនអាចថតចម្លងបាន

*បន្ទុកនៃការខកចិត្ត អំពើបាប និងកំហុសរបស់យើង អាចដាក់នៅចំពោះព្រះភ័ក្ត្រព្រះអម្ចាស់ និងក្នុងលក្ខខណ្ឌដ៏សប្បុរសរបស់ទ្រង់ គ្រប់ចំណុចនីមួយៗនៅក្នុងបញ្ជីអាចត្រូវបានបានគូសថា « បានបង់ពេញថ្លៃ » ។*

ខ្ញុំប្រកាស ធ្វើជាសាក្សីពិសេសរបស់ព្រះអម្ចាស់ យេស៊ូវគ្រីស្ទជាមួយនឹងបងប្អូនប្រុសជាពួកសាវករបស់ខ្ញុំ ។ សាក្សីនោះត្រូវបានបញ្ជាក់សាជាថ្មី គ្រប់ពេលដែលខ្ញុំបានទទួលអារម្មណ៍នៅក្នុងខ្លួនខ្ញុំ ឬនៅក្នុងឥទ្ធិពលលាងសម្អាតផ្សេងទៀត អំពីពលិកម្មដ៏ពិសិដ្ឋរបស់ទ្រង់ ។ សាក្សីរបស់ខ្ញុំ និងសាក្សីនៃបងប្អូនប្រុសរបស់ខ្ញុំ ជាការពិត ។ យើងស្គាល់ព្រះអម្ចាស់ ។ ទ្រង់មិនមែនជាមនុស្សចម្លែកទេ ចំពោះពួកព្យាការី អ្នកមើលឆុត និងអ្នកបើកសម្ដែងរបស់ទ្រង់ ។

ខ្ញុំយល់ថា អ្នកមិនល្អឥតខ្ចោះនោះទេ ប៉ុន្តែអ្នកកំពុងតែធ្វើដំណើរនៅតាមផ្លូវនោះ ។ ចូរមានភាពក្លាហាន ។ សូមដឹងថា អ្នកដែលមានរូបរាងកាយ មានអំណាចលើអ្នកដែលគ្មាន ។[2] សាតាំងត្រូវបានបដិសេធពីរូបកាយ ដូច្នោះប្រសិនបើអ្នកប្រឈមជាមួយនឹងការល្បួង ចូរដឹងថាអ្នកមានអំណាចខ្លាំងជាងការល្បួងទាំងអស់នោះ ប្រសិនបើអ្នកនឹងអនុវត្តនូវសិទ្ធជ្រើសរើសដែលបាន ប្រទានឲ្យអ័ដាម និងអេវ៉ានៅក្នុងសួនច្បារ ហើយបានបន្តមកដល់ជំនាន់នេះ ។

ប្រសិនបើអ្នកឆ្ពោះទៅមុខដោយសេចក្ដីសង្ឃឹម និងបំណងដើម្បីធ្វើនូវអ្វីដែលព្រះអម្ចាស់សព្វព្រះទ័យឲ្យអ្នកធ្វើ — នោះគឺជាអ្វីដែលត្រូវបានរំពឹងទុក ។ ■

*ដកស្រង់ចេញពីសុន្ទរកថា « ការដឹងការពិតដ៏មានតម្លៃបំផុត » ដែលបានផ្ដល់នៅក្នុងការប្រជុំធម្មនិដ្ឋាន នៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ថ្ងៃទី 6 ខែ វិច្ឆិកា ឆ្នាំ 2011 ។ សម្រាប់អត្ថបទទាំងមូលជាភាសាអង់គ្លេស សូមចូលទៅកាន់គេហទំព័រ speeches.byu.edu ។*

**កំណត់ចំណាំ**
1. សូមមើល « មកឯព្រះយេស៊ូវ » *ទំនុកតម្កើង* ទំព័រ 64 ។
2. សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស៊្មីធ* ( ឆ្នាំ 2007 ), ទំព័រ 211 ។

# ច្រៀងទំនុកតម្កើងសំណព្វចិត្តរបស់អ្នក

ខ្ញុំទើបតែបានផ្ដល់កំណើតដល់កូនស្រី រ៉េបេការបស់យើង ។ ការសម្រាលកូនរបស់ខ្ញុំមានការពិបាកណាស់ ហើយខ្ញុំអស់កម្លាំងពីខ្លួនរលីង ។

ពេលដែល រ៉េបេកា ត្រូវបានដាក់នៅក្នុងរង្វង់ដៃរបស់ខ្ញុំ ខ្ញុំពោរពេញដោយអារម្មណ៍ថាខ្ញុំគួរតែច្រៀងទំនុកតម្កើងសំណព្វចិត្តរបស់ខ្ញុំគឺបទ « ខ្ញុំជាកូនរបស់ព្រះ » ( *ទំនុកដំកើង*, ទំព័រ 118 ) ។ ការឆ្លើយតបដំបូងរបស់ខ្ញុំគឺ « ទេ ខ្ញុំអស់កម្លាំងណាស់ ។ ខ្ញុំនឹងច្រៀងឲ្យនាងស្ដាប់នៅពេលក្រោយ » ។ ប៉ុន្ដែគំនិតនោះបានកើតមកម្ដងទៀត ។ ដូច្នេះ ទោះបីជាខ្ញុំអស់កម្លាំង ខ្ញុំបានបានចាប់ផ្ដើមច្រៀងនៅវគ្គទីមួយ ។ ស្វាមី និងម្ដាយរបស់ខ្ញុំបានចូលរួមនឹងខ្ញុំ ។

ពេលដែលយើងច្រៀងចប់ ខ្ញុំបានមានអារម្មណ៍ពិសេសនៅក្នុងបន្ទប់នោះ ។ សូម្បីតែវេជ្ជបណ្ឌិតដែលជំនាញ និងសោះអង្គើយ ក៏មានទឹកភ្នែកហូរចុះមកលើមុខគាត់ដែរ ។ គាត់បានអរគុណយើងសម្រាប់ការច្រៀងនូវចម្រៀងដ៏ពិរោះ ។ គាត់បាននិយាយថា ក្នុងកំឡុងឆ្នាំទាំងអស់ដែលគាត់បានសម្រាលទារកឲ្យគេ គាត់មិនដែលមានអារម្មណ៍ដូចដែលគាត់មាននៅពេលនោះទេ ។

ខ្ញុំបានគិតពីបទពិសោធន៍នោះ ហើយឆ្ងល់ថាតើខ្ញុំគួរតែស្វែងរកសីឌីនៃទំនុកតម្កើងនោះឲ្យគាត់ឬទេ ។ ជាអកុសល ខ្ញុំបានជាប់រវល់ជាមួយនឹងជីវិតហើយបានភ្លេចអំពីវា ។

ហើយថ្ងៃត្រួតពិនិត្យក្រោយពីការឆ្លងទន្លេរចរបស់ខ្ញុំក៏មកដល់ ។ ពេលដែលវេជ្ជបណ្ឌិតដើរចូលមកក្នុងបន្ទប់ ទឹកមុខរបស់គាត់បានស្រស់ថ្លាឡើងហើយគាត់បានឱបខ្ញុំ ។ គាត់បាននិយាយថា គាត់មិនអាចយកចម្រៀងនោះចេញពីគំនិតគាត់សោះហើយថែមទាំងព្យាយាមដើម្បីស្វែងរកបទនោះនៅលើអ៊ិនធើរណែតទៀតផង ដូច្នេះគាត់អាចច្រៀងវាឲ្យក្រុមគ្រួសារគាត់ស្ដាប់ ។ នៅពេលនោះហើយដែលព្រះវិញ្ញាណបរិសុទ្ធបានរំឭកខ្ញុំថា ខ្ញុំគួរតែរកច្បាប់ចម្លងនៃបទនោះឲ្យគាត់ ។ ខ្ញុំបានសន្យានឹងគាត់ថាខ្ញុំនឹងត្រឡប់មកវិញជាមួយនឹងបទចម្រៀងនៅក្នុងអាទិត្យនោះ ។

នៅយប់នោះ ខ្ញុំបានអធិស្ឋានសម្រាប់ជំនួយដើម្បីស្វែងរកទំនុកភ្លេងនៃចម្រៀងនោះ ដែលនឹងមានគុណភាពល្អបំផុតសម្រាប់គាត់ ។ នៅរសៀលថ្ងៃបន្ទាប់ ខ្ញុំបានបញ្ជាទិញសីឌីដែលមានបទនោះ ។ ពេលដែលវាមកដល់នៅក្នុងសំបុត្រពីរបីថ្ងៃបន្ទាប់មក ខ្ញុំមិនអាចរង់ចាំដើម្បីយកវាទៅឲ្យគាត់ទេ ។

គាត់មានការរំភើបយ៉ាងខ្លាំងក្នុងការទទួលយកវាហើយគាត់បានអរគុណខ្ញុំសម្រាប់អំណោយនោះ ។ គាត់បានប្រាប់ខ្ញុំថា គាត់មិនប្រាកដថាហេតុអ្វីទេ តែចម្រៀងនេះមានសារៈសំខាន់ណាស់សម្រាប់គាត់ដើម្បីចែកចាយវាជាមួយនឹងក្រុមគ្រួសាររបស់គាត់ ។ ពេលដែលយើងបន្តនិយាយគ្នា ខ្ញុំមិនត្រឹមតែបានចែកចាយជាមួយគាត់នូវក្ដីស្រឡាញ់របស់ខ្ញុំចំពោះបទនោះទេ ថែមទាំងចែកចាយទីបន្ទាល់របស់ខ្ញុំនៃការពិតដ៏សាមញ្ញដែលបទនោះបង្រៀនទៀតផង ។

នៅពេលដែលខ្ញុំបើកឡានត្រឡប់មកផ្ទះវិញនៅថ្ងៃនោះ ខ្ញុំមានអារម្មណ៍ពីក្ដីស្រឡាញ់នៃព្រះវរបិតាសួគ៌របស់យើងសម្រាប់បុត្រីម្នាក់របស់ទ្រង់ — គឺវេជ្ជបណ្ឌិតរបស់ខ្ញុំ ។ ទ្រង់ស្គាល់ និងស្រឡាញ់គាត់ហើយទ្រង់ចង់ឲ្យគាត់យល់ថាគាត់ក៏អាចត្រឡប់ទៅរស់នៅនឹងទ្រង់ម្ដងទៀតផងដែរ ។ ■

អែនជីឡា អូសិន សែនធើរ រដ្ឋអូហៃអូ ស.រ.អា

ពេលដែលយើងបានច្រៀងបទនោះចប់ វេជ្ជបណ្ឌិត ដែលជំនាញ និងសោះអង្គើយ ក៏ស្រក់ទឹកភ្នែកមកលើផ្ទៃមុខគាត់ដែរ ។



តើហេតុអ្វីបានជាព្រះវរបិតាសួគ៌មិនទតមើលការពារយើង និងព្រមានយើង « ជាដរាប » ដូច្នេះ ?



# ការសន្យាជាដរាបរបស់ទ្រង់

ពេលដែលខ្ញុំអង្គុយនៅក្នុងការប្រជុំសាក្រាម៉ង់ សញ្ជឹងគិតពីការអធិស្ឋានអំពីនំប៉ុង ពាក្យទាំងនោះបន្លសូត្រឡើងច្រំដែលៗនៅក្នុងគំនិតខ្ញុំថា ៖ « ប្រយោជន៍ឲ្យពួកគេអាច បានព្រះវិញ្ញាណរបស់ទ្រង់ គង់នៅជាមួយនឹងពួកគេជាដរាប » ( ម៉ូរ៉ូណៃ 4:3; គ និង ស 20:77 ) ។

វានិយាយថា « ជាដរាប » — មិនមែនគ្រាន់តែនៅពេលជាក់លាក់ណាមួយទេ ។ តើហេតុអ្វីបានជាបីបួនខែមុននេះ ខ្ញុំ និងស្វាមីខ្ញុំមិនត្រូវបានបំផុសគំនិតពីរបៀបដើម្បីការពារកូនប្រុសអាយុ 11 ឆ្នាំរបស់យើង ពីមុនគាត់ត្រូវស្លាប់ក្នុងគ្រោះថ្នាក់ចរាចរណ៍ដែលបណ្ដាលមកពីឡានបុកកង់ដូច្នេះ ? តើហេតុអ្វីបានជាព្រះវរបិតាសួគ៌មិនទតមើលការពារយើង និងព្រមានយើង « ជាដរាប » ដូច្នេះ ?

ខ្ញុំត្រូវបានបង្រៀននៅក្នុងថ្នាក់កុមារ ហើយជឿថាព្រះវិញ្ញាណបរិសុទ្ធនឹងការពារយើង ។ ទ្រង់នឹងប្រើសម្លេងតូចហៀង ដើម្បីមើលការខុសត្រូវដឹកនាំ និងព្រមានយើងពីគ្រោះថ្នាក់ ។ គំនិតនេះបានមាននៅក្នុងចិត្តរបស់ខ្ញុំតាំងពី បិន បានស្លាប់ទៅ ។ ខ្ញុំនឹកគាត់ខ្លាំងណាស់ ហើយដួងចិត្តខ្ញុំពេញដោយការយល់ដឹង និងសេចក្ដីសុខសាន្ត ។

តើសម្លេងព្រមានរបស់ខ្ញុំនៅឯណាទៅ ? តើព្រះវិញ្ញាណបរិសុទ្ធនៅឯណា ? ខ្ញុំមានអារម្មណ៍ថា យើងបានធ្វើល្អអស់ពីសមត្ថភាពដើម្បីក្លាយជាមនុស្សសុចរិត ។ យើងបានបង់ដង្វាយមួយភាគដប់ ចូលរួមការប្រជុំទាំងឡាយរបស់យើង និងបានបម្រើគ្រប់ពេលដែលយើងសូមឲ្យបម្រើ ។ យើងនៅឆ្ងាយពីភាពល្អឥតខ្ចោះ ប៉ុន្តែយើងធ្វើរាត្រីជួបជុំក្រុមគ្រួសារ និងសិក្សាព្រះគម្ពីរ ។ យើងកំពុងតែព្យាយាម ។

នៅពេលនោះ ខ្ញុំកំពុងអង្គុយនៅក្នុងថ្នាក់សមាគមសង្គ្រោះ ពេលដែលអ្នកគ្រូបានប្រាប់រឿងមួយពីសាច់ញាតិជិតដិតម្នាក់ ។ ពេលកំពុងរង់ចាំភ្លើងស្តុប សាច់ញាតិនោះបានមានអារម្មណ៍ខុសប្លែកមួយ ឲ្យនៅស្ងៀមកន្លែងដដែល ពេលដែលភ្លើងប្ដូរទៅពណ៌ខៀវ ។ គាត់ស្ដាប់តាមការបំផុសគំនិតនោះ ហើយស្ទើរតែភ្លាមនោះ រថយន្តដឹកទំនិញដ៏ធំមួយ បានមកលឿនស្លុងតាមផ្លូវប្រសព្វ បើកកាត់ភ្លើងក្រហម ។ បើគាត់មិនឮ ហើយស្ដាប់តាមសម្លេងនោះទេ គាត់ និងកូនៗគាត់ប្រហែលជាមានគ្រោះថ្នាក់ ឬក៏ត្រូវស្លាប់ហើយមើលទៅ ។

រឿងនេះ បានចាក់ទម្លុះទៅក្នុងដួងចិត្តខ្ញុំជាខ្លាំង តែខ្ញុំអង្គុយនៅលើកៅអីរបស់ខ្ញុំដោយទឹកភ្នែករៀបចំនឹងចេញពីបន្ទប់រៀនទៅហើយ ស្រាប់តែការលួងលោមដ៏អស្ចារ្យមួយបានមានមកលើខ្ញុំ ។ ខ្ញុំបានមានអារម្មណ៍នៃសេចក្ដីសុខសាន្ត ដែលជាព្រះវិញ្ញាណបរិសុទ្ធពិតជានៅជាមួយខ្ញុំមែន ។ ក្នុងករណីរបស់ខ្ញុំ ទ្រង់មិនបានគង់នៅទីនោះជាសម្លេងព្រមានទេ ប៉ុន្តែជាការលួងលោមចិត្តវិញ ។

ចាប់ពីពេលនៃគ្រោះថ្នាក់របស់ បិន ខ្ញុំបានមានអារម្មណ៍ថា មានកម្លាំងលើសពីកម្លាំងខ្ញុំផ្ទាល់ ហើយត្រូវបានកម្សាន្តចិត្តដោយក្ដីស្រឡាញ់របស់ព្រះវរបិតាសួគ៌ខ្ញុំ ។ ខ្ញុំបានខ្វះការយល់ដឹងម្ដងម្កាល ពីមូលហេតុដែលរឿងមួយចំនួនកើតឡើង ប៉ុន្តែខ្ញុំមិនដែលសង្ស័យពីក្ដីស្រឡាញ់ទ្រង់នោះទេ ។

ខ្ញុំមានជំនឿថា ព្រះជ្រាបអ្វីគ្រប់យ៉ាង ហើយទ្រង់នឹងមិនទុកខ្ញុំចោលដោយគ្មានការលួងលោមចិត្តនោះទេ ។ ព្រះវិញ្ញាណបរិសុទ្ធ ដើរតួនាទីជាច្រើននៅក្នុងជីវិតយើង ។ ទ្រង់អាចការពារយើង តែទ្រង់ក៏ដឹកនាំយើង លួងលោមយើង បង្រៀនយើង និងប្រទានការយល់ដឹង និងពរជ័យផ្សេងទៀត ។

ខ្ញុំបានរៀនថា ព្រះវរបិតាសួគ៌ពិតជារក្សាការសន្យារបស់ទ្រង់មែន ។ ទ្រង់បានគង់នៅជាមួយខ្ញុំ « ជាដរាប » ។ ■

រ៉ូប៊ីន កាសតើរ រដ្ឋយូថាហ៍ ស.រ.អា

រចនាដោយ ប្រាយអិន ប៊ីច



ខ្ញុំបានសម្គាល់ឃើញ ក្មេងប្រុសពីរនាក់អាយុប្រហែលប្រាំ និងប្រាំពីរឆ្នាំ កំពុងរត់តាមកន្លែងចតឡាននៅតាមហាង ដោយទឹកភ្នែកហូរមកលើមុខរបស់ពួកគេ ។

# ព្រះវិញ្ញាណបានខ្សឹបប្រាប់ខ្ញុំ

« អូ៎ ! ក្មេងៗ ! ត្រឡប់មកវិញ ! សម្លេងដ៏អង្វរមួយបានហៅឡើង ។

ខ្ញុំបានបែរទៅហើយបានសំគាល់ឃើញ ក្មេងប្រុសពីរនាក់អាយុប្រហែលប្រាំ និងប្រាំពីរឆ្នាំ កំពុងរត់តាមកន្លែងចតឡាននៅតាមហាង ដោយទឹកភ្នែកហូរមកលើមុខរបស់ពួកគេ ។ បុរសអ្នកលក់មើលទឹកមុខបារម្ភ ពេលដែលគាត់បានហៅពួកគេ ។

ពេលដែលត្រឡប់មករកឡានរបស់ខ្ញុំវិញ ព្រះវិញ្ញាណបានខ្សឹបប្រាប់ថា « អ្នកអាចជាជំនួយនៅទីនេះ » ។ ការខ្សឹបប្រាប់នោះស្ងាត់ តែច្បាស់ណាស់ ដែលមួយសន្ទុះក្រោយមកខ្ញុំបានរត់តាមកន្លែងចតឡានទៅរកក្មេងប្រុសទាំងពីរនាក់នោះ ។

ខ្ញុំឃើញថា ក្មេងប្រុសធំកំពុងឈរនៅជិតឡានពណ៌ត្នោតមួយ ។ ខ្ញុំបានទៅរកគេ ហើយលត់ជង្គង់ចុះនៅជិតគេ ។

« សួស្តី ។ » ខ្ញុំឈ្មោះ គ្រីស្ទីណា ។ តើប្អូនមិនអីទេឬ ?

គ្រាន់តែខ្ញុំសួរចប់ គេយំកាន់តែខ្លាំង ហើយលាក់មុខគេនៅក្នុងដៃរបស់គេ ។ បុរសអ្នកលក់ និងក្មេងប្រុសម្នាក់ទៀតបានមកដល់ដែរ ។

បុរសអ្នកលក់បានប្រាប់ខ្ញុំថា « ខ្ញុំគិតថាពួកគេចេះនិយាយតែភាសាបារាំងប៉ុណ្ណោះ » ។ « យើងឃើញពួកគេរត់កាត់តាមហាង ដោយវង្វេង » ។

ខ្ញុំបាននិយាយណែនាំខ្លួនរបស់ខ្ញុំទៅក្មេងប្រុសទាំងពីរឡើងវិញជាភាសាបារាំង ។ ភាសាបារាំងជាភាសាកំណើតរបស់ខ្ញុំ ប៉ុន្តែខ្ញុំមិនបាននិយាយវាចាប់ពីខ្ញុំត្រូវបានយកមកចិញ្ចឹមនៅក្នុងគ្រួសារដែលនិយាយភាសាអង់គ្លេសតាំងពីតូចមកម្លេះ ។ ជាធម្មតា ភាសាបារាំងរបស់ខ្ញុំគឺពុំសូវល្អទេ ។ ទោះបីជាដូច្នេះក៏ដោយ នៅពេលនោះវាមិនស្គាំស្គង ក៏មិនរឹងឆ្អឹងដែរ ។ ពាក្យទាំងនោះ គឺច្បាស់នៅក្នុងគំនិតខ្ញុំ ហើយសម្លេងខ្ញុំដូចជាការលួងលោមដល់ក្មេងប្រុសទាំងពីរនោះ ។

នៅចន្លោះការយំខ្សឹបខ្សួល ក្មេងប្រុសធំបានពន្យល់ដោយពាក្យយ៉ាងលឿនថា គេនឹងប្អូនប្រុសរបស់គេមិនអាចរកឪពុកម្ដាយរបស់គេនៅក្នុងហាងឃើញទាល់តែសោះ ហើយបានរត់រកពួកគេទៅខាងក្រៅហាងទៀត ។ នៅពេលដែលខ្ញុំបានស្ដាប់ ឮដូច្នោះ ខ្ញុំបានដឹងដោយស្រពិចស្រពឹលថា ខ្ញុំមិនត្រឹមតែអាចសន្ទនាជាភាសាបារាំងដោយសេរីទេ ប៉ុន្តែថែមទាំងត្រៀមខ្លួនរួចជាស្រេចដើម្បីយល់ នឹងលួងលោមចិត្តដល់ក្មេងប្រុសដែលភ័យខ្លាចទាំងពីរនាក់នោះផង ។

ខ្ញុំបានប្រាប់ទៅបុរសអ្នកលក់ថា « ពួកគេបានវង្វេងឪពុកម្ដាយ ហើយរង់ចាំឪពុកម្ដាយគេនៅឯឡានពួកគេ » ។ ក្មេងប្រុសតូចនោះបានប្រាប់ខ្ញុំឈ្មោះឪពុកម្ដាយគេ ហើយខ្ញុំបានឲ្យឈ្មោះនោះទៅបុរសអ្នកលក់ ដើម្បីឲ្យគាត់ប្រកាសរកពួកគេ ។ ពីរបីនាទីក្រោយមក ក្មេងប្រុសនោះបានឃើញឪពុកគេចេញពីហាង ហើយរត់មករកគេ ។

នៅពេលដែលខ្ញុំជូនក្មេងប្រុសនោះទៅឪពុករបស់គេ ខ្ញុំឃើញថាខ្ញុំមិនអាចទាំងនិយាយជម្រាបលាជាភាសាបារាំងបានល្អផង ។ ខ្ញុំព្យាយាមដោយឥតប្រយោជន៍ ក្នុងការនិយាយឲ្យក្មេងទាំងពីរនាក់នោះបានយល់ តែខ្ញុំមិនអាចនិយាយអ្វីក្រៅពីពាក្យព្រាវពីរបីពាក្យ ។ នៅទីបញ្ចប់ ខ្ញុំបានត្រឡប់មកនិយាយជាភាសាអង់គ្លេសវិញ ដោយនិយាយទៅកាន់ក្មេងនោះ « លាហើយ រីករាយណាស់ដែលបានជួបប្អូន » ។

នៅពេលដែលពួកគេបានចេញទៅជាមួយនឹងឪពុកម្ដាយគេ ខ្ញុំបានពោរពេញទៅដោយក្ដីអំណរ ។ ព្រះវរបិតាសួគ៌បានធ្វើការអស្ចារ្យតាមរយៈខ្ញុំ ដើម្បីលួងលោមកូនតូចៗរបស់ទ្រង់ ។ ខ្ញុំមានចិត្តរាបទាបដែលព្រះអម្ចាស់ អាចតម្កើងកម្រិតសមត្ថភាពរបស់ខ្ញុំ ដើម្បីបំពេញព្រះគោលបំណងរបស់ទ្រង់ ។ ខ្ញុំមានក្ដីអំណរ ដើម្បីធ្វើជាសាក្សីនូវអ្វីដែលអាចកើតឡើង នៅពេលដែលយើងថ្វាយខ្លួនយើងដល់ទ្រង់ ពេលទ្រង់បានហៅមកលើយើង ទោះជានៅក្នុងស្ថានការណ៍ដែលមិនគួរអាចទៅរួចក្ដី ។ ■

គ្រីស្ទីណា អាល់ប្រិច អៀហាត រដ្ឋ វ៉ាស៊ីនតោន ស.រ.អា

# យើងត្រូវតែទៅព្រះវិហារបរិសុទ្ធឥឡូវនេះ !

នៅព្រឹកថ្ងៃអាទិត្យមួយ សមាជិកដែលទើបបានជ្រមុជទឹកម្នាក់ ត្រូវបានណែនាំឲ្យស្គាល់នៅក្នុងវួដ ។ ឈ្មោះរបស់គាត់គឺ លីឡៀ ។ គាត់បានយកឈ្នះលើដួងចិត្តយើងមួយរំពេច ។

លីឡៀ ជាស្ត្រីចំណាស់ ហើយពិការភ្នែក ពីការប្រយុទ្ធប្រឆាំងនឹងជំងឺទឹកនោមផ្អែមជាច្រើនឆ្នាំ ។ គាត់បានស្គាល់សមាជិកក្នុងវួដនេះយ៉ាងរហ័សដោយសម្លេង និងសម្រឹបជើងរបស់ពួកគេ ។ គាត់នឹងហៅឈ្មោះរបស់យើង និងចាប់អង្រួនដៃយើង ហើយយើងមិនដែលគិតថាគាត់ពិការភ្នែកនោះទេ ។

បន្ទាប់ពីការតម្រូវឲ្យរង់ចាំមួយឆ្នាំបានផុតទៅ នោះលីឡៀបានជួបជាមួយនឹងប៊ីស្សព និងប្រធានស្តេក ដើម្បីទទួលយកប័ណ្ណចូលព្រះវិហារបរិសុទ្ធរបស់គាត់ ។ នៅក្នុងថ្នាក់ស្ត្រីនាថ្ងៃ អាទិត្យមួយគាត់បានទាញខ្ញុំចុះទៅជិតគាត់ ហើយប្រាប់ថា « ប្រធានស្តេកបានប្រាប់ខ្ញុំថា ខ្ញុំត្រូវតែទៅព្រះវិហារបរិសុទ្ធឲ្យឆាប់តាមដែលអាចធ្វើទៅបាន ។ តើអ្នកនាំខ្ញុំទៅបានទេ ? »

វាជាសប្តាហ៍ដំបូងនៃខែធ្នូ — ជាពេលវេលាដ៏មមាញឹកសម្រាប់ពួកយើងរាល់គ្នា ។ ខ្ញុំបានព្យាយាមដោះសារដូចសព្វមួយដងថា « តើយើងមិនអាចចាំដល់ខែមករាទេឬអី ? »

« ទេ យើងត្រូវទៅឥឡូវនេះ ! »

ស្ត្រីមួយក្រុមពីវួដនេះ បានទៅព្រះវិហារបរិសុទ្ធជារៀងរាល់ខែ ដូច្នេះខ្ញុំបានទៅសើបសួរពួកគេអំពីការធ្វើដំណើរទៅព្រះវិហារបរិសុទ្ធជាមួយនឹងលីឡៀ ។ ពួកគេរវល់ខ្លាំងណាស់ ។ ប៉ុន្តែ ដោយទឹកភ្នែកនៅក្នុងភ្នែកគាត់ លីឡៀបានប្រាប់យើងម្តងទៀតថា ប្រធានស្តេកបានប្រាប់គាត់ឲ្យទៅព្រះវិហារបរិសុទ្ធឲ្យឆាប់តាមដែលអាចធ្វើទៅបាន ។

នៅចំណុចនោះ យើងបានយល់ព្រមដើម្បីធ្វើដំណើរចម្ងាយ 241 គ. ម. នៅសប្តាហ៍បន្ទាប់ ។ នៅក្នុងការធ្វើដំណើរនោះ ឡានរបស់យើងបានពេញទៅដោយការជជែកគ្នា និងមិត្តភាពរបស់ស្ត្រីទាំងប្រាំបីនាក់ ។ លីឡៀពោរពេញទៅដោយភាពរីករាយ តាមរយៈបទពិសោធន៍ពីការទៅព្រះវិហារបរិសុទ្ធរបស់គាត់ និងពរជ័យនៃការទទួលអំណោយទានពិសិដ្ឋរបស់គាត់ ។

នៅសប្តាហ៍ទីមួយនៃខែ មករា ស្ថានភាពរបស់លីឡៀបានដុនដាបឡើង ហើយគាត់បានចូលមន្ទីរពេទ្យសម្រាប់ការសង្គ្រោះបន្ទាន់ ។ មួយសប្តាហ៍ក្រោយមក គាត់បានទទួលមរណភាព ។ ប៉ុន្តែ លីឡៀនាំទៅជាមួយខ្លួននូវពរជ័យដ៏អស់កល្បដែលគាត់បានទទួលនៅក្នុងព្រះវិហារបរិសុទ្ធប៉ុន្មានសប្តាហ៍មុននេះ ។

ក្រោយមក ខ្ញុំបានប្រាប់ដល់ប្រធានស្តេកអំពីរឿងនៃដំណើរទៅព្រះវិហារបរិសុទ្ធរបស់យើង ហើយបានប្រាប់គាត់ថា ខ្ញុំចាប់អារម្មណ៍ជាខ្លាំងចំពោះការបំផុសគំនិតដែលគាត់បានទទួលក្នុងការប្រាប់លីឡៀឲ្យត្រូវទៅព្រះវិហារបរិសុទ្ធជាបន្ទាន់ ។

គាត់បានឆ្លើយថា « ខ្ញុំពិតជាមិនមានន័យថា គាត់ត្រូវទៅឥឡូវនេះទេ » ។ « ខ្ញុំតែងតែប្រាប់អ្នកដែលកាន់ប័ណ្ណចូលព្រះវិហារបរិសុទ្ធថ្មីឲ្យឆាប់ទៅព្រះវិហារបរិសុទ្ធ ។ ព្រះវិញ្ញាណបានមានព្រះបន្ទូលទៅកាន់លីឡៀ មិនមែនជាខ្ញុំទេ ! »

លីឡៀបានបង្រៀនយើងទាំងអស់ឲ្យស្តាប់តាមព្រះវិញ្ញាណ ហើយធ្វើតាមការបំផុសគំនិតនោះភ្លាម ។ ខ្ញុំមានអំណរគុណចំពោះការរំឭករបស់គាត់ដើម្បីស្តាប់តាមសម្លេងតូចរហៀង ។ ■

ម៉ារី ហូមស៍ អេរិន រដ្ឋកាលីហ្វ័រញ៉ា ស.រ.អា

លីឡៀបាននិយាយថា « ប្រធានស្តេកបានប្រាប់ខ្ញុំឲ្យទៅព្រះវិហារបរិសុទ្ធឲ្យបានឆាប់តាមដែលអាចធ្វើបាន » ។ « តើនាងជូនខ្ញុំទៅបានទេ ? »






**ដោយ អែលឌើរ អាន់ថូនី ឌី ភើគីន**
នៃពួកចិតសិបនាក់


# ឆ្ពោះទៅមុខដោយ ជំនឿ

ប្អូនៗយុវមជ្ឈឹមវ័យទាំងអស់ កំពុងរស់នៅក្នុងអ្វីដែលហៅថា « ទសវត្សន៍ នៃការសម្រេចចិត្ត » ។ អ្នកកំពុងធ្វើការជ្រើសរើសសំខាន់ៗជាច្រើនក្នុងជីវិតរបស់អ្នក ដូចជា « ការទៅព្រះវិហារបរិសុទ្ធ ការបម្រើបេសកកម្ម ការទទួលការអប់រំ ជ្រើសរើសមុខនាទីការងារ និងជ្រើសរើសដៃគូ ហើយផ្សារភ្ជាប់អស់កល្បជានិច្ចនៅក្នុងព្រះវិហារបរិសុទ្ធ » ។[1]

ខ្ញុំនិយាយផ្តោតពិសេសចំពោះ អ្នកដែលកំពុងពុះពារជាមួយនឹងការសម្រេចចិត្តមួយ ឬច្រើន — អ្នកខ្លះប្រហែលជាស្ទើរតែកម្រើកខ្លួនមិនរួចពីការភ័យខ្លាច នៃការសម្រេចចិត្តខុស ឬត្រូវការការពង្រឹងដើម្បីមានទំនុកចិត្ត ក្នុងការធ្វើការសម្រេចចិត្តពីមុនមក ។

បើយើងអនុវត្តមេរៀនបួននៃការបំផុសគំនិតក្នុងការសម្រេចចិត្ត ដោយនីហ្វៃ អាចកាត់បន្ថយភាពភ័យខ្លាចរបស់អ្នក ហើយបង្កើនទំនុកចិត្តរបស់អ្នកដើម្បីឆ្ពោះទៅមុខ ។

### 1. សូមគោរពតាមព្រះបញ្ញត្តិទាំងឡាយ

ខចុងក្រោយនៃកំណត់ត្រាពិសិដ្ឋរបស់នីហ្វៃបានសង្ខេបពីជីវិតរបស់លោក ៖ « ដ្បិតទ្រង់បានបញ្ជាខ្ញុំថាដូច្នេះ ហើយខ្ញុំត្រូវតែគោរពធ្វើតាម » ។ ( នីហ្វៃទី 2 33:15 ) ។

សេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់នីហ្វៃចំពោះព្រះអង្គសង្គ្រោះ គឺបានបញ្ជាក់បង្ហាញនៅក្នុងការគោរពព្រះបញ្ញត្តិរបស់ព្រះ ។ លោកបានអធិស្ឋាន ( សូមមើល នីហ្វៃទី 1 2:16 ) លោកបានអានព្រះគម្ពីរ ( សូមមើល នីហ្វៃទី 1 22:1 ) ។ លោកបានស្វែងរក និងដើរតាមការចង្អុលបង្ហាញមកពីព្យាការីដែលនៅរស់ ( សូមមើល នីហ្វៃទី 1 16:23–24 ) ។ ការគោរពតាមបែបនោះ អនុញ្ញាតឲ្យព្រះវិញ្ញាណធ្វើជាដៃគូដ៏ខ្លាំងដល់នីហ្វៃ ពេញមួយជីវិតរបស់លោក ហើយជម្រុញឲ្យមានវិវរណៈផ្ទាល់ខ្លួនជាបន្តបន្ទាប់ ។

អ្នកទាំងអស់គ្នាក៏ត្រូវតែនៅជិតនឹងព្រះអម្ចាស់ដែរ ដោយរក្សាបទបញ្ញត្តិទាំងឡាយរបស់ព្រះ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា ការគោរពប្រតិបត្តិយ៉ាងខ្ជាប់ខ្ជួនទៅនឹងអ្វីតូចមួយដូចជា ការអានព្រះគម្ពីរ ការអធិស្ឋានជារៀងរាល់ថ្ងៃ ចូលរួមការប្រជុំសាសនាចក្រនានា ស្តាប់តាមដំបូន្មានរបស់ព្យាការីដែលនៅរស់ និងការបម្រើអ្នកដទៃ នោះវានឹងឲ្យអ្នកមានភាពសក្តិសមសម្រាប់ព្រះវិញ្ញាណ — និងវិវរណៈដែលមកជាមួយគ្នានោះ ។

> **មេរៀនបួននៃការសម្រេចចិត្តដោយបំផុសគំនិត ដោយនីហ្វៃ អាចកាត់បន្ថយភាពភ័យខ្លាចរបស់អ្នក ហើយបង្កើនទំនុកចិត្តរបស់អ្នកដើម្បីឆ្ពោះទៅមុខ ។**

ភាពល្អឥតខ្ចោះ ពុំមែនជាតម្រូវការដំបូងដើម្បីទទួលបានវិវរណៈផ្ទាល់ខ្លួននោះទេ ។ តម្រូវការដំបូង គឺជាការកែប្រែចិត្តជារៀងរាល់ថ្ងៃ ( សូមមើល រ៉ូម 3:23 ) ។ បើសិនជាការកែប្រែចិត្តរបស់អ្នកស្មោះពីចិត្ត និងពេញលេញ ( សូមមើល គ និង ស 58:42–43 ) អំណាចនៃការលាងសម្អាតរបស់

ភាពលម្អិតពី *THE SPIRIT OF PRAYER*, ដោយ ក្លីន រ៉ូប៊ី អាកៀ ក៏មីវែល





សេចក្តីជំនឿ និងសេចក្តីស្រឡាញ់របស់នីហ្វៃចំពោះព្រះអង្គសង្គ្រោះ គឺបានបញ្ជាក់បង្ហាញនៅក្នុងការគោរពព្រះបញ្ញត្តិរបស់ព្រះ ។

ដង្វាយធួន នឹងនាំព្រះវិញ្ញាណដើម្បីដឹកនាំអ្នកនៅក្នុងការសម្រេចចិត្តដ៏សំខាន់នៃជីវិត ។

**2. ឆ្ពោះទៅមុខដោយជំនឿ**

សូមដាក់ខ្លួនអ្នកក្នុងស្ថានភាពរបស់នីហ្វៃវិញ ឪពុករបស់អ្នកប្រាប់អ្នកថា ព្រះអម្ចាស់បានបញ្ជាឲ្យគ្រួសារអ្នកបោះបង់ចោលទ្រព្យសម្បត្តិរបស់អ្នក ហើយចេញទៅវាលរហោស្ថាន ។ តើអ្នកមិនចង់ដឹងអំពីដំណើរ និងគោលដៅរបស់អ្នកទេឬ ?

ខ្ញុំគិតថា នីហ្វៃនឹងរំភើបចិត្តបើព្រះអម្ចាស់បានបង្ហាញយ៉ាងច្បាស់ពីអនាគតរបស់គាត់ ។ ប៉ុន្តែ នោះមិនមែនជារបៀបដែលព្រះបានធ្វើការជាមួយនីហ្វៃទេ ហើយវាក៏មិនមែនជារបៀបដែលទ្រង់នឹងធ្វើការជាមួយអ្នកដែរ ។

ពេលដែលក្រុមគ្រួសាររបស់នីហ្វៃបានធ្វើដំណើរតាមវាលរហោស្ថាន សេចក្ដីណែនាំបានមកដល់គាត់ត្រឹមតែ « យូរៗម្ដង » ប៉ុណ្ណោះ ( នីហ្វៃទី 1 16:29; 18:1 ) ។ ការមើលទៅដំណើរជីវិតរបស់លោកដោយភាពជាក់ច្បាស់នៅមុខនឹងមិនផ្ដល់ឲ្យលោកនូវការពង្រីកព្រលឹង និងការបង្កើតសេចក្ដីជំនឿដែលជួយលោកឲ្យក្លាយកាន់តែដូចព្រះគ្រីស្ទទេ ។

បើសិនអ្នកកំពុងតែរង់ចាំឲ្យព្រះចង្អុលបង្ហាញថា គួរតែរៀនមុខវិជ្ជាអ្វី ត្រូវរៀបការជាមួយអ្នកណា ត្រូវធ្វើការងារអ្វី ត្រូវរស់នៅកន្លែងណា គួររៀនបន្តយកអនុបណ្ឌិត ហើយគួរបង្កើតកូនប៉ុន្មាននាក់ នោះអ្នកនឹងមិនដែលចាកចេញពីផ្ទះរបស់អ្នកបានឡើយ ។ ខ្ញុំសូមថ្លែងទីបន្ទាល់ថា វិវរណៈផ្ទាល់ខ្លួននឹងមកត្រឹមតែ « ពីពេលមួយទៅពេលមួយ » ប៉ុណ្ណោះ ។

ព្រះវរបិតាសួគ៌របស់យើង ចង់ឲ្យយើងរីកចម្រើន ហើយវារួមបញ្ចូលការអភិវឌ្ឍសមត្ថភាពរបស់យើងដើម្បីថ្លឹងថ្លែងការពិត ផ្ដល់ការវិនិច្ឆ័យ និងធ្វើការសម្រេចចិត្ត ។ ប៉ុន្តែ ទ្រង់ក៏អញ្ជើញយើងឲ្យយកការសម្រេចចិត្តទាំងឡាយរបស់យើងទៅកាន់ទ្រង់ក្នុងការអធិស្ឋានដែរ ( សូមមើល គ និង ស 9:7–9 ) ។ អែលឌើរ រីឆាត ជី ស្កត នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា ចម្លើយចំពោះការអធិស្ឋានរបស់យើងមក « ក្នុងវិធីមួយក្នុងចំណោម *វិធី បី* » ។[2]

***ការបញ្ជាក់ពីការអះអាង***

អែលឌើរ ស្កតបានមានប្រសាសន៍ថា « ជាដំបូង អ្នកអាចមានអារម្មណ៍សុខសាន្ត លួងលោមចិត្ត និងការអះអាងថាការសម្រេចចិត្តរបស់អ្នក គឺត្រឹមត្រូវ »[3] ខ្ញុំ និងគ្រីស្ទីភរិយារបស់ខ្ញុំ បានរកឃើញថាការអះអាងចំពោះការសម្រេចចិត្តដ៏សំខាន់ដែលប៉ះពាល់ដល់ជីវិត អាចជាការសន្ទនាតាមរយៈព្រះគម្ពីរ ហើយជារឿយ បន្ទាប់ពីការគោរពបូជាព្រះវិហារបរិសុទ្ធ ។

ឧទាហរណ៍ បន្ទាប់ពីការសញ្ជឹងគិត និងការអធិស្ឋានជាច្រើន យើងបានសម្រេចចិត្តបោះបង់ផ្ទះក្នុងក្ដីសុបិន្តថ្មីរបស់យើងក្នុងរដ្ឋតិចសាស់ ទទួលយកការផ្លាស់ប្ដូរការងារ ហើយផ្លាស់ទៅទីក្រុងប៉េកាំង ប្រទេសចិនជាមួយនឹងកូនប្រាំមួយនាក់ ។ តែយើងប្រាថ្នាចង់បានការបញ្ជាក់ខាងវិញ្ញាណយ៉ាងខ្លាំង សម្រាប់ការផ្លាស់ប្ដូរដ៏សំខាន់មួយនេះ ។ ការអះអាងដ៏ទេវភាពពិតជាមានចំពោះយើង — នៅក្នុងព្រះវិហារបរិសុទ្ធ — ពេលយើងអានពាក្យទាំងនេះនៅក្នុងគោលលទ្ធិ និង សេចក្ដីសញ្ញា ៖ « គឺជាព្រះហឫទ័យរបស់យើង ថាអ្នកគប្បី . . . កុំនៅកន្លែងនេះច្រើនថ្ងៃពេក . . . ចូរកុំគិតពីទ្រព្យសម្បត្តិរបស់អ្នកឡើយ ។ ចូរទៅឯដែនដីទាំងឡាយនៅទិសខាងលិច » ( គ និង ស 66:5–7 ) ។

**ដើម្បីកាត់បន្ថយការភ័យខ្លាច និងបង្កើនជំនឿចិត្ត**

1. សូមគោរពតាមព្រះបញ្ញត្តិទាំងឡាយ ។
2. ឆ្ពោះទៅមុខដោយជំនឿ ។
3. រស់នៅក្នុងបច្ចុប្បន្ន ។
4. ទាញយកកម្លាំងពីអ្នកដទៃ ។



*THEIR JOY WAS FULL,* ដោយ វ៉ាល់ធើរ រ៉ាណេ ទទួលបានសិទ្ធិអនុញ្ញាតជាផ្លូវការដោយ សារមន្ទីរប្រវត្តិសាស្ត្ររបស់សាសនាចក្រ



*នីហ្វៃនឹងរំភើបចិត្តបើព្រះអម្ចាស់បានបង្ហាញយ៉ាងច្បាស់ពីអនាគតរបស់គាត់ ។ ប៉ុន្តែ វាមិនមែនជារបៀបដែលព្រះបានធ្វើការជាមួយនីហ្វៃទេ ហើយវាក៏មិនមែនជារបៀបដែលទ្រង់នឹងធ្វើការជាមួយអ្នកដែរ ។*

សម្លេងរបស់ព្រះយេស៊ូវគ្រីស្ទនៅក្នុងខគម្ពីរទាំងនេះ អមមកដោយនូវអារម្មណ៍ដ៏មានអំណាចពីព្រះវិញ្ញាណបរិសុទ្ធ បានបញ្ជាក់ថា ការសម្រេចចិត្តរបស់យើងក្នុងការផ្លាស់ទៅប្រទេសចិនគឺត្រឹមត្រូវ ។

***អារម្មណ៍សោប់សល់***

វិធីទីពីរ ព្រះវរបិតាសួគ៌ឆ្លើយតបនឹងការអធិស្ឋានតាមរយៈ « អារម្មណ៍សោប់សល់ ភាពចេងចោងនៃគំនិត បង្ហាញថាជម្រើសរបស់អ្នកខុស » ។[4]

បន្ទាប់ពីបេសកកម្មរបស់ខ្ញុំនៅប្រទេសតៃវ៉ាន់ ខ្ញុំគិតថា ច្បាប់អន្តរជាតិនឹងជាជម្រើសអាជីពដ៏ល្អ ។ ពេលខ្ញុំ និងគ្រីស្ទីបានចាត់ទុកថា វាអាចទៅរួចសម្រាប់អនាគត យើងបានយល់ពី ការសិក្សាអប់រំដ៏ថ្លៃនៅប្រាំឆ្នាំទៅមុខទៀត ។

សហរដ្ឋអាមេរិក បានធ្លាក់ទៅក្នុងវិបត្តិសេដ្ឋកិច្ចយ៉ាងធ្ងន់ធ្ងរ ហើយមូលនិធិរបស់យើងពិតជាស្ដួចស្ដើង ដូច្នេះ យើងបានថ្លឹងថ្លែងថាការចូលរួមក្នុងកងទ័ពជើងអាកាសឈ្មោះ អរអូធីស៊ី ( ROTC ) ដើម្បីបង់ថ្លៃសាលាជាជម្រើសដ៏ឆ្លាតវៃ ។ ប៉ុន្តែ នៅពេលដែលខ្ញុំធ្វើតេស្ត និងបំពេញឯកសារដែលបានតម្រូវ យើងមិនស្រណុកចិត្តក្នុងការធ្វើកិច្ចសន្យានោះសោះ ។ គ្មានអារម្មណ៍មិននឹងនរ ឬក៏អារម្មណ៍ងងឹតណាមួយមកទេ — គ្រាន់តែអវត្តមាននៃភាពសុខសាន្តប៉ុណ្ណោះ ។

ផ្នែកខ្លះ វាហាក់ដូចជាមិនសមហេតុផលនឹងការសម្រេចចិត្តផ្នែកហិរញ្ញវត្ថុដែលបានបំផុសគំនិតទេ ដោយសារបើមិនដូច្នោះទេ ខ្ញុំនឹងក្លាយជាមេធាវីដ៏អាក្រក់ !

***ទំនុកចិត្តដ៏ទេវភាព***

ព្រះឆ្លើយតបចំពោះការអធិស្ឋានរបស់យើងតាមវិធីទីបី ៖ គ្មានចម្លើយ ។ អែលឌើរ ស្កុត បានមានប្រសាសន៍ថា « ពេលអ្នករស់នៅដោយសក្តិសម ហើយជម្រើសអ្នកសមស្របនឹងការបង្រៀននៃព្រះអង្គសង្គ្រោះ នោះអ្នកចាំបាច់ត្រូវតែអនុវត្តតាមបន្តទៅមុខដោយទំនុកចិត្ត » ។[5]

ការព្យាយាមចុងក្រោយរបស់នីហ្វៃ ដើម្បីទទួលបានផ្ទាំងលង្ហិន បង្ហាញពីរបៀបដែលយើងគួរបន្តទៅមុខដោយទំនុកចិត្តដ៏ទេវភាព ។ លោកបានកត់ត្រាថា ៖

« ខ្ញុំត្រូវ បានដឹកនាំខាងវិញ្ញាណ ដោយមិនដឹងជាមុនសោះឡើយថា តើខ្ញុំត្រូវធ្វើអ្វីខ្លះ ។

ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ » ( នីហ្វៃទី 1 4:6–7 ) ។

ពេលទាំងនោះនឹងមកដល់អំឡុងទសវត្សរ៍នៃការសម្រេចចិត្តរបស់អ្នក ពេលអ្នកមិនអាចបង្អង់យូរទៀត ហើយត្រូវតែធ្វើវា ។ ខ្ញុំបានរៀនថា ដូចអែលឌើរ ដាល្លិន អេក អូក នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « យើងនឹងទទួលបានការបំផុសគំនិត ពីព្រះវិញ្ញាណពេលយើងបានធ្វើអ្វីគ្រប់យ៉ាងអស់ពីសមត្ថភាព ពេលយើងចេញទៅធ្វើការក្រោមកំដៅថ្ងៃជាជាងការអង្គុយនៅក្នុងម្លប់អធិស្ឋានសម្រាប់ការណែនាំពីជំហានដំបូងដែលត្រូវដើរ » ។[6]

ដូចជានីហ្វៃដែរ ព្រះវិញ្ញាណនឹងបញ្ជាក់ ឬព្រមានពីការជ្រើសផ្លូវរបស់អ្នកនៅពេលដែលដល់ពេល ។

**3. រស់នៅក្នុងបច្ចុប្បន្នភាព**

ការប្ដេជ្ញារបស់នីហ្វៃលើការធ្វើដំណើរទៅកាន់ដែនដីសន្យា ឈរផ្ទុយស្រឡះពីបងប្រុសរបស់លោក លេមិន និងលេមយួល ។ ពួកគាត់បានធ្វើការសម្រេចចិត្តទៅ ប៉ុន្តែដួងចិត្តរបស់ពួកគេមិនដែលចាកចេញពីក្រុងយេរូសាឡិមឡើយ ។ នីហ្វៃកំពុងផ្ចួសផ្ចុលធ្នូដែលបានបាក់របស់គាត់ ដើម្បីបរបាញ់ម្ហូប និងរករ៉ែដើម្បីសាងសង់សំពៅ ខណៈដែលបងប្រុសប្អូនរបស់លោកកំពុងសម្រាកនៅក្នុងត្រសាល ។

សព្វថ្ងៃនេះ ពិភពលោកមានលេមិន និងលេមួលជាច្រើន ។ ប៉ុន្តែ ព្រះអម្ចាស់ត្រូវការបុរស និងស្ត្រី ដែលប្ដេជ្ញាចិត្តដូចនីហ្វៃ ។ អ្នកនឹងមានបទពិសោធន៍ពីការរីកចម្រើនដ៏ធំនៅក្នុងជីវិត ពេលអ្នកប្ដេជ្ញាទាំងស្រុងទៅនឹងការសម្រេចចិត្តរបស់អ្នក ហើយព្យាយាមដើម្បីបានខ្លាំងពូកែក្នុងកាលៈទេសៈបច្ចុប្បន្នរបស់អ្នក សូម្បីតែពេលដែលអ្នកបើកភ្នែកសម្លឹងមើលទៅអនាគតក៏ដោយ ។

នីហ្វៃបង្ហាញឲ្យឃើញជាក់ពី ដំបូន្មានរបស់ប្រធាន ថូម៉ាស អេស ម៉នសុន ៖ « ការស្រមើស្រម៉ៃពីអតីតកាល និងការទន្ទឹងពីអនាគត អាចផ្ដល់នូវការលួងលោមចិត្ត ប៉ុន្តែវានឹងមិនជំនួសកន្លែងនៃការរស់នៅក្នុងបច្ចុប្បន្នភាពទេ ។ ថ្ងៃនេះជាថ្ងៃនៃឱកាសរបស់យើង ហើយយើងនឹងចាប់យកវា » ។[7]

**4. ទាញយកកម្លាំងពីអ្នកដទៃ**

ទោះបីបន្ទាប់ពីយើងស្វែងរកព្រះវិញ្ញាណក៏ដោយ ឆ្ពោះទៅមុខជាមួយការសម្រេចចិត្តរបស់យើង នឹងប្ដេជ្ញាចិត្តទាំងស្រុងទៅលើវា ក៏ការសង្ស័យនៅតែមាន ហើយធ្វើឲ្យមានសំណួរលើការសម្រេចចិត្តរបស់យើងដែរ ។ នៅក្នុងស្ថានភាពបែបនោះ សមាជិកគ្រួសារ ឬមិត្តភក្ដិដែលយើងទុកចិត្ត អាចផ្ដល់ដំបូន្មាន និងកម្លាំងដើម្បីឲ្យយើងរឹងមាំ ។ ខ្ញុំគិតថា ភរិយារបស់នីហ្វៃបានក្លាយជាយុត្តកាដ៏គួរឲ្យទុកចិត្តរបស់លោក នៅតាមដំណើរទៅដែនដីឡា ។

ការដឹងគុណចំពោះភរិយារបស់នីហ្វៃ បានមកដល់ខ្ញុំ នៅពេលទៅទស្សនាសារមន្ទីរប្រវត្តិសាស្ត្ររបស់សាសនាចក្រ ។ ខ្ញុំបានដក់ជាប់នឹងផ្ទាំងគំនូរនៅទីនោះ ជាផ្ទាំងគំនូរដែលនីហ្វៃបានចងភ្ជាប់ទៅនឹងដងក្ដោងនៃសំពៅ ទទឹកជោកដោយព្យុះដែលកំពុងបក់បោក ។[8]

**សមាជិកគ្រួសារ ឬមិត្តភក្ដិដែលយើងទុកចិត្ត អាចផ្ដល់ដំបូន្មាន និងកម្លាំងដើម្បីឲ្យយើងរឹងមាំ ។**





*HELPMEET,* ដោយ សន ស៊ូលីវ៉ាន់

នៅក្បែរនីហ្វៃ គឺជាភរិយា និងកូនម្នាក់របស់លោក ។ គាត់កំពុងតែទទួលបទពិសោធន៍ពីខ្យល់ព្យុះ និងបញ្ហាដូចនីហ្វៃដែរ ប៉ុន្តែកែវភ្នែករបស់គាត់មានភាពក្លាហាន ហើយដៃដ៏រឹងមាំរបស់គាត់បានឱបក្រសោបជុំវិញស្មារបស់លោក ។ នៅពេលនោះ ខ្ញុំបានដឹងថា ខ្ញុំក៏មានពរជ័យដោយមានភរិយាដែលស្មោះត្រង់ ផ្ដល់កម្លាំងដល់ខ្ញុំនៅពេលមានទុកលំបាកដែរ ។ ខ្ញុំសង្ឃឹមថា ខ្ញុំក៏ជាកម្លាំងស្រដៀងគ្នាចំពោះភរិយាខ្ញុំដែរ ។

បងប្អូនប្រុសទាំងឡាយ ការរក្សា និងពង្រឹងកម្លាំងខាងវិញ្ញាណដែលអ្នកបានបង្កើត ( ឬដែលនឹងបង្កើត ) ដូចជាអ្នកផ្សព្វផ្សាយសាសនា ឬក្នុងការបម្រើដ៏សុចរិតផ្សេងទៀត គឺជាទ្រព្យដ៏មានតម្លៃបំផុត នៅក្នុងការក្លាយជាស្វាមី និងឪពុកដែលគួរឲ្យចង់បាន ។ បងប្អូនស្រីទាំងឡាយ ភាពទន់ភ្លន់ខាងវិញ្ញាណ សេចក្ដីជំនឿ នឹងភាពក្លាហាន ដើម្បីដើរតាមព្រះយេស៊ូវគ្រីស្ទ គឺជាគុណសម្បត្តិជាភរិយា និងជាម្ដាយដ៏ល្អបំផុត ។

ខ្ញុំសូមអញ្ជើញអ្នកឲ្យក្លាយជាប្រភេទមនុស្សដែលភរិយា/ស្វាមីក្នុងពេលបច្ចុប្បន្ន ឬនាពេលអនាគត អាចពឹងផ្អែកសម្រាប់កម្លាំង និងដំបូន្មានដ៏វៃឆ្លាត ។ បុរសប្រកបដោយគុណធម៌ និងស្ត្រីដែលមានភាពសក្ដិសម ហើយដែលបានផ្សារភ្ជាប់ដ៏នៅអស់កល្បជានិច្ចនៅក្នុងព្រះវិហារបរិសុទ្ធ អាចធ្វើនូវកិច្ចការលំបាកបានជាដៃគូស្មើភាព ។

ខ្ញុំសូមសន្យាថា បើអ្នកនឹងអនុវត្តនូវមេរៀនទាំងឡាយដែលបានរៀនពីនីហ្វៃ និងព្យាការីសម័យទំនើប អំពីការធ្វើការសម្រេចចិត្ត អ្នកនឹងត្រូវបានដឹកនាំតាមផ្លូវដោយវិវរណៈផ្ទាល់ខ្លួន « ពីពេលមួយទៅពេលមួយ » ។ ពេលអ្នករីកចម្រើនតាមទស្សវត្សរ៍នៃការសម្រេចចិត្តរបស់អ្នក អ្នកអាចមានសេចក្ដីជំនឿដើម្បីនិយាយដូចជានីហ្វៃដែរថា ៖

« ខ្ញុំត្រូវ បានដឹកនាំខាងវិញ្ញាណ ដោយមិនដឹងជាមុនសោះឡើយថា តើខ្ញុំត្រូវធ្វើអ្វីខ្លះ ។

« ទោះយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរតម្រង់ទៅមុខ » ( នីហ្វៃទី 1 4:6–7 ) ។ ■

*ដកស្រង់ចេញពីសុន្ទរកថាការប្រជុំធម្មនិដ្ឋាន « ទោះជាយ៉ាងណាក៏ដោយ គង់តែខ្ញុំដើរទៅមុខ » ដែលបានផ្ដល់នៅសាកលវិទ្យាល័យ ព្រិកហាំយ៉ង់ ថ្ងៃ ទី 4 ខែ កុម្ភៈ ឆ្នាំ 2014 ។ ដើម្បីទទួលបានសុន្ទរកថាពេញលេញ ជាភាសាអង់គ្លេស សូមចូលទៅ speeches.byu.edu ។*


**កំណត់ចំណាំ**

1. រ៉ូបឺត ឌី ហែល « To the Aaronic Priesthood: Preparing for the Decade of Decision » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2007, ទំព័រ 48 ។
2. រីឆាដ ជី ស្កុត « Using the Supernal Gift of Prayer » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2007, ទំព័រ 10; សង្កត់ធ្ងន់នៅក្នុងច្បាប់ដើម ។
3. រីឆាដ ជី ស្កុត « Using the Supernal Gift of Prayer, » ទំព័រ 10 ។
4. រីឆាដ ជី ស្កុត « Using the Supernal Gift of Prayer, » ទំព័រ 10 ។
5. រីឆាដ ជី ស្កុត « Using the Supernal Gift of Prayer, » ទំព័រ 10 ។
6. ដាល្លិន អេក អូក « In His Own Time, in His Own Way, » *លីអាហូណា* ខែ សីហា ឆ្នាំ 2013, ទំព័រ 26 ។
7. ថូម៉ាស អេស ម៉នសុន « In Search of Treasure, » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2003, ទំព័រ 20 ។
8. សូមមើល *Helpmeet,* ដោយ សន ស៊ូលីវ៉ាន់ « The Book of Mormon: A Worldwide View » *លីអាហូណា* ខែ ធ្នូ ឆ្នាំ 2000, ទំព័រ 37 ។

# ចូរស្វែងរកទ្រង់

« ហេតុអ្វីបានជាមករកព្រះអង្គដែលមានព្រះជន្មរស់នៅក្នុងទីខ្មោចស្លាប់
ដូច្នេះ ? ទ្រង់មានព្រះជន្មរស់ឡើងវិញ ហើយមិនគង់នៅទីនេះទេ »

( លូកា 24:5–6 ។ )



ទ្រង់មិនគង់នៅទីនេះទេ ដោយ វ៉លធើរ រ៉ាណេ

មេរៀនទាំងឡាយនៅថ្ងៃអាទិត្យ

ប្រធានបទសម្រាប់ខែនេះ ៖
ការក្បត់ សាសនា និង
ការស្ដារឡើងវិញ

# ដោយសារតែ
# យ៉ូសែប

*ស្វែងយល់ពីវិធីប្រាំមួយយ៉ាងដែលជីវិតរបស់អ្នកផ្លាស់ប្ដូរ ( ឬអាច )
ដោយសារតែព្យាការីយ៉ូសែបស្ម៊ីធ ។*

**ដោយ ធិឌ បានិស**
*ការិយាល័យបព្វជិតភាព*

យ៉ូសែប ស្ម៊ីធ បានស្លាប់ជាង 170 ឆ្នាំមុនមកហើយ ។ លោករស់នៅបានតែ 38 ឆ្នាំ លោកបានចំណាយពេលជាច្រើននៃពេលវេលានោះ នៅកន្លែងជាច្រើនដែលអ្នកប្រហែលជានឹងមិនអាចរកឃើញ លុះត្រានៅលើផែនទីដែលលម្អិតបំផុត ។ ហើយអ្នកប្រហែលជាបានដឹងពីអ្វីៗជាច្រើនដែលលោកបានធ្វើនៅក្នុងជីវិតរបស់លោក ។ ប៉ុន្តែ តើអ្នកធ្លាប់បានគិតអំពីរបៀបដែលវាបានមានឥទ្ធិពលលើអ្នកដែរឬទេ ? ខណៈពេលដែលវិធីទាំងនោះមានច្រើនរាប់មិនអស់ អ្នកអាចចាប់ផ្ដើមជាមួយនិងវិធីទាំងប្រាំមួយនេះ ។

ដោយសារតែយ៉ូសែប ស្ម៊ីធ ៖

## 1. អ្នកយល់ថាព្រះ និង ព្រះយេស៊ូវគ្រីស្ទ គឺជាតួអង្គណាពិតប្រាកដ ។

ទោះបីមិនដោយសារយ៉ូសែប ស្ម៊ីធ ក៏អ្នកអាចនៅតែជឿលើព្រះ ជាព្រះវរបិតា និងលើព្រះយេស៊ូវគ្រីស្ទដែរ ។ អ្នកអាចមានទីបន្ទាល់ពីព្រះគម្ពីរបរិសុទ្ធ ។ ប៉ុន្តែ សូមគិតពីរបៀបដែលការយល់ដឹងរបស់អ្នកកាន់តែជ្រៅជ្រះ និងកាន់តែប្រសើរជាងមុនដោយសារតែការស្ដារឡើងវិញរបស់ យ៉ូសែប ស្ម៊ីធ — សាក្សីយ៉ាងក្លាហាន បញ្ជាក់ពីគម្ពីរមរមន គោលលទ្ធិនិងសេចក្ដីសញ្ញា និងមុក្ដាដ៏មានតម្លៃមហិមា ។ ឧទាហរណ៍ អ្នកដឹងពីអ្វីដែលមនុស្សភាគច្រើនមិនដឹង ៖ ថាព្រះសង្គ្រោះបានមានព្រះជន្មរស់ឡើងវិញ ហើយលេចនៅចំពោះមុខជនជាតិអាមេរិក — បញ្ជាក់នៅក្នុងពាក្យរបស់ទ្រង់ថាទ្រង់គឺជា « ព្រះនៃអ៊ីស្រាអែល [ និងជា ] ព្រះនៃផែនដីទាំងមូលតែមួយអង្គគត់ » ( នីហ្វៃទី 3 11:14 ) ។

សូមគិតពីរបៀបដែលទីបន្ទាល់នៃព្រះវរបិតាសួគ៌ និងនៃព្រះយេស៊ូវគ្រីស្ទរបស់អ្នកត្រូវបានពង្រឹងដោយសាក្សីដ៏មានអនុភាព នៃពួកព្យាការីដូចជានីហ្វៃ អាលម៉ា និងម៉ូរ៉ូណៃ — នោះមិនចាំបាច់និយាយអំពីយ៉ូសែប ស្ម៊ីធ ផងដែលបានប្រកាសថា « ទ្រង់មានព្រះជន្មរស់នៅ ! ដ្បិតយើងខ្ញុំបានឃើញទ្រង់ គង់នៅខាងស្ដាំព្រហស្ដនៃព្រះ » ( គ និង ស 76:22–23 ) ។ នៅថ្ងៃដែលជំនឿនៅលើព្រះ និងព្រះយេស៊ូវគ្រីស្ទត្រូវបានផ្ទាញ់ផ្ទាល ហើយត្រូវបានបោះបង់ចោលជារឿយៗ វាគឺជាពរជ័យដើម្បីមានពន្លឺបន្ថែមនេះ ។










## 3. គ្រួសារអ្នកអាចរស់នៅជាមួយគ្នាអស់កល្បជានិច្ច ។

ហេតុអ្វីបានជាមនុស្សជាច្រើនភាន់ច្រឡំ អំពីសារៈសំខាន់នៃអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ ? ប្រហែលជាពួកគេមិនដឹងពីគោលលទ្ធិ ដែលបានស្ដារឡើងវិញដោយយ៉ូសែប ស្ម៊ីធ ថាអាពាហ៍ពិពាហ៍ និងក្រុមគ្រួសារ គឺត្រូវបានតែងតាំងដោយព្រះ ហើយមានន័យថារស់នៅជាមួយគ្នាអស់កល្បជានិច្ច ( សូមមើល គ និង ស 49:15; 132:7 ) ។ ប្រពៃណីទាំងនេះវាមិនគ្រាន់តែជាទង្វើដែលមនុស្សបង្កើតឡើង ដែលហួសពីសង្គមឡើយ — វាជាផ្នែកមួយនៃបញ្ញាដ៏អស់កល្បជានិច្ចនៃស្ថានសួគ៌ ។ ហើយសូមអរគុណចំពោះកូនសោរបព្វជិតភាព និងពិធីបរិសុទ្ធនៅក្នុងព្រះវិហារបរិសុទ្ធ ដែលបានស្ដារឡើងវិញតាមរយៈយ៉ូសែប ស្ម៊ីធ ក្រុមគ្រួសារដ៏អស់កល្បរបស់អ្នកអាចចាប់ផ្ដើមនៅលើផែនដីនេះ ។

## 2. អ្នកដឹងថាអ្នកជាកូនចៅរបស់ព្រះ — ហើយអ្នកដទៃក៏ដូច្នេះដែរ ។

ប្រហែលការពិតដែលសំខាន់បំផុតដែលយ៉ូសែប ស្ម៊ីធបានស្ដារឡើង គឺជាការពិតអំពីទំនាក់ទំនងរបស់យើងជាមួយព្រះ ។[1] ទ្រង់ពិតជាព្រះបិតារបស់យើងមែន ។ តើអ្នកធ្លាប់ឈប់ ដើម្បីនឹងសញ្ជឹងគិតអំពីអ្វីដែលហូរចេញពីការពិតនោះទេ ? វាបានផ្លាស់ប្ដូរទស្សនៈដែលអ្នកមើលឃើញខ្លួនឯង ៖ ដោយមិនគិតពីអ្វីដែលលោកិយគិតពីអ្នក អ្នកដឹងថាអ្នកគឺជាបុត្រជាទីស្រឡាញ់របស់ព្រះ ដោយមានគុណសម្បត្តិរបស់ទ្រង់នៅក្នុងខ្លួនអ្នក ។ វាផ្លាស់ប្ដូរទស្សនៈរបស់អ្នកក្នុងការមើលទៅអ្នកដទៃ ៖ រំពេចនោះអ្នករាល់គ្នា — *អ្នករាល់គ្នា* — គឺជាបងប្អូនប្រុសស្រីរបស់អ្នក ។ វាផ្លាស់ប្ដូរទស្សនៈដែលអ្នកមើលទៅជីវិតផ្ទាល់ ៖ ក្ដីអំណររបស់វា និងការសាកល្បងទាំងអស់គឺជាផ្នែកនៃផែនការរបស់ព្រះវរបិតាសួគ៌ ដើម្បីជួយអ្នកប្រែក្លាយដូចជាទ្រង់ ។ វាមិនមែនជាអ្វីដែលមិនល្អ ដែលអ្នកអាចច្រៀងនៅក្នុងថ្នាក់កុមារនោះទេ ![2]

ខាងឆ្វេង ៖ *THE DESIRES OF MY HEART (FIRST VISION),* ដោយ វលធើរ រេន ខាងលើ ព្រះវិហារបរិសុទ្ធ នៅទីក្រុងអាសាំងស្យុង ប្រទេស ប៉ារ៉ាហ្គាយ





## 4. អ្នកមានសិទ្ធចូលទៅកាន់បព្វជិតភាព និងពរជ័យរបស់បព្វជិតភាព ។

ដោយសារព្រះបានស្ដារបព្វជិតភាពរបស់ទ្រង់ឡើងវិញតាមរយៈយ៉ូសែប ស្ម៊ីធ អ្នកអាចទទួលបុណ្យជ្រមុជទឹក និងទទួលយកអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធ ។ អ្នកអាចស្វែងរកពរជ័យបព្វជិតភាពនៃការប្រោសឲ្យជា ការលួងលោម និងការដឹកនាំ។ អ្នកអាចធ្វើសេចក្ដីសញ្ញាដ៏ពិសិដ្ឋដែលចងភ្ជាប់អ្នកនឹងព្រះ ។ ហើយអ្នកអាចរំឭកសេចក្ដីសញ្ញារបស់អ្នកសារជាថ្មី នៅរៀងរាល់សប្ដាហ៍ពេលអ្នកទទួលទានសាក្រាម៉ង់ ។ តាមរយៈពិធីបរិសុទ្ធទាំងឡាយនៃបព្វជិតភាព អំណាចនៃព្រះ ចូលមកក្នុងជីវិតរបស់អ្នក ( សូមមើល គ និង ស 84:20–21 ) ។ គ្មានអ្វីនឹងអាចធ្វើទៅបានដោយគ្មានកិច្ចការដែលសម្រេចបានតាមរយៈយ៉ូសែប ស្ម៊ីធឡើយ ។







## 5. អ្នកមានសេរីភាពពីការញៀននឹងសារធាតុគ្រោះថ្នាក់ទាំងឡាយ ។

ឬយ៉ាងហោចណាស់អ្នកអាចមានសេរីភាព បើអ្នកគោរពតាមវិវរណៈដែល យ៉ូសែប បានទទួលនៅក្នុងឆ្នាំ 1833 — ជាច្រើនឆ្នាំមុនពេលដែលថ្នាំជក់ត្រូវបានបញ្ជាក់ពីគ្លីនិក ថាវាបង្កឲ្យមានជម្ងឺមហារីកសួត ហើយគ្រឿងស្រវឹងត្រូវបានតភ្ជាប់ទៅនឹងជម្ងឺថ្លើមទៅទៀត ។ ពេលអ្នកមានព្យាការីបង្ហាញពីប្រាជ្ញានៃព្រះ តើហេតុអ្វីរង់ចាំប្រជ្ញានៃលោកិយដើម្បីតាមឲ្យទាន់វិញ ។ ច្បាប់សុខភាពបង្ហាញថាព្រះមិនត្រឹមតែយកព្រះទ័យទុកដាក់លើព្រលឹងយើងប៉ុណ្ណោះទេ តែទ្រង់ក៏យកព្រះទ័យទុកដាក់ដល់រាងកាយយើងផងដែរ ( សូមមើល គ និង ស 89 ) ។ ទីបំផុត ដូចវិវរណៈចំពោះ យ៉ូសែប ស្ម៊ីធត្រូវបានបើកបង្ហាញឡើង ការទទួលរូបរាងកាយធ្វើឲ្យយើង មានលក្ខណៈសម្បត្តិកាន់តែច្រើនឡើង — ពុំមែនកាន់តែតិចនោះទេ — ដូចជាព្រះវរបិតាសួគ៌យើង ដែលមានរូបកាយជាសាច់និងឆ្អឹងដែរ ( សូមមើល គ និង ស 130:22 ) ។

## ចូលរួមក្នុងការសន្ទនា

### រឿងដើម្បីពិចារណាសម្រាប់ថ្ងៃអាទិត្យ

- តើខ្ញុំអាចពង្រឹងទីបន្ទាល់របស់ខ្ញុំពីព្យាការី យ៉ូសែប ស្ម៊ីធ ដោយរបៀបណា ?
- តើខ្ញុំអាចបង្ហាញការដឹងគុណចំពោះព្យាការីដែលនៅរស់តាមរយៈពាក្យសម្ដី និងសកម្មភាពខ្ញុំ ដោយរបៀបណា ?

### រឿងទាំងឡាយដែលអ្នកអាចធ្វើ

- នៅក្នុងសាសនាចក្រ ជាមួយក្រុមគ្រួសារ និងមិត្តភក្តិរបស់អ្នក ឬក៏ប្រព័ន្ធផ្សព្វផ្សាយសង្គម សូមចែកចាយពីរបៀបដែលព្យាការី យ៉ូសែប ស្ម៊ីធ មានឥទ្ធិពលមកលើជីវិតអ្នក ។
- យ៉ូសែបអ្វីដែល យ៉ូសែប ស្ម៊ីធ បានធ្វើ សូមសួរដល់ព្រះវរបិតាសួគ៌នូវសំណួរទាំងឡាយរបស់អ្នក ។ ញែកពេលវេលាដើម្បីលត់ជង្គង់ចុះនៅក្នុងការអធិស្ឋាន ហើយសូមដល់ទ្រង់សម្រាប់ការដឹកនាំផ្លូវ ។ បន្ទាប់មក សូមរង់ចាំ ហើយផ្ទៀងត្រចៀកស្ដាប់សម្រាប់គំនិត និងអារម្មណ៍ទាំងឡាយ ។ សូមកត់ត្រាគំនិតរបស់អ្នកនៅក្នុងសៀវភៅកំណត់ហេតុរបស់អ្នក ។
- សូមអានប្រសាសន៍ ដែលមានចំណងជើងថា « Joseph Smith » ដោយ អែលឌើរ នែល អិល អាន់ឌើរសិន នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ ពីសន្និសីទទូទៅ ខែ តុលា ឆ្នាំ 2014 ។ សូមធ្វើផែនការ ដើម្បីអនុវត្តគំនិតទាំងពីរនេះ ដែលលោកផ្ដល់ឲ្យក្នុងការស្ដាបនា និងចែកចាយទីបន្ទាល់របស់អ្នក ពីព្យាការី យ៉ូសែប ស្ម៊ីធ ។





## 6. អ្នកអាចដឹងពីការពិតសម្រាប់ខ្លួនឯងតាមរយៈព្រះវិញ្ញាណបរិសុទ្ធ ។

ពេលដែលយ៉ូសែប ដែលមានវ័យក្មេងបានឈានទៅក្នុងព្រៃពិសិដ្ឋនៅក្នុងឆ្នាំ 1820 ជំនឿជាទូទៅក្នុងចំណោមក្រុមជំនុំជាច្រើន គឺថាវិវរណៈជារឿងពីបុរាណប៉ុណ្ណោះ ។ ការនិមិត្តដំបូងរបស់យ៉ូសែប ស្ម៊ីធ បានបង្ហាញថាជំនឿនោះខុស ។ ស្ថានសួគ៌បើកចំហរ — មិនតែចំពោះពួកព្យាការីទេ ។ អ្នកដែលមានសំណួរ អាចទទួលបានចម្លើយតាមរយៈការបន្ទាបខ្លួន និងព្យាយាមស្វែងរក ( សូមមើល គ និង ស 42:61; 88:63 ) ។ ឧទាហរណ៍ អ្នកអាចស្វែងរកដោយខ្លួនឯងថា យ៉ូសែប ស្ម៊ីធ គឺជាព្យាការីរបស់ព្រះ ដូចគ្នានឹងអ្វីដែល យ៉ូសែប ស្ម៊ីធបានរកឃើញដែរ ៖ ដោយសួរព្រះដោយខ្លួនលោកផ្ទាល់ ។

បញ្ជីនេះគឺគ្រាន់តែជាការចាប់ផ្ដើមប៉ុណ្ណោះ ។ តើអ្នកនឹងបន្ថែមអ្វី ? តើជីវិតរបស់អ្នកបានផ្លាស់ប្ដូរយ៉ាងដូចម្ដេចខ្លះ ដោយសារតែ យ៉ូសែប ស្ម៊ីធ ? ■

**កំណត់ចំណាំ**

1. សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ឆ្នាំ ( 2007 ), ទំព័រ 37–44 ។
2. សូមមើល ខ្ញុំជាកូនរបស់ព្រះ *ទំនុកតម្កើង* ទំព័រ 58 ។

# « ព្យាការីដែលនៅរស់ មានសារៈសំខាន់ ជាងព្យាការីដែលបានស្លាប់ទៅ ។ . . .

« . . . វិវរណៈរបស់ព្រះទៅកាន់អ័ដាម មិនបង្រៀនដល់ណូអេពីរបៀបសង់សំពៅទេ ណូអេត្រូវការវិវរណៈផ្ទាល់ខ្លួន ។ ដូច្នេះ ព្យាការីដែលសំខាន់បំផុត គឺជាព្យាការីដែលកំពុងរស់ក្នុងជំនាន់ និងសម័យរបស់យើង ដែលព្រះអម្ចាស់កំពុងបង្ហាញព្រះរាជបំណងសម្រាប់យើង ។ ដូច្នេះ ការអានដ៏សំខាន់បំផុតដែលយើងអាចធ្វើ គឺជាពាក្យសម្ដីទាំងឡាយរបស់ព្យាការី . . . ដែលមានជារៀងរាល់ខែនៅក្នុងទស្សនាវដ្ដីរបស់សាសនាចក្រ ។ ការបញ្ជាទិញរបស់យើង សម្រាប់ប្រាំមួយខែម្ដង គឺរកឃើញនៅក្នុងសុន្ទរកថានៃសន្និសីទទូទៅ ដែលបានបោះពុម្ពនៅក្នុង *[ លីអាហូណា ]* ទស្សនាវដ្ដី ។ . . . »

« សូមប្រយ័ត្នពីអ្នកទាំងឡាយដែលយកព្យាការីដែលបានស្លាប់មកដាក់ប្រឆាំងនឹងព្យាការីដែលនៅរស់ ព្រោះ ព្យាការីដែលនៅរស់ តែងតែមានអាទិភាពជានិច្ច » ។■

*ដកស្រង់ចេញពីប្រធាន អ៊ែសរ៉ា ថាហ្វ ប៊ែនសឹន ( ឆ្នាំ 1899–1994 ) « គោលការណ៍គ្រឹះទាំងដប់បួនយ៉ាង ក្នុងការធ្វើតាមព្យាការី » ( Brigham Young University devotional ថ្ងៃទី 26 ខែកុម្ភៈ ឆ្នាំ 1980 ) ទំព័រ 2 speeches.byu.edu.*



***សូមចែកចាយគំនិតរបស់អ្នក***

តើវាមានន័យចំពោះអ្នកយ៉ាងណា ក្នុងការគាំទ្រព្យាការីដែលនៅរស់ ? សូមចែកចាយគំនិតរបស់អ្នកជាមួយក្រុមគ្រួសារ និង មិត្តភក្តិ ឬប្រព័ន្ធផ្សព្វផ្សាយសង្គមនានា ។

# គំរូរបស់ព្រះអង្គសង្គ្រោះនៃ ការគោរពប្រតិបត្តិ

*គំរូរបស់ទ្រង់បានកំណត់ដានសម្រាប់យើងទាំងអស់ដើម្បីធ្វើតាម ។*

នៅក្នុងសន្និសីទទូទៅ ខែ មេសា ឆ្នាំ 2014 អែលឌើរ រ៉ូបឺត ឌី ហែល នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « មេរៀនទាំងអម្បាលម៉ានដែលយើងរៀនពីឆាកជីវិតរបស់ព្រះសង្គ្រោះ គ្មានមេរៀនណាមួយដែលច្បាស់ និងមានអំណាចជាងមេរៀននៃការគោរពប្រតិបត្តិឡើយ » ។ គំរូរបស់ព្រះអង្គសង្គ្រោះមិនត្រឹមតែបង្រៀនយើងពី *មូលហេតុ* ដែលការគោរពប្រតិបត្តិចំពោះព្រះវរបិតាសួគ៌មានសារៈសំខាន់ប៉ុណ្ណោះទេ តែក៏ *ពីរបៀប* ដែលយើងអាចគោរពប្រតិបត្តិតាមផងដែរ ។ នៅពេលដែលអ្នកពិនិត្យនូវគំរូខាងក្រោមនេះពីការបង្រៀនរបស់ទ្រង់ឡើងវិញ សូមគិតពីរបៀបដែលវាអាចកំណត់ផ្លូវសម្រាប់អ្នកដើម្បីដើរតាមនៅក្នុងជីវិតរបស់អ្នក ។

« ខ្ញុំ មិន រកតាមតែចិត្តខ្ញុំទេ គឺ **តាមព្រះហឫទ័យនៃព្រះវិញ** ដែលទ្រង់ចាត់ឲ្យខ្ញុំមក ។ »

( យ៉ូហាន 5:30; សូមមើលផងដែរ យ៉ូហាន 6:38; 8:28–29; 14:31 )







## តើខ្ញុំអាចធ្វើអ្វីបាន ?

អែលឌើរ ហែលស៍ បានមានប្រសាសន៍ថា « ព្រះយេស៊ូវបានបង្រៀនយើងឲ្យស្ដាប់តាមភាសាដ៏សាមញ្ញដែលងាយយល់ថា ៖ ‹ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ › [ យ៉ូហាន 14:15 ], និង 'Come, follow me' [ លូកា 18:22 ] » ។

**តើអ្នកនឹងធ្វើអ្វីនៅថ្ងៃនេះ ដើម្បីគោរពប្រតិបត្តិឲ្យកាន់តែច្រើន ?**



2



3

**1.** *ទោះបីជាព្រះយេស៊ូវគ្មានអំពើបាបសោះ ក៏ទ្រង់ទទួលយកការជ្រមុជទឹកដើម្បី « ធ្វើសំរេចតាមគ្រប់ទាំងសេចក្ដីសុចរិត »* ( ម៉ាថាយ 3:13–17; សូមមើលផងដែរ នីហ្វៃទី2 31:4–7; យ៉ូហាន 3:5 ) ។

**2.** *នៅអាយុ 12 ឆ្នាំ យ៉ូសែប និងម៉ារា បានឃើញព្រះយេស៊ូវកំពុងបង្រៀននៅក្នុងព្រះវិហារទ្រង់ « បាននៅក្នុងឱវាទរបស់គាត់ » ហើយត្រឡប់មកផ្ទះវិញជាមួយពួកគេដោយស្ដាប់បង្គាប់* ( សូមមើល លូកា 2:42–51 ) ។

**3.** *ទោះបីជាទ្រង់បានសូមឲ្យពែងនេះកន្លងហួសពីទ្រង់ ទ្រង់បានទទួលយកការរងទុក្ខ នៅក្នុងសួនច្បារគែតសេម៉ានីដែរ* ( សូមមើល ម៉ាថាយ 26:36–44; លូកា 22:39–54 ) ។

**4.** *ទ្រង់បានរក្សាថ្ងៃឈប់សម្រាក ហើយបានចូលរួមក្នុងសាលាប្រជុំ* ( សូមមើល លូកា 4:16–44 ) ។

**5.** *ព្រះយេស៊ូវទទួលយកការកាត់ទោសរបស់មនុស្សដូច្នេះកិច្ចការ និងសិរីល្អរបស់ព្រះវរបិតាអាចសម្រេចបាន* ( សូមមើល អេសាយ 53:7; ម៉ាថាយ 26:53; ម៉ូសេ 1:39 ) ។

**6.** *ទ្រង់បានបញ្ចប់កិច្ចការរបស់ទ្រង់ ដោយអនុញ្ញាតឲ្យមនុស្សទុច្ចរិតឆ្កាងទ្រង់* ( សូមមើល ម៉ាថាយ 27:35; យ៉ូហាន 10:17–18; កាឡាទី 1:3–5 ) ។



**ដោយសារតែព្រះអង្គសង្គ្រោះយើងទ្រង់គោរពប្រតិបត្តិ**

« ដោយសារព្រះអង្គសង្គ្រោះយើងទ្រង់គោរពប្រតិបត្តិ ទ្រង់បានធ្វើឲ្យធួននឹងអំពើបាបរបស់យើង ដោយធ្វើឲ្យមានលទ្ធភាពនៃការរស់ឡើងវិញ ហើយរៀបចំផ្លូវសម្រាប់យើងត្រឡប់ទៅព្រះវរបិតាសួគ៌វិញ ជាអង្គដែលជ្រាបថាយើងនឹងមានកំហុស ពេលយើងរៀនគោរពប្រតិបត្តិក្នុងជីវិតរមែងស្លាប់នេះ ។ ពេលយើងគោរពប្រតិបត្តិ យើងទទួលយកពលិកម្មរបស់ទ្រង់ ដ្បិតយើងជឿថាតាមរយៈដង្វាយធួន នៃព្រះយេស៊ូវគ្រីស្ទ នោះមនុស្សលោកទាំងអស់អាចបានសង្គ្រោះតាមរយៈ ការគោរពតាមក្រិត្យវិន័យ ពិធីបរិសុទ្ធទាំងឡាយ និងបទបញ្ញត្តិដែលបានប្រទានឲ្យនៅក្នុងដំណឹងល្អ » ។

អែលឌើរ រ៉ូប៊ើត ឌី ហែលស៍ នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « ‹ បើអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ចូរកាន់តាមបញ្ញត្តរបស់ខ្ញុំចុះ › » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2014, ទំព័រ 35 ។

1. *ការជ្រមុជទឹករបស់ព្រះគ្រីស្ទ* ដោយ យ៉ូសែប ព្រីយើរ; ទំព័រ 2 ។ *កុមារាយេស៊ូវនៅក្នុងព្រះវិហារ* ដោយ គ្រែន រ៉មនី កួសុន;ទំព័រ 7 ។ *ព្រះគ្រីស្ទនៅចំកណ្ដាល* ដោយ ជីឌីត អេ មើរ ទំព័រ 8 ។ *សាតាំង ចូរឯងថយចេញពីអញទៅ* ដោយ ខាល ហេនរីក ប្លូច;ទំព័រ 9 ។ *ការនិមិត្តដំបូងរបស់ យ៉ូសែប ស្ម៊ីធ* ដោយ ហ្វ្រេដ អូលសិន
















8

« ការបង្រៀនរបស់ [ព្រះគ្រីស្ទ] ទាំងមូល ‹ ទ្រង់ **បានរងការល្បួង** ប៉ុន្តែមិនបានរវីរវល់ដល់ [ សេចក្តីទាំងនោះ ] **ឡើយ** › [ គ. និង ស. 20:22 ] » ។

— អែលឌើរ រ៉ូបឺត ឌី. ហែលស៍






**7.** *ទ្រង់គោរពប្រតិបត្តិតាមព្រះវរបិតាទ្រង់ជានិច្ច ព្រះយេស៊ូវបានយាងទៅពិភពវិញ្ញាណ ហើយបានរៀបចំឲ្យមានកិច្ចការផ្សព្វផ្សាយសាសនានៅទីនោះ* **( សូមមើល ពេត្រុសទី 1 3:18–20; 4:6 ) ។**

**8.** *ព្រះយេស៊ូវ ត្រូវបានល្បួងដោយសាតាំង ប៉ុន្តែទ្រង់មិនចាញ់ការល្បួងទេ* **( សូមមើល ម៉ាថាយ 4:1–11; គ. និង ស. 20:22 ) ។**

**9.** *ទ្រង់បន្តធ្វើតាមព្រះហឫទ័យព្រះវរបិតា ហើយដឹកនាំសាសនាចក្រ* **( សូមមើល យ៉ូសែប ស្ម៊ីធ — ប្រវត្តិ 1:16–17; គ. និង ស. 19:2, 24 ) ។**

# ទីកន្លែងរបស់យើង






## អ្នកពន្លត់អគ្គីភ័យ និង គ្រឿងសឹករបស់ព្រះ

វាជាថ្ងៃមួយដ៏ស្ងាត់ស្ងៀមនៅកន្លែងធ្វើការរបស់ខ្ញុំជាអ្នកស្ម័គ្រចិត្តពន្លត់អគ្គីភ័យ ដូច្នេះខ្ញុំបានសម្រេចចិត្តអានព្រះគម្ពីរមរមន ។ ពេលដែលមិត្តរួមការងារម្នាក់របស់ខ្ញុំឃើញខ្ញុំអាន គាត់បានសួរថាបើខ្ញុំបានដឹងពីរបៀបដែលយើងអាចពាក់គ្រឿងសឹករបស់ព្រះនៅក្នុងសម័យទំនើបនេះ ។ នៅពេលដែលយើងកំពុងនិយាយគ្នា កណ្ដឹងប្រកាសអាសន្នបានរោទ៍ឡើង ។ មានភ្លើងឆេះនៅហាងជិតនេះ ។

យើងប្រញាប់ប្រញាល់ស្លៀកពាក់ឯកសណ្ឋានពន្លត់អគ្គីភ័យ ហើយឆ្ពោះទៅទីនោះ ។ ភ្លើងឆេះយ៉ាងសន្ធោសន្ធៅ ហើយយើងបានទៅដល់ហាងនោះ មានអ្វីមួយបានផ្ទុះឡើងនៅទិសដៅរបស់យើង ។ ភ្លើងបានឆាបឆេះពួកយើង ។ ការផ្ទុះនោះបានធ្វើឲ្យខ្ញុំ និងមិត្តរួមការងារខ្ញុំបាត់ស្មារតីអស់ពីរបីនាទី ។ ប៉ុន្តែមានអំណរគុណចំពោះសម្ភារ និងសម្លៀកបំពាក់ការពាររបស់យើង យើងមិនរងរបួសអ្វីទេ ។

ពេលយើងត្រឡប់មកស្ថានីយ៍វិញបន្ទាប់ពីការប្រយុទ្ធនឹងអគ្គីភ័យនោះ ខ្ញុំបានសួរទៅមិត្តរួមការងាររបស់ខ្ញុំថាបើគាត់បានចងចាំសំណួររបស់គាត់អំពីគ្រឿងសឹករបស់ព្រះ ។ គាត់បាននិយាយថា គាត់ចាំ ហើយខ្ញុំពន្យល់ថា គ្រឿងសឹករបស់ព្រះគឺដូចជាសម្លៀកបំពាក់ការពារអគ្គីភ័យរបស់យើងដែរ ។ យើងត្រូវតែពាក់វាជាប់ជានិច្ច ដូច្នេះយើងអាចស៊ូទ្រាំនឹងការវាយប្រហារដ៏មានឥទ្ធិពលនៃមារសត្រូវបាន ។ បើយើងរក្សាព្រះបញ្ញត្តិទាំងឡាយ យើងនឹងត្រូវបានប្រទានពរដោយអំណាចការពារនៃគ្រឿងសឹករបស់ព្រះ ហើយព្រះវិញ្ញាណបរិសុទ្ធនឹងធ្វើជាអ្នកដឹកនាំយើង ។ ■

ហ្វើណាន់ដូ ឌី ឡា រ៉ូសា មកពីទីក្រុងម៉ារ៉ុន ប្រទេសម៉ិកស៊ិក ។



# ខគម្ពីរដែលជាទីពេញចិត្តរបស់ខ្ញុំ

**សាំយ៉ូអែលទី 1 16:7** ។ « ព្រះទ្រង់មិនទតចំពោះសេចក្ដី ដែលមនុស្សលោកពិចារណាមើលទេ ឯមនុស្សលោក តែងមើលតែឫកពាខាងក្រៅប៉ុណ្ណោះ តែព្រះយេហូវ៉ាទ្រង់ទតចំពោះក្នុងចិត្តវិញ » ។

មុនពេលដែលខ្ញុំបានចូលរួមក្នុងសាសនាចក្រ ខ្ញុំតែងតែមើលខ្លួនឯងជាមនុស្សធម្មតា ដែលមានសមត្ថភាពធម្មតា ។ ខ្ញុំមានអារម្មណ៍ថា ខ្ញុំគ្មានអ្វីដែលមានតម្លៃដែលផ្ដល់ជូនទេ ។ ខ្ញុំមានការភ័យខ្លាច ក្នុងការបង្ហាញគេឯងនូវអត្តសញ្ញាណពិតប្រាកដរបស់ខ្ញុំ ពីព្រោះតែការខ្លាចក្រែងការបដិសេធ ហើយឈឺចាប់ ។ ខ្ញុំបានគិតថា អ្នករាល់គ្នានៅជុំវិញខ្ញុំ រឹងមាំជាង ឆ្លាតជាង និងល្អប្រសើរជាងខ្ញុំ ។

តែទស្សនវិស័យទាំងអស់នោះ បានផ្លាស់ប្ដូរពេលដែលខ្ញុំក្លាយជាសមាជិកសាសនាចក្រនៃព្រះយេស៊ូវគ្រីស្ទនៃពួកបរិសុទ្ធថ្ងៃចុងក្រោយ ។ ខ្ញុំបានរៀនថា យើងទាំងអស់គ្នាគឺជាកូនរបស់ព្រះ ហើយយើងនឹងស្នងមរតកគុណសម្បត្តិដ៏ទេវភាពទាំងឡាយ ។ ឥឡូវខ្ញុំយល់ហើយថា វាគ្មានការប្រកួតប្រជែងលើអ្នកណាឆ្លាតជាងមានជាង ឬល្អប្រសើរជាងនរណាម្នាក់ឡើយ ។ នៅក្នុងព្រះនេត្ររបស់ព្រះអម្ចាស់ យើងទាំងអស់គ្នាឈរលើទំនាបស្មើរគ្នា ហើយទ្រង់គឺជាអង្គតែមួយដែលកាត់សេចក្ដី — ដោយមិនផ្អែកលើរូបរាងខាងក្រៅរបស់យើងឡើយ ប៉ុន្ដែដោយការគោរពប្រតិបត្តិតាម និងបំណងចង់ដើរតាមផ្លូវ ដែលទ្រង់បានញែកឲ្យយើង ។ ■

*ចូអាន អាស៊ូសេណា ប្រទេស ហ្វីលីពីន*

## តើអ្នកនឹងធ្វើការនៅថ្ងៃអាទិត្រទេ ?

ពេលខ្ញុំអាយុ15 ឆ្នាំ ខ្ញុំបានទីទ្នាល់ដ៏រឹងមាំមួយពីដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ហើយមានភាពសប្បាយរីករាយ ដើម្បីចូលរួមក្នុងសាសនាចក្រ ។ នៅពេលនោះ ខ្ញុំកំពុងធ្វើដើម្បីជួយគាំទ្រក្រុមគ្រួសាររបស់ខ្ញុំ ។ មិនយូរប៉ុន្មាន បន្ទាប់ពីខ្ញុំបានទទួលបុណ្យជ្រមុជទឹក ខ្ញុំបានបាត់បង់ការងាររបស់ខ្ញុំ ។

ខ្ញុំត្រូវការស្វែងរកការងារថ្មីឲ្យបានឆាប់ដោយសារគ្រួសារខ្ញុំពឹងផ្អែកលើខ្ញុំ ប៉ុន្ដែគ្រប់ការងារដែលខ្ញុំបានដាក់ពាក្យសុំ បានតម្រូវឲ្យខ្ញុំធ្វើការនៅថ្ងៃអាទិត្រ ។ ខ្ញុំបានបដិសេធការងារជាច្រើន ដោយសារខ្ញុំដឹងថា ខ្ញុំត្រូវការនៅព្រះវិហារនៅថ្ងៃអាទិត្រ ( សូមមើល គ និង ស 59:9–10 ) ។

បន្ទាប់ពីពីរខែនៃការស្វែងរកការងារ ខ្ញុំនៅតែមិនអាចរកបានការងារមួយសោះ ។ ម្ដាយរបស់ខ្ញុំ ពុំមែនជាសមាជិកសាសនាចក្រទេ ហើយទោះបីជាគាត់ជឿលើព្រះ គាត់ខឹងសម្បារនឹងខ្ញុំជាខ្លាំងថាខ្ញុំបានបដិសេធការងារច្រើនពេក ។

នៅយប់មួយ គាត់បានសម្លឹងមើលមកខ្ញុំដោយទឹកភ្នែកនៅក្នុងភ្នែករបស់គាត់ ហើយសួរខ្ញុំវា « ហេតុបានជាព្រះបណ្ដោយឲ្យរឿងនេះកើតឡើងចំពោះយើង ពេលដែលឯងពោរពេញដោយក្ដីជំនឿ និងធ្វើអ្វីដែលត្រឹមត្រូវយ៉ាងនេះ ? »

ខ្ញុំបានឆ្លើយថា « ម៉ាក់ ខ្ញុំមិនដឹងថាហេតុអ្វីបានជារឿងនេះកើតឡើងចំពោះយើងទេ ប៉ុន្ដែខ្ញុំដឹងថាខ្ញុំកំពុងធ្វើអ្វីដែលត្រឹមត្រូវ ហើយខ្ញុំដឹងដែរថា ព្រះនឹងប្រទានពរឲ្យយើងក្នុងការធ្វើត្រូវ » ។

នៅព្រឹកបន្ទាប់ មាននរណាម្នាក់បានផ្ដល់ប្រាក់ច្រើនគួរសម្យឲ្យខ្ញុំ ដើម្បីចំណាយលើការជញ្ជូនទំនិញធុនធ្ងន់មួយចំនួន ពីផ្ទះមួយទៅផ្ទះមួយទៀត ។ ការងារនោះត្រូវការប្រើកម្លាំងខ្លាំង ប៉ុន្ដែពេលខ្ញុំទទួលបានកម្រៃ ខ្ញុំបានប្រញាប់ទៅផ្ទះ ហើយអធិស្ឋានដោយអំណរគុណ ។ មិនយូរប៉ុន្មាន ខ្ញុំបានឃើញការងារល្អមួយដែលអនុញ្ញាតឲ្យខ្ញុំឈប់សម្រាកថ្ងៃអាទិត្រ ហើយខ្ញុំមិនដែលអត់ការងារតាំងពីពេលនោះមក ។

ខ្ញុំមានចិត្តរីករាយដែលខ្ញុំបានជ្រើសរើស ដើម្បីរក្សាថ្ងៃបរិសុទ្ធឲ្យបានបរិសុទ្ធ ? មានឧបសគ្គជាច្រើននៅក្នុងជីវិត ប៉ុន្ដែខ្ញុំដឹងថា បើយើងខិតខំនៅរឹងមាំទោះឧបសគ្គទាំងនោះ ព្រះអម្ចាស់នឹងប្រទានពរឲ្យយើង ។ ■

សាសឹល ហ្សាម៉ា មកពី ប្រទេសឥណ្ឌា



ដោយ អែលឌើរ នែល អិល អាន់ឌើរសិន
ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់

# របៀប ដើម្បីមានប្រាជ្ញា

នៅក្នុងជំនាន់នៃរលកព័ត៌មានសព្វថ្ងៃនេះ យើងពិតជាត្រូវការប្រាជ្ញាយ៉ាងខ្លាំង — ប្រាជ្ញាដើម្បី រៀបចំ និង ជឹង ដើម្បីអនុវត្តអ្វីដែលយើងកំពុងរៀន ។

សូមចងចាំ

1. យើងត្រូវតែស្វែងរកប្រជ្ញា ។
2. ប្រាជ្ញាមានច្រើនសណ្ឋាន និង មានលក្ខណៈផ្សេងៗពីគ្នា ។
3. ប្រាជ្ញាដែលទទួលបានភ្លាមៗ នាំមកនូវពរជ័យជាច្រើន ។
4. ប្រាជ្ញាលើផ្នែកអ្វីមួយ នោះវាមិនអាចផ្ទេរទៅផ្នែកមួយផ្សេងទៀតបានទេ ។
5. ថ្វីបើនៅក្នុងករណីជាច្រើនប្រាជ្ញារបស់លោកិយមានតម្លៃក៏ដោយ តែវាមានតម្លៃបំផុត នៅពេលវាឱនចុះយ៉ាងរាបទាបទៅនឹងប្រាជ្ញារបស់ព្រះ ។

ព្រះគម្ពីរបានរៀបរាប់ពីប្រាជ្ញាពីរប្រភេទ ៖ ប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ ។ ប្រាជ្ញារបស់លោកិយមានទាំងចំណុចវិជ្ជមាន និង អវិជ្ជមាន ។ នៅក្នុងការរៀបរាប់ដ៏ងងឹតងងល់បំផុតនោះ វាអាចពិពណ៌នាបានថា ជាចំណែកនៃសេចក្ដីពិតដែលលាយឡំជាមួយនឹងប្រាជ្ញា និង ឧបាយកល ដើម្បីសម្រេចនូវគោលបំណងនៃភាពអត្មានិយម ឬ បំណងអាក្រក់ទាំងឡាយ ។

មានប្រាជ្ញារបស់លោកិយមួយប្រភេទទៀតដែលមិនអាក្រក់ណាស់ណាទេ ។ តាមពិតទៅគឺវាមានភាពវិជ្ជមាន ។ ប្រាជ្ញានេះគឺជាចំណេះដឹងដែលទទួលបានតាមរយៈ ការសិក្សា ការគិតពិចារណា ការអង្កេត និង ការខិតខំធ្វើការ ។ វាមានតម្លៃ និងមានប្រយជន៍ខ្លាំងណាស់ក្នុងអ្វីដែលយើងធ្វើ ៖ ចំពោះមនុស្សល្អ និង ត្រឹមត្រូវ ចំណេះដឹងទាំងនោះកើតមានមកតាមបទពិសោធន៍នៅក្នុងជីវិតរមែងស្លាប់របស់យើង ។

អ្វីដែលសំខាន់ជាងនេះ គឺប្រាជ្ញាដែលនាំមកនូវភាពជោគជ័យនៅក្នុងពិភពលោកនេះ ត្រូវតែមានឆន្ទៈដើម្បីពឹងផ្អែកលើប្រាជ្ញានៃព្រះ ហើយសូមកុំគិតថាវាអាចជំនួសប្រាជ្ញារបស់ព្រះបាននោះឡើយ ។

មិនមែនប្រាជ្ញាទាំងអស់គឺត្រូវបានបង្កើតមកស្មើគ្នានោះទេ ។ យើងត្រូវតែរៀនថា នៅពេលមានភាពផ្ទុយគ្នា រវាងប្រាជ្ញារបស់លោកិយ និង ប្រាជ្ញារបស់ព្រះ នោះយើងត្រូវតែ សម្របឆន្ទៈរបស់យើងទៅនឹងប្រាជ្ញារបស់ព្រះ ។

ខ្ញុំផ្ដល់យោបល់ដល់អ្នកថា សូមដកយកបញ្ហាមួយចំនួនដែលអ្នកជួបប្រទះ ។ សូមគូសបន្ទាត់មួយនៅចំកណ្ដាលក្រដាសមួយសន្លឹក ។ សូមធ្វើបញ្ជីនៃប្រាជ្ញារបស់លោកិយនៅផ្នែកខាងឆ្វេង និង ប្រាជ្ញារបស់ព្រះនៅផ្នែកខាងស្ដាំ ។ សូមសរសេរពីបញ្ហាទាំងឡាយណាដែលមានការប្រកួតប្រជែងគ្នា ។

## តើអ្នកនឹងជ្រើសរើសយកមួយណា ?

នៅក្នុងកណ្ឌទី 45 នៃ គោលលទ្ធិ និង សេចក្ដីសញ្ញា ដែលបានប្រាប់ពីព្រឹត្តិការណ៍ដែលឆ្ពោះទៅរកការយាងមកជាលើកទីពីរនៃព្រះអង្គសង្គ្រោះ នោះព្រះអម្ចាស់បានប្រាប់ម្ដងទៀតនូវរឿងអំពីស្ត្រីព្រហ្មចារីដប់នាក់ ហើយបានបន្យល់នូវបន្ទូលទាំងនេះថា ៖ « ត្បិតពួកអ្នកណាដែលមានប្រាជ្ញា ហើយបានទទួលសេចក្ដីពិត ហើយបានទទួលយកព្រះវិញ្ញាណបរិសុទ្ធទុកជាអ្នកណែនាំរបស់ខ្លួន ហើយដែលពុំត្រូវគេបញ្ឆោត — យើងប្រាប់អ្នកជាប្រាកដថា ពួកគេនឹងពុំត្រូវកាប់បោះចោលទៅក្នុងភ្លើងឡើយ ប៉ុន្តែនឹងធន់នៅថ្ងៃនោះវិញ » ( សូមមើល គ និង ស 45:57 ) ។

សូមឲ្យយើង ស្វែងរកប្រាជ្ញារបស់ព្រះ ។ មានអ្វីៗជាច្រើនដែលយើងអាចរៀនពីប្រាជ្ញាក្នុងពេលឥឡូវនេះ ។ ខ្ញុំសូមសន្យានឹងអ្នកថា ពរជ័យរបស់ព្រះអម្ចាស់នឹងមានមកដល់អ្នកនៅពេលអ្នកស្វែងរកប្រាជ្ញា ដែលជាប្រាជ្ញារបស់ព្រះ ។ ទ្រង់ពិតជាមានព្រះទ័យចង់ប្រគល់ប្រាជ្ញាទ្រង់ដល់យើង ។ ហើយបើយើងនឹងគោរពតាម និងប្រកបដោយការអធិដ្ឋាន ហើយស្វែងរកវា វានឹងមក ។ ■

*ដកស្រង់ចេញពីសុន្ទរកថាដែលបានផ្ដល់នៅ សាកលវិទ្យាល័យ ព្រិកហាំ យ៉ង់ — អៃដាហូធ្វើឡើងនៅថ្ងៃទី 10 ខែ មេសា ឆ្នាំ 2009 ។*

## តើអ្នកធ្លាប់អនុវត្តគោលការណ៍នេះដោយរបៀបណា ?

« វាតែងតែមានលទ្ធភាពពីដើម្បីជ្រើសរើស ។ អ្នកអាចជ្រើសរើសអ្វីដែលអ្នកចង់បាន ។ ប៉ុន្តែ អ្នកគួរតែសម្រេចចិត្តប្រកបដោយប្រាជ្ញា ។ ខ្ញុំអាចនិយាយបានថា ការជ្រើសរើសព្រះអម្ចាស់ អាចជួយអ្នកជារៀងរាល់ថ្ងៃ ហើយការមានព្រះវិញ្ញាណបរិសុទ្ធគង់នៅក្បែរអ្នក អាចជួយអ្នកនៅគ្រប់ស្ថានភាព ។ ការជ្រើសរើសខាងខុស អាចនាំទៅកាន់អារម្មណ៍មិនរីករាយ ជាអារម្មណ៍ដែលនឹងហាក់ដូចជាសេចក្ដីសុខនៅក្នុងពេលដ៏ខ្លី ប៉ុន្តែបន្ទាប់មកអ្នកនឹងឃើញពីលទ្ធផល ហើយអ្នកនឹងសោកស្ដាយយ៉ាងខ្លាំង ចំពោះការសម្រេចចិត្តដែលអ្នកបានធ្វើ ។ ចូរនៅខាងព្រះអម្ចាស់! វាមិនងាយស្រួលជានិច្ចនោះទេ ប៉ុន្តែវាសមនឹងតម្លៃ ! »

*សាំយូអែល ដេ មកពីប្រទេស អូស្ត្រាលី*

# ទៅកាន់គោលដៅ



## តើវាមិនអីទេឬ ក្នុងការទៅ **រាំលេង** ឬ **ទៅជប់លៀង** នៅកន្លែងដែលខ្ញុំដឹងថា **អ្វីមិនល្អ** នឹងកើតឡើង ដើម្បីធ្វើជា **គំរូដ៏ល្អនោះ** ?

សូមសួរខ្លួនឯងថា ៖ « តើគំរូប្រភេទណា ដែលខ្ញុំពិតជាគិតថា ខ្ញុំនឹងធ្វើក្នុងស្ថានភាពបែបនោះ ? » បើអ្នកមានបំណងនឹងទៅកន្លែងណាមួយ ដែលអាចមានថ្នាំញៀន ឬគ្រឿងស្រវឹង សម្លៀកបំពាក់មិនសមរម្យ តន្ត្រីដែលមានពាក្យពេជន៍អាសគ្រាម ឬការរាំធ្វើឲ្យស្រើបស្រាល តើអ្នកនឹងបង្ហាញដល់មនុស្សជាច្រើនថា ពួកគេអាចមានក្ដីសប្បាយរីករាយ ដោយគ្មានរឿងទាំងអស់នោះដោយរបៀបណា ? តើអ្នកដែលនៅជុំវិញខ្លួនអ្នកនឹងគិតយ៉ាងណា — « តើវាមិនមែនជាគំរូដ៏ល្អនៃសេចក្ដីជំនឿ និងបទដ្ឋានទេឬអី ? » ឬ « តើហេតុអ្វី បានជាមនុស្សម្នាក់នោះមកដែរ ? » ក្នុងករណីជាច្រើន អ្នកនឹងធ្វើជាគំរូប្រសើរជាងនេះ ដោយមិនទៅកន្លែងនោះទាល់តែសោះ ពីព្រោះអ្នកនឹងមិនបណ្ដោយខ្លួនឲ្យស្ថិតក្នុងការល្បួងដោយចេតនា ។ ■

## តើ **សាតាំង** មាន **ឥទ្ធិពល** លើគំនិតរបស់ខ្ញុំដល់ **កម្រិតណា**?

ព្រះវរបិតាសួគ៌របស់យើងធានាថា យើងមានសិទ្ធិសេរីភាពខាងសីលធម៌ ជាសមត្ថភាពដើម្បីជ្រើសរើសទង្វើល្អ ឬអាក្រក់ ។ ទ្រង់មិនបង្ខំយើងឲ្យធ្វើល្អទេ ហើយអារក្សក៏មិនអាចបង្ខំយើងឲ្យធ្វើអាក្រក់ដែរ ( សូមមើល *ការបង្រៀនរបស់ប្រធានសាសនាចក្រ ៖ យ៉ូសែប ស្ម៊ីធ* ឆ្នាំ [ 2007 ], ទំព័រ 214 ) ។

ដូច្នេះ ពេលវាកើតឡើងចំពោះគំនិតរបស់អ្នក អារក្សមានឥទ្ធិពលត្រឹមតែពេលដែលអ្នកពេញចិត្តឲ្យថាប៉ុណ្ណោះ ។ ព្យាការី យ៉ូសែប ស្ម៊ីធ បានមានប្រសាសន៍ថា « សាតាំងមិនអាចល្បួងយើងដោយការបញ្ឆោតចិត្តរបស់វាឡើយ លុះត្រាតែយើងយល់ព្រមនឹងវានៅក្នុងដួងចិត្តយើង » ។ ( *ការបង្រៀនរបស់ ៖ យ៉ូសែប ស្ម៊ីធ* ទំព័រ 213 ) ។ លោកក៏បានមានប្រសាសន៍ផងដែរថា « អារក្សគ្មានអំណាចលើយើងទេ លើកលែងតែយើងអនុញ្ញាតឲ្យវាប៉ុណ្ណោះ » ទំព័រ ( 214 ) ។

បន្ថែមពីលើនោះ ព្រះគម្ពីរប្រាប់យើងថា « គ្មាននរណាឡើយក្រៅពីព្រះ ដែលជ្រាបដឹងនូវគំនិតរបស់អ្នក និងបំណងដែលនៅក្នុងដួងចិត្តរបស់អ្នក » ។ ( គ. និង ស. 6:16 ) ដូច្នេះ សាតាំងពិតជាមិនដឹងថាអ្នកកំពុងគិតពីអ្វីទេ ។ វាអាចត្រឹមតែផ្ដល់នូវការល្បួង និងការបញ្ឆោតចិត្តប៉ុណ្ណោះ ។ ប៉ុន្តែ បើអ្នកជ្រើសរើសអនុញ្ញាតឲ្យវា វានឹងទទួលបានអំណាចលើអ្នកខ្លាំងជាងមុន ហើយការល្បួងក៏ខ្លាំងជាងមុនដែរ ។ ដោយសញ្ញាដូចគ្នានេះ បើអ្នកតតាំងនឹងទង្វើអាក្រក់ ហើយជ្រើសរើសទង្វើល្អវិញ អ្នកនឹងរឹងមាំ និងបានពរ ។ ■

# ហ្វូងតែមួយ និង អ្នកគង្វាលតែមួយ

*ការដាក់របងជុំវិញហ្វូងចៀម បង្រៀនយើងអំពីព្រះទ័យយកចិត្តទុកដាក់របស់ព្រះអង្គសង្គ្រោះចំពោះកូនចៅរបស់ទ្រង់ ។*




ក្រោលចៀមសម័យបុរាណ

***តើវាជាអ្វី ៖*** ជាបិចធម្មតាមួយ ជញ្ជាំងរបង ។

***គោលបំណង ៖*** ដើម្បីការពារហ្វូងចៀមប្រឆាំងនឹងសត្វរំពា និងចោរ ជាពិសេសនៅពេលយប់ ។

***សម្ភារ និង សំណង់ ៖*** ជាធម្មតាមានថ្ម ជារឿយៗមានចម្រាសបន្លាដាក់លើដំបូលជញ្ជាំង ។ ចម្រាសបន្លាក្រាស់ក៏ប្រើដើម្បីធ្វើរបងសម្រាប់ក្រោចៀមបណ្ដោះអាសន្នរបស់ ជាញឹកញាប់ផងដែរ ។ ពេលខ្លះ គុហាបម្រើជាក្រោលចៀម ដោយមានថ្មតូចៗ ឬចម្រាសបន្លាជារបាំងដាក់នៅពីមុខពួកវា ។



## រឿងពិតពីព្រះគម្ពីរបរិសុទ្ធ

- ចៀមមានតម្លៃខ្លាំងណាស់សម្រាប់សាច់ ទឹកដោះ ខ្លាញ់ រោម ស្បែក និងស្នែង ហើយគឺជាសត្វថ្វាយយញ្ញបូជាដ៏សំខាន់បំផុត ។
- នៅក្នុងស្រុកអ៊ីស្រាអែល ចចក ឆ្កែព្រៃ ខ្លារខិន និងកញ្ជ្រោង គឺជាពពួកសត្វព្រៃដែលចាំវាយប្រហារសត្វចៀម ។ នៅសម័យបុរាណ តោ និងខ្លាឃ្មុំក៏រស់នៅតំបន់នោះដែរ ( សូមមើល សាំយូអែលទី 1 17:33–37 ) ។
- អ្នកគង្វាលប្រើដំបងដើម្បីដឹកនាំសត្វចៀម ហើយដំបងនិងខ្សែដង្ហក់ដើម្បីការពារពួកវា ។
- អ្នកគង្វាលម្នាក់បានដឹកនាំសត្វចៀមរបស់គាត់ ទៅរកចំណី និងទឹកនៅពេលថ្ងៃ ( សូមមើល ទំនុកដំកើង 23:1–2 ) ហើយត្រឡប់ទៅក្រោលវិញនៅពេលយប់ ។ អ្នកគង្វាលនឹងរាប់ចំនួនសត្វចៀមពេលដែលពួកវាត្រឡប់មកវិញ រកមើលថាបើមានចៀមណាបានវង្វេងបាត់ទេ ។ បន្ទាប់មក គាត់នឹងដេកសម្រាកនៅមាត់ទ្វារដើម្បីការពារពួកវា ។
- ព្រះយេស៊ូវគ្រីស្ទ បានហៅអង្គទ្រង់ថាជា អ្នកគង្វាលល្អ ( សូមមើល យ៉ូហាន 10:11–15 ) ដោយសារទ្រង់ស៊ូប្ដូរជីវិតទ្រង់នឹងយើង ។ ទ្រង់ក៏បានប្រៀបធៀបអង្គទ្រង់ផ្ទាល់ទៅនឹងទ្វានៃក្រោលចៀមផងដែរ ( សូមមើល យ៉ូហាន 10:1–9 ) ដោយសារតាមរយៈទ្រង់ យើងទទួលបានការបើបាច់ខាងវិញ្ញាណ ការសម្រាក ភាពសុខសាន្ត ការសង្គ្រោះ និងការលើកកម្ពើង ។
- សាវកប៉ុល បានប្រៀបធៀបសាសនាចក្រទៅនឹងហ្វូងចៀម ( សូមមើល កិច្ចការ 20:28 ) ។

រូបភាពដោយ ដាន់ ប៊ឺរ ; ពីផ្ទាំងគំនូរ *ព្រះគ្រីស្ទ និង អ្នកគង្វាលនៅយូដា* ដោយ ហេនរីក ហូហ្វមែន



**ចៀមឯទៀត**

ព្រះអង្គសង្គ្រោះបានមានបន្ទូលពី « ចៀមឯទៀត . . . ដែលមិនទាន់នៅក្នុងក្រោលនេះនៅឡើយ ( យ៉ូហាន 10:16 ), មានន័យពីពួកសាសន៍នីហ្វៃ និងសាសន៍លេមិន ដែលត្រូវបាននាំចេញឆ្ងាយពីផ្ទះនៃអ៊ីស្រាអែល ( សូមមើល នីហ្វៃទី 3 15:14–24 ) ។ ទ្រង់ក៏មានបន្ទូលពីការទៅចំពោះពួកកុលសម្ព័ន្ធនៃសាសន៍អ៊ីស្រាអែលដែលវង្វេងបាត់ ( សូមមើល នីហ្វៃទី 3 15:20; 16:1–3 ) ។

## អ្វីដែលយើងអាចរៀន

ក្រោលចៀមគឺជា ៖

***កន្លែងដែលហ្វូងចៀមប្រមូលផ្ដុំ ។*** ក្នុងនាមជាសមាជិកសាសនាចក្រ យើងមានចំណងនៃភាពសាមគ្គី តាមរយៈសេចក្ដីជំនឿ និងសេចក្ដីសញ្ញារបស់យើង ក៏ដូចជាតាមរយៈការប្រមូលផ្ដុំគ្នាផងដែរ ។ ប្រធាន ហិនរី ប៊ី អាវរិងជាទីប្រឹក្សាទីមួយនៅក្នុងគណៈប្រធានទីមួយបានបង្រៀនថា ៖ « សេចក្ដីអំណរនៃភាពសាមគ្គីដែលព្រះវរបិតាសួគ៌ចង់ប្រទានឲ្យដល់យើងខ្លាំងបំផុត គឺមិនមែនតែម្នាក់ឯងទេ ។ យើងត្រូវតែស្វែងរកវា ហើយនឹងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់វាជាមួយនឹងអ្នកផ្សេង ។ វាមិនគួរឲ្យភ្ញាក់ផ្អើលដែលថាព្រះជម្រុញយើងឲ្យប្រមូលផ្ដុំ ដូច្នេះទ្រង់អាចប្រទានពរដល់យើង ។ ទ្រង់ចង់ឲ្យយើងប្រមូលផ្ដុំនៅក្នុងក្រុមគ្រួសារ ។ ទ្រង់បានបង្កើតថ្នាក់ វួដ និងសាខាជាច្រើន ហើយបានបញ្ជាយើងឲ្យជួបជុំគ្នាជារឿយៗ ។ នៅក្នុងការប្រមូលផ្ដុំទាំងនោះ . . . យើងអាចអធិស្ឋានសម្រាប់ភាពសាមគ្គីដែលនឹងនាំយើងនូវសេចក្ដីអំណរ និងពង្រីកអំណាចរបស់យើងដើម្បីបម្រើ » ( « ដួងចិត្តរបស់យើង រួបរួមតែមួយ » *លីអាហូណា* ខែ វិច្ឆិកា ឆ្នាំ 2008, ទំព័រ 69 ) ។

***កន្លែងដែលមានសុវត្ថិភាព និងសម្រាក ។*** នៅក្នុងព្រះយេស៊ូវគ្រីស្ទ យើង « បានសេចក្ដីសម្រាកដល់ព្រលឹង » ( ម៉ាថាយ 11:29 ) ។ សាសនាចក្ររបស់ទ្រង់គឺជា« ជាទីការពារ និង . . . ជាទីជ្រកកោន » ( គ និង ស 115:6 ) ។ ហើយដូចជាប្រធាន ប៊ិយដ៍ ឃេ ផាកកឺ ជាប្រធាននៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់ បានបង្រៀនថា « យើងរកឃើញសុវត្ថិភាព និង ភាពកក់ក្ដៅសម្រាប់ខ្លួនយើង . . . ក្នុងការគោរពតាមសេចក្ដីសញ្ញា ដែលយើងបានធ្វើ និង រស់នៅក្នុងទង្វើដ៏សាមញ្ញនៃការគោរពតាម ដែលជាការតម្រូវសម្រាប់អ្នកដើរតាមព្រះគ្រីស្ទ ។ ( « These Things I Know » *លីអាហូណា* ខែ ឧសភា ឆ្នាំ 2013 ទំព័រ 7 ) ។

***បានការពារដោយអ្នកគង្វាល ។*** ព្រះយេស៊ូវគ្រីស្ទ គឺជាអ្នកគង្វាលល្អដែលបានសង្គ្រោះយើង ។ ទ្រង់រងទុក្ខ ហើយបានសុគត ដូច្នេះយើងអាចយកឈ្នះអំពើបាប និងសេចក្ដីស្លាប់ ហើយត្រឡប់ទៅរកព្រះវរបិតាសួគ៌របស់យើងវិញ ។ នៅពេលដែលយើងមកឯព្រះគ្រីស្ទ ហើយគោរពតាមបទបញ្ញត្តិទាំងឡាយរបស់ទ្រង់ នោះទ្រង់នឹងប្រទានពរ ដឹកនាំ និងការពារយើងរៀងៗខ្លួន និងជាប្រជាជននៃសេចក្ដីសញ្ញារបស់ទ្រង់ផងដែរ ។ ■

# « តើខ្ញុំអាចមានទំនុកចិត្តគ្រប់គ្រាន់ល្មម ដើម្បីនិយាយទៅកាន់ប៊ីស្សពរបស់ខ្ញុំអំពី បញ្ហានានា ឬកង្វល់ដោយរបៀបណា ? »

អ្នកអាចមានអារម្មណ៍ភ័យខ្លាច ដើម្បីនិយាយទៅប៊ីស្សពរបស់អ្នកអំពីអ្វីដែលអ្នកកំពុងពុះពារ ហើយនោះគឺជារឿងធម្មតាទេ ។ ជារឿយៗ យើងមានការភ័យខ្លាចចំពោះបទពិសោធន៍ថ្មី ឬចំពោះការនិយាយជាមួយនឹងមនុស្សពេញវ័យ ។

ប៉ុន្តែ ប៊ីស្សពរបស់អ្នកត្រូវបានហៅដោយព្រះ ។ លោកត្រូវបានហៅដោយសារលោកបានប្ដេជ្ញាចិត្តក្នុងនាមជាសិស្សរបស់ព្រះយេស៊ូវគ្រីស្ទ ។ លោកនឹងធ្វើយ៉ាងល្អបំផុតដោយចិត្តរាបសា និង ការយោគយល់ ។ គោលបំណងរបស់លោក គឺដើម្បីជួយអ្នកមកកាន់ព្រះអង្គសង្គ្រោះ ដើម្បីឲ្យអ្នកអាចរកឃើញសេចក្ដីសុខសាន្ត ។ ជាដំបូងអ្នកអាចមានអារម្មណ៍ខ្មាស់អៀន ដើម្បីនិយាយទៅកាន់លោកអំពីសំណួរ ឬអំពីបាបរបស់អ្នក ប៉ុន្តែលោកនឹងមិនគិតមើលងាយអ្នកឡើយ ។ តាមពិតទៅ លោកនឹងរីករាយដែលអ្នកមានបំណង ដើម្បីកែលម្អ ។ ហើយលោកនឹងរក្សាការសន្ទនារបស់អ្នក ជាការសម្ងាត់ ។

អ្នកមិនចាំបាច់រែកពន់បន្ទុករបស់អ្នកតែម្នាក់ឯងទេ ។ ប៊ីស្សពរបស់អ្នកអាចជួយអ្នករកឃើញចម្លើយទៅ នឹងសំណួររបស់អ្នក ហើយបើចាំបាច់ លោកនឹងជួយអ្នកឲ្យកែប្រែចិត្ត ហើយយកឈ្នះលើអារម្មណ៍ខុសឆ្គង ភាពអស់សង្ឃឹម ឬភាពមិនសក្ដិសម តាមរយៈដង្វាយធួនរបស់ព្រះគ្រីស្ទ ។

នៅពេលដែលអ្នកនិយាយទៅកាន់ប៊ីស្សពរបស់អ្នក អ្នកនឹងមានអារម្មណ៍ពីក្ដីស្រឡាញ់របស់លោកចំពោះអ្នក ។ ទោះបីជា លោកមានទំនួលខុសត្រូវសម្រាប់វួដទាំងមូលក្ដី ការផ្ដោតសំខាន់របស់លោកគឺជា សុខុមាលភាពនៃយុវជន និងយុវនារីដែរ ។ អ្នកមិនរំខានលោកដោយការសូមជំនួយនោះទេ ។

អ្នកអាចអធិស្ឋានទៅព្រះវរបិតា សម្រាប់កម្លាំង និងភាពក្លាហានដើម្បីនិយាយទៅកាន់ប៊ីស្សពរបស់អ្នក ។ ទ្រង់បានអនុញ្ញាតឲ្យប៊ីស្សពអ្នកជួយអ្នក ហើយប៊ីស្សពអ្នក ចង់ធ្វើដូច្នោះដែរ ។ នៅពេលដែលអ្នកទៅដោយបើកដួងចិត្ត និងប្រាថ្នាដើម្បីបានល្អប្រសើរជាងមុន អ្នកនឹងរកឃើញថា អ្នកចាកចេញពីការិយាល័យរបស់លោក ដោយមានអារម្មណ៍ល្អប្រសើរជាងពេលមុន ។

**លោកនឹងមិនគិតមើលងាយអ្នកឡើយ**

ប៊ីស្សពនៃវួដរបស់អ្នក គឺត្រូវបានផ្ដល់នូវសិទ្ធិអំណាច ដើម្បីដឹកនាំអ្នកតាមរយៈជំហាននៃការកែប្រែចិត្ត ។ ពេលខ្លះ ការងាកទៅរកប៊ីស្សពរបស់អ្នក គឺជាវិធីតែមួយគត់សម្រាប់អ្នក ដើម្បីកែប្រែចិត្តយ៉ាងពេញលេញ តាមរយៈព្រះអង្គសង្គ្រោះ ។ នៅពេលដែលខ្ញុំត្រូវការនិយាយទៅកាន់ប៊ីស្សពរបស់ខ្ញុំ លោកបានជួយខ្ញុំឲ្យស្វែងរកព្រះអង្គសង្គ្រោះ ហើយជំនះលើមុខរបួសជ្រៅបំផុតដែលខ្ញុំមាន ។ ប៊ីស្សពរបស់អ្នក ចង់ជួយអ្នក ។ ការហៅបម្រើរបស់លោក គឺដើម្បីយកចិត្តទុកដាក់ចំពោះអ្នក ហើយលោកនឹងមិនគិតមើលងាយអ្នកដោយសារតែអ្វីដែលអ្នកត្រូវការជួបលោកដើម្បីដោះស្រាយនោះឡើយ ។

*ម៉ាឌីសុន ឌី អាយុ 18 ឆ្នាំ យូថាហ៍ សហរដ្ឋ អាមេរិក*

**ប៊ីស្សពរបស់អ្នក នឹងពេញចិត្តដើម្បីជួយ**

ខ្ញុំធ្លាប់មានអារម្មណ៍មិនស្រួលក្នុងការសម្ភាសន៍ ប៉ុន្តែនៅទីបំផុត ខ្ញុំបានដឹងថាប៊ីស្សពរបស់ខ្ញុំ គឺតែងតែពេញចិត្តដើម្បីជួយខ្ញុំដោះស្រាយបញ្ហារបស់ខ្ញុំ ។ សូមជឿទុកចិត្តលើប៊ីស្សពរបស់អ្នក លោកគឺជាអ្នកគង្វាល ហើយវួដទាំងមូលគឺជាហ្វូងចៀមរបស់លោក ។

*ជេមស៍ អរ អាយុ 19 ឆ្នាំ កូកាបាំបា ប្រទេស បូលីវី*



**លោកនឹងមិនក្បត់សេចក្ដីទុកចិត្តរបស់អ្នកឡើយ**

ខ្ញុំបានដឹងថា ប៊ីស្សពគឺប្រហែលជាមនុស្សពេញវ័យគួរឲ្យទុកចិត្តបំផុត ដែលក្មេងជំទង់អាចស្វែងរកជំនួយពី ។ លោកនឹងមិនក្បត់សេចក្ដីទុកចិត្តរបស់អ្នកឡើយ — អ្វីគ្រប់យ៉ាងដែលអ្នកចែករំលែកជាមួយលោកនៅក្នុងការិយាល័យលោក ។ ពេលខ្លះវាមានការលំបាកខ្លាំងណាស់ ដើម្បីចែករំលែកបញ្ហារបស់អ្នក ប៉ុន្តែការនិយាយផ្ទាល់មុខជាមួយនរណាម្នាក់ ដែលស្រឡាញ់ និងយកចិត្តទុកដាក់ ហើយចង់បានអ្វីដែលល្អបំផុតសម្រាប់អ្នក ធ្វើឲ្យវាងាយស្រួលជាងមុន ។

*នីកូល អេស អាយុ 18 ឆ្នាំ មកពីរដ្ឋអៃដាហូ ប្រទេស ស.រ.អា*



*ចម្លើយទាំងឡាយគឺសម្រាប់ជាគោលបំណងទុកជាជំនួយ និង ជាទស្សនវិស័យ មិនមែនជា ការប្រកាសអំពីគោលលទ្ធិសាសនាចក្រជាផ្លូវការនោះទេ ។*



**អ្នកអាចពឹងផ្អែកលើលោក**

ប៊ីស្សព ឬប្រធានសាខារបស់អ្នក គឺជាអ្នកបម្រើពិតរបស់ព្រះអម្ចាស់ ។ អ្នកអាចពឹងផ្អែកលើលោកសម្រាប់ការណែនាំនៅពេលដែលអ្នកស្វែងរកការបំផុសគំនិត ពីព្រះវិញ្ញាណបរិសុទ្ធ និងពីព្រះគម្ពីរ ។ អ្នកត្រូវតែយល់ថា ប៊ីស្សពនៅទីនោះដើម្បីជួយ ហើយថាលោកត្រូវបានដឹកនាំដោយព្រះ ។

*ស្តានីស្លូវ អរ អាយុ 19 ឆ្នាំ មកពីទីក្រុងដូនេស ប្រទេសអ៊ុយក្រែន*



**សូមចងចាំថា លោកស្រឡាញ់អ្នក**

បើអ្នកមានអ្វីដែលអ្នកពិតជាចង់ពិភាក្សាជាមួយនឹងប៊ីស្សព វាប្រហែលជាងាយស្រួលជាង ដោយជជែកជាមួយលោក អំពីសាលារៀន និងរឿងទូទៅជាមុនសិន ។ បើអ្នកភ័យខ្លាច ដោយសារអ្នកត្រូវការនិយាយនឹងលោកអំពីបញ្ហាការកែប្រែចិត្ត សូមគ្រាន់តែចងចាំថាលោកស្រឡាញ់អ្នក ។ អ្នកមិនត្រូវភ័យខ្លាចអំពីអ្វីដែលលោកនឹងគិតពីអ្នកឡើយ ព្រោះថាមូលហេតុអ្វីបានជាលោកមើលងាយអ្នក ចំពោះការចង់ខិតទៅជិតព្រះគ្រីស្ទកាន់តែខ្លាំងនោះ ?

*អាស្លី ឌី អាយុ 17 ឆ្នាំ រដ្ឋអារីហ្សូណា ស.រ.អា*



**អធិស្ឋានដើម្បីឲ្យបានដឹង**

សូមសួរខ្លួនឯងថា ហេតុអ្វីបានជាអ្នកមានអារម្មណ៍មិនកក់ក្ដៅក្នុងការនិយាយទៅកាន់ប៊ីស្សព ។ តើអ្នកគិតថាលោកនឹងមិនអាចជួយអ្នកដោះស្រាយបញ្ហារបស់អ្នកឬ ? អធិស្ឋានដើម្បីឲ្យបានដឹងថា ប៊ីស្សពស្រឡាញ់អ្នក ហើយត្រូវបានហៅឲ្យជួយអ្នក ។

*អាដាម អេច អាយុ 13 ឆ្នាំ រដ្ឋ កាលីហ្វូញ៉ា ស.រ.អា*

**ទោះបីជាអ្នកធ្វើខុសក៏ដោយ**

វាអាចមានការពិបាក និងខ្មាសអៀន ដើម្បីសារភាពនូវអ្វីៗទាំងឡាយទៅកាន់ប៊ីស្សពរបស់អ្នក ប៉ុន្តែពេលអ្នកដើរចេញពីការិយាល័យនោះ អ្នកនឹងមានអារម្មណ៍ធូរស្រាល ហើយអ្នកនឹងដឹងថា ព្រះវរបិតាសួគ៌ស្រឡាញ់អ្នក ។ ទ្រង់ចង់ឲ្យអ្នកបានរីករាយ ទោះបីជាអ្នកធ្វើខុសក៏ដោយ ។

*អាម៉ែនដា ដឺបបលយូ អាយុ 16 ឆ្នាំ យូថាហ៍ សហរដ្ឋ ស.រ.អា*

**លោកនៅទីនេះដើម្បីជួយ**

ប៊ីស្សពគឺជាអ្នកគង្វាលក្នុងវួដរបស់អ្នក ។ សូមចងចាំថា លោកនឹងព្យាយាមឲ្យអស់ពីសមត្ថភាព ដើម្បីជួយអ្នក ហើយលោកមានអំណាចនៃព្រះទ្រទ្រង់លោក ។ អ្នកអាចអធិស្ឋានទៅព្រះវរបិតាសុំកម្លាំង និងភាពក្លាហាន ដើម្បីអាចនិយាយទៅកាន់ប៊ីស្សពរបស់អ្នក ។ នៅទីបញ្ចប់ អ្នកនឹងរីករាយដែលអ្នកបានទៅរកលោក — ហើយវានឹងសមថ្លៃនឹងការខិតខំនោះ ។

*សេមួល អេច អាយុ 14 ឆ្នាំ មកពីរដ្ឋអៃដាហូ ប្រទេសស.រ.អា*

*សម្រាប់ព័ត៌មានបន្ថែមលើប្រធានបទនេះ សូមមើល ស៊ី ស្កត គ្រូវ « ហេតុអ្វី និងអ្វីដែលខ្ញុំត្រូវសារភាពទៅកាន់ប៊ីស្សពខ្ញុំ ? » លីអាហូណា ខែ តុលា ឆ្នាំ 2013, ទំព័រ 59 ។*



**ចូរទុកចិត្តនឹងលោក**

« ស្វែងរកដំបូន្មានពីអ្នកដឹកនាំបព្វជិតភាពរបស់អ្នក ជាពិសេសប៊ីស្សពរបស់អ្នក ។ លោកយល់ដឹងអំពីបទដ្ឋានទាំងឡាយ ហើយលោកដឹងអំពីអ្វីដែលលោកត្រូវបង្រៀនដល់អ្នក ។ ចូរស្វែងរកឱកាស ដើម្បីនៅជាមួយលោក ។ អ្នកអាចរំពឹងថា លោកនឹងសួរនូវសំណួររុករកយ៉ាងយ៉ាងចំៗ ។ ចូរទុកចិត្តលោក ។ ចូរទុកចិត្តនឹងលោក ចូរសូមលោកឲ្យជួយអ្នកយល់ពីអ្វីដែលព្រះអម្ចាស់រំពឹងពីអ្នក ។ សូមធ្វើការតាំងចិត្តមួយដើម្បីរស់នៅឲ្យស្របទៅនឹងបទដ្ឋានសីលធម៌របស់សាសនាចក្រ ។ មិត្តភាពដ៏មានតម្លៃជាមួយនឹងអ្នកដឹកនាំចំណាស់ គឺសំខាន់ដើម្បីជួយអ្នករក្សាសីលធម៌ស្អាតស្អំ និងមានភាពសក្ដិសម » ។

អែលឌើរ អែលឌើរ អិម រ័សុល បាឡឹដ ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់ « Purity Precedes Power » *Ensign,* ខែ វិច្ឆិកា ឆ្នាំ 1990, ទំព័រ 37 ។

## សំណួរនាពេលខាងមុខ

« ខ្ញុំត្រូវបានគេចំអកឲ្យនៅសាលារៀន ដោយសារខ្ញុំជាពួក អិល.ឌី.អែស ។ ខ្ញុំដឹងថាខ្ញុំត្រូវឈរទ្រទ្រង់ចំពោះអ្វីដែលខ្ញុំជឿ ប៉ុន្តែវាអាចពិបាកណាស់ ! តើខ្ញុំអាចមានភាពក្លាហានគ្រប់គ្រាន់ល្មម ដើម្បីប្រាប់មនុស្សទាំងនោះឲ្យឈប់ដោយរបៀបណា ? »

ប្រសិនបើអ្នកមានបំណង សូមផ្ញើចម្លើយរបស់អ្នក និងរូបថតច្បាស់មួយសន្លឹក ត្រឹម ថ្ងៃទី1 ខែ ឧសភា 2015 នៅគេហទំព័រ liahona.lds.org តាមអ៊ីមែលទៅអាស័យដ្ឋាន liahona@ldschurch.org ឬតាមសំបុត្រ ( សូមមើលអាស័យដ្ឋាននៅទំព័រទី 3 ) ។

ព័ត៌មាន និង ការអនុញ្ញាតខាងក្រោម ត្រូវតែបញ្ចូលនៅក្នុងអ៊ីម៉ែល ឬ សំបុត្ររបស់អ្នក ៖ ( 1 ) នាមត្រកូលទាំងមូល ( 2 ) ថ្ងៃខែឆ្នាំកំណើត ( 3 ) វួដ ឬ សាខា ( 4 ) ស្តេក ឬ មណ្ឌល ( 5 ) សំបុត្រអនុញ្ញាតដែលមានជាលាយលក្ខណ៍អក្សររបស់អ្នក ហើយបើសិនអ្នកមានមានអាយុក្រោម 18 ឆ្នាំ នោះត្រូវមានសំបុត្រអនុញ្ញាតពីឪពុកម្ដាយរបស់អ្នកជាលាយលក្ខណ៍អក្សរ ( អ៊ីម៉ែល អាចទទួលយកបាន ) ដើម្បីធ្វើការបោះពុម្ពចម្លើយ និង រូបថតរបស់អ្នក ។

ចម្លើយអាចនឹងត្រូវបានកែសម្រួលឡើងវិញ បើវាវែងពេក ឬមិនសូវច្បាស់លាស់ ។

*អេលី បានដឹងថាអ្នកណាជាវីរបុរសរបស់នាង ប៉ុន្តែនាងមានការភ័យខ្លាចនឹងនិយាយវា ។*

# តើនរណាជា

**ដោយឆាឡូត មៃ ស្ប៉ាង**
ផ្អែកទៅលើដំណើររឿងពិត

*« ប្រកាន់ខ្ជាប់នូវកិត្តិយស និងជំនឿអ្នកឈរដូចជាវីរបុរសច្បាំងដល់ស្លាប់ »។*
*( សៀវភៅចម្រៀងកុមារ ទំព័រ 80 ) ។*



អេលី បានខាំក្រចកមេដៃនាងដោយការភ័យខ្លាច ។ អ្នកគ្រូ ហ្វីតស៍ បានដើរតាមជួរតុ ហើយសួរសិស្សម្នាក់ម្ដងៗនូវសំណួរនេះ ។

« តើនរណាជាវិរបុរសរបស់អ្នក ? » អ្នកគ្រូ ហ្វីតស៍ បានសួរ ជេរ៉េមី ។

ជេរ៉េមី មិនបានខ្វះខ្វាយពេលវេលាក្នុង

រចនារូបភាពដោយ ក៉ាឡូ ហ្វាប្រេទី

# វីរបុរស របស់អ្នក ?

ការឆ្លើយតបទេ ។ ដេវមីបានឆ្លើយដោយមោទនភាពថា « ឪពុករបស់ខ្ញុំ » ។

អ្នកគ្រូ ហ្វីតស៍ ញញឹម ។ « ចុះប្អូនវិញ សារ៉ា ? »

ចម្លើយរបស់នាងក៏មកយ៉ាងឆាប់រហ័សដែរ ។ « អ័ប្រាហាំ លីនខុន » ។

អេលីមានអារម្មណ៍ថាបេះដូងនាងលោតយ៉ាងញាប់ ពេលអ្នកគ្រូ ហ្វីតស៍ បានបន្តចុះតាមជួរសិស្ស ។ ពួកគេបាននិយាយពីវីរបុរសពេលមួយថ្ងៃ ហើយឥឡូវនេះអ្នកគ្រប់គ្នាត្រូវនិយាយថាវីរបុរសរបស់គេជានរណាហើយ — នៅចំពោះមុខថ្នាក់ទាំងមូល !

អេមបើរ និង ចាស្ទីន បាននិយាយថាម្ដាយពួកគេជាវីរបុរសរបស់គេ ។ វ៉លធើរ បាននិយាយថាលោកតាជាវីរបុរស ។ សិស្សពីរបីនាក់ដទៃទៀតបាននិយាយថា ស្ដេច ឬប្រធានាធិបតីជាវីរបុរសពួកគេ ។

នៅសល់តែសិស្សពីរបីនាក់ប៉ុណ្ណោះដែលមិនទាន់បាននិយាយ អ្នកគ្រូ ហ្វីតស៍ បានហៅ អេលី ។ នាងត្រូវតែគិតពីវីរបុរសណាម្នាក់ — យ៉ាងលឿន ។

អេលីមើលចុះទៅស្បែកជើងនាងដោយក្ដីខ្មាសអៀន ។ ការគិតឃើញវីរបុរសម្នាក់មិនមែនជាបញ្ហាពិតប្រាកដទេ ។ នាងពិតជាបានដឹងថាអ្នកណាជាវីរបុរសរបស់នាងហើយ ។ គឺជាព្រះយេស៊ូវគ្រីស្ទ ។ ទ្រង់បានប្រោសអ្នកជម្ងឺឲ្យជា ប្រោសអ្នកស្លាប់ឲ្យរស់ឡើងវិញ ហើយបានបង់ថ្លៃសម្រាប់អំពើបាបរបស់មនុស្សគ្រប់គ្នា ។ ទ្រង់គឺជាវីរបុរសដែលអស្ចារ្យជាងគេក្នុងប្រវត្តិនៃពិភពលោក ! នាងគ្រាន់តែមានការភ័យខ្លាចដើម្បីនិយាយវាចេញ ។

អេលីងានខាំក្រចកមេដៃរបស់នាងម្ដងទៀត គិតពីការប្រាប់ថ្នាក់ទាំងមូលថា ព្រះយេស៊ូវគ្រីស្ទ គឺជាវីរបុរសរបស់នាង ។ ចុះបើ ដេវមីសើចចំអកឲ្យនាងវិញ ? ចុះបើ សារ៉ា និង អេមបើរ ខ្សឹបខ្សៀវគ្នាពីនាងនៅពេលចេញលេងវិញនោះ ?

ប្រាកដណាស់ នាងបានដឹងថាព្រះយេស៊ូវគ្រីស្ទ គឺជាវីរបុរសរបស់នាង ។ ប៉ុន្តែ វាមិនមានន័យថាមនុស្សផ្សេងទៀត ត្រូវដឹងដែរទេ ។



អ្នកគ្រូ ហ្វីតស៍ បានឈប់នៅចំពីមុខតុរបស់ អេលី ហើយបានញញឹម ។ « ហើយតើនរណាជាវីរបុរសរបស់អ្នក អេលី ? »

អេលីបានក្រឡេកមើលពីជួរសិស្សនៅក្បែរនាង រហូតដល់អ្នកគ្រូ ហ្វីតស៍ ។ នាងបានខ្សឹបថា « អ័ប្រាហាំ លីនខុន » ។

អ្នកគ្រូ ហ្វីតស៍ បាននិយាយទាំងញញឹម ។ គាត់បាននិយាយថា « ល្អ ! » ពេលគាត់ដើរទៅជួរសិស្សបន្ទាប់ ។

ពេលដែលគាត់បានចេញបាត់ ស្មារបស់ អេលី បានធ្លាក់ស្រយុងចុះដោយការធូរស្រាលក្នុងចិត្ត ។ អរគុណដល់ក្ដីល្អ វាបានចប់ហើយ ។ អ្វីចុងក្រោយដែលនាងត្រូវការនោះ គឺឲ្យអ្នកគ្រប់គ្នានៅក្នុងថ្នាក់ដឹងថាវីរបុរសរបស់នាងគឺ —

សម្លេងមួយបាននិយាយថា « ព្រះយេស៊ូវគ្រីស្ទ » ។

ភ្នែករបស់ អេលី បើកធំឡើងនៅពេលដែលនាងមើលឡើងលើ ។ នៅ — តែប៉ុន្មានជួរបន្ទាប់ — មានក្មេងប្រុសតូចដែលមានសក់ញក់ញីបានអង្គុយ ។ គេមានរាងស្គម ហើយខ្មាស់អៀន ហើយគេតែងតែអង្គុយនៅក្រោយថ្នាក់ ។ អេលី មិនទាំងដឹងឈ្មោះរបស់គេផង ។ នាងមិនអាចចាំបានថាធ្លាប់ឮគេនិយាយមួយពាក្យទេ — រហូតដល់ពេលនេះ ។

ក្មេងពីរបីនាក់បានងាកទៅសម្លឹងក្មេងប្រុសនោះ ប៉ុន្តែគេមិនខ្វល់ពីក្មេងទាំងនោះទេ ។ គេគ្រាន់តែមើលទៅអ្នកគ្រូ ហ្វីតស៍ ហើយបាននិយាយម្ដងទៀតថា ។ « វីរបុរសរបស់ខ្ញុំ គឺព្រះយេស៊ូវគ្រីស្ទ » ។

អ្នកគ្រូ ហ្វីតស៍ បានញញឹមយ៉ាងស្រស់ថ្លា ហើយបន្តទៅជួរមួយទៀត ។ ប៉ុន្តែ អេលីមើលទៅក្មេងប្រុសនោះដោយក្ដីភ្ញាក់ផ្អើល ។ នាងធ្លាប់មានការភ័យខ្លាចដើម្បីប្រាប់អ្នករួមថ្នាក់រាល់គ្នាអំពីវីរបុរសរបស់នាង ប៉ុន្តែក្មេងប្រុសនោះគ្មានទេ គេមិនទាំងទៅព្រះវិហារផង ! ប៉ុន្តែ គេដឹងថាវាសំខាន់ដល់កម្រិតណា ដើម្បីឈរជាគំរូនៃព្រះយេស៊ូវគ្រីស្ទ ទោះបីជាវាមានការពិបាកក៏ដោយ ។

អេលី បានញញឹមដាក់ក្មេងប្រុសនោះ ។ នាងនឹងមិនភ័យខ្លាច ដើម្បីនិយាយថាអ្នកណាជាវីរបុរសរបស់នាងទៀតឡើយ ។ នៅទីបញ្ចប់ នាងមាន វីរបុរសពីររូបហើយ ។ ■

*អ្នកនិពន្ធរស់នៅរដ្ឋ កាលីហ្វ័រញ៉ា ស.រ.អា. ។*

# ការអធិស្ឋាន និង ព្រះវិហារ

**ដោយ ម៉ាក់ផៃល ធធ**

ផ្អែកទៅលើដំណើររឿងពិតមួយ



*« អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក ។ » ( យ៉ូហាន 13:35 ) ។*

ដានីបានមើលឡើងទៅលើ តែនៅតែមិនឃើញកំពូលរបស់ព្រះវិហារដ៏ស្រស់ស្អាតនោះ ។ មនុស្សដែលនៅក្រុមជុំនំខុសគ្នាបានមកទីនេះ ។ ដានី មិនយល់ថាហេតុអ្វីបានជាក្រុមគ្រួសាររបស់នាងមកទស្សនាព្រះវិហារនេះនៅថ្ងៃសុក្រទេ ប៉ុន្តែឪពុករបស់នាងបាននិយាយថា ពួកគេនឹងទៅកន្លែងមួយដែលហៅថា អ៊ីវិនសង ( Evensong ) ។

« នោះជាអ្វីទៅ ? » ដានីបានសួរ ។

ឪពុកនាងបាននិយាយថា « វាជាការប្រជុំដែលមនុស្សជាច្រើនច្រៀង អានព្រះគម្ពីរ និង អធិស្ឋានរួមគ្នា » ។ វាក៏អាចត្រូវបានប្រើប្រាស់នៅចុងបញ្ចប់នៃវគ្គសិក្សាផងដែរ ។

ដានីចូលចិត្តអ្វីដែលឪពុកនាងបាននិយាយ ។ នាង និង គ្រួសារនាងបានទៅកំសាន្តប្រទេសអង់គ្លេស ។ នៅថ្ងៃអាទិត្យមុន ពួកគេបានទៅវួដមួយនៅទីក្រុងហៅថា យ៉ក ។ នៅក្នុងថ្នាក់កុមារ ក្មេងទាំងអស់ស្គាល់ខគម្ពីរ និង បទចម្រៀងដែលដានីធ្លាប់បានច្រៀងដែរ ។ នាងបានដឹងថា វួដដែលនាងបានទៅគឺជាផ្នែកមួយនៃសាសនាចក្រដ៏ពិតរបស់ព្រះយេស៊ូវ ដូចជាវួដរបស់នាងនៅផ្ទះដែរ ។

ប៉ុន្តែព្រះវិហារនេះ គឺខុសពីអ្វីដែលនាងធ្លាប់ទៅណាស់ ។ នាងបានសម្គាល់ឃើញតុតូចមួយពេញទៅដោយទាន ។ ដានីបានមើលក្មេងប្រុសម្នាក់ដុតទៀន ។

« ហេតុអ្វី អ្នក ដុតទៀន ? » ដានីបានសួរក្មេងប្រុសនោះ ។

ក្មេងប្រុសនោះញញឹម ។ « ខ្ញុំដុតទៀនពេលខ្ញុំអធិស្ឋានសម្រាប់អ្វីដែលពិសេស ។ ដរាបណាភ្លើងនៅតែឆេះ ខ្ញុំសង្ឃឹមថាការអធិស្ឋាននឹងបន្តឮទៅដល់ព្រះ » ។





« យើងគួរស្រឡាញ់មនុស្សទាំងអស់ ធ្វើជាអ្នកស្ដាប់ដ៏ល្អ ហើយបង្ហាញការព្រួយបារម្ភចំពោះជំនឿដ៏ស្មោះសររបស់ពួកគេ » ។

**អែលឌើរ ដាល្លិន អេក អូក នៃ កូរ៉ុម នៃ ពួក សាវក ដប់ ពីរ នាក់ « Loving Others and Living with Differences »** ***លីអាហូណា*** **ខែ វិច្ឆិកា ឆ្នាំ 2014, ទំព័រ 27 ។**

វាមើលទៅដូចជាទៀនធម្មតាសម្រាប់ដានី ។ នាងភាំងបន្តិច ប៉ុន្តែនាងចង់គួរសម ។ នាងបានញញឹមដាក់ក្មេងប្រុសនោះ ។

ដានី និងគ្រួសារនាងបានអង្គុយចុះ ហើយមិនយូរប៉ុន្មានអ៊ីវិនសងបានចាប់ផ្ដើម ។ នាងបានឃើញក្មេងប្រុសដដែលនោះ នៅពីរបីជួរខាងក្រោយ ។ បន្ទាប់មកនាងបានដឹងថា នាងមិនស្គាល់បទចម្រៀងដែលគេគ្រប់គ្នាកំពុងតែច្រៀងសោះ ។ ពេលពួកគេអធិស្ឋាន ពួកគេអានចេញពីកូនសៀវភៅតូចមួយ ។ អ្វីគ្រប់យ៉ាងហាក់ដូចជាខុសពីអ្វីដែលនាងធ្លាប់ធ្វើ ។

ប៉ុន្តែតន្ត្រីពិរោះ ទោះបីជាវាមិនធ្លាប់ស្គាល់ក៏ដោយ ។ បន្ទាប់មកបុរសម្នាក់បានក្រោកឈរឡើង ដើម្បីអានគម្ពីរ ។ គាត់ពាក់រ៉ូប ជំនួសឲ្យខោអាវធំ និងក្រវ៉ាត់ក ដូចជាប៊ីស្សពរបស់ដានី ។ ប៉ុន្តែនៅពេលដែលគាត់ចាប់ផ្ដើមអានដានីបានដឹងថានាងស្គាល់រឿងនេះ ! គាត់កំពុងអានពីព្រះយេស៊ូវប្រោសមនុស្សឃ្លង់ទាំង 10 នាក់ ។

ដានីបានខ្សឹបថា « ប៉ាខ្ញុំស្រឡាញ់រឿងនេះ » ។

ឪពុកញញឹម ។ « ប៉ា ក៏ស្រឡាញ់រឿងនេះដែរ » ។

បន្ទាប់មកបុរសដែលពាក់រ៉ូបបានធ្វើការអធិស្ឋាន ។ គាត់បានសូមដល់ព្រះឲ្យប្រទានពរដល់អស់អ្នកដែលឈឺ និងខ្វះខាត ។ ដូចជាអ្វីដែលឪពុករបស់ដានីបានសូមដែរ ! គាត់ក៏បានសូមពរជ័យពិសេសលើអ្នកដឹកនាំព្រះវិហាររបស់គាត់ផងដែរ ។ ដានីបានចាំពីរបៀបគ្រួសារនាងតែងតែសូមព្រះវរបិតាសួគ៌ឲ្យប្រទានពរដល់ប្រធាន ថូម៉ាស អេស ម៉នសុន និងទីប្រឹក្សាលោកផងដែរ ។



អារម្មណ៍ដ៏កក់ក្ដៅមួយបានមកលើដួងចិត្តរបស់ដានី ។ នាងបានដឹងថា ព្រះវរបិតាសួគ៌ប្រាប់នាងថាទ្រង់ស្រឡាញ់ *កូនចៅ* របស់ទ្រង់ទាំងអស់ ហើយបានឮ *ពាក្យ* អធិស្ឋានទាំងអស់របស់ពួកគេ ទោះជាពួកគេទៅព្រះវិហារខុសគ្នា ហើយពុំមានដំណឹងល្អដ៏ពេញលេញក៏ដោយ ។

ពេលដែលពួកគេក្រោកឈរឡើងរៀបនឹងចាកចេញ លោកប៉ាបានពិនិត្យទូរសព្ទរបស់គាត់ ។ គាត់មើលទៅកើតទុក្ខ នៅពេលដែលគាត់អានសារជាអក្សររបស់គាត់ ។ គាត់បាននិយាយថា « ស៊ីស្ទើរ ម៉នសុន បានទទួលមរណភាព » ។

« អូ៎ ទេ ! » ដានីបានធ្វើការអធិស្ឋានយ៉ាងលឿនមួយនៅក្នុងដួងចិត្តរបស់នាង សូមឲ្យប្រធាន ម៉នសុន មិនអី ។

នរណាម្នាក់បានសួរថា « តើអ្នកមិនអីទេឬ ? » វាជាក្មេងប្រុសពីមុន ។ គេបានឮដានី ហើយគេដូចជាបារម្ភ ។

ដានី បាននិយាយថា « ស៊ីស្ទើរ ម៉នសុន បានទទួលមរណភាព ។ គាត់គឺជាភរិយាព្យាការី ម៉នសុន របស់យើង» ។

គេបាននិយាយដោយសណ្ដានចិត្តល្អថា « ខ្ញុំសោកស្ដាយណាស់» ។ «ខ្ញុំនឹងដុតទៀនមួយសម្រាប់គាត់» ។

ដានីញញឹម ហើយបានអរគុណគេ ។ នាងបានគិតថា វាជាសណ្ដានចិត្តល្អរបស់ក្មេងប្រុសនោះ ដើម្បីធ្វើការអធិស្ឋានពិសេសសម្រាប់ប្រធាន ម៉នសុន ។ នាងបានដឹងថា ព្រះវរបិតាសួគ៌នឹងឮពាក្យអធិស្ឋានដែលនាងបាននិយាយនៅក្នុងដួងចិត្តរបស់នាង នឹងការអធិស្ឋានដែលក្មេងប្រុសនោះបាននិយាយដែរ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា. ។*

**សាក្សីពិសេស**



**ដោយ អែលឌើរ រ័សុល អិម ណិលសុន**

**ក្នុងកូរ៉ុមនៃពួកសាវកដប់ពីរនាក់**

*សមាជិកកូរ៉ុមនៃពួកដប់ពីរនាក់ គឺជាសាក្សីពិសេសរបស់ព្រះយេស៊ូវគ្រីស្ទ ។*

# តើហេតុអ្វីបានជា ការគោរពប្រតិបត្តិតាម សំខាន់ម្ល៉េះ ?




គំនូរដោយ អេព្រិល ស្តូ

*ដកស្រង់ចេញពី « ចូរបង្ហាញសេចក្តី ជំនឿរបស់អ្នក » លីអាហូណា ខែ ឧសភា ឆ្នាំ 2014, ទំព័រ 29–32 ។*



« ថ្ងៃនេះជាថ្ងៃដែល
ព្រះយេហូវ៉ាបានកំណត់ទុក
នៅថ្ងៃនេះ យើងរាល់គ្នានឹង
រីករាយសប្បាយឡើង » ។

— ទំនុកដំកើង 118:24

រូបភាពដោយ ម៉ាត់ ស្មីត

# ព្រះយេស៊ូវ បានប្រោសមនុស្សឃ្លង់ម្នាក់ឲ្យជា



**ដោយ អ៊ែរិន សាន់ជីសុន**

សូមគិតពីពេលវេលាមួយពេលដែលអ្នកឈឺ ។ តើមាននរណាម្នាក់ ធ្វើអ្វីមួយល្អដើម្បីជួយអ្នកមានអារម្មណ៍ប្រសើរឡើងទេ ?

នៅក្នុងព្រះគម្ពីរសញ្ញាថ្មី យើងអានពីរបៀបព្រះយេស៊ូវគ្រីស្ទបានបង្ហាញព្រះហឫទ័យសប្បុរសទៅកាន់មនុស្សដែលឈឺ ។ នៅថ្ងៃមួយ មានបុរសម្នាក់មានជម្ងឺស្បែកដ៏ឈឺចាប់ដែលហៅថា ជម្ងឺឃ្លង់ បានចូលទៅព្រះយេស៊ូវ ។ គាត់បានដឹងថា ព្រះយេស៊ូវមានព្រះចេស្ដាដើម្បីប្រោសអ្នកគ្រប់គ្នាដែលឈឺឲ្យជា គាត់បានជឿថាព្រះយេស៊ូវ អាចប្រោសគាត់ឲ្យជា ។ ព្រះយេស៊ូវ បានពាល់មនុស្សឃ្លង់នោះ ហើយមានបន្ទូលថា « ឲ្យជាស្អាតទៅ » ( ម៉ាកុស 1:41 ) ។ ភ្លាមៗបន្ទាប់ពីព្រះយេស៊ូវ បានមានព្រះបន្ទូលដូច្នេះ បុរសនោះត្រូវបានជាស្អាត ។

យើងអាចដើរតាមស្នាមព្រះបាទារបស់ព្រះយេស៊ូវ ដើយមានចិត្តសប្បុរស និងស្រឡាញ់អ្នកដទៃ ដែលមានជម្ងឺ និងសោកសៅ ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។*

## គំនិតយោបល់សម្រាប់ការនិយាយក្នុងគ្រួសារ

អ្នកអាចប្រើតួអង្គនៅក្នុងព្រះគម្ពីរ នៅទំព័រ 74 ដើម្បីប្រាប់រឿងចេញពី ម៉ាកុស 1:40–42 ។ បន្ទាប់មក អ្នកអាចអាន យូដាស 1:22 ហើយរៀបផែនការដើម្បីធ្វើអ្វីមួយជាក្រុមគ្រួសារ ដើម្បីធ្វើឲ្យមានភាពផ្លាស់ប្ដូរនៅក្នុងជីវិតរបស់មនុស្សម្នាក់ដែរ ។ ប្រហែលជាអ្នកអាចបម្រើនរណាម្នាក់ដោយសម្ងាត់ !

**បទចម្រៀង ៖** « សូមប្រាប់ខ្ញុំពីរឿងព្រះយេស៊ូវ » ( *សៀវភៅចម្រៀងកុមារ* ទំព័រ 36 )

**ខគម្ពីរ ៖** ម៉ាកុស 1:40–42

**វីដេអូ ៖** សូមចូលទៅគេហទំព័រ **Biblevideos.org** ដើម្បីមើល « ព្រះយេស៊ូវប្រោសមនុស្សខ្វិនឲ្យដើររួចនៅថ្ងៃ សប្ប័ទ » ហើយ « ព្រះយេស៊ូវប្រោសមនុស្សខ្វាក់ពីកំណើតបានភ្លឺ » ។



## ការដើរតាមជំហានរបស់ព្រះយេស៊ូវ

ជាមួយនឹងគ្រួសាររបស់អ្នក ដើរតួពីរបៀបអ្នកអាចបង្ហាញសេចក្ដីស្រឡាញ់ចំពោះអ្នកដទៃនៅក្នុងស្ថានភាពទាំងនេះ ។ សូមបង្កើតស្ថានភាពខ្លះដោយខ្លួនឯង !



មានក្រុមគ្រួសារថ្មីមួយបានផ្លាស់មកនៅក្នុងសង្កាត់របស់អ្នក ។

ក្មេងមួយចំនួនប្រព្រឹត្តកាចចំពោះក្មេងផ្សេងទៀតនៅសាលារៀន ។

ភ្ញៀវម្នាក់ដែលមិនស្គាល់នរណាម្នាក់នៅព្រះវិហារបានមកក្នុងថ្នាក់កុមារ ។

ប្អូនប្រុស ឬប្អូនស្រីរបស់អ្នក គ្មាននរណាម្នាក់ដើម្បីលេងជាមួយ ។

ប្អូនតូចកំពុងយំ ហើយម្ដាយរបស់អ្នកកំពុងព្យាយាមធ្វើអាហារពេលល្ងាច ។

មនុស្សម្នាក់នៅក្នុងវួដ ឬសាខារបស់អ្នកឈឺ ហើយមិនអាចចេញពីផ្ទះបាន ។

ខាងឆ្វេង ៖ *មនុស្សឃ្លង់ដែលបរិយាយថា «អរគុណ»* ដោយ ចន ស្មៀល © PROVIDENCE LITHOGRAPH; ខាងស្ដាំ ៖ រចនាបថដោយ ម៉ារឹង ម៉ាលេន រចនាបថទៅស្បែកជើង ដោយ ម៉ាក រ៉ូប៊ីនសុន

### រៀនថែមទៀតពី ៖ ដំណឹងល្អ

ព្រះគម្ពីរសញ្ញាថ្មី មានគម្ពីរពិសេសបួនដែលហៅថា ដំណឹងល្អ ដែលបានសរសេរដោយពួកសាវកខ្លះរបស់ព្រះយេស៊ូវ ។ ដំណឹងល្អប្រាប់អំពីពេលដែលព្រះគ្រីស្ទគង់នៅលើផែនដី ។ ដំណើររឿងពីការប្រោសមនុស្សឃ្លង់ឲ្យជា គឺនៅក្នុងដំណឹងល្អទាំងបីនេះ ។ វាមាននៅក្នុង ម៉ាកុស 1:40–42 ហើយក៏នៅក្នុង ម៉ាថាយ 8:2–4 និង លូកា 5:12–14 ។

### ព័ត៌មានជំនួយនៅក្នុងព្រះគម្ពីរ

នៅក្នុង ម៉ាកុស 1:41 ពាក្យ *ក្ដួលអាណិត* ត្រូវបានប្រើ ។ ពេលខ្លះ មានពាក្យជ្រៅនៅក្នុងព្រះគម្ពីរបរិសុទ្ធ ដែលអ្នកមិនយល់ ។ ពេលអ្នកឃើញពាក្យដែលអ្នកមិនស្គាល់ អ្នកអាចប្រើមគ្គុទេសន៍នៅក្នុងព្រះគម្ពីរដើម្បីជួយអ្នក! ឧទាហរណ៍ អ្នកអាចរកមើលពាក្យ « ក្ដួលអាណិត » ដើម្បីរកថាវាមានន័យយ៉ាងណា ហើយដើម្បីរកខគម្ពីរផ្សេងទៀតដែលប្រើវា ។ តើពាក្យអ្វីផ្សេងទៀតដែលអ្នកអាចរកមើលនៅក្នុងរឿងអំពីព្រះយេស៊ូវប្រោសឲ្យសដែលកើតឃ្លង់ឲ្យជា ?

តួអង្គទាំងឡាយ នៅក្នុងព្រះគម្ពីរសញ្ញាថ្មី

# ព្រះយេស៊ូវ ប្រោសអ្នកឈឺឲ្យជា

**ម៉ាកុស 1:40–42**
**លូកា 4:38–40**

សូមបិទទំព័រនេះ ទៅនឹងក្រដាស ឬក្រដាសកាតុងរឹង ។ បន្ទាប់មក សូមកាត់តួអង្គទាំងនេះ ហើយបិទពួកគេទៅនឹងឈើការ៉េម ឬថង់ក្រដាស ។ ប្រើវាដើម្បីជួយដើរតួរឿងពីព្រះគម្ពីរសញ្ញាថ្មី ។

*អ្នកអាចព្រីនច្បាប់ចម្លងជាច្រើនទៀត នៅ គេហទំព័រ liahona.lds.org.*



ពួកមហាជន



ព្រះយេស៊ូវគ្រីស្ទ



បុរសឃ្លង់



ម្ដាយក្មេករបស់ពេត្រុស

រចនារូបភាព ដោយ បេត អិម វាយថេកឃើរ



ដោយ អែលឌើរ ក្វូឌូ ឌី ហ្សុីក
នៃពួកចិតសិបនាក់

# មាគ៌ាដែលត្រឹមត្រូវ

*« ឮព្រះបន្ទូលទាំងឡាយនៃព្រះ ដែលបានបង្កើតអ្នកចុះ »*
*( គ និង ស 43:23 )* ។

ជាច្រើនឆ្នាំមកហើយ ខ្ញុំ និងគ្រួសារខ្ញុំ បានទៅទស្សនាឧទ្យានជាតិ អាក ( Arches National Park ) នៅក្នុងរដ្ឋ យូថាហ៍ ស.រ.អា ។ ថ្មដុះរាងខ្លោងទ្វារដ៏ស្រស់ស្អាត និងល្បីល្បាញមួយក្នុងចំណោមថ្មដុះទាំងអស់គឺ ដេលីខេត អាក ( Delicate Arch ) ហើយយើងបានសម្រេចចិត្តឡើងភ្នំដើម្បីទៅដល់វា ។

យើងបានចាប់ផ្ដើមដោយចិត្តរីករាយណាស់ ប៉ុន្តែមិនយូរប៉ុន្មាន អ្នកដទៃទៀតបានចង់ឈប់សម្រាក ។ ខ្ញុំចង់ទៅដល់ទីនោះឲ្យកាន់តែឆាប់រហ័ស ដូច្នេះខ្ញុំបានទៅម្នាក់ឯង ។ ដោយគ្មានការប្រុងប្រយ័ត្ននៅលើជម្រាលដែលខ្ញុំគួរតែដើរ ខ្ញុំបានចាប់ផ្ដើមដើរតាមបុរសម្នាក់ដែលហាក់ដូចជាដឹងថាគាត់ទៅណា ។

ជម្រាលនោះមានការលំបាកឡើងៗក្នុងការឡើង ។ ខ្ញុំបានប្រាកដថាគ្រួសាររបស់ខ្ញុំមិនអាចឡើងតាមនេះឡើយ ។ ភ្លាមនោះខ្ញុំបានមើលឃើញថ្មដុះ ដេលីខេត អាក តែគួរឲ្យភ្ញាក់ផ្អើល ខ្ញុំមិនអាចទៅដល់វាទេ ។ ផ្លូវដែលខ្ញុំបានជ្រើសយក មិនបាននាំខ្ញុំទៅថ្មដុះនោះទេ ។

ខ្ញុំមានអារម្មណ៍តានតឹង ហើយបានត្រឡប់មកក្រោយវិញ ។ ខ្ញុំបានរង់ចាំរហូតដល់ខ្ញុំបានជួបក្រុមរបស់ខ្ញុំវិញដោយអន្ទះសា ។ ពួកគេបានប្រាប់ខ្ញុំថា ពួកគេបានដើរតាមផ្លាកសញ្ញា បង្ហាញផ្លូវដោយប្រុងប្រយ័ត្ន ហើយដោយព្យាយាមទើបបានទៅដល់ ដេលីខេត អាក ។ ជាអកុសលខ្ញុំបានដើរខុសផ្លូវ ។ វាជាមេរៀនដ៏ល្អដែលខ្ញុំបានរៀន ។

សូមកុំភ្លេចខ្លួនចេញពីផ្លូវរបស់អ្នកទៅកាន់ ជីវិតដ៏អស់កល្ប ជាមួយជីវិតដ៏អស់កល្បរបស់អ្នក ។ សូមធ្វើតាមគោលការណ៍ដំណឹងល្អ និងព្រះបញ្ញត្តិទាំងឡាយដែលអ្នកបានរៀន នោះអ្នកនឹងស្ថិតនៅលើផ្លូវត្រឹមត្រូវ ដើម្បីរស់នៅជាមួយទ្រង់ជារៀងរហូត ។ ■

*ដកស្រង់ចេញពី « ចូរកុំដើរផ្លូវខុស » លីអាហូណា ខែ ឧសភា ឆ្នាំ 2014, ទំព័រ 39–41 ។*

សម្រាប់កុមារតូចៗ

# ខ្ញុំដឹងថាព្រះសង្គ្រោះខ្ញុំស្រឡាញ់ខ្ញុំ

**ដោយ ជេន ម៉ាកប្រាយដ៍ ឆូត**

ស្រង់ចេញពីរឿងពិតមួយ

ឡានី កំពុងព្យាយាមយ៉ាងខ្លាំងដើម្បីមានគារវភាពនៅក្នុងព្រះវិហារ ។ ប៉ុន្តែ នាងនឿយហត់ ហើយជើងរបស់នាងញ័រ ។





បន្ទាប់ពីការចែកសាក្រាម៉ង់ត្រូវបានបញ្ចប់ ឡានីបានបើកមើលសៀវភៅអំពីព្រះយេស៊ូវរបស់នាង ។ នាងបានរកឃើញរូបភាពព្រះយេស៊ូវ ជាមួយនឹងកូនក្មេងតូចៗ ។ វាបានធ្វើឲ្យនាងមានអារម្មណ៍សុខសាន្ត ហើយរីករាយក្នុងចិត្ត ។

បន្ទាត់ចនាយទដោយ ប៉ុល ម៉ាន់ គំនូរពណ៌ដោយ ជេស ហ្គូលដិន

*រឿងនេះបន្តនៅទំព័រ 79 ។*




1-កាត់



8 ខ្ញុំដឹងថាព្រះអង្គសង្គ្រោះខ្ញុំស្រឡាញ់ខ្ញុំ
ដឹកនាំដោយ ថេមី ចែបសុន គ្រីមើរ និង ដេវីណា ប៉ែល



# សៀវភៅរបស់ខ្ញុំអំពី
# ព្រះយេស៊ូវគ្រីស្ទ

1

2-បត់

5 ខ្ញុំមិនបានពាល់ទ្រង់ ឬអង្គុយនៅលើផង្គង់ទ្រង់ទេ ប៉ុន្តែព្រះគ្រីស្ទគឺពិតសម្រាប់ខ្ញុំ ។

4 សេចក្ដីស្រឡាញ់ដែលទ្រង់មានចំពោះកូនចៅតូចៗរបស់ទ្រង់
ខ្ញុំដឹងថាទ្រង់មានចំពោះខ្ញុំដែរ ។

4-កាត់





3-បត់



② មានពេលមួយជាយូរមកហើយ ក្នុងទីកន្លែងដ៏ស្រស់ស្អាតមួយ
ក្មេងៗជាច្រើនបានប្រមូលផ្ដុំជុំវិញព្រះយេស៊ូវ ។



⑦ ខ្ញុំបានឲ្យដួងចិត្តខ្ញុំដល់ទ្រង់ ។ ខ្ញុំដឹងថាព្រះអង្គសង្គ្រោះខ្ញុំស្រឡាញ់ខ្ញុំ ។

បត់

③ ទ្រង់បានប្រទានពរ និងបានបង្រៀនពួកគេនៅពេលដែលពួកគេមានអារម្មណ៍ពីក្ដីស្រឡាញ់
នៃទ្រង់ ។ ពួកគេម្នាក់ៗបានឃើញទីកនេត្រានៅលើព្រះភ័ក្ត្ររបស់ទ្រង់ ។



⑥ ខ្ញុំដឹងថា ទ្រង់មានព្រះជន្មរស់! ខ្ញុំនឹងដើរតាមទ្រង់ដោយស្មោះត្រង់ ។



បត់



បន្ទាប់ពីការប្រជុំសាក្រាម៉ង់ត្រូវបានបញ្ចប់ ឡានីបានសួរម្ដាយរបស់នាងថា « ហេតុអ្វីបានជាវាមានការងាយស្រួលជាងដើម្បីមានគារវភាព នៅពេលខ្ញុំមើលសៀវភៅអំពីព្រះយេស៊ូវ ? »

ម្ដាយរបស់នាងបាននិយាយថា « ម៉ាក់គិតថា ដោយសារវារំឭកកូនថាព្រះយេស៊ូវស្រឡាញ់កូនដល់កម្រិតណានោះអី » ។



ឡានី បានងក់ក្បាល ។ នាងបានសួរថា « តើម៉ាក់គិតថា ព្រះយេស៊ូវជ្រាបទេថា ខ្ញុំក៏ស្រឡាញ់ទ្រង់ដែរ ? »

ម្ដាយបានឱបឡានី ។ « ចាស ម៉ាក់ប្រាកដថាទ្រង់ពិតជាជ្រាប » ។ ■

*អ្នកនិពន្ធរស់នៅក្នុងរដ្ឋ ខូឡូរ៉ាដូ ស.រ.អា ។*

*ខែនេះបានគំរប់ខួប 100 ឆ្នាំ ចាប់តាំងពីគណៈប្រធានទីមួយបានលើកទឹកចិត្តឲ្យសមាជិកធ្វើរាត្រីជួបជុំក្រុមគ្រួសារ ។ ការដកស្រង់ខាងក្រោមនេះ ចេញពីសារលិខិតរបស់គណៈប្រធានទីមួយណែនាំពីរាត្រីជួបជុំក្រុមគ្រួសារ ។ វាត្រូវបានចេញផ្សាយ នៅក្នុងខែ មេសា ឆ្នាំ 1915 ហើយបានបោះពុម្ពក្នុង* Improvement Era *នៅ ខែ មិថុនា ឆ្នាំ 1915 ( ទំព័រ 733–34 ) ។ ការដាក់អក្សរធំ និងការដាក់វណ្ណយុត្ត ត្រូវបានធ្វើឲ្យទំនើបឡើង ។*

# ខួប 100 ឆ្នាំនៃ រាត្រីជួបជុំក្រុមគ្រួសារ



បងប្អូនប្រុសស្រីជាទីស្រឡាញ់ ៖ យើងសូមស្នើដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយឲ្យប្រតិបត្តិតាមដោយល្អិតល្អន់លើព្រះបញ្ញត្តិនៃព្រះអម្ចាស់ ដែលបានប្រទានឲ្យនៅក្នុងកណ្ឌទី 68 នៃព្រះគម្ពីរ គោលលទ្ធិ និង សេចក្ដីសញ្ញា ៖

*« ហើយជាថ្មីទៀត ដរាបណាឪពុកម្ដាយមានកូនចៅនៅក្នុងក្រុងស៊ីយ៉ូន . . . ដែលពុំបាន បង្រៀនកូនចៅឲ្យយល់នូវគោលលទ្ធិអំពីការប្រែចិត្ត សេចក្ដីជំនឿជឿដល់ព្រះគ្រីស្ទ ជាព្រះរាជបុត្រានៃព្រះដ៏មានព្រះជន្មរស់នៅ និង អំពីបុណ្យជ្រមុជទឹក ហើយនិងអំពីអំណោយទានជាព្រះវិញ្ញាណបរិសុទ្ធ ដោយសារការដាក់ដៃលើ កាលមានអាយុប្រាំបីឆ្នាំ នោះអំពើបាបនឹងធ្លាក់មកលើក្បាលរបស់ឪពុកម្ដាយវិញ . . .*

*« ហើយពួកគេក៏ត្រូវបង្រៀនកូនចៅរបស់ខ្លួន ឲ្យអធិស្ឋាន និង ឲ្យដើរដោយទៀងត្រង់នៅចំពោះព្រះអម្ចាស់ » [ សូមមើល គ និង ស 68:25–28 ] ។*

កូនចៅនៃក្រុងស៊ីយ៉ូន ក៏គួរតែប្រតិបត្តិឲ្យបានពេញលេញផងដែរ តាមព្រះបញ្ញត្តិនៃព្រះអម្ចាស់ដែលបានប្រទានដល់ពួកសាសន៍អ៊ីស្រាអែលនៅសម័យបុរាណ និងធ្វើឡើងជាថ្មីទៀតដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ៖

*« ចូរឲ្យគោរពប្រតិបត្តិដល់ឪពុកម្ដាយ ដើម្បីឲ្យបានអាយុវែងនៅក្នុងស្រុក ដែលព្រះយេហូវ៉ា ជាព្រះនៃឯងទ្រង់ប្រទានឲ្យ » [ និក្ខមនំ 20:12 ] ។*

វិវរណៈទាំងនេះ អនុវត្តជាមួយនឹងកម្លាំងដ៏អស្ចារ្យ ដល់ពួកបរិសុទ្ធថ្ងៃចុងក្រោយ ហើយវាតម្រូវឲ្យឪពុកម្ដាយទាំងឡាយនៅក្នុងសាសនាចក្រនេះឲ្យបង្រៀន និងអនុវត្តព្រះបញ្ញត្តិទាំងនេះនៅក្នុងផ្ទះរបស់ពួកគេ ។

ដល់ទីបញ្ចប់នេះ យើងសូមទូន្មាន និងជម្រុញការចាប់ផ្ដើមនៃ « រាត្រីជួបជុំក្រុមគ្រួសារ » នៅទូទាំងសាសនាចក្រនេះ ជាពេលដែលឪពុកម្ដាយទាំងឡាយ ប្រមូលផ្ដុំកូនប្រុស និងកូនស្រីរបស់ខ្លួននៅក្នុងផ្ទះ ហើយបង្រៀនពួកគេពីព្រះបន្ទូលនៃព្រះអម្ចាស់ ។ ដូច្នេះ ពួកគេអាចរៀនកាន់តែពេញលេញពីតម្រូវការ និងការទាមទាររបស់ក្រុមគ្រួសាររបស់គេ ហើយនៅពេលជាមួយគ្នា អាចធ្វើឲ្យខ្លួនគេ និងកូនចៅពួកគេកាន់តែយល់ច្បាស់ពីគោលការណ៍នៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ។ រាត្រីជួបជុំក្រុមគ្រួសារនេះ គួរតែឧទ្ទិសដល់ការអធិស្ឋាន ការច្រៀងទំនុកតម្កើង បទចម្រៀង ឧបករណ៍តន្ត្រី ការអានព្រះគម្ពីរ ប្រធានបទក្រុមគ្រួសារ និងការណែនាំជាក់លាក់លើគោលការណ៍នៃដំណឹងល្អ និងលើបញ្ហាសីលធម៌នៃជីវិត ក៏ដូចជាតួនាទី និងកាតព្វកិច្ចរបស់កូនចៅចំពោះឪពុកម្ដាយ ផ្ទះសម្បែង សាសនាចក្រ សង្គម និងចំពោះប្រជាជាតិ ។ សម្រាប់កូនចៅតូចៗ យើងណែនាំឲ្យមានការសូត្រមេរៀនសមរម្យ បទចម្រៀង រឿងនិទាន និងល្បែងនានា ។ អាហារសម្រន់ ដែលជាធម្មតាចម្អិននៅក្នុងផ្ទះ ក៏អាចដាក់ឲ្យទទួលទានផងដែរ ។

គួរតែព្យាយាមចៀសវាងភាពជាផ្លូវការ និងភាពតឹងរឹង ហើយគ្រួសារទាំងអស់គួរតែចូលរួមក្នុងសកម្មភាពនេះ ។

ការប្រមូលផ្ដុំទាំងនេះ នឹងផ្ដល់ឱកាសសម្រាប់ការមានទំនុកចិត្តទៅលើគ្នាទៅវិញទៅមករវាងឪពុកម្ដាយ និងកូនចៅ រវាងបង/ប្អូនប្រុសស្រី ក៏ដូចជាផ្ដល់ឱកាសសម្រាប់ពាក្យព្រមាន ការទូន្មាន និងដំបូន្មានពីឪពុកម្ដាយដល់កូនប្រុសស្រីរបស់ពួកគេ ។ វានឹងផ្ដល់ឱកាសដល់កូនប្រុសស្រីទាំងឡាយ ដើម្បីគោរពឪពុកម្ដាយ និងដើម្បីបង្ហាញការដឹងគុណរបស់ពួកគេសម្រាប់ពរជ័យនៃគេហដ្ឋាន ដើម្បីធ្វើឲ្យសេចក្ដីសន្យានៃព្រះអម្ចាស់ចំពោះពួកគេ នឹងអាចត្រូវបានបំពេញ ហើយចម្រើនជីវិតរបស់ពួកគេ និងធ្វើឲ្យពួកគេមានភាពរីករាយទៀតផង ។ . . .

យើង . . . សូមលើកទឹកចិត្តដល់សមាជិកវ័យក្មេងទាំងឡាយឲ្យនៅផ្ទះនារាត្រីនោះ ហើយប្រើប្រាស់ថាមពលពួកគេក្នុងការធ្វើឲ្យរាត្រីនោះពោរពេញដោយចំណេះដឹង គុណប្រយោជន៍ និងគួរឲ្យចាប់អារម្មណ៍ ។

ប្រសិនបើពួកបរិសុទ្ធគោរពតាមការទូន្មាននេះ យើងសូមសន្យាថា ពរជ័យដ៏អស្ចារ្យនឹងមានជាលទ្ធផល ។ សេចក្ដីស្រឡាញ់ក្នុងផ្ទះ និងការគោរពប្រតិបត្តិតាមឪពុកម្ដាយនឹងកើនឡើង ។ សេចក្ដីជំនឿនឹងត្រូវបានអភិវឌ្ឍឡើងក្នុងដួងចិត្តរបស់យុវជននៃសាសន៍អ៊ីស្រាអែល ហើយពួកគេនឹងទទួលបានអំណាច ដើម្បីប្រយុទ្ធប្រឆាំងនឹងឥទ្ធិពល និងការល្បួងដែលរុំព័ទ្ធពួកគេ ។

ពីបងប្រុសរបស់អ្នក<br>
យ៉ូសែប អេហ្វ ស្ម៊ីធ<br>
អាន់ថុន អេជ ឡាន់<br>
ឆាលី ដបុលយូ ផេនរ៉ូស<br>
គណៈប្រធានទីមួយ ■

ទទួលបានសិទ្ធិអនុញ្ញាតពីបណ្ណាល័យប្រវត្តិសាស្ត្រសាសនាចក្រ

# ការយល់ដឹងជ្រៅជ្រះ




**តើខ្ញុំអាចធ្វើឲ្យរាត្រីជួបជុំក្រុមគ្រួសារជាអាទិភាព បានយ៉ាងដូចម្ដេច ?**

« ខណៈពេលអ្នកកំពុងធ្វើការ ដើម្បីពង្រឹងក្រុមគ្រួសារអ្នក ហើយសាបព្រោះភាពសុខសាន្ត សូមចងចាំពី . . . រាត្រីជួបជុំក្រុមគ្រួសារប្រចាំសប្ដាហ៍ ។ សូមប្រយ័ត្នកុំធ្វើឲ្យរាត្រីជួបជុំក្រុមគ្រួសាររបស់អ្នក គ្រាន់តែជារឿងបន្ទាប់បន្សំពីថ្ងៃមួយដ៏រវល់ឲ្យសោះ ។ សូមសម្រេចថា រាត្រីថ្ងៃច័ន្ទ ក្រុមគ្រួសាររបស់អ្នកនឹងនៅជាមួយគ្នានៅផ្ទះ សម្រាប់រាត្រីជួបជុំក្រុមគ្រួសារ ។ សូមកុំអនុញ្ញាតឲ្យ តម្រូវការខាងការងារ កីឡា សកម្មភាពបន្ថែម កិច្ចការផ្ទះ ឬក៏អ្វីផ្សេងទៀតក្លាយជាមានសារៈសំខាន់ជាង ពេលវេលាដែលអ្នកចំណាយជាមួយគ្នានៅផ្ទះជាមួយក្រុមគ្រួសារអ្នកឡើយ ។ រចនាសម្ព័ន្ធនៃរាត្រីជួបជុំក្រុមគ្រួសារ គឺមិនសំខាន់ដូចពេលវេលាដែលអ្នកបានបណ្ដាក់នោះទេ ។ ដំណឹងល្អ គួរតែត្រូវបានបង្រៀនទាំងខាងផ្លូវការ និងខាងក្រៅផ្លូវការ ។ សូមធ្វើវាឲ្យជាបទពិសោធន៍ដ៏មានន័យ សម្រាប់សមាជិកគ្រួសារម្នាក់ៗ » ។

---

**អែលឌើរ រីឆាត ជីស្កុត** នៃកូរ៉ុមនៃពួកសាវកដប់ពីរនាក់, « ចូរធ្វើឲ្យការអនុវត្តសេចក្ដីជំនឿបងប្អូនក្លាយជាអាទិភាពទីមួយ » *លីអាហូណា*, ខែ វិច្ឆិកា ឆ្នាំ 2014,ទំព័រ 94 ។

# កំមាននៅក្នុងច្បាប់នេះផងដែរ

## សម្រាប់មជ្ឈិមវ័យវ័យក្មេង

### ឆ្ពោះទៅមុខដោយ ជំនឿ

ការយល់ដឹងទាំងបួននេះពី ជីវិតនីហ្វៃ អាចផ្ដល់ឲ្យអ្នកនូវ ទំនុកចិត្តក្នុងការសម្រេចចិត្តផ្ទាល់ខ្លួនរបស់អ្នក ។



ទំព័រ 44

## សម្រាប់យុវវ័យ



ទំព័រ 50

### ដោយសារតែ យ៉ូសែប

តើជីវិតរបស់អ្នកបានផ្លាស់ប្ដូរយ៉ាងដូចម្ដេចខ្លះ ដោយសារតែព្យាការី យ៉ូសែប ស្ម៊ីធ ? សូមពិចារណា ពីវិធីទាំងប្រាំមួយនេះ ។

## សម្រាប់កុមារ

### ខ្ញុំដឹងថាព្រះសង្គ្រោះ ខ្ញុំស្រឡាញ់ខ្ញុំ

បង្កើតកូនសៀវភៅផ្ទាល់ខ្លួនរបស់អ្នក ដើម្បីជួយអ្នកឲ្យ មានគារវភាពក្នុងអំឡុងពេលចូលរួមសាសនាចក្រ ។



ទំព័រ 76

CAMBODIAN

4 02125 64258 3

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ